# សុត្តន្តបិដក





១៩

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ទីឃនិកាយ បាដិកវគ្គ
# ឆដ្ឋភាគ
# ១៩



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

# DĪGHANIKĀYA

# PĀṬIKAVAGGA

# CHAṬṬHABHĀGA

# 19

សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្ដេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្វះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្វះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្ដេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្ដីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្ដីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមឆ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ប្បួរ-គ្រី

VATT Botum Dhammayutt Sangkat Chatumuk Khan Daun Penh P.Penh

# អំព័នអទអ

# សេចក្តីណែនាំក្នុងការអាន

១- ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្+ល** ក្នុងពាក្យនេះ ព្យញ្ជនៈ ល គឺជាជើងរបស់ព្យញ្ជនៈ ម ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្+ស** គឺ **តស្ស** ។

២- ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣- ចំពោះ **សន្ទឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## ទីឃនិកាយ បាដិកវគ្គ

## ឆដ្ឋភាគ

## ១៩

## លក្ខណសូត្រ សិង្គាលកសូត្រ

## អាដានាដិយសូត្រ សង្គីតិសូត្រ

## និង

## ទសុត្តរសូត្រ

ព. ស. ២៥០៣

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## បាដិកវគ្គោ

## ឆដ្ឋោ ភាគោ

## លក្ខណសុត្តំ សត្តមំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ទ្វត្តឹសិមានិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេ វ[១] គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ

---

១ ឱ. វសទ្ទោ ន ទិស្សតិ ។

# សុត្តន្តបិដក ទីឃនិកាយ

# បាដិកវគ្គ

# ឆដ្ឋភាគ

## លក្ខណសូត្រ ទី ៧

[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងវេលានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ឆ្លើយតបព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនេះ មហាបុរស (នោះ) រមែងមានគតិ ២ យ៉ាង មិនមែនក្រៅពី ២ យ៉ាងនេះទេ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ មានជ័យជំនះផ្សាយអំណាច រហូតដល់ផែនដី ដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ដល់នូវភាវៈជាអ្នកមានជនបទដ៏មាំមួន

សត្តរតនសមន្នាគតោ តស្សិមានិ សត្ត រតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បថវឹ សាគរបរិយន្តំ អខិលំ អនិមិត្តំ អកណ្ដកំ ឥទ្ធំ ផីតំ ខេមំ សិវំ និរព្វុទំ[១] អទណ្ឌេន អសត្ថេន ធម្មេន សមេន អភិវិជិយ អជ្ឈាវសតិ ។ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ។ កតមានិ[២] តានិ ភិក្ខវេ ទ្វត្តឹស មហាបុរិសស្ស[៣] មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស

---

១ ឱ. ម. អខីលំ អនិមិត្តំ អកណ្ឌកំ ឥទ្ធំ ផីតំ ខេមំ សិវំ និរព្វុទន្តិ ន ទិស្សតិ ។ ២ ឱ. កតមានិ ច ។ ៣ ឱ. ម. មហាបុរិសស្ស ទ្វត្តឹស ។

ទ្រង់ប្រកបដោយរតន៍ ៧ ប្រការ ឯរតន៍ ៧ ប្រការនៃស្តេចចក្រពត្តិនោះ គឺ ចក្ករតន៍ ១ ហត្ថិរតន៍ ១ អស្សរតន៍ ១ មណិរតន៍ ១ ឥត្ថី[១]រតន៍ ១ គហបតិរតន៍[២] ១ បរិនាយករតន៍[៣] ១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្រ របស់ស្តេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្តេចឯទៀតបាន ។ ព្រះអង្គប្រាបប្រាមគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លា គឺចោរឡើយ ជាផែនដីស្តុកស្តម្ភមាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ដ៏ស្មើគឺសីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ បើមហាបុរសនោះ ចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួសហើយ នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងលោកមានដំបូលគឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ មហា-បុរសប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនោះ តើដូចម្តេចខ្លះ

---

១ អដ្ឋកថា ថា បានដល់ស្រីដែលនាំមកនូវសេចក្តីសុខដ៏វិសេស ដល់ស្តេចចក្រពត្តិ ដែលគេនាំអំពីមទ្ទរាជត្រកូល ឬឧត្តរកុរុទ្វីប មកថ្វាយឲ្យតាំងជាអគ្គមហេសី ។ ២ អដ្ឋកថា ក្នុងមហាសុទស្សនសូត្រថា បានដល់ពួកអ្នកមានភោគសម្បត្តិច្រើន ។ ៣ ព្រះរាជបុត្រច្បងដែលមានប្រាជ្ញាឈ្លាសវៃ អាចស្គាល់ចិត្តរបស់ស្តេចចក្រពត្តិ ជាអ្នកចាត់ចែងកិច្ចការគ្រប់ចំពូកថ្វាយស្តេចចក្រពត្តិបាន ។

៣

## លក្ខណសុត្តេ ទ្វត្តឹសមហាបុរិសលក្ខណកថា

ទ្វេ វ គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ សង្ខិត្តំ ។ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ។ ឥធ ភិក្ខវេ មហាបុរិសោ សុប្បតិដ្ឋិតបាទោ ហោតិ ។ យំបិ ភិក្ខវេ មហាបុរិសោ សុប្បតិដ្ឋិតបាទោ ហោតិ ។ ឥទំបិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។ បុន ចបរំ ភិក្ខវេ មហាបុរិសស្ស ហេដ្ឋា-បាទតលេសុ ចក្កានិ ជាតានិ ហោន្តិ សហស្សារានិ សនេមិកានិ សនាភិកានិ សព្វាការបរិបូរានិ[១] ។ យំ-បិ ភិក្ខវេ មហាបុរិសស្ស ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ ហោន្តិ សហស្សារានិ សនេមិកានិ សនាភិ-កានិ សព្វាការបរិបូរានិ[២] ។ ឥទំបិ ភិក្ខវេ មហាបុរិ-សស្ស មហាបុរិសលក្ខណំ ភវតិ ។ បុន ចបរំ ភិក្ខវេ

១-២ ឱ. ម. សព្វាការបរិបូរានិ សុវិភត្តន្តរានិ ។

លក្ខណសូត្រ ពោលអំពីមហាបុរិសលក្ខណៈ ៣២ ប្រការ

ទើបបានជាមានគតិ ២ យ៉ាង មិនមែនក្រៅពី ២ យ៉ាងនេះឡើយ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ សេចក្តីបំប្រួញ ។ បើមហាបុរសចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសក្នុងលោកនេះ មានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។ ម្នាលភិក្ខុទាំង-ឡាយ មហាបុរសមានព្រះបាទប្រតិស្ឋានល្អ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ត្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់និងដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នា គ្រប់អន្លើ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ផ្ទៃព្រះបាទទាំងគូខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់និងដុំព្រមទាំងកាំ ១.០០០ មានចន្លោះស្មើគ្នា គ្រប់អន្លើ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហា-បុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

មហាបុរិសោ អាយតបណ្ហិ[១] ហោតិ ។ ទីឃង្គុលី ហោតិ ។ មុទុតលុនហត្ថបាទោ[២] ហោតិ ។ ជាលហត្ថបាទោ ហោតិ ។ ឧស្សង្ខបាទោ ហោតិ ។ ឯណិជង្ឃោ ហោតិ ។ ឋិតកោ វ អនោនមន្តោ ឧភោហិ បាណិតលេហិ ជន្នុកានិ បរិមសតិ បរិមជ្ជតិ ។ កោសោហិតវត្ថគុយ្ហោ ហោតិ ។ សុវណ្ណវណ្ណោ កាញ្ចនសន្និភតចោ[៣] ។ សុខុមច្ឆវី ហោតិ សុខុមត្តា ឆវិយា រជោជល្លំ កាយេ ន ឧបលិម្បតិ ។ ឯកេកលោមោ ហោតិ ឯកេកានិ លោមានិ លោមកូបេសុ ជាតានិ ។ ឧទ្ធគ្គលោមោ ហោតិ ឧទ្ធគ្គានិ លោមានិ ជាតានិ នីលានិ អញ្ជនវណ្ណានិ កុណ្ឌលាវត្តានិ ទក្ខិណាវត្តកជាតានិ[៤] ។ ព្រហ្មុជុគត្តោ ហោតិ ។ សត្តុស្សទោ ហោតិ ។ សីហបុព្វទ្ធកាយោ ហោតិ ។ ចិតន្តរំសោ[៥] ហោតិ ។

---

១ ឱ. ម. អាយតបណ្ហី ។ ២ ឱ. ម. មុទុតលុណហត្ថបាទោ ។ ៣ ឱ. សុវណ្ណវណ្ណោ ហោតិ កញ្ចនសន្និភត្តចោ ។ ៤ ឱ. កុណ្ឌលវត្តានិ បទក្ខិណាវត្តកជាតានិ ។ ៥ ឱ. ម. ចិត្តន្តរំសោ ។

មហាបុរសមានព្រះបណ្ហិ គឺកែងវែង ។ មានព្រះអង្គុលិ គឺម្រាមព្រះហស្ត និងម្រាមព្រះបាទវែង ៗ ។ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទដ៏ទន់ល្មើយ ។ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡា ដូចជាសំណាញ់ ។ មានព្រះបាទដូចជាអណ្ដែតឡើងខាងលើ ។ មានព្រះជង្ឃាគឺស្មងវៀវមូលត្រសូល ស្រដៀងនឹងស្មងសត្វទ្រាយ ។ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាចស្ទាបអង្អែលព្រះជាណុ គឺជង្គង់ដោយផ្ទៃព្រះហស្តទាំងពីរបាន ។ មានព្រះអង្គាវយវៈ ដែលត្រូវលាក់កំបាំងដោយសំពត់បិតនៅក្នុងស្រោម ។ មានស្បែកសម្បុរថ្លៃ (ល្មើង ភ្លឺអន្ទង់) ដូចជាសម្បុរនៃមាស ។ មានព្រះឆវីគឺសម្បុរថ្លៃ ល្អិតផូរផង់រលើងស្រិល រអិលធូលីធ្លាក់មកមិនជាប់ព្រះកាយ ។ មានព្រះលោមាតែ ១ សរសៃ ៗ គឺក្នុងរណ្ដៅរោម ១ មានរោម ១ ។ មានព្រះលោមាមានចុង-ងឡើងលើ ព្រះលោមា ដែលដុះឡើងហើយ មានចុងឡើងលើជាទក្ខិណាវដ្ដ វិលវង់ព័ទ្ធពេនទៅខាងស្ដាំ មានសម្បុរខៀវ ដូចជាសម្បុរនៃផ្កាអញ្ចាន កួចមូលដូចជាកុណ្ឌល ។ មានព្រះកាយត្រង់ ដូចជាកាយនៃព្រហ្ម ។ មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញបរិបូណ៌ ។ មានព្រះកាយពាក់កណ្ដាលខាងលើ ដូចជាកាយនៃរាជសីហ៍ ។ មានព្រះបិដ្ឋិ គឺខ្នង ដ៏ពេញបរិបូណ៌ ។

និគ្រោធបរិមណ្ឌលោ ហោតិ យាវតក្វស្ស កាយោ តាវតក្វស្ស ព្យាមោ យាវតក្វស្ស ព្យាមោ តាវតក្វស្ស កាយោ ។ សមវដ្ដក្ខន្ធោ ហោតិ ។ រសគ្គសគ្គី ហោតិ ។ សីហហនុ ហោតិ ។ ចត្តាឡីសទន្តោ[១] ហោតិ ។ សមទន្តោ ហោតិ ។ អវិរឡទន្តោ ហោតិ ។ សុសុក្កទាឋោ ហោតិ ។ បហូតជិវ្ហោ[២] ហោតិ ។ ព្រហ្មស្សរោ ហោតិ ។ ករវិកភាណី ហោតិ ។ អភិនីលនេត្តោ ហោតិ ។ គោបខុមោ ហោតិ ។ ឧណ្ណា ភមុកន្តរេ ជាតា ហោតិ ឱទាតា មុទុតូលសន្និភា ។ យំបិ ភិក្ខវេ មហាបុរិសស្ស ឧណ្ណា ភមុកន្តរេ ជាតា ហោតិ ឱទាតា មុទុតូលសន្និភា ។ ឥទំបិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។ បុន ចបរំ ភិក្ខវេ មហាបុរិសោ ឧណ្ហីសសីសោ ហោតិ ។

---

១ ឱ. ចត្តារីសទន្តោ ។ ២ ឱ. បហូលាជិវ្ហោ ។

លក្ខណសូត្រ ពោលអំពីមហាបុរិសលក្ខណៈ ៣២ ប្រការ

មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ កាយរបស់មហាបុរសប្រវែងណា ព្យាមរបស់មហាបុរសក៏ប្រវែងនោះដែរ គឺមានកាយនិងព្យាមស្មើគ្នា ។ មានព្រះសូរង៍មូលសម ។ មានព្រះប្រសាទ គឺសរសៃល្អិតធ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ ។ មានព្រះហនុកា (ចង្កា) ដូចជាចង្កានៃរាជសីហ៍ ។ មានព្រះទន្ត ៤០ គត់ ។ មានព្រះទន្តរាបស្មើ ។ មានព្រះទន្តជិតស្និទ្ធល្អ ។ មានព្រះទាឋា គឺចង្កូម (ទាំង ៤) សស្អាត ។ មានព្រះជិវ្ហាដ៏ធំវែង ។ មានព្រះសូរស័ព្ទ ដូចជាសំឡេងនៃព្រហ្ម ។ កាលបើបញ្ចេញវាចា លាន់ឮពីរោះ ដូចជាសំឡេងនៃសត្វករវិក ។ មានព្រះនេត្រខៀវស្រស់ ។ មានដួងព្រះនេត្រ ដូចជាភ្នែកនៃ (កូន) គោ ។ មានព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើម ដុះត្រង់ចន្លោះនៃព្រះភមុកា (ចិញ្ចើម) មានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី ។ ម្នាលភិក្ខុទាំងឡាយ មហាបុរស ដែលមានព្រះឧណ្ណាលោមដុះត្រង់ចន្លោះនៃព្រះភមុកា មានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាបុរសមានព្រះសិរ្ស៍ ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។

យំបិ ភិក្ខវេ មហាបុរិសោ ឧណ្ហីសសីសោ ហោតិ ។ ឥទំបិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។ ឥមានិ ខោ តានិ ភិក្ខវេ ទ្វត្តឹស មហាបុរិសស្ស មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ[១] គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ សង្ខិត្តំ ។ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ។ ឥមានិ ខោ ភិក្ខវេ ទ្វត្តឹស មហាបុរិសស្ស មហាបុរិសលក្ខណានិ ពាហិរកាបិ ឥសយោ ធារេន្តិ នោ ច ខោ តេ ជានន្តិ ។ ឥមស្ស កម្មស្ស កតត្តា ។ បេ ។ ឥមំ លក្ខណំ បដិលភតីតិ ។

---

១ ឱ. វការោ ន ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ មហាបុរសដែលមានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំង-ឡាយ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការនេះឯង ទើបបានជា មានគតិជាពីរយ៉ាង មិនមែនក្រៅអំពី ២ យ៉ាងនេះឡើយ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ សេចក្តីបំប្រួញ ។ បើទ្រង់ចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកឥសីជាខាងក្រៅ (អ្នកថា) តែងចេះចាំ មហាបុរិសលក្ខណៈ របស់មហាបុរសទាំង ៣២ ប្រការនេះឯង តែឥសីទាំងនោះ ឥតដឹងសោះ ។ ព្រោះមហាបុរសបានធ្វើនូវកម្មនេះ ។ បេ ។ ទើបបាននូវលក្ខណៈនេះ ។

៧

លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

[២] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ទឡ្ហសមាទានោ អហោសិ កុសលេសុ ធម្មេសុ អវត្ថិតសមាទានោ កាយសុចរិតេ វចីសុចរិតេ មនោសុចរិតេ ទានសំវិភាគេ សីលសមាទានេ ឧបោសថុបវាសេ[១] មត្តេយ្យតាយ[២] បេត្តេយ្យតាយ សាមញ្ញតាយ ព្រហ្មញ្ញតាយ កុលេជេដ្ឋាបចាយិតាយ អញ្ញតរញ្ញតរេសុ ច អធិកុសលេសុ ធម្មេសុ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ឧស្សន្នត្តា វិបុលត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ[៣] ។ សោ តត្ថ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគណ្ហាតិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ ។

១ ឱ. ឧបោសថូបវាសេ ។ ២ ម. មេត្តេយ្យតាយ ។ ៣ ឱ. ឧប្បជ្ជតិ ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[២] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលពីមុន ជាអ្នកបានសមាទានមាំមួន ក្នុងកុសលធម៌ទាំងឡាយ គឺជាអ្នកសមាទានជាប់មិនដាច់ ក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ការបរិច្ចាគទាន ការសមាទានសីល ការរក្សាឧបោសថ វត្តដែលត្រូវធ្វើចំពោះមាតា វត្តដែលត្រូវធ្វើចំពោះបិតា វត្តដែលត្រូវធ្វើចំពោះសមណៈ វត្តដែលត្រូវធ្វើចំពោះព្រាហ្មណ៍ វត្តដែលត្រូវធ្វើចំពោះជន ដែលជាច្បងក្នុងត្រកូល និងក្នុងពួកធម៌ជាកុសល ដ៏ក្រៃលែងឯទៀត ៗ ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះហេតុតែកុសលកម្ម ដែលមហាបុរស បានធ្វើសន្សំបណ្ដុះ ឲ្យធំទូលាយហើយនោះ ។ ព្រះតថាគតនោះ តែងគ្របសង្កត់ពួកទេវតាឯទៀត ក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ គឺ អាយុទិព្យ ១ សម្បុរទិព្យ ១ សុខទិព្យ ១ យសទិព្យ ១ ភាពជាធំដ៏ជាទិព្យ ១ រូបទិព្យ ១ សំឡេងទិព្យ ១ ក្លិនទិព្យ ១ រសទិព្យ ១ ផ្សព្វទិព្យ ១ ។ លុះព្រះតថាគត ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ ។

៨



[៣] សុបតិដ្ឋិតចាទោ ហោតិ សមំ ចាទំ ភូមិយំ និក្ខិបតិ សមំ ឧទ្ធរតិ សមំ សព្វាវន្តេហិ ចាទតលេហិ ភូមឹ ផុសតិ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ជម្មិកោ ជម្មរាជា ចាតុរន្តោ វិជិតាវី ជនបទដ្ឋាវរិយប្បត្តោ សត្តរតនសមន្នាគតោ ។ តស្សិមានិ សត្តរតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បឋវឹ សាគរបរិយន្តំ អខីលមនិមិត្តមកណ្ដកំ ឥទ្ធំ ផីតំ ខេមំ សិវំ និរព្វុទំ អទណ្ឌេន អសត្ថេន ជម្មេន សមេន អភិវិជិយ អជ្ឈាវសតិ រាជា សមានោ កឹ លភតិ

[៣] ព្រះតថាគត មានជើងប្រតិស្ឋានល្អ ដាក់ជើងលើផែនដីក៏ស្មើ លើកឡើងក៏ស្មើ គឺបាតជើងជិតស៊ប់នឹងផែនដីសព្វផ្ទៃជើង ។ ព្រះតថាគតនោះ ប្រកបហើយដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ មានជ័យជំនះ ផ្សាយអំណាចរហូតដល់ផែនដី ដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញ នឹងដល់នូវភាពជាអ្នកមានជនបទដ៏មាំមួន ប្រកបដោយរតន៍ទាំង ៧ ប្រការ ។ រតន៍ ៧ ប្រការរបស់ស្តេចចក្រពត្តិនោះ គឺចក្ករតន៍ ១ ហត្ថិរតន៍ ១ អស្សរតន៍ ១ មណិរតន៍ ១ ឥត្ថីរតន៍ ១ គហបតិរតន៍ ១ បរិនាយករតន៍ ១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្ររបស់ស្តេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្តេចឯទៀតបាន ។ ស្តេចចក្រពត្តិនោះ ប្រាបប្រាមគ្រប់គ្រងផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លាគឺចោរឡើយ ជាផែនដីស្តុកស្តម្ភ មាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ស្មើគឺសីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី

៩



អក្ខម្ភិយោ[១] ហោតិ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បច្ចាមិត្តេន រាជា សមានោ ឥទំ លភតិ ។ សចេ ខោ បន អគារស្មា[២] អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ពុទ្ធោ សមានោ កឹ លភតិ អក្ខម្ភិយោ ហោតិ អព្ភន្តរេហិ វា ពាហិរេហិ វា បច្ចត្ថិកេហិ[៣] បច្ចាមិត្តេហិ រាគេន វា ទោសេន វា មោហេន វា សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[៤] សច្ចេ ច ធម្មេ ច ទមេ ច សំយមេ
សោចេយ្យសីលាលយុបោសថេសុ ច
ចាណេ[៤] អហឹសាយ អសាហសេ រតោ
ទឡ្ហំ សមាទាយ សមន្តមាចរិ[៥] ។

---

១ ឱ. អវិក្ខម្ភិយោ ។ ២ ឱ. បនាគារស្មា ។ ៣ ឱ. ពាហិរកេហិ វា បច្ចត្ថិកេហិ វា ។ ៤ ឱ. ម. ទានេ ។ ៥ ឱ. សមត្តមាចរិ ។

នឹងបានជាអ្នកមិនតក់ស្លុត ដោយមនុស្សណាមួយជាសឹកសត្រូវ ជាបច្ចា-
មិត្ត កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បើចេញ
ចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងលោក
មានដំបូលគឺកិលេសបើកចេញហើយ កាលបើព្រះតថាគតបានត្រាស់ជា
ព្រះពុទ្ធ បាននូវរបស់អ្វី ទើបជាអ្នកមិនតក់ស្លុតដោយសឹកសត្រូវ បច្ចា-
មិត្ត ខាងក្នុងឬខាងក្រៅ គឺ រាគៈក្តី ទោសៈក្តី មោហៈក្តី សមណៈក្តី
ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ក្នុងលោក
(នេះ) ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ បានរបស់នេះ
ឯង ។ លុះព្រះមានព្រះភាគ បានពោលនូវសេចក្តីនេះ រួចហើយ ។
ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៤] ព្រះតថាគត តែងត្រេកអរ ក្នុងវចីសច្ចៈផង ក្នុងធម៌
គឺកុសលកម្មបថ ១០ ផង ក្នុងការទូន្មាននូវឥន្ទ្រិយផង ក្នុង
សេចក្តីសង្រួម (ក្នុងសីល) ផង ក្នុងការសម្អាតផ្លូវកាយ
ជាដើម និងសីលជាទីនៅអាស្រ័យ[១] និងឧបោសថកម្មផង
ក្នុងកិរិយាមិនបៀតបៀន នូវពួកសត្វផង ក្នុងអំពើដែល
មិនរួសរាន់ផង សមាទានមាំទាំ ប្រព្រឹត្តគ្រប់ទាំងអស់ ។

១ ដីកាថា សីលជាទីតាំងរបស់សមថៈនិងវិបស្សនា ។

សោ តេន កម្មេន តិទិវំ អបក្កមិ[១]
សុខញ្ច ខិឌ្ឌា រតិយោ ច អន្វភិ[២]
តតោ ចវិត្វា បុនរាគតោ ឥធ
សមេហិ បាទេហិ ផុសី វសុន្ធរំ[៣] ។
ព្យាកំសុ វេយ្យញ្ជនិកា សមាគតា
សមប្បតិដ្ឋស្ស ន ហោតិ ខម្ភនា
គិហិស្ស វា បព្វជិតស្ស វា បុន
តំ លក្ខណំ ភវតិ តទត្ថជោតកំ ។
អក្ខម្ភិយោ ហោតិ អគារមាវសំ
បរាភិភូ សត្តុភិ នប្បមទ្ទនោ[៤]
មនុស្សភូតេហិធ ហោតិ[៥] កេនចិ
អក្ខម្ភិយោ[៦] តស្ស ផលេន កម្មុនោ ។
សចេ ច[៧] បព្វជ្ជមុបេតិ តាទិសោ
នេក្ខម្មឆន្ទាភិរតោ វិចក្ខណោ

---

១ ឱ. ទិវំ សមក្កមិ ។ ២ ឱ. អានុភិ ។ ម. អន្វភិ ។ ៣ ឱ. ម. វសុន្ធរំ ។ ៤ ឱ. សត្តុ មទ្ទនោ ។ ៥ ឱ. មនុស្សភូតេន ន ហោតិ ។ ៦ ឱ. សុខម្ភិយោ ។ ៧ ឱ. ម. ច ។

ព្រោះកម្មនោះឯង ទើបតថាគត បានទៅកាន់ឋានសួគ៌ សោយសេចក្តីសុខ សេចក្តីសម្រាន្ត និងសេចក្តីត្រេកអរ លុះច្យុតចាកឋានសួគ៌នោះ បានមកកើតក្នុងមនុស្សលោកនេះវិញ ក៏មានផ្ទៃជើងទាំងពីររាបស្មើល្អ ជាន់ត្រូវនូវផែនដី (ដោយព្រះបាទដ៏ស្មើ) ។ ពួកជនអ្នកស្គាល់លក្ខណៈ មកប្រជុំគ្នាហើយទាយថា ព្រះតថាគត ដែលមានព្រះបាទប្រតិស្ឋានល្អ ទោះបីនៅជាគ្រហស្ថក្តី ធ្វើជាបព្វជិតក្តី ក៏ឥតញាប់ញ័រ (ដោយសត្រូវឡើយ) ព្រោះមានលក្ខណៈនោះ ជាគ្រឿងឆ្ពុះបំភ្លឺសេចក្តីនោះ ។ កាលបើនៅគ្រប់គ្រងគេហដ្ឋានតែងមិនញាប់ញ័រ (ដោយសត្រូវ) អាចគ្របសង្កត់នូវជនដទៃបាន ពួកសត្រូវក៏មិនអាចញាំញីបាន ព្រះតថាគត មិនបានតក់ស្លុតនឹងមនុស្សណាមួយ ក្នុងលោកនេះ ដោយសារផលនៃកម្មនោះឯង ។ បើបុគ្គល (មានលក្ខណៈ) ដូចព្រះតថាគតនោះ ចូលទៅកាន់ផ្នួស រមែងពេញចិត្តត្រេកអរ ក្នុងនេក្ខម្មៈ បានជាអ្នកប្រាជ្ញ ប្រសើរបំផុត

អគ្គោ ច សោ គច្ឆតិ ជាតុ ខម្ភនំ[១]
ចរុត្តមោ ឯស ហិ តស្ស ធម្មតាតិ ។

[៤] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ពហុជនស្ស សុខាវហោ[២] អហោសិ ឧព្វេគឧត្តាសភយំ[៣] អបនុទិតា ធម្មិកញ្ច រក្ខាវរណគុត្តឹ សំវិធាតា សបរិវារញ្ច ទានំ អទាសិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ឧស្សន្នត្តា វិបុលត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ សោ តត្ថ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគណ្ហាតិ ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ

---

១ ឱ. គត្តំ ។ ២ ឱ. ពហុជនសុខាយ ។ ៣ ឱ. ឧព្វេគំ ឧត្តាសំ ភយំ ។

អ្នកប្រាជ្ញនោះ ជាអគ្គបុគ្គលប្រសើរជាងនរជន តែងមិនដល់នូវសេចក្តីញាប់ញ័រ (ដោយកិលេស) ជាដាច់ខាត នេះឯងជាធម្មតា របស់ព្រះតថាគតនោះ ។

[៥] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបាននាំមកនូវសេចក្តីសុខ ឲ្យដល់ជនច្រើននាក់ផង ជាអ្នកកម្ចាត់បង់នូវភ័យគឺសេចក្តីភ្ញាក់ផ្អើល និងសេចក្តីតក់ស្លុតផង ជាអ្នកចាត់ចែង នូវការរក្សាការពារ គ្រប់គ្រងប្រកបដោយធម៌ផង បានឲ្យទានព្រមទាំងបរិវារ (របស់ទាន[១]) ផង ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះកុសល-កម្មដែលព្រះតថាគតបានធ្វើ សន្សំ បណ្តុះបណ្តាល ឲ្យធំទូលាយនោះឯង ។ ព្រះតថាគត តែងគ្របសង្កត់នូវទេវតាឯទៀត ក្នុងឋានសួគ៌នោះដោយហេតុ ១០ ប្រការ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ

១ អដ្ឋកថា ថា បរិវារ របស់ទានមាន ១០ ប្រការគឺ បាយ ទឹក សំពត់ យាន ផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាប គ្រែ ឬ តាំង លំនៅ ប្រទីបនិងប្រេង ។

ហេដ្ឋាចាគតលេសុ ចក្កានិ ជាតានិ ហោន្តិ សហស្សា-
រានិ សនេមិកានិ សនាភិកានិ សព្វាការបរិបូរានិ
សុវិភត្តន្តរានិ ។ សោ តេន លក្ខណេន សមន្នាគតោ
សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។
រាជា សមានោ កឹ លភតិ មហាបរិវារោ ហោតិ
មហាស្ស ហោន្តិ បរិវារា[១] ព្រាហ្មណគហបតិកា
នេគមា ជានបទា[២] គណកមហាមត្តា អនិកដ្ឋា
ទោវារិកា អមច្ចា បារិសជ្ជា រាជានោ ភោគិកា[៣]
កុមារា រាជា សមានោ ឥទំ លភតិ ។ សចេ[៤] អគា-
រស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មា-
សម្ពុទ្ធោ លោកេ វិវដច្ឆទោ ពុទ្ធោ សមានោ កឹ
លភតិ មហាបរិវារោ ហោតិ មហាស្ស ហោន្តិ
បរិវារា[៥] ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិ-
កាយោ ទេវា មនុស្សា អសុរា នាគា គន្ធព្វា
ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា
អវោច ។ តត្ថេតំ វុច្ចតិ

---

១ ឱ. បរិវារោ ។ ២ ឱ. នេគមជានបទា ។ ៣ ឱ. ម. ភោគិយា ។ ៤ ឱ. សចេ បន ។ ៥ ឱ. ហោតិ បរិវារោ ។

គឺ ត្រង់ផ្ទៃជើងទាំងគូខាងក្រោម មានរូបចក្រ ប្រកបដោយខ្នងកង់និងដុំព្រមទាំងកាំ ១.០០០ មានចន្លោះស្មើគ្នា គ្រប់អន្លើ ។ ព្រះតថាគតនោះប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ បើបានជាស្តេចហើយ តើនឹងបានរបស់អ្វី ទើបជាអ្នកមានបរិវារច្រើន ឯបរិវារច្រើនរបស់ស្តេចនោះគឺ ព្រាហ្មណ៍ គហបតីអ្នកនិគម អ្នកជនបទ ពួកស្មៀននិងមហាមាត្រ ពួកសេនាមានអង្គ ៤ (មានសេនាដំរីជាដើម) អ្នករក្សាទ្វារ អាមាត្យ ពួកបរិស័ទ ស្តេច (បំណុះ) ពួកអ្នកមានទ្រព្យ និងពួករាជកុមារ កាលបើបានជាស្តេចនឹងបានរបស់នេះ ។ បើចេញចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូលគឺកិលេសបើកចេញហើយ កាលបើបានត្រាស់ជាព្រះពុទ្ធហើយ តើបានរបស់អ្វី ទើបជាអ្នកមានបរិវារច្រើន ឯបរិវារច្រើនរបស់ព្រះពុទ្ធនោះគឺ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើបានត្រាស់ជាព្រះពុទ្ធ បាននូវបរិស័ទនេះ ។ លុះព្រះមានព្រះភាគបានត្រាស់សេចក្តីនេះចប់ហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះក្នុងលក្ខណៈនោះថា

១៣

## លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

[៦] បុរេ បុរត្ថា បុរិមាសុ ជាតិសុ
មនុស្សភូតោ ពហុនំ(១) សុខាវហោ
ឧព្វេគឧត្តាសភយាបនូទនោ
គុត្តីសុ រក្ខាវរណេសុ ឧស្សុកោ ។
សោ តេន កម្មេន តិទិវំ អបក្កមិ(២)
សុខញ្ច ខិឌ្ឌា រតិយោ ច អន្វភិ(៣)
តតោ ចវិត្វា បុនរាគតោ ឥធ
ចក្កានិ បាទេសុ ទុវេសុ វិន្ទតិ
សមន្តនេមិនិ សហស្សារានិ ច ។
ព្យាកំសុ វេយ្យញ្ជនិកា សមាគតា
ទិស្វា កុមារំ សតបុញ្ញលក្ខណំ
បរិវារវា ហេស្សតិ សត្តុមទ្ទនោ
តថា ហិ ចក្កានិ សមន្តនេមិនិ ។
សចេ ន បព្វជ្ជមុបេតិ តាទិសោ
វត្តេតិ ចក្កំ បឋវឹ បសាសតិ
តស្សានុយន្តា ឥធ ភវន្តិ ខត្តិយា

១ ឱ. ពហុន្នំ ។ ២ ឱ. ទិវំ សមក្កមិ ។ ៣ ឱ. អានុភិ ។ ម. អន្វភិ ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[៦] ព្រះតថាគត កើតជាមនុស្សក្នុងកាលពីមុន ៗ ជាតិពីមុន ៗ ជាអ្នកនាំនូវសេចក្តីសុខមកឲ្យដល់ជនច្រើននាក់ ជាអ្នកបន្ទោបង់នូវភ័យ គឺសេចក្តីភ្ញាក់ផ្អើល និងសេចក្តីតក់ស្លុតជាអ្នកខ្វល់ខ្វាយក្នុងការគ្រប់គ្រង ការរក្សា ការពារ ។ ព្រោះកម្មនោះ ព្រះតថាគតបានទៅកាន់ឋានសួគ៌ ហើយសោយសេចក្តីសុខ សេចក្តីសម្រាន្ត និងសេចក្តីត្រេកអរ លុះព្រះតថាគត ច្យុតចាកឋានសួគ៌នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវចក្រត្រង់ផ្ទៃជើងទាំងពីរ ប្រកបដោយខ្នងកង់និងដុំព្រមទាំងកាំ ១.០០០ មានចន្លោះស្មើគ្នា ។ ពួកជនអ្នកស្គាល់លក្ខណៈ បានឃើញរាជកុមារ ដែលមានលក្ខណៈនៃបុណ្យច្រើន (យ៉ាងនេះ) ទើបព្រមគ្នាព្យាករថា (ព្រះរាជកុមារនេះ) នឹងមានបរិវារច្រើន អាចញ៉ាំញីនូវសត្រូវបានដូចជាចក្រដែលមានខ្នងកង់ (និងដុំព្រមទាំងកាំ ១ .០០០) មានចន្លោះស្មើគ្នា ដូច្នោះឯង ។ បើព្រះរាជកុមារ (ដែលប្រកបដោយលក្ខណៈ) ដូច្នោះ មិនបានចេញទៅទ្រង់ព្រះផ្នួសទេ នឹងបានជាស្តេចចក្រពត្តិ ទ្រង់ប្រាបប្រាមផែនដី មានពួកក្សត្រ

មហាយសា សបរិវារយន្តិ(១) នំ ។
សចេ វ(២) បព្វជ្ជមុបេតិ តាទិសោ
នេក្ខម្មឆន្ទាភិរតោ វិចក្ខណោ
ទេវា(៣) មនុស្សាសុរសក្ករក្ខសា
គន្ធព្វនាគា វិហគ្គា(៤) ចតុប្បទា
អនុត្តរំ ទេវមនុស្សបូជិតំ
មហាយសា សបរិវារយន្តិ នំ(៥) ។

[៧] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ(៦) និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហាសិ ។ សោ តស្ស កម្មស្ស កតត្តា ។ បេ ។ សោ តតោ ចុតោ

១ ឱ. មហាយសំ សម្បរិវារយន្តិ ។ ២ ឱ. ម. ច ។ ៣ ឱ. ទេវ ។ ៤ ឱ. ម. វិហគា ។ ៥ ម. នន្តិ ។ ៦ ឱ. ម. អហោសិ ។

ដែលចុះចូល មានយសសក្តិធំ ទៅតាមហែហមព្រះរាជ-កុមារនោះក្នុងទីនេះ ។ បើព្រះរាជកុមារ (ដែលប្រកបដោយលក្ខណៈ) ដូច្នោះ ចេញទៅទ្រង់ព្រះផ្នួស តែងពេញចិត្តត្រេកអរ ចំពោះនេក្ខម្មៈ នឹងបានជាអ្នកប្រាជ្ញ មានទេវតា មនុស្ស អសុរ ព្រះឥន្ទ្រ អារក្ស គន្ធព្វ នាគ សត្វបក្សី សត្វជើង ៤ ដែលមានយសសក្តិធំ ចោមរោមព្រះពុទ្ធដ៏ប្រសើរ ដែលទេវតានិងមនុស្ស បូជាហើយនោះ ។

[៧] ម្នាលភិក្ខុទាំងឡាយ កាលតថាគត អាស្រ័យនូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញានិងគ្រឿងសស្ត្រាវុធ មានសេចក្តីខ្មាសបាប មានចិត្តអាសូរករុណា តែងអនុគ្រោះសព្វសត្វដោយប្រយោជន៍ ។ ព្រះតថាគតនោះ ព្រោះបានធ្វើនូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះច្យុតចាកឋានសួគ៌នោះ

ឥត្ថត្តំ អាគតោ សមានោ ឥមានិ តីណិ មហាបុរិសលក្ខណានិ បដិលភតិ អាយតបណ្ហិ ច ហោតិ ទីឃង្គុលី ច ព្រហ្មុជុគត្តោ ច ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ ទីឃាយុកោ ហោតិ ចិរដ្ឋិតិកោ ទីឃមាយុបាលេតិ[1] ន សក្កា ហោតិ អន្តរា ជីវិតា វោរោបេតុំ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បច្ចាមិត្តេន រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ ទីឃាយុកោ ហោតិ ចិរដ្ឋិតិកោ ទីឃមាយុបាលេតិ ន សក្កា ហោតិ អន្តរា ជីវិតា វោរោបេតុំ បច្ចត្ថិកេហិ បច្ចាមិត្តេហិ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

១ ឱ. ទីឃមាយុម្បាលេតិ ។ ម. ទីឃមាយុំ . . . ។

មកកាន់អត្តភាព ជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣ នេះ គឺជាអ្នកមានកែងជើងវែង ១ មានម្រាមដៃនិងម្រាមជើងវែង ៗ ១ មានកាយត្រង់ដូចជាកាយព្រហ្ម ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈ (ទាំង ៣) នោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ បើបានជាស្តេចហើយ តើនឹងបាននូវរបស់អ្វី គឺនឹងបានជាអ្នកមានអាយុវែង ប្រតិស្ឋាននៅអស់កាលយូរ គ្រប់គ្រងនូវជន្មាយុឲ្យរស់នៅបានយូរ មនុស្សជាសឹកសត្រូវនិងជាបច្ចាមិត្តណាមួយ មិនអាចនឹងផ្តាច់បង់ជីវិតត្រង់រវាងអាយុបានទេ កាលបើបានជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានអាយុវែង ប្រតិស្ឋាននៅអស់កាលយូរ គ្រប់គ្រងជន្មាយុរស់នៅបានយូរ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ជាសឹកសត្រូវជាបច្ចាមិត្ត ក្នុងលោកនេះ មិនអាចនឹងផ្តាច់បង់ជីវិតត្រង់រវាងអាយុបានឡើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបាននូវរបស់នេះឯង ។ លុះព្រះមានព្រះភាគបានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៨] មរណវធភយមត្តនោ(១) វិទិត្វា
បដិវិរតោ បរំ មរណាយ អហោសិ
តេន សោ(២) សុចរិតេន សគ្គមគមាសិ(៣)
សុកតផលវិបាកមនុភោសិ ។
ចវិយ បុនរាគតោ សមានោ
បដិលភតិ ឥធ តីណិ លក្ខណានិ
ភវតិ វិបុលទីឃបាសុណិកោ(៤)
ព្រហ្មាវ សុជ្ជុ(៥) សុភោ សុជាតគត្តោ ។
សុភុជោ សុសូ(៦) សុសណ្ឋិតោ សុជាតោ
មុទុតលុនង្គុលិយស្ស ហោន្តិ
ទីឃា តីហិ បុរិសលក្ខណេហិ(៧)

---

១ ឱ. ម. មរណវធភយវត្តនោ ។ ២ ឱ. ម. សោតិ ន ទិស្សតិ ។ ៣ ឱ. ម. សគ្គមគមា ។ ៤ ឱ. វិបុលទីឃបាណិកោ ។ ម. វិបុលទីឃបាសណ្ហិកោ ។ ៥ ឱ. ព្រហ្មាវិយុជ្ជុ ។ ៦ ឱ. ម. សុសុ ។ ៧ ឱ. ម. តីហិ បុរិសវរលក្ខណេហិ ។

[៨] ព្រះតថាគតដឹងច្បាស់នូវភ័យអំពីសេចក្ដីស្លាប់ ដែលហៅថា មរណៈចំពោះខ្លួនឯងហើយ បានវៀរស្រឡះចាកការសម្លាប់នូវសត្វដទៃ ព្រោះអំពើសុចរិតនោះឯង ព្រះតថាគតនោះ បានទៅកើតក្នុងឋានសួគ៌ សោយផលវិបាករបស់កម្ម ដែលបានធ្វើទុកល្អហើយ ។ លុះច្យុតចាក (ឋានសួគ៌) នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវលក្ខណៈទាំង ៣ នេះក្នុងភពនេះ គឺជាអ្នកមានកែងជើងវែងទូលាយ ១ មានកាយត្រង់ល្អស្អាត ដូចជាកាយព្រហ្ម ១។ មានភ្នែនល្អ មានរូបនៅក្មេង មានទ្រង់ទ្រាយល្អ មានជាតិល្អ អង្គុលីរបស់ព្រះតថាគតនោះ ទន់ល្វន់វែងល្អ ព្រះតថាគតប្រកបដោយមហាបុរិសលក្ខណៈ ៣ (នេះ)

ចិរយាបនាយ(១) កុមារមាទិសន្តិ ។
ភវតិ យទិ គិហី ចិរំ យបេតិ
ចិរតរំ បព្វជតិ យទិ តតោ ហិ
យាបយតិ វសិទ្ធិភាវនាយ
ឥតិ ទីឃាយុកតាយ តន្និមិត្តន្តិ(២) ។

[៩] យម្បិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ទាតា អហោសិ បណីតានំ រសិតានំ ខាទនីយានំ ភោជនីយានំ សាយនីយានំ លេហនីយានំ បានានំ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ សត្តស្ស ឧស្សទា ហោន្តិ(៣) ឧភោសុ ហត្ថេសុ ឧស្សទា ហោន្តិ ឧភោសុ បាទេសុ ឧស្សទា ហោន្តិ

១ ឱ. ម. ចិរយបនាយ ។ ២ ម. តំ និមិត្តន្តិ ។ ៣ ឱ. សត្តុស្សទោ ហោតិ សត្តុស្សទា ហោន្តិ ។ ម. សត្តុស្សទោ ហោតិ សត្តុស្ស ឧស្សទា ហោន្តិ ។

ដើម្បីញ៉ាំងជីវិត ឲ្យប្រព្រឹត្តទៅអស់កាលយូរ ប្រហែលដូច ជានៅក្មេង ។ បើព្រះតថាគតនៅជាគ្រហស្ថ តែងញ៉ាំង ជីវិតឲ្យរស់នៅអស់កាលយូរ បើចេញទៅបួសនឹងញ៉ាំងជីវិត ឲ្យរស់នៅអស់កាលយូរជាងនោះទៅទៀត ព្រះតថាគតជា អ្នកស្ទាត់ជំនាញ រមែងញ៉ាំងជីវិតឲ្យរស់នៅ ដោយការចម្រើន ឫទ្ធិ លក្ខណៈទាំង ៣ នោះ ជានិមិត្តរូបនៃទីឃាយុភាព យ៉ាងនេះឯង ។

[៩] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវ ជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលមុន ជា អ្នកឲ្យនូវខាទនីយភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក (៨ ប្រការ) ដែលគួរភ្លក្ស គួរលិទ្ធ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំកុសលកម្មនោះ ។ បេ ។ លុះបែកធ្លាយរាងកាយខាងមុខ អំពី មរណៈក៏បានទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។ បេ ។ លុះព្រះ តថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏ បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានសាច់ដ៏ពេញក្នុងទីទាំង ៧ អន្លើ គឺសាច់ពេញត្រង់ខ្នងដៃទាំងពីរ សាច់ពេញត្រង់ខ្នងជើងទាំងពីរ

ឧភោសុ អំសកូដេសុ ឧស្សទា ហោន្តិ ខន្ធេ ឧស្សទា ហោន្តិ[១] ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ លាភី ហោតិ បណីតានំ រសិតានំ ខាទនីយានំ ភោជនីយានំ សាយនីយានំ លេហនីយានំ បានានំ រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ លាភី ហោតិ បណីតានំ រសិតានំ ខាទនីយានំ ភោជនីយានំ សាយនីយានំ លេហនីយានំ បានានំ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[១០] ខជ្ជភោជ្ជំ អថ លេហសាយិតំ[២]
ឧត្តមគ្គរសទាយកោ អហុ
តេន សោ សុចរិតេន កម្មុនា
នន្ទវនេ[៣] ចិរមភិប្បមោទតិ ។
សត្ត ចុស្សទេ[៤] ឥធាធិគច្ឆតិ

១ ឱ. ម. ឧស្សទោ ហោតិ ។ ២ ឱ. លេយ្យសាយិយំ ។ ម. លេយ្យំ សាយិតំ ។ ៣ ឱ. នន្ទនេ ។ ៤ ឱ. វុស្សទេ ។

សាច់ពេញត្រង់ចន្លុយស្មាទាំងពីរ សាច់ពេញត្រង់-ក ។ ព្រះតថាគត នោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹង បានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយ តើនឹង បានរបស់អ្វី គឺនឹងបាននូវខាទនីយភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក (៨ ប្រការ) ដែលគួរភ្លក្ស គួរលិទ្ធ បើបានជាស្តេចនឹង បាននូវរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបាននូវខាទនីយភោជនីយាហារ មានរសជាតិ ដ៏ថ្លៃថ្លា ព្រមទាំងទឹក (៨ ប្រការ) ដែលគួរភ្លក្ស គួរលិទ្ធ កាលបើ បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុង លក្ខណៈនោះថា

[១០] ព្រះតថាគត ជាអ្នកឲ្យនូវខាទនីយភោជនីយាហារ និងទឹកដែលគួរលិទ្ធ គួរភ្លក្ស ដែលមានរសជាតិដ៏ឧត្តមថ្លៃថ្លា ព្រោះកម្ម ជាសុចរិតនោះ ព្រះតថាគតនោះទើបរីករាយក្នុង នន្ទវ័ន (ឱទ្យាន) អស់កាលយូរ ។ (លុះច្យុតមកកើត) ក្នុង មនុស្សលោកនេះ ក៏បាននូវសាច់ដ៏ពេញក្នុងទីទាំង ៧ អន្លើផង

១៩

លក្ខណសុត្តេ តថាគតបុព្វាធិការកថា

ហត្ថបាទមុទុតលញ្ច(១) វិទ្ធតិ
អាហុ ព្យញ្ជននិមិត្តកោវិទា
ខជ្ជភោជនរសលាភិតាយ(២) ។
ន តំ គិហិស្សបិ(៣) តទត្ថជោតកំ
បព្វជ្ជំបិ ច តទាធិគច្ឆតិ(៤)
ខជ្ជភោជនស្ស(៥) លាភិរុត្តមំ
អាហុ សព្វគិហិពន្ធនច្ឆិទន្តិ ។

[១១] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ចតូហិ សង្គហវត្ថូហិ ជនសង្គហិកោ(៦) អហោសិ ទានេន បិយវាចេន អត្ថចរិយាយ ស-មានត្តតាយ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ឧស្សន្នត្តា វិបុលត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។

---

១ ឱ. ហត្ថបាទមុទុតញ្ច ។ ២ ឱ. ខជ្ជភោជនរសលាភិតាយ ។ ម. ខជ្ជភោជនស្ស លា-ភិតាយ ។ ៣ ម. នំ យំ គិហិស្សាបិ ។ ៤ ឱ. បព្វជ្ជម្បិ តទធិគច្ឆតិ។ ៥ ឱ. ខជ្ជភោជរស ។ ៦ ឱ. ជនំ សង្គហិតា ។ ម. ជនំ សង្គាហកោ ។

បាននូវផ្ទៃដៃ និងផ្ទៃជើង ដ៏ទន់ល្មន់ផង ជនទាំងឡាយ ដែលជាអ្នកឈ្លាស ក្នុងការទាយនូវព្យញ្ជនៈនិងនិមិត្ត នាំគ្នាទាយ (ព្រះតថាគត) ព្រោះហេតុដែលព្រះតថាគតបានឲ្យនូវខាទនីយភោជនីយាហារ ទើបបាននូវខាទនីយភោជនយាហារ មានរស (ជាតិដ៏ថ្លៃថ្លា) ។ លក្ខណៈនោះ មិនមែនជាគ្រឿងធ្វើ្ទុះបំភ្លឺសេចក្ដីដល់ព្រះតថាគត ដែលនៅជាគ្រហស្ថប៉ុណ្ណោះទេ ទោះបីតថាគតចេញទៅបួស ក៏គង់បានទទួលផលនោះដែរ អ្នកដែលបាននូវខាទនីយភោជនីអាហារ មានរសជាតិដ៏ឧត្តម ហៅថា អ្នកកាត់បង់នូវចំណងរបស់គ្រហស្ថទាំងអស់បាន ។

[១១] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានសង្រ្គោះ ដល់ពពួកជន ដោយសង្គហវត្ថុ ៤ ប្រការ គឺទាន ១ ពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តដែលជាប្រយោជន៍ ១ ការតាំងខ្លួនស្មើគឺមិនប្រកាន់ខ្លួន ១ ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះកុសលកម្មដែលព្រះតថាគតបានធ្វើ សន្សំ បណ្ដុះបណ្ដាលឲ្យធំទូលាយនោះឯង ។

សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ មុទុតលុហត្ថ-ចាទោ ច[១] ហោតិ ជាលហត្ថចាទោ ច ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមា-នោ កឹ លភតិ សុសង្គហិតបរិជនោ ហោតិ សុសង្គ-ហិតស្ស ហោន្តិ ព្រាហ្មណគហបតិកា នេគមា ជា-នបទា[២] គណកមហាមត្តា អនីកដ្ឋា ទោវារិកា អមច្ចា ចារិសជ្ជា រាជានោ ភោគិកា[៣] កុមារា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ សុសង្គហិតបរិជនោ ហោតិ សុសង្គ-ហិតស្ស ហោន្តិ ភិក្ខូ ភិក្ខុនិយោ ឧចាសកា ឧចាសិកាយោ ទេវា មនុស្សា អសុរា នាគា គន្ធព្វា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

---

១ ឱ. មុទុតលុនហត្ថបាទោ ។ ម. មុទុតលុនហត្ថបាទោ ច ។ ២ ឱ. ម. នេគមជា-នបទា ។ ៣ ឱ. ម. ភោគិយា ។

លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្ស នេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានផ្ទៃដៃនិងផ្ទៃជើងទន់ល្វន់ (ដូចជាសំឡីដែលគេថ្លៃចអស់ ១០០ ដង) ១ មានផ្ទៃដៃនិងផ្ទៃជើង ប្រទាក់ដោយក្រឡា ដូចជាសំណាញ់ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយ តើនឹងបាននូវរបស់អ្វី គឺនឹងបានជាអ្នកសង្គ្រោះនូវជនជាបរិស័ទ ជនជាបរិស័ទដែលព្រះតថាគតបានសង្គ្រោះនោះគឺ ពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន មហាមាត្រ ពួកសេនាមានអង្គ ៤ (មានសេនាដំរីជាដើម) ឆ្មាំទ្វារ អាមាត្យ រាជបរិស័ទ ស្តេចចំណុះ អ្នកមានភោគៈ និងរាជកុមារ កាលបើព្រះតថាគតនៅជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបាននូវរបស់អ្វី គឺនឹងបានជាអ្នកសង្គ្រោះនូវជនជាបរិស័ទ ជនជាបរិស័ទដែលព្រះតថាគត បានសង្គ្រោះនោះគឺ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

២១

លក្ខណសុត្តេ តថាគតបុញ្ញាធិការគាថា

[១២] ទានំបិ ចត្ថចរិយតញ្ច[១]
បិយវទតញ្ច សមានឆន្ទញ្ច[២]
ការិយ ចរិយ សុសង្គហំ ពហុន្នំ
អនវមតេន[៣] គុណេន យាតិ សគ្គំ ។
ចវិយ បុនរិធាគតោ សមានោ
ករចរណមុទុតញ្ច[៤] ជាលិនោ ច
អតិរុចិរសុវគ្គុទស្សនេយ្យំ
បដិលភតិ ទហរោ សុសុកុមារោ ។
ភវតិ បរិជនស្ស វោ វិធេយ្យោ
មហិមំ អាវសិតោ[៥] សុសង្គហិតោ
បិយវទូ[៦] ហិតសុខតំ ជិគីសមានោ
អភិរុចិតានិ គុណានិ អាចរតិ ។
យទិ បជហាតិ[៧] សព្វកាមភោគំ[៨]

---

១ ឱ. ទានម្បិ ច អត្ថចរិយតម្បិ ច ។ ម. ទានម្បិ... ។ ២ ម. បិយវាទិតញ្ច សមានត្តញ្ច ។ ៣ ម. អនមតេន ។ ៤ ឱ. ករចរណមុទុតញ្ច ។ ម. ករចរណមុទុត-លញ្ច ។ ៥ ម. អាវសិកោ ។ ៦ ម. បិយវទំ ។ ៧ ឱ. ម. យទិ ច ជហាតិ ។ ៨ ឱ. សព្វកាមគុណភោគំ ។

លក្ខណសូត្រ គាថាសំដែងអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[១២] ព្រះតថាគតបានធ្វើ បានប្រព្រឹត្តការសង្គ្រោះដោយល្អ ដល់ពួកជនច្រើននាក់ (ដោយសង្គហវត្ថុ ៤ ប្រការ) គឺ ទាន ១ ការប្រព្រឹត្តដែលជាប្រយោជន៍ ១ ពាក្យជាទីស្រឡាញ់ ១ សេចក្តីពេញចិត្ត ក្នុងការតាំងខ្លួនស្មើ ១ ទើបទៅកាន់ឋានសួគ៌ដោយគុណ គឺសេចក្តីមិនប្រមាទ ។ លុះព្រះតថាគតច្យុត (ចាកឋានសួគ៌នោះ) មកកើតក្នុងភពនេះទៀត ជាមនុស្សកំឡោះ នៅក្មេងល្អ ក៏បាននូវអំពើដែលគួរធ្វើ គួរប្រព្រឹត្តទន់ភ្លន់ផង បាននូវសេចក្តីរុងរឿងសេចក្តីឈ្លាសវៃក្រៃលែង និងរូបដែលគួរឲ្យអ្នកផងពិតពិលរមិលមើល ដើម្បីចេញចាកសំណាញ់ ពោលគឺសង្សារ ។ ព្រះតថាគតបានចាត់ចែងការងារ បានគ្រប់គ្រងនូវផែនដីធំនេះ និងការសង្គ្រោះដោយល្អ ចំពោះជនជាបរិស័ទ ពោលពាក្យជាទីស្រឡាញ់ ស្វែងរកនូវប្រយោជន៍ និងសេចក្តីសុខ អើពើតែនឹងគុណដែលខ្លួនគាប់ចិត្តដ៏ក្រៃលែង ។ បើព្រះតថាគតលះបង់ នូវការបរិភោគកាមគ្រប់យ៉ាងហើយ

កាថយតិ ធម្មកថំ ជិនោ ជនស្ស
វចនបដិករស្សាភិប្បសន្នា
សុត្វាន ធម្មានុធម្មមាចរន្តីតិ[១] ។

[១៣] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ អត្ថុបសញ្ហិតំ ធម្មុបសញ្ហិតំ[២] វាចំ ភាសិតា អហោសិ ពហុជនំ និទស្សេតិ[៣] បាណីនំ ហិតសុខាវហោ ធម្មយាគី ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបុលត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ ឧស្សង្ខបាទោ ច ហោតិ ឧទ្ធគ្គលោមោ ច ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ

១ ឱ. សុត្វា ធម្មានុធម្មំ អាចរន្តីតិ ។ ២ ឱ. សមានោ ពហុនោ ជនស្ស អត្ថូបសំហិតំ ធម្មូបសំហិតំ ។ ៣ ឱ. ម. និទំសេតិ ។

(ចេញទៅបួស) នឹងបានជាព្រះជិនស្រី សំដែងនូវធម្មកថា ដល់ជនជាបរិស័ទ ពួកជនជាបរិស័ទ ដែលបានស្តាប់ ធម្មកថានោះ ក៏ជ្រះថ្លា ហើយធ្វើតាមពាក្យនៃព្រះតថាគត នោះ ទើបនាំគ្នាប្រព្រឹត្តនូវធម៌ដ៏សមគួរដល់ធម៌ ។

[១៣] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានពោលពាក្យប្រកបដោយប្រយោជន៍ ទាំងប្រកបដោយធម៌ បានពន្យល់ជនច្រើននាក់ តែងនាំមកនូវប្រយោជន៍និងសេចក្តីសុខ ឲ្យដល់សត្វទាំង-ឡាយ ជាអ្នកបូជានូវធម្មទាន ។ ព្រោះកុសលកម្មដែលព្រះតថាគតបានធ្វើ សន្សំឲ្យធំទូលាយហើយនោះ ព្រះតថាគតនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមាន-កជើងដូចជាអណ្តែតឡើងខាងលើ ១ មានចុងរោម-ងឡើងលើ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបាន

លក្ខណសុត្តេ តថាគតបុញ្ញាធិការគាថា

កឹ លភតិ អគ្គោ ច ហោតិ សេដ្ឋោ ច ចា-
មោក្ខោ ច ឧត្តមោ ច បវរោ ច កាមភោគីនំ
រាជា សមានោ ឥធំ លភតិ ។ បេ ។ ពុទ្ធោ
សមានោ កឹ លភតិ អគ្គោ ច ហោតិ សេដ្ឋោ
ច ចាមោក្ខោ ច ឧត្តមោ ច បវរោ ច សព្វ-
សត្តានំ ពុទ្ធោ សមានោ ឥធំ លភតិ ។ ឯតមត្ថំ
ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[១៤] អត្តជម្មំ សង្ហិតំ បុរេ គិរំ
ឯរិយំ[១] ពហុជនំ និធំសយិ
ចាណិនំ[២] ហិតសុខាវហោ អហុ
ជម្មយាគំ អស្សជ្ជិ[៣] អមច្ឆរី ។
តេន សោ សុចរិតេន កម្មុនា
សុគតឹ វជតិ[៤] តត្ថ មោទតិ
លក្ខណានិ ច ទុវេ[៥] ឥធាគតោ
ឧត្តមសុខតាយ វិន្ទតិ[៦] ។

---

១ ឱ. ម. ឯរយំ ។ ២ ឱ. ម. បាណីនំ ។ ៣ ឱ. ធម្មយាគមស្សជ្ជិ ។
៤ ម. ភជតិ ។ ៥ ឱ. ទ្វេ ។ ៦ ឱ. ឧត្តមសុខានិ សំវិន្ទតិ ។

របស់អ្វី គឺនឹងបានជាចម្បង ប្រសើរ ជាប្រធាន ឧត្តម បវរ ជាងពួកជនដែលបរិភោគកាម កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាចម្បង ប្រសើរ ជាប្រធាន ឧត្តម បវរ ជាងពួកសត្វទាំងអស់ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ ព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[១៤] ក្នុងភពពីមុន ព្រះតថាគត បានពោលពាក្យដែលប្រកបដោយអត្ថ ទាំងប្រកបដោយធម៌ បានពន្យល់ប្រយោជន៍ដល់ជនច្រើននាក់ ជាអ្នកបាននាំមកនូវប្រយោជន៍និងសេចក្តីសុខ ឲ្យដល់សត្វទាំងឡាយ ជាអ្នកមិនមានសេចក្តីកំណាញ់ បានចាត់ចែងនូវការបូជាធម្មទាន ។ ព្រះតថាគតនោះ បានទៅកាន់ឋានសុគតិ រីករាយក្នុងឋានសុគតិនោះ ព្រោះកម្មជាសុចរិតនោះឯង (លុះច្យុតចាកឋានសួគ៌នោះ) មកកើតក្នុងភពនេះ ក៏បាននូវលក្ខណៈទាំងពីរ ដើម្បីភាពនៃសេចក្តីសុខដ៏ឧត្តម ។

ឧគ្គមុប្បតិតលោមវា សសោ[១]
ចារគណ្ឋិរហុ សាធុ សណ្ឋិតា ។
មំសលោហិតាចិតា តចោត្តជា[២]
ឧបរិជានុ សោភណា[៣] អហុ ។
គេហមាវសតិ ចេ តថាវិធោ
អគ្គតំ វជតិ កាមភោគិនំ
តេន ឧត្តរិតរញ្ញ[៤] ន វិជ្ជតិ
ជម្ពុទីបំ អភិភុយ្យ ឥរិយតិ ។
បព្វជ្ជាបិ[៥] ច អនោមនិក្កមោ
អគ្គតំ វជតិ សព្វចាណិនំ
តេន ឧត្តរិតរោ ន វិជ្ជតិ
សព្វលោកំ[៦] អភិភុយ្យ វិហរតីតិ ។

---

១ ម. សេសោ ។ ២ ឱ. តចោតតា ។ ម. តចោត្តតា ។ ៣ ឱ. បរិ ច បន សោភណា ។ ម. ឧបរិ ចរណោសោភណោ ។ ៤ ឱ. ម. ឧត្តរិតរោ ។ ៥ ឱ. បព្វជម្បិ ។ ម. បព្វជំបិ ។ ៦ ឱ. ម. សព្វំ លោកំ ។

ព្រះតថាគតនោះ មានចុងរោម-ងឡើងលើ មានសន្ទាក់-កជើង ប្រតិស្ឋានល្អ មានសាច់និងឈាមប្រផូរ បិទបាំងដោយស្បែក មានជង្គង់ល្អ ។ ព្រះតថាគតបានប្រកបដោយលក្ខណៈដូច្នោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាអ្នកខ្ពង់ខ្ពស់ ជាងពួកជនអ្នកបរិភោគកាម មិនមានអ្នកដទៃក្រៃលែងជាងព្រះតថា-គតនោះបានឡើយ ព្រះតថាគតតែងគ្របសង្កត់ នូវជម្ពូទ្វីប (ទាំងមូល) ។ សូម្បីបព្វជ្ជា (របស់ព្រះតថាគត) ក៏មិនថយថោកឡើយ តែងដល់នូវភាពជាអ្នកខ្ពង់ខ្ពស់ ជាងពួកសត្វទាំងអស់ មិនមានសត្វឯទៀតលើសលុបជាងព្រះតថាគតនោះឡើយ ព្រះតថាគតជាអ្នកគ្របសង្កត់នូវសត្វលោកទាំងអស់ ។

លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

[១៤] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ សក្កច្ចំ វាចេតា អហោសិ សិប្បំ វា វិជ្ជំ វា ចរណំ វា កម្មំ វា កិន្តិមេ ខិប្បំ វិជានេយ្យុំ[១] ខិប្បំ សម្បដិបជ្ជេយ្យុំ ន ចិរំ កិលិសេយ្យុន្តិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ ឯណិជង្ឃោ ហោតិ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ

១ ឱ. ម. ជានេយ្យុំ ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[១៥] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលមុន ជាអ្នកបានបង្ហាញនូវសិល្បសាស្ត្រ (ថោកទាបនិងសិល្បសាស្ត្រឧត្តម) ផង នូវវិជ្ជា (ច្រើនប្រការ មានវិជ្ជាស្តោះពស់ជាដើម) ផង នូវចរណៈ គឺសីល ៥ សីល ៨ ឬសីល ១០ ឬបាតិមោក្ខសំវរសីលផង នូវការងារផង ដោយយកចិត្តទុកដាក់ ដោយតាំងចិត្តថា ធ្វើដូចម្តេចហ្ន៎ ពួកជននេះ បានចេះដឹងឆាប់ បានទទួលសេចក្តីប្រតិបត្តិឆាប់ កុំឲ្យលំបាកអស់កាលជាយូរអង្វែងឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំនូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានស្មងរៀវមូលត្រសូល ស្រដៀងនឹងស្មងសត្វទ្រាយ ។ ព្រះតថាគតនោះ ប្រកបហើយដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើព្រះតថាគតនៅសោយរាជ្យ

កឹ លភតិ យានិ តានិ រាជារហានិ រាជង្គានិ រាជុបភោគានិ រាជានុច្ឆវិកានិ តានិ ខិប្បំ បដិលភតិ រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ យានិ តានិ សមណារហានិ សមណង្គានិ សមណុបភោគានិ សមណានុច្ឆវិកានិ តានិ ខិប្បំ បដិលភតិ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[១៦] សិប្បេសុ វិជ្ជាចរណេសុ កម្មេសុ
កថំ វិជានេយ្យ(១) លហុន្តិ(២) ឥច្ឆតិ
យតុបឃាតាយ(៣) ន ហោតិ កស្សចិ
វាចេតិ ខិប្បំ ន ចិរំ កិលិស្សតិ ។
តំ កម្មំ កត្វា កុសលំ សុខុន្ទ្រិយំ(៤)

---

១ ឱ. ម. វិជ្ជានេយ្យុំ ។ ២ ឱ. លហូតិ ។ ៣ ឱ. យត្វូបឃាតាយ ។ ម. យទូបឃាតាយ ។ ៤ ឱ. ម. សុខិន្ទ្រិយំ ។

នឹងបានរបស់អ្វី គឺនឹងបាននូវរាជវាហនៈដ៏សមគួរដល់ស្ដេច និងវាហនៈជាអង្គនៃរាជសេនា និងគ្រឿងរាជូបភោគ ដ៏សមគួរដល់ស្ដេច ដោយឆាប់រហ័ស កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបាននូវបច្ច័យដ៏សមគួរដល់សមណៈ និងបរិស័ទដែលជាអង្គរបស់សមណៈ និងគ្រឿងសមណូបភោគ ដ៏សមគួរដល់សមណៈដោយឆាប់រហ័ស កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ ត្រាស់នូវសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[១៦] ព្រះតថាគត តែងប្រាថ្នាដូច្នេះថា ធ្វើម្ដេចហ្ន៎ ជនទាំងឡាយនេះ នឹងចេះដឹងនូវសិល្បសាស្ត្រ វិជ្ជា ចរណៈ និងការងារទាំងឡាយ បានដោយឆាប់រហ័ស ឯសិល្បសាស្ត្រណា មិនបៀតបៀន ដល់អ្នកណាមួយ ព្រះតថាគត បង្រៀននូវសិល្បសាស្ត្រនោះ យ៉ាងឆាប់រហ័ស មិនឲ្យលំបាកអស់កាលយូរឡើយ ។ ព្រោះព្រះតថាគត បានធ្វើកុសលកម្មនោះ ដែលជាកម្មញុំាំងសុខឲ្យចម្រើន ទើបបាននូវ

## ២៧

លក្ខណសុត្តេ តថាគតបុញ្ញាធិការគាថា

ជង្ឃា មនុញ្ញា លភតេ សុសណ្ឋិតា
វត្ដា[១] សុជាតា អនុបុព្វមុគ្គតា
ឧទ្ធគ្គលោមា សុខុមត្តចោត្ថដា[២] ។
ឯណេយ្យជង្ឃោតិ តមាហុ បុគ្គលំ
សម្បត្តិយា វិប្បមិជាហុ លក្ខណំ
ឯកេកលោមានិ យជាភិកង្ខតិ
អបព្វជំ វិប្បមិជានិគច្ឆតិ ។
សចេ វ បព្វជ្ជមុបេតិ តាទិសោ
នេក្ខម្មឆន្ទាភិរតោ វិចក្ខណោ
អនុច្ឆវិកស្ស យជានុលោមិយំ[៣]
តំ វិន្ទតិ វិប្បមនោមនិក្កមោតិ ។

---

១ ឱ. ម. វដ្ដា ។ ២ ឱ. សុខុមត្តចោតតា ។ ម. សុខុមត្តចោត្ថតា ។ ៣ ឱ. ម. យទានុលោមិកំ ។

ស្មង់ដ៏ល្អ មានរបៀបរៀបរយល្អ ព្រះតថាគតមានចុង់រោម-ង់ឡើងលើ វិលជាទក្ខិណាវដ្ត ដុះឡើងល្អ ប្រាង់ឡើងលើ ទៅតាមលំដាប់ ទាំងមានស្បែកកាយដ៏ល្អិតម៉ដ្ឋព័ទ្ធជុំវិញ ។ បុគ្គលដែលប្រកបដោយលក្ខណៈដូច្នោះ អ្នកប្រាជ្ញទាំងឡាយពោលថា មានព្រះជង្ឃារៀវមូល ដូចជាស្មង់សត្វទ្រាយឯរោមមួយ ៗ (ក៏ដុះឡើងល្អ) ព្រះតថាគត ប្រាថ្នានូវសម្បត្តិណា សម្បត្តិនោះ ទោះបីព្រះតថាគតមិនបានបព្វជ្ជា ក៏គង់បានឆាប់ក្នុងលោកនេះ ។ បើបុគ្គល (មានលក្ខណៈ) ដូចព្រះតថាគតនោះ ចេញទៅបួស នឹងបានជាអ្នកប្រាជ្ញ មានសេចក្តីពេញចិត្ត ត្រេកអរចំពោះនេក្ខម្មៈ ជាអ្នកមានសេចក្តីព្យាយាមមិនថោកថយឡើយ តែងបាននូវសម្បត្តិដ៏សមគួរដល់បុគ្គល ដែលមានសភាពដ៏សមគួរ ។

[១៧] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បរិបុច្ឆិតា អហោសិ កឹ ភន្តេ កុសលំ កឹ អកុសលំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិតព្វំ កឹ ន សេវិតព្វំ កឹ មេ ករិយមានំ[១] ទីឃរត្តំ អហិតាយ ទុក្ខាយ អស្ស កឹ វា បន មេ ករិយមានំ[២] ទីឃរត្តំ ហិតាយ សុខាយ អស្សាតិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ឧស្សន្នត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ[៣] មហាបុរិសលក្ខណំ បដិលភតិ សុខុមច្ឆវិ ហោតិ សុខុមត្តា ឆវិយា រជោជល្លំ កាយេ ន ឧបលិម្បតិ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។

---

១-២ ឱ. ម. កយិរមានំ ។ ៣ ឱ. ម. ឥទំ ។

[១៧] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកចូលទៅរកសមណព្រាហ្មណ៍ហើយសាកសួរថា បពិត្រលោកដ៏ចម្រើន អំពើដូចម្តេចជាកុសល អំពើដូចម្តេចជាអកុសល អំពើដូចម្តេចដែលប្រកបដោយទោស អំពើដូចម្តេចដែលមិនប្រកបដោយទោស អំពើដូចម្តេចគួរសេព អំពើដូចម្តេចមិនគួរសេព អំពើដូចម្តេចដែលខ្ញុំធ្វើហើយ ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរអង្វែង មួយទៀត អំពើដូចម្តេច ដែលខ្ញុំធ្វើហើយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលយូរអង្វែង ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាង នូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានឆវី (សម្បុរថ្ងៃ) ដ៏ល្អិតផូរផង់ រលើងស្រិលរអិលធូលីធ្លាក់មកត្រូវមិនជាប់កាយ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។

២៩

លក្ខណសុត្តេ តថាគតបុញ្ញាធិការគាថា

រាជា សមានោ កឹ លភតិ មហាបញ្ញោ[១] ជាស្ស ហោតិ គោចិ បញ្ញាយ សទិសោ វា សេដ្ឋោ[២] វា កាមភោគីនំ រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ មហាបញ្ញោ ហោតិ បុថុប្បញ្ញោ ហាសប្បញ្ញោ ជវនប្បញ្ញោ តិក្ខប្បញ្ញោ និព្វេធិកប្បញ្ញោ ជាស្ស ហោតិ គោចិ បញ្ញាយ សទិសោ វា សេដ្ឋោ វា សព្វសត្តានំ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[១៨] បុរេ បុរត្ថា បុរិមាសុ ជាតិសុ
អញ្ញាតុកាមោ បរិបុច្ឆិតា អហុ
សុស្សូសិតា[៣] បព្វជិតំ ឧបាសិតា
អត្ថន្តរោ អត្ថកថំ និសាមយិ ។
បញ្ញាបដិលាភគតេន កម្មុនា

---

១ ឱ. ម. មហាបញ្ញោ ហោតិ ។ ២ ឱ. វិសិដ្ឋោ ។ ៣ ឱ. ម. សុស្សូសិតា ។

លក្ខណសូត្រ  គាថាសំដែងអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត

*កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានប្រាជ្ញាច្រើន បណ្តាអ្នកបរិភោគកាមទាំងឡាយ នឹងរកអ្នកណាមួយ ឲ្យមានប្រាជ្ញាប្រហែល ឬប្រសើរវិសេស ជាងបញ្ញារបស់ព្រះតថាគតនោះគ្មានឡើយ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាដ៏មោះមុត មានប្រាជ្ញាជាគ្រឿងសង្កត់សង្កិន ឬទម្លាយ (នូវគំនរកិលេស មានលោភៈជាដើម) បណ្តាសត្វទាំងពួង នឹងរកសត្វណាមួយ ឲ្យមានប្រាជ្ញាស្មើ ឬប្រសើរវិសេស ជាងបញ្ញារបស់ព្រះតថាគតនោះ គ្មានឡើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា*

*[១៨] ក្នុងកាលមុន ភពមុន ជាតិពីមុន ព្រះតថាគតជាអ្នកចង់ចេះដឹង បានចូលទៅរកបព្វជិត ហើយសាកសួរ (នូវប្រស្នា) បានស្តាប់ដោយគោរព ធ្វើសេចក្តីឲ្យតាំងនៅខាងក្នុង ហើយចំណាំនូវពាក្យ ដែលប្រកបដោយប្រយោជន៍តែមួយយ៉ាង ។ ព្រោះកម្មដែលប្រព្រឹត្តទៅ ដើម្បីបាន*

មនុស្សភូតោ សុខុមច្ឆវី អហុ
ព្យាកំសុ ឧប្បាទនិមិត្តកោវិទា[១]
សុខុមានិ អត្ថានិ អវេច្ច ទក្ខតិ[២] ។
សចេ ន បព្វជ្ជមុបេតិ តាទិសោ
វត្តេតិ ចក្កំ បថវឹ បសាសតិ
អត្ថានុសិដ្ឋីសុ បរិគ្គហេសុ ច
ន តេន សេយ្យោ សទិសោ ន[៣] វិជ្ជតិ ។
សចេ វ[៤] បព្វជ្ជមុបេតិ តាទិសោ
នេក្ខម្មឆន្ទាភិរតោ វិចក្ខណោ
បញ្ញាវិសិដ្ឋំ លភតេ អនុត្តរំ
បប្បោតិ ពោធឹ វរភូរិមេធសោតិ ។

---

១ ឱ. ម. ឧប្បាទនិមិត្តកោវិទា ។ ២ ម. ទក្ខិតិ ។ ៣ ឱ. វ ។ ម. ច ។ ៤ ឱ. សចេ ។ ម. សចេ ច ។

នូវប្រាជ្ញា (នោះ) ទើបព្រះតថាគត កើតមកជាមនុស្ស មានធរីដ៏ល្អិតផូរផង់ ពួកអ្នកប្រាជ្ញឈ្លាស ក្នុងការទាយនូវឧប្បាតនិងនិមិត្តនាំគ្នាទាយថា ព្រះតថាគត នឹងពិចារណាឃើញច្បាស់នូវអត្ថដ៏ល្អិតសុខុមទាំងឡាយបាន ។ បើបុគ្គល (មានលក្ខណៈ) ដូចព្រះតថាគតនោះ មិនបានចេញទៅបព្វជ្ជាទេ ក៏គង់ញុំាំងចក្រឲ្យប្រព្រឹត្តទៅ នឹងគ្រប់គ្រងផែនដីបាន បណ្តាពួកអ្នកប្រៀនប្រដៅនូវអត្ថ និងពួកអ្នកកំណាត់កត់ចាំ (នូវអត្ថ) នឹងរកបុគ្គលណាមួយឲ្យត្រឹមស្មើ ឬប្រសើរជាងព្រះតថាគតនោះគ្មានឡើយ ។ បើបុគ្គល (មានលក្ខណៈ) ដូចព្រះតថាគតនោះ ចេញទៅបព្វជ្ជា នឹងបានជាអ្នកប្រាជ្ញមានសេចក្តីពេញចិត្ត ទាំងត្រេកអរក្នុងនេក្ខម្មៈ ជាអ្នកមានប្រាជ្ញាដ៏ប្រសើរប្រៀបដោយផែនដី នឹងបានដល់ពោធិ-ញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុងផ្លូវប្រាជ្ញា ។

៣១

## លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

[១៩] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ អក្កោធនោ អហោសិ អនុបាយាសពហុលោ ពហុន្នំបិ[១] វុត្តោ សមានោ នាភិសជ្ជិ ន កុប្បិ ន ព្យាបជ្ជិ ន បតិដ្ឋយិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច ចាត្វាកាសិ ទាតា ច អហោសិ សុខុមានំ មុទុកានំ អត្ថរណានំ ចាបុរណានំ ខោមសុខុមានំ កប្បាសិកសុខុមានំ កោសេយ្យសុខុមានំ កម្ពលសុខុមានំ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ សុវណ្ណវណ្ណោ ហោតិ កាញ្ចនសន្និភត្តចោ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ

---

១ ឱ. ពហុន្នម្បិ ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[១៩] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលមុន ជាអ្នកមិនមានសេចក្តីក្រោធ មិនច្រើន ដោយសេចក្តីចង្អៀតចង្អល់ចិត្ត សូម្បីជនច្រើននាក់ នាំគ្នាស្តីថាឲ្យ ក៏មិនឈឺចិត្ត មិនក្រោធ មិនចងកំហឹងទុក មិនតម្កល់ទុកនូវសេចក្តីក្រោធ ទាំងមិនបានធ្វើនូវសេចក្តីក្រោធ នូវការប្រទូស្ត និងសេចក្តីតូចចិត្តឲ្យប្រាកដឡើង (ដោយកាយវិការ ឬ វចីវិការ) ឡើយ ព្រះតថាគតជាអ្នកបានឲ្យនូវកម្រាល និងសំពត់ដណ្តប់មានសាច់ល្អិតទន់ល្មៃ គឺសំពត់ធ្វើពីសម្បកឈើ មានសាច់ម៉ដ្ឋ សំពត់ធ្វើពីកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើពីសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើពីរោមសត្វមានសាច់ម៉ដ្ឋ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំនូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនោះ ក៏បាននូវមហាបុរិស-លក្ខណៈនេះ គឺជាអ្នកមានពណ៌សម្បុរ (ល្បឿងភ្លឺបំព្រង) ដូចជាសម្បុរនៃមាស និងមានស្បែកជិតស្និទ្ធល្អ ដូចជាមាស ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈ នោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបាន

ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ លាភី ហោតិ សុខុមានំ មុទុកានំ អត្ថរណានំ ចាបុរ- ណានំ ខោមសុខុមានំ កប្បាសិកសុខុមានំ កោ- សេយ្យសុខុមានំ កម្ពលសុខុមានំ រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ លាភី ហោតិ សុខុមានំ មុទុកានំ អត្ថរណានំ ចាបុរណានំ ខោមសុខុមានំ កប្បាសិកសុខុមានំ កោសេយ្យសុខុមានំ កម្ពលសុខុមានំ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[២០] អក្កោធញ្ច អធិដ្ឋហិ អទាសិ[១]

ទានញ្ច វត្ថានិ[២] សុខុមានំ សុច្ឆវីនិ

បុរិមតរភវេ ឋិតោ អភិវិសជ្ជ

១ ឱ. អទាសិ ច ។ ២ ឱ. ទានំ វត្ថានិ ច ។

ជាស្តេចចក្រពត្តិ ។ បេ ។ កាលបើព្រះតថាគត នៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបាននូវកម្រាល និងសំពត់ដណ្តប់ មានសាច់ល្អិតទន់ល្មៃ គឺសំពត់ធ្វើដោយសម្បកឈើមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយរោមសត្វមានសាច់ម៉ដ្ឋ កាលបើព្រះតថាគត នៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបាននូវកម្រាល និងសំពត់មានសាច់ល្អិតទន់ល្មៃ គឺសំពត់ធ្វើដោយសម្បកឈើមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយរោមសត្វមានសាច់ម៉ដ្ឋ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះ រួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[២០] ព្រះតថាគតតាំងទុកនូវសេចក្តីមិនក្រោធផង នូវទានផង ហើយបានឲ្យនូវសំពត់ទាំងឡាយ មានសាច់ម៉ដ្ឋ មានពណ៌ស្រស់ ព្រះតថាគតឋិតនៅក្នុងភពពីមុន បានបរិច្ចាគ

៣៣

លក្ខណសុត្តេ តថាគតបុញ្ញាធិការគាថា

មហិមិវ សុភេ អភិវស្សំ ។
តំ កត្វាន ឥតោ ចុតោ ទិព្វមុបបជ្ជិ(១)
សុកតំ ផលវិបាកមនុភុត្វា(២) កនកតនុបដិភោ(៣)
ឥធាភិភវតិ(៤) សុរវរតរោរិវ ឥន្ទោ ។
តេហញ្ញាវសតិ នរេ អបព្ពជ្ជ
មិច្ឆំ មហតឹ មហឹ បសាសតិ(៥)
បសយ្ហ សហិជ សត្តុរតនំ(៦) បដិលភតិ
វិបុលសុខុមច្ឆវិ សុចិញ្ញ(៧) ។
លាភី អច្ឆាទនវត្ថមោក្ខចាបុរណានំ
ភវតិ យទិ អនតារិយតមុបេតិ
សុហិតបុរិមកតផលំ(៨) អនុភវតិ
ន ភវតិ កាតស្ស បជាសោតិ ។

១ ឱ. ទិព្វំ ឧប្បជ្ជ ។ ម. ទិព្វំ ឧបបជ្ជិ ។ ២ ឱ. សុកតផលវិបាកមនុភោត្វា ។ ៣ ឱ. ម. គនកតនុសន្និភោ ។ ៤ ឱ. ឥធ ភវតិ ។ ៥ ឱ. ម. អនុសាសតិ ។ ៦ ឱ. អភិវសនវរតរំ ។ ម. សហិវ សត្តុរតនំ ។ ៧ ឱ. វិបុលំ សុខុមញ្ញ សុច្ឆវិញ្ញ ។ ៨ ឱ. សហីបុរិមកតផលំ ។ ម. សហិតោបុរិមកតផលំ ។

(ទាន) ហាក់ដូចជាទឹកភ្លៀង ដែលធ្លាក់ចុះមកលើផែនដី ដូច្នោះឯង ។ ព្រះតថាគត ព្រោះបានធ្វើនូវកុសល-កម្មនោះ លុះច្យុតចាកអត្តភាពនេះហើយ ចូលទៅកាន់ទិព្វវិមាន បានសោយផលវិបាក នៃអំពើដែលខ្លួនបានធ្វើហើយ ជាអ្នកមានខ្លួនដូចជាមាស (លុះមកកើត) ក្នុងភពនេះ បានគ្របសង្កត់ (នូវមនុស្សទាំងអស់) ហាក់ដូចជាព្រះឥន្ទ្រ ដែលប្រសើរជាងពួកទេវតាដូច្នោះឯង ។ បើព្រះតថាគតនៅជាមនុស្ស គ្រប់គ្រងគេហដ្ឋាន មិនប្រាថ្នានឹងបួសទេ ក៏គង់តែបានគ្រប់គ្រងនូវផែនដីធំ គ្របសង្កត់ (នូវពួកបច្ចាមិត្ត) ព្រមទាំងបាននូវរតនៈ ៧ ប្រការក្នុងលោកនេះផង បាននូវសំពត់ដ៏ធំទូលាយ មានសាច់ល្អិតម៉ដ្ឋ មានសម្បុរស្រស់ស្អាតផង ។ បើព្រះតថាគតចេញទៅទ្រង់ព្រះផ្នួស នឹងបានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់ដ៏ប្រសើរ ព្រះតថាគត រមែងបានសោយផលរបស់កម្ម ដែលបានទំនុកបម្រុងល្អហើយ នឹងបានធ្វើទុកមកពីជាតិមុន សេចក្ដីវិនាសនៃកម្ម ដែលព្រះតថាគតធ្វើនោះ មិនមានឡើយ ។

[២១] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ចិរប្បដជ្ជេ សុចិរប្បវាសិនេ[១] ញាតិមិត្តេ សុហជ្ជេ សខិនោ សមានេតា អហោសិ មាតរំបិ បុត្តេន សមានេតា អហោសិ បុត្តំបិ មាតរា សមានេតា អហោសិ បិតរំបិ បុត្តេន សមានេតា អហោសិ បុត្តំបិ បិតរា សមានេតា អហោសិ បិតរំបិ ភាតរា សមានេតា អហោសិ ភាតរំបិ ភគិនិយា សមានេតា អហោសិ ភគិនឹបិ ភាតរា សមានេតា អហោសិ សមគ្គឹ[២] កត្វា ច អព្ភនុមោទិតា អហោសិ ។ សោ តស្ស កម្មស្ស កតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ កោសោហិតវត្ថគុយ្ហោ ហោតិ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ

១ ឱ. ម. សុចិរប្បវាសិនោ ។ ២ ម. សមគ្គំ ។

[២១] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានរាប់អាននូវញាតិមិត្ត សំឡាញ់ស្និទ្ធស្នាល ដែលព្រាត់ប្រាសនិរាសបាត់មុខឃ្លាតឆ្ងាយហើយផង ជាអ្នករាប់អានមាតាព្រមទាំងកូនផង រាប់អាននូវកូនព្រមទាំងមាតាផង រាប់អានបិតាព្រមទាំងកូនផង រាប់អានកូនព្រមទាំងបិតាផង រាប់អានបិតាព្រមទាំងបងប្អូនប្រុស រាប់អានបងប្អូនប្រុសព្រមទាំងបងប្អូនស្រីផង រាប់អានបងប្អូនស្រី ព្រមទាំងបងប្អូនប្រុសផង ហើយជាអ្នកត្រេកអរក្រៃលែង ព្រោះបានធ្វើគេឲ្យព្រមព្រៀងគ្នាផង ។ ព្រះតថាគតនោះ ព្រោះបានធ្វើនូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានអង្គាវយវៈ ដែលត្រូវលាក់ឲ្យកំបាំងដោយសំពត់ ឋិតនៅក្នុងស្រោម (ដូចជាអង្គជាតនៃដំរី) ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើព្រះតថាគតនៅសោយរាជ្យ នឹង

កឹ លភតិ បហូតបុត្តោ អហោសិ[១] បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ បហូតបុត្តោ អហោសិ[២] អនេកសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[២២] បុរេ បុរត្ថា បុរិមាសុ ជាតិសុ
ចិរប្បនដ្ឋេ សុចិរប្បវាសិនោ
ញាតីសុហជ្ជេ សខិនោ សមានយិ
សមគ្គិ កត្វា ច អនុមោទិតា អហុ ។
សោ តេន កម្មេន តិទិវំ អបក្កមិ[៣]
សុខញ្ច ខិឌ្ឌា រតិយោ ច អន្វភិ[៤]
តតោ ចវិត្វា បុនរាគតោ ឥធ

---

១-២ ឱ. ម. ហោតិ ។ ៣ ឱ. ទិវំ សមក្កមិ ។ ម. ទិវំ អបក្កមិ ។ ៤ ម. អនុភិ ។

បានរបស់អ្វី គឺនឹងបានជាអ្នកមានបុត្រច្រើន ឯបុត្ររបស់ព្រះតថាគតនោះ មានចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា អង់អាច អាចញាំញីនូវសេនារបស់ស្តេចដទៃបាន កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបុត្រច្រើន ឯបុត្ររបស់ព្រះតថាគតនោះ ចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា អង់អាច អាចញាំញីនូវសេនារបស់ស្តេចឯទៀតបាន កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះ រួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងកម្មជាដើមនោះថា

[២២] ក្នុងកាលពីមុន ភពពីមុន ជាតិពីមុន ព្រះតថាគតរាប់អាននូវញាតិ មិត្ត និងសំឡាញ់ស្និទ្ធស្នាល ដែលព្រាត់ប្រាសនិរាសបាត់មុខអស់កាលយូរហើយផង ជាអ្នកត្រេកអរក្រៃលែង ព្រោះបានធ្វើគេឲ្យព្រមព្រៀងគ្នាផង ។ ព្រោះកម្មនោះ ព្រះតថាគតបានទៅកាន់ឋានសួគ៌ សោយសេចក្តីសុខសេចក្តីសម្រាន្ត និងសេចក្តីត្រេកអរ លុះច្យុតចាកឋានសួគ៌នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវ

កោសោហិតំ វិជ្ជតិ វត្ថឆាទិយំ ។
បហូតបុត្តោ ភវតិ តថាវិធោ
បរោសហស្សញ្ច[១] ភវន្តិ អត្រជា[២]
សូរា ច វីរា ច[៣] អមិត្តតាបនា
គិហិស្ស បីតិជននា បិយំ វទា ។
បហុតរា[៤] បព្វជិតស្ស ឥរិយតោ
បុត្តា ភវន្តិ វចនានុសារិនោ[៥]
គិហិស្ស វា បព្វជិតស្ស វា បន
តំ លក្ខណំ ភវតិ[៦] តទត្ថជោតកន្តិ[៧] ។

[២៣] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ

---

១ ឱ. បរោសហស្សស្ស ។ ម. បរោសហស្សំ ច ។ ២ ឱ. អតុជា ។ ៣ ម. វីរង្គរូបា ។ ៤ ឱ. បហុត្តរា ។ ៥ ឱ. វចនានុចារិនោ ។ ៦. ម. ជាយតិ ។ ៧ ឱ. ឥតោ បរំ បឋមក-ភាណវារន្តិ ទិស្សតិ ។

គុយ្ហប្រទេស ដ៏កំបាំងនៅក្នុងស្រោម ដែលគេត្រូវបិទបាំង ដោយសំពត់ ។ បុគ្គលដែលមានលក្ខណៈបែបនោះ រមែង មានកូនច្រើន ឯកូនដែលកើតអំពីខ្លួនជាច្រើនពាន់ (នោះ) សុទ្ធ សឹងជាអ្នកក្លៀវក្លា អង់អាច អាចញាំញីនូវពួកសត្រូវបាន កាលបើ ព្រះតថាគតនៅជាគ្រហស្ថ ក៏គង់ញ៉ាំងបីតិឲ្យកើត ឡើងបាន ព្រោះតែពោលពាក្យគួរស្រឡាញ់ ។ កាលបើ ព្រះតថាគតចេញទៅទ្រង់ព្រះផ្នួស ក៏មានកូនច្រើនជាងនោះ ទៅទៀត ឯកូនទាំងនោះសុទ្ធតែជាអ្នកជឿស្តាប់ពាក្យ (របស់ ព្រះតថាគត) ទោះព្រះតថាគត នៅជាគ្រហស្ថ ឬទៅជា បព្វជិត មានលក្ខណៈនោះ ជាគ្រឿងបំភ្លឺនូវសេចក្តីនោះ ។

[២៣] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងភពមុន ជាអ្នក

លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

មហាជនសង្គាហកំ[១] សមេក្ខមានោ[២] សមំ[៣] ជានាតិ សាមំ ជានាតិ បុរិសំ ជានាតិ បុរិសវិសេសំ ជានាតិ អយមិទមរហតិ អយមិទមរហតីតិ តត្ថ តត្ថ វិសេសត្ថការោ បុរេ[៤] អហោសិ ។ សោ តស្ស កម្មស្ស កតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ និគ្រោធបរិមណ្ឌលោ ច ហោតិ ឋិតោយេវ[៥] អនោនមន្តោ ឧភោហិ ចាណិតលេហិ ជន្នុកានិ[៦] បរិមសតិ បរិមជ្ជតិ ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ

---

១ ឱ. មហាជនសង្គហំ ។ ២ ម. សមបេក្ខមានោ ។ ៣ ឱ. សំ ។ ៤ ឱ. បុរិសវិសេសករោ ។ ម. បុរិសវិសេសករោ បុរេ ។ ៥ ឱ. ឋិតកោ ច ។ ម. ឋិតោយេវ ច ។ ៦ ម. ជាណុកានិ ។

បានពិចារណានូវការសង្គ្រោះមហាជន តែងស្គាល់ស្មើ[១] គឺស្គាល់ថា អ្នកនេះស្មើនឹងអ្នកនោះ ស្គាល់ដោយខ្លួនឯង[២] ស្គាល់បុរស[៣] ស្គាល់គុណវិសេសរបស់បុរសថា បុរសនេះ គួរទទួលនូវទាននិងគ្រឿងសក្ការៈនេះ បុរសនេះ គួរទទួលនូវទាននិងគ្រឿងសក្ការៈនេះ (លុះស្គាល់ដូច្នោះហើយ) ក៏បានធ្វើនូវប្រយោជន៍ប្លែក ៗ គ្នា តម្រូវទៅតាមគុណវិសេសរបស់បុរសជាន់នោះ ៗ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានបរិមណ្ឌល (នៃកាយ) ដូចជាបរិមណ្ឌលនៃដើមជ្រៃ ១ កាលបើឈរមិនបាច់ឱនខ្លួនចុះ អាចស្ទាបពាល់ជង្គង់ដោយដៃទាំងពីរបាន ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿង

---

១ ពាក្យថា ស្គាល់ស្មើនោះ គឺស្គាល់ថា ជននេះមានគុណស្មើនឹងជននោះ ហើយស្រុះស្រួលទទួលបុរសនោះ តាមវិធីដែលត្រូវទទួល ។ ដីកា ។ ២ ពាក្យថា ស្គាល់ដោយខ្លួនឯង គឺស្គាល់ដោយមិនចាំបាច់អ្នកឯទៀត មកពន្យល់ឡើយ ។ ៣ ពាក្យថា ស្គាល់បុរសនោះ គឺស្គាល់ពិតប្រាកដថា បុរសនេះជាន់ខ្ពស់ បុរសនេះជាន់កណ្តាល បុរសនេះ ជាន់ទាប ។ ដីកា ។

បហូតជាតរូបរជតោ បហូតវិត្តូបករណោ បហូតធនធញ្ញោ បរិបុណ្ណកោដ្ឋាគារោ(១) រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ តស្សិមានិ ធនានិ ហោន្តិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[២៤] តុលិយ បវិចយ(៣) ចិន្តយិត្វា
មហាជនសង្គាហកំ(៣) សមេក្ខមានោ
អយមិធមរហាតីតិ(៤) តត្ថ តត្ថ
បុរិសវិសេសង្ករោ(៥) បុរេ អហោសិ ។
សមា ច បនដ្ឋិតោ(៦) អនោនមន្តោ

---

១ ឱ. ម. បរិបុណ្ណកោសកោដ្ឋាគារោ ។ ២ ឱ. បវិចេយ្យ ។ ៣ ឱ. មហាជនសង្គហតំ ។ ម. មហាជនំ សង្គាហកំ ។ ៤ ម. អយមិទមរហាតិ ។ ៥ ឱ. ម. បុរិសវិសេសករោ ។ ៦ ឱ. សហិ ច បន ឋិតោ ។ ម. មហឹ ច បន ឋិតោ ។

ប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ដែលធ្វើចិត្ត ឲ្យរីករាយច្រើន មានធញ្ញាហារជាទ្រព្យច្រើន មានឃ្លាំងដ៏ពេញប្រៀប កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បេ ។ កាល បើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នក ស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ទ្រព្យរបស់ តថាគតទាំងនេះ គឺ សទ្ធាធនំ (ទ្រព្យពោលគឺការជឿ) ១ សីលធនំ (ទ្រព្យគឺការសង្រួមកាយវាចាឲ្យរៀបរយ) ១ ហិរិធនំ (ទ្រព្យគឺសេចក្តី ខ្មាសបាប) ១ ឱត្តប្បធនំ (ទ្រព្យគឺសេចក្តីក្តៅក្រហាយនឹងបាប) ១ សុតធនំ (ទ្រព្យគឺការស្តាប់) ១ចាគធនំ (ទ្រព្យគឺការលះ) ១ បញ្ញាធនំ (ទ្រព្យគឺកិរិយាដឹងសព្វ) ១ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបាននូវរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសំដែងសេចក្តីនេះ រួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[២៤] ព្រះតថាគតបានលៃលក ពិចារណា គិតហើយទើបសំ-
ឡឹងមើលនូវការសង្គ្រោះមហាជនដោយស្មោះស្មើ ជាអ្នកបានធ្វើ
នូវគ្រឿងសក្ការៈតម្រូវតាមគុណវិសេសរបស់បុរសនោះ ៗ ក្នុង
កាលមុនថា បុរសនេះគួរបាននូវទាននិងគ្រឿងសក្ការៈនេះ ។ ព្រះ
តថាគត ជាបុគ្គលមានកាយស្មើ កាលបើឈរមិនបាច់ឱនខ្លួនចុះ

ផុសតិ ករេហិ ឧភោហិ ជន្នុកានិ[១]
មហិរុហប្បរិមណ្ឌលោ[២] អហោសិ
សុចរិតកម្មវិបាកសេសកេន ។
ពហុវិវិធនិមិត្តលក្ខណញ្ញូ
អភិនិបុណា[៣] មនុជា ព្យាករឹសុ
ពហុវិវិធគិហីនំ អរហានិ
បដិលភតិ ទហរោ សុសូ កុមារោ[៤]
ឥធ ច[៥] មហិបតិស្ស កាមភោគា[៦]
គិហីបតិរូបកា ពហូ ភវន្តិ
យទិ បជហាតិ[៧] សព្វកាមភោគំ[៨]
លភតិ អនុត្តរំ ឧត្តមំ ធនគ្គន្តិ[៩] ។

[២៨] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ពហុជនស្ស[១០] អត្ថកាមោ អហោសិ ហិតកាមោ ផាសុកាមោ យោគក្ខេមកាមោ កិន្តិមេ

១ ម. ជាណុកានិ ។ ២ ឱ. ម. មហិរុហបរិមណ្ឌលោ ។ ៣ ម. អតិនិបុណា ។ ៤ ឱ. សុសុ កុមារោ ។ ម. សុកុមារោ ។ ៥ ឱ. ច សទ្ទោ ន ទិស្សតិ ។ ៦ ម. កាមភោគី ។ ៧ ឱ. ម. យទិ ច ជហាតិ ។ ៨ ឱ. សព្វំ កាមភោគំ ។ ៩ ម. ឧត្តមធននត្ថន្តិ ។ ១០ ឱ. ពហុនោ ជនស្ស ។

អាចស្ទាបជង្គង់ដោយដៃទាំងពីរបាន មានបរិមណ្ឌល (នៃកាយ) ដូចបរិមណ្ឌលនៃដើមជ្រៃ ដែលដុះឡើងអំពីផែនដី ព្រោះសេសសល់វិបាកនៃអំពើសុចរិត (នោះឯង) ។ ពួកមនុស្ស ដែលមានប្រាជ្ញាល្អិតជ្រាលជ្រៅ ដឹងនូវលក្ខណៈនៃនិមិត្តផ្សេង ៗ ជាច្រើននាំគ្នាទាយថា ព្រះរាជកុមារកំឡោះក្មេងនេះ នឹងបាននូវរបស់ដ៏សមគួរ ដល់គ្រហស្ថច្រើនប្រការផង ជាអ្នកមានភោគសម្បត្តិ ដែលគួរប្រាថ្នារបស់ស្តេច នឹងសមគួរដល់ពួកគ្រហស្ថ ក្នុងលោកនេះជាច្រើនផង បើព្រះរាជកុមារនេះ លះបង់នូវកាមភោគៈទាំងអស់ (ហើយចេញទៅទ្រង់ព្រះផ្នួស) នឹងបានទ្រព្យដ៏ខ្ពង់ខ្ពស់ថ្លៃថ្លា រកទ្រព្យឯទៀតឲ្យលើសលុបជាងមិនមានឡើយ ។

[២៥] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសុខ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ ដល់ពួកជនច្រើនថា ធ្វើដូចម្តេចជនទាំងនេះ

៤០



សទ្ធាយ វឌ្ឍយ្យុំ សីលេន វឌ្ឍយ្យុំ សុតេន វឌ្ឍយ្យុំ ពុទ្ធិយា វឌ្ឍយ្យុំ[១] ចាគេន វឌ្ឍយ្យុំ ធម្មេន វឌ្ឍយ្យុំ បញ្ញាយ វឌ្ឍយ្យុំ ធនធញ្ញេន វឌ្ឍយ្យុំ ខេត្តវត្ថុនា វឌ្ឍយ្យុំ ទ្វិបទចតុប្បទេហិ[២] វឌ្ឍយ្យុំ បុត្តទារេហិ វឌ្ឍយ្យុំ ទាសកម្មករបោរិសេហិ វឌ្ឍយ្យុំ ញាតីហិ វឌ្ឍយ្យុំ មិត្តេហិ វឌ្ឍយ្យុំ ពន្ធវេហិ វឌ្ឍយ្យុន្តិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ តីណិ មហាបុរិសលក្ខណានិ បដិលភតិ សីហបុព្វទ្ធកាយោ ច ហោតិ បិត្តន្តរំសោ[៣] ច សមវដ្ដក្ខន្ធោ ច ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ អបរិហានធម្មោ ហោតិ ន បរិហាយតិ ធនធញ្ញេន

១ ឱ. ម. ពុទ្ធិយា វឌ្ឍយ្យុន្តិ ន ទិស្សតិ ។ ២ ឱ. ទិបទចតុប្បទេហិ ។ ៣ ឱ. ម. ចិត្តន្តរំសោ ។

នឹងបានចម្រើនដោយសទ្ធា ចម្រើនដោយសីល ចម្រើនដោយសុតៈ ចម្រើនដោយវុឌ្ឍិ ចម្រើនដោយចាគៈ ចម្រើនដោយលោកិយធម៌ ចម្រើនដោយប្រាជ្ញា ចម្រើនដោយទ្រព្យនិងធញ្ញាហារ ចម្រើនដោយស្រែ និងចំការ ចម្រើនដោយសត្វជើងពីរនិងសត្វជើង ៤ ចម្រើនដោយកូននិងប្រពន្ធ ចម្រើនដោយពួកបុរស ជាទាសៈនិងកម្មករ ចម្រើនដោយពួកញាតិ ចម្រើនដោយពួកមិត្ត ចម្រើនដោយពួកផៅពង្ស ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំ កុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បានទូវមហាបុរិស-លក្ខណៈទាំង ៣ នេះ គឺមានចំណែកកន្លះកាយខាងលើ ស្រដៀងនឹងចំណែកកន្លះកាយនៃរាជសីហ៍ ១ មានខ្នងពេញស្មើ ឥតមានចង្អូរផតខូងត្រង់កណ្តាល ១ មាន-កម្ពលសម ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមិនសាបសូន្យជាធម្មតា គឺមិនសាបសូន្យចាកទ្រព្យ និងធញ្ញាហារ

ខេត្តវត្ថុជា ទ្វិបទចតុប្បទេហិ បុត្តទារេហិ ទាស-កម្មករបោរិសេហិ ញាតីហិ មិត្តេហិ[១] ពន្ធវេហិ ន បរិហាយតិ សព្វសម្បត្តិយា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ អបរិហានធម្មោ ហោតិ ន បរិហាយតិ សទ្ធាយ សីលេន សុតេន ចាគេន បញ្ញាយ ន បរិហា-យតិ សព្វសម្បត្តិយា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[២៦] សទ្ធាយ សីលេន សុតេន ពុទ្ធិយា
ចាគេន ធម្មេន ពហូហិ សាធុភិ
ធនេន ធញ្ញេន ច ខេត្តវត្ថុនា
បុត្តេហិ ទារេហិ ចតុប្បទេហិ ច
ញាតីហិ មិត្តេហិ ច ពន្ធវេហិ
ពលេន វណ្ណេន សុខេន ចូភយំ
កាមំ ន ហាយេយ្យុន្តិ[២] បរេហិ ឥច្ឆតិ
អទ្ធំ សមិទ្ធញ្ច[៣] បជាភិកង្ខតិ ។

---

១ ឱ. ញាតិមិត្តេហិ ។ ២ ឱ. ម. ន ហាយេយ្យំ ។ ៣ ឱ. អត្ថស្សមិទ្ធី ច ។ ម. ឥទំ សមិទ្ធញ្ច ។

ស្រែចំការ សត្វជើង ២ និងសត្វជើង ៤ កូនប្រពន្ធ ពួកបុរសជាទាសៈ និងកម្មករ ពួកញាតិ មិត្ត និងផៅពង្ស មិនបានសាបសូន្យចាកសម្បត្តិទាំងពួងឡើយ កាលបើបានជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមិនសាបសូន្យជាធម្មតា គឺមិនសាបសូន្យចាកសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា ទាំងមិនសាបសូន្យចាកសម្បត្តិទាំងពួងឡើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសំដែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[២៦] ព្រះតថាគត តែងប្រាថ្នានឹងប៉ុនប៉ងនូវសេចក្តីមាំមួន និងសេចក្តីបរិបូណ៌ដល់ជនដទៃថា ធ្វើដូចម្តេច កុំឲ្យជនទាំងឡាយ សាបសូន្យចាកសទ្ធា សីលៈ សុតៈ បញ្ញា ចាគៈ និងលោកិយធម៌ និងគុណគឺសេចក្តីល្អច្រើនប្រការ និងទ្រព្យធញ្ញាហារស្រែចំការ កូនប្រពន្ធ (សត្វជើងពីរ) សត្វជើង ៤ ញាតិ មិត្ត ផៅពង្សនិងកម្លាំង ពណ៌សម្បុរកាយ និងសុខទាំងពីរប្រការ ។ ព្រះតថាគតជាបុគ្គល

សសីហបុព្វទ្ធសុសណ្ឋិតោ អហុ
សមវដ្ដក្ខន្ធោ ច បិត្តន្តរំសោ
បុព្វេ សុចិណ្ណេន កតេន កម្មុនា
អហានិយំ[១] បុព្វនិមិត្តមស្សតំ ។
គិហីបិ ធញ្ញេន ធនេន វឌ្ឍតិ
បុត្តេហិ ទារេហិ ចតុប្បទេហិ ច
អកិញ្ចនោ បព្វជិតោ[២] អនុត្តរំ
បប្បោតិ សម្ពោធិមហានធម្មតន្តិ[៣] ។

[២៧] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ សត្តានំ អវិហេសកជាតិកោ[៤] អហោសិ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ

១ ឱ. អហានិយា ។ ២ ឱ. បព្វជិតោ ច ។ ៣ ឱ. ពោធិអសហានធម្មតន្តិ ។ ៤ ឱ. ម. អវិហេឋកជាតិកោ ។

មានចំណែកកន្ទះកាយខាងលើ ស្រដៀងគ្នានឹងចំណែកកន្ទះកាយនៃរាជសីហ៍ មានទ្រូងទ្រាយល្អ ១ មាន-កម្ពូលក្ងំ ១ មានខ្នងពេញស្មើឥតមានផតខ្វង់ ត្រង់កណ្តាល ១ ព្រោះកម្មដែលព្រះតថាគតបានសន្សំ កសាងពីជាតិមុនមក ទើបមិនបានសាបសូន្យ បុព្វនិមិត្តរបស់ព្រះតថាគតនោះ មិនបានសាបសូន្យឡើយ ។ បើព្រះតថាគតនៅជាគ្រហស្ថ តែងចម្រើនដោយធញ្ញាហារ ទ្រព្យ កូន ប្រពន្ធ (សត្វជើង ២) និងសត្វជើង ៤ (បើ) ព្រះតថាគតឥតមានកង្វល់ ចេញទៅបួស ក៏បានសម្រេចសម្ពោធិញ្ញាណ រកគុណជាតឯទៀតឲ្យក្រៃលែងជាងគ្មាន ជាធម៌មិនបានសាបសូន្យ ។

[២៧] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកមិនបៀតបៀនសត្វទាំងឡាយ ដោយដៃ ឬដុំដី ឬក៏ដំបង គ្រឿងសស្ត្រាវុធឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំ នូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ

៤៣

## លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ រសគ្គសគ្គី ហោតិ ឧទ្ធគ្គស្ស រសហរណិយោ គីវាយំ ជាតា ហោន្តិ សមវាហរសហរណិយោ[១] ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

១ ឱ. សមភិវាហិនិយោ ។ ម. សមាតិវាហិនិយោ ។

មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានប្រសាទ គឺសរសៃល្អិតធ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ ឯប្រសាទសម្រាប់ទទួលរសអាហារ របស់ព្រះតថាគតនោះ មានចុង-ង ឡើងលើ ប្រជុំស្រោបត្រង់-កសម្រាប់ទទួលរសអាហារ ជ្រួតជ្រាបផ្សព្វផ្សាយស្មោះស្មើគ្នា (សព្វសព៌ាង្គកាយ) ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្ដេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយឧទរមានភ្លើងធាតុដ៏ស្មើ គឺមិនត្រជាក់ពេក មិនក្ដៅពេក កាលបើនៅជាស្ដេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយឧទរមានភ្លើងធាតុដ៏ស្មើ គឺមិនត្រជាក់ពេក មិនក្ដៅពេក ជាយ៉ាងកណ្ដាល ល្មមសមគួរដល់សេចក្ដីព្យាយាម កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានពោលសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[២៨] ន បាណិនា ន ច បន ទណ្ឌលេឌ្ឌុនា(១)
សត្ថេន វា មរណវធេន វា បន
ឧព្ពាធនាយ បរិតជ្ជនាយ វា
ន វិហេឋយី(២) ជនតមហេឋកោ(៣) អហុ ។
តេនេវ សោ សុគតិសុ បេច្ច(៤) មោទតិ
សុខប្ផលំ ករិយ(៥) សុខានិ វិន្ទតិ
សាមុញ្ជសា(៦) វសហារណី សុសណ្ឋិតា
ឥធាគតោ លភតិ វសគ្គិសគ្គិតំ(៧) ។
តេនាហុ នំ អភិនិបុណា វិចក្ខណា
អយំ នរោ សុខពហុលោ ភវិស្សតិ
គិហិស្ស វា បព្វជិតស្ស វា បន
តំ លក្ខណំ ភវតិ តទត្ថជោតកន្តិ ។

---

១ ម. ន បាណិទណ្ឌេហិ បនាថ លេឌ្ឌុនា ។ ២ ឱ. ន ហេឋយី ។ ម. ហេឋយំ ។ ៣ ឱ. ជន្តុមហេឋកោ ។ ៤ ឱ. សុគតិមុបេច្ច ។ ៥ ឱ. ករិយ ។ ៦ ឱ. សម្បជ្ជសា ។ ម. សាមញ្ញសា ។ ៧ ឱ. ម. វេសគ្គសគ្គិតំ ។

[៤៨] ព្រះតថាគត ជាអ្នកមិនបានបៀតបៀន មិនបានប្រទូស្តដល់ប្រជុំជន ដោយដៃ ឬដោយដំបងនិងដុំដី ឬក៏ដោយគ្រឿងសស្ត្រាវុធ ពុំនោះសោត ដោយការប្រើគេឲ្យសម្លាប់និងបៀតបៀន ឬដោយកិរិយាចងក្រៀក និងការគម្រាមឡើយ ។ ព្រោះកម្មនោះឯង ទើបព្រះតថាគតលះលោកនេះទៅក៏រមែងរីករាយក្នុងឋានសួគ៌ បានទូវសេចក្តីសុខ ព្រោះធ្វើនូវអំពើដែលមានផលជាសុខ ប្រសាទសម្រាប់ទទួលរសអាហារជាទីត្រេកអរ (ណា) បានតម្កល់នៅស៊ប់ល្អហើយលុះព្រះតថាគត មកកើតក្នុងមនុស្សលោកនេះ ក៏បានទូវប្រសាទគឺសរសៃល្អិតឆ្មារ ដ៏លើសលែងសម្រាប់ទទួលរសអាហារ (នោះ) ។ ព្រោះហេតុនោះ បានជាអ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាដ៏ល្អិតនាំគ្នាទាយព្រះតថាគតនោះ ថាជននេះមុខជានឹងច្រើនទៅដោយសេចក្តីសុខ ទោះបីនៅជាគ្រហស្ថឬទៅជាបព្វជិត ក៏គង់មានលក្ខណៈនោះ ជាគ្រឿងបំភ្លឺនូវសេចក្តីនោះ ។

៤៥

## លក្ខណសុត្តេ តថាគតបុញ្ញាធិការគាថា

[២៩] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ន ច[១] វិសមំ ន ច វិសាចិ[២] ន ច បន វិជេយ្យបេក្ខិតា[៣] ឧជុ តថា បសដមុជុមនោ[៤] ហុត្វា ឧជុបេក្ខិតា អហោសិ[៥] បិយចក្ខុនា ពហុជនំ ឧទក្ខិតា[៦] អហោសិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ អភិនីលនេត្តោ ច ហោតិ គោបខុមោ ច ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ បិយទស្សនោ ហោតិ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ ព្រាហ្មណគហបតិកានំ នេគមជានបទានំ

---

១ ឱ. ចសទ្ទោ ន ទិស្សតិ ។ ២ ឱ. វិសាចិតំ ។ ម. វិសាចិ ។ ៣ ឱ. ន បន វចេយ្យោ ។ ៤ ឱ. បសដមុទុមនោ ។ ៥ ឱ. ហុត្វា ឧជុបេក្ខិតា អហោសីតិ ន ទិស្សតិ ។ ៦ ឱ. ម. ឧទិក្ខិតា ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[២៩] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនសំឡក់មើល (ដោយទោសចិត្ត) មិនមៀងមើលដោយចុងភ្នែក មិនលបសំឡក់គេ (ដោយស្អប់) ជាអ្នកមានចិត្តស្មោះត្រង់ រមិលមើលត្រង់ពេញភ្នែក ជាអ្នកសំឡឹងមើលជនច្រើន ដោយចក្ខុគួរឲ្យស្រឡាញ់ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានភ្នែកខៀវស្រស់ ១ មានកែវភ្នែកស្រដៀងនឹងកែវភ្នែកកូនគោ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាននឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយនឹងបានរបស់អ្វី គឺនឹងបានជាអ្នកគួរឲ្យអ្នកផងពិតពិលរមិលមើល ដោយសេចក្តីពេញចិត្ត ជាទីស្រឡាញ់នៃជនច្រើន ជាទីគាប់ចិត្តរបស់ពួកព្រាហ្មណ៍និងគហបតី អ្នកនិគម អ្នកជនបទ

គណកមហាមត្តានំ អនីកដ្ឋានំ ទោវារិកានំ(១) អមច្ចានំ បារិសជ្ជានំ រាជូនំ ភោគិកានំ(២) កុមារានំ រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ បិយទស្សនោ ហោតិ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ ច(៣) ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ទេវានំ មនុស្សានំ អសុរានំ នាគានំ គន្ធព្វានំ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[៣០] ន ច វិសដំ ន ច វិសារិ(៤)
ន ច បន វិចេយ្យបេក្ខិតា(៥)
ឧជុ តថា បសដមុជុមនោ(៦)
បិយចក្ខុនា ពហុជនំ ឧទក្ខិតា(៧) ។
សុគតិសុ សោ ផលវិបាកំ
អនុភវតិ តត្ថ មោទតិ

១ ឱ. អនីកដ្ឋទោវារិកានំ ។ ២ ឱ. ម. ភោគិយានំ ។ ៣ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។ ៤ ឱ. វិសាចិតំ ។ ម. វិសាចិ ។ ៥ ឱ. វិចេយ្យ ។ ៦ ឱ. បសដមុទុមនោ ។ ៧ ឱ. ម. ឧទិក្ខិតា ។

ពួកស្មៀន ពួកមហាមាត្រ ពួកសេនាមានអង្គ ៤ (មានសេនាដំរីជាដើម) អ្នករក្សាទ្វារ អាមាត្យ ពួកបរិស័ទ ពួកស្តេចចំណុះ អ្នកមានភោគសម្បត្តិ និងពួករាជកុមារ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកគួរឲ្យអ្នកផងពិតពិលរមិលមើល ដោយសេចក្តីពេញចិត្ត ជាទីស្រឡាញ់នៃជនច្រើន ជាទីគាប់ចិត្តរបស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានពោលសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៣០] ព្រះតថាគត ជាអ្នកមិនសំឡក់មើល (ដោយទោសចិត្ត) មិនមៀងមើលដោយចុងភ្នែក មិនលបសំឡក់គេ (ដោយស្អប់) ជាអ្នកមានចិត្តស្មោះត្រង់ ពិតពិលរមិលមើលត្រង់ពេញភ្នែក ជាអ្នកសំឡឹងមើលមហាជន ដោយចក្ខុគួរស្រឡាញ់ ។ ព្រះតថាគតនោះ បានទៅសោយផលវិបាកក្នុងសុគតិ រីករាយក្នុងសុគតិនោះ (លុះច្យុតចាកឋានសួគ៌)

ឥធ ច ភវតិ គោបខុមោ
អភិនីលនេត្តនយនោ សុទស្សនោ ។
អភិយោគិនោ ច និបុណា
ពហុបទនិមិត្តកោវិទា[១]
គោបខុមនយនកុសលា មនុជា
បិយទស្សនោតិ អភិនិទ្ទិសន្តិ[២] នំ ។
បិយទស្សនោ គិហិ[៣] សន្តោ ច[៤]
ភវតិ ពហុជនបិយាយិតោ[៥]
យទិ ច ភវតិ គិហិ សមណោ
ហោតិ បិយោ ពហូនំ[៦] សោកនាសនោតិ ។

[៣១] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ

---

១ ឱ. ម. ពហូបននិមិត្តកោវិទា ។ ២ ឱ. ម. អភិនិទ្ទិសន្តិ។ ៣ ឱ. ម. គិហីបិ ។ ៤ ឱ. ចសទ្ទោ នត្ថិ ។ ៥ ឱ. ពហុន្នបិយាយិតោ ។ ម. ពហុជនបិយាយិតោ ។ ៦ ឱ. ពហុន្នំ ។

*មកកើតក្នុងមនុស្សលោកនេះ បានជាអ្នកមានកែវភ្នែកស្រ-ដៀងនឹងកែវភ្នែកកូនគោ ១ ជាអ្នកមានភ្នែកខៀវស្រស់ គួរឲ្យរមិលមើល (ដោយចិត្តរាប់អាន) ១ ។ មនុស្សទាំងឡាយជាអ្នកប្រកបក្នុងលក្ខណសាស្រ្ត មានប្រាជ្ញាដ៏ល្អិត ឈ្លាសវៃក្នុងបទនិងនិមិត្តដ៏ច្រើន និងជាអ្នកឈ្លាសវាងវៃក្នុងការទាយនូវភ្នែកដែលដូចជាភ្នែកកូនគោ នាំគ្នាទាយព្រះតថាគតនោះថា ព្រះរាជកុមារនេះ គួរឲ្យពិតពិលរមិលមើលដោយចិត្តជាទីស្រឡាញ់ ។ បើព្រះតថាគតនៅជាគ្រហស្ថ ជាបុគ្គលគួរឲ្យពិតពិលរមិលមើល ដោយចិត្តជាទីស្រឡាញ់ ជាទីរាប់អានរបស់ជនជាច្រើន នេះបើនៅជាគ្រហស្ថ បើទៅជាសមណៈវិញ ក៏គង់ជាទីស្រឡាញ់ និងជាអ្នកធ្វើសេចក្តីសោករបស់ជនច្រើនឲ្យវិនាសបាន ។*

*[៣១] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលពីមុន*

ពហុជនបុព្វង្គមោ អហោសិ កុសលេសុ ធម្មេសុ ពហុជនចាមោក្ខោ កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន[១] ទានសំវិភាគេ សីលសមាទានេ ឧបោសថុបវាសេ មត្តេយ្យតាយ[២] បេត្តេយ្យតាយ សាមញ្ញតាយ ព្រហ្មញ្ញតាយ កុលេជេដ្ឋាបចាយិតាយ អញ្ញតរញ្ញតរេសុ ច[៣] អធិកុសលេសុ ធម្មេសុ ។ សោ តស្ស កម្មស្ស កតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ ឧណ្ហីសសីសោ ហោតិ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ មហាស្ស ជនោ អន្វាយិកោ ហោតិ ព្រាហ្មណគហបតិកា នេគមជានបទា គណកមហាមត្តា អនីកដ្ឋា ទោវារិកា

---

១ ឱ. ម. កាយសុចរិតេ វចីសុចរិតេ មនោសុចរិតេ ។ ២ ឱ. ម. មេត្តេយ្យតាយ ។ ៣ ឱ. ចសទ្ទោ ន ទិស្សតិ ។

ជាចម្បងរបស់ជនច្រើន ក្នុងកុសលធម៌ទាំងឡាយ ជាប្រធានរបស់ជនច្រើន ក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ការបរិច្ចាគទាន សមាទានសីល កិរិយារក្សាឧបោសថ វត្តដែលត្រូវធ្វើចំពោះមាតា វត្តដែលត្រូវធ្វើចំពោះបិតា វត្តដែលត្រូវធ្វើចំពោះសមណៈ វត្តដែលត្រូវធ្វើចំពោះព្រាហ្មណ៍ វត្តដែលត្រូវធ្វើចំពោះជន ដែលជាចម្បងក្នុងត្រកូល និងក្នុងពួកកុសលធម៌ដ៏ក្រៃលែងឯទៀត ៗ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានសីសៈដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្ដេចហើយ តើនឹងបានរបស់អ្វី គឺនឹងមានជនច្រើននាក់ជាបរិវារ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ សេនាប្រកបដោយអង្គ ៤ អ្នករក្សាទ្វារ

៤៩

## លក្ខណសុត្តេ តថាគតបុព្វាធិការគាថា

អមច្ចា ចារិសជ្ជា រាជានោ ភោគិកា កុមារា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ មហាស្ស ជនោ អន្វាយិកោ ហោតិ ភិក្ខូ ភិក្ខុនិយោ ឧចាសកា ឧចាសិកាយោ ទេវា មនុស្សា អសុរា នាគា គន្ធព្វា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[៣២] បុព្វង្គមោ សុចរិតេសុ អហុ
ធម្មេសុ ធម្មចរិយាភិរតោ
អន្វាយិកោ ពហុជនស្ស អហុ
សគ្គេសុ វេទយិថ បុញ្ញផលំ ។
វេទយិត្វា សោ សុចរិតស្ស ផលំ
ឧណ្ហីសសីសត្តមិធជ្ឈគមា
ព្យាកំសុ ព្យញ្ជននិមិត្តធរា

អាមាត្យ បរិស័ទ ស្តេចចំណុះ អ្នកមានភោគសម្បត្តិ ព្រះរាជកុមារ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងមានជនច្រើននាក់ ជាបរិវារ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះ រួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៣២] ព្រះតថាគតជាចម្បង (របស់ជនច្រើន) ក្នុងសុចរិត-ធម៌ទាំងឡាយ ជាអ្នកត្រេកអរក្នុងការប្រព្រឹត្តធម៌ មានជនច្រើននាក់ជាបរិវារ លុះព្រះតថាគតលះលោកនេះ ក៏បានទៅសោយផលនៃបុណ្យក្នុងឋានសួគ៌ ។ លុះព្រះតថាគតសោយផលសុចរិតនោះហើយ ច្យុតមកកើត ក្នុងមនុស្សលោកនេះ ក៏បានជាអ្នកមានសីសៈ ហាក់ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ ឯពួកមនុស្សជាអ្នកចេះចាំនូវព្យញ្ជនៈនិងនិមិត្ត នាំគ្នាទាយថា ព្រះតថាគតនេះ នឹងបានជាចម្បងរបស់ជនច្រើន ។

បុព្វង្គមោ ពហុជនំ ហេស្សតិ(១) ។
បដិភោគិយានិ មនុជេសុ ឥធ
បុព្វេបិ(២) តស្ស អភិហរន្តិ តទា
យទិ ខត្តិយោ ភវតិ ភូមិបតិ
បដិហារកំ(៣) ពហុជនេ លភតិ ។
អថ ចេវ(៤) បព្វជតិ សោ មនុជោ
ធម្មេសុ ហោតិ បគុណោ វិសវី(៥)
តស្សានុសាសនគុណាភិរតោ(៦)
អន្វាយិកោ ពហុជនោ ភវតីតិ ។

[៣៣] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ អហោសិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ។ សោ តស្ស កម្មស្ស កតត្តា ។ បេ ។ សោ

---

១ ឱ. ម. ហេស្សតាយំ ។ ២ ឱ. ម. បុព្វេវ ។ ៣ ម. បដិហារក ។ ៤ ឱ. ម. ចេបិ ។ ៥ ម. វសី ។ ៦ ឱ. តស្សានុសាសនី គុណាភិរតោ ។ ម. តស្សានុសាសនិ...។

បណ្តាពួកមនុស្សក្នុងលោកនេះ នឹងមានមនុស្សជាអ្នកខ្វល់ខ្វាយបម្រើ (ព្រះតថាគតនេះជាច្រើន) សូម្បីកាលព្រះតថាគតនៅពីក្មេង ក្នុងកាលនោះឯង ក៏មានពួកមនុស្សទាយព្រះតថាគតនោះថា បើព្រះតថាគត ជាក្សត្រិយ៍នៅគ្រប់គ្រងផែនដី នឹងបានពួកជនច្រើននាក់ ធ្វើការខ្វល់ខ្វាយបម្រើ ។ បើមនុស្សនោះចេញទៅបួស នឹងបានជាអ្នកស្ទាត់ជំនាញក្នុងធម៌ទាំងឡាយ ជនជាច្រើនតែងត្រេកអរក្នុងគុណ គឺការប្រៀនប្រដៅរបស់មនុស្សនោះ ជាអ្នកប្រព្រឹត្តតាម (ព្រះតថាគតនោះ) ។

[៣៣] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកលះបង់នូវមុសាវាទ វៀរស្រឡះហើយចាកមុសាវាទ ជាអ្នកនិយាយតែពាក្យពិត បញ្ចេញតែពាក្យពិត ជាអ្នកទៀងត្រង់ និយាយពាក្យគួរឲ្យគេជឿ ជាអ្នកមិនពោលបំភ្លាត់សត្វលោកឡើយ ។ ព្រះតថាគតនោះព្រោះបានធ្វើកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាក

លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ ឯកេកលោមោ ច ហោតិ ឧណ្ណា ច ភមុកន្តរេ ជាតា ហោតិ ឱទាតា មុទុ តូលសន្និភា ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ មហាស្ស ជនោ ឧបវត្តតិ ព្រាហ្មណគហបតិកា នេគមជានបទា គណកមហាមត្តា អនីកដ្ឋា ទោវារិកា អមច្ចា បារិសជ្ជា រាជានោ ភោគិកា កុមារា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ មហាស្ស ជនោ ឧបវត្តតិ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ទេវា មនុស្សា អសុរា នាគា គន្ធព្វា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

ឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិស-លក្ខណៈទាំងពីរនេះ គឺជាអ្នកមានរោម ក្នុងរណ្ដៅមួយ ៗ តែមួយសរសៃ ៗ (ពាល់រណ្ដៅទាំងអស់) ១ មានរោមប្រជុំចិញ្ចើមដុះត្រង់ចន្លោះចិញ្ចើម មានពណ៌-សក្បុស ទន់ល្វន់ដូចជាសំឡី ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្ដេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជនច្រើននាក់ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្រ សេនាប្រកបដោយអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្ដេចចំណុះ អ្នកមានភោគសម្បត្តិ និងព្រះរាជកុមារ តែងប្រព្រឹត្តតាមអធ្យាស្រ័យរបស់តថាគតនោះ កាលបើនៅជាស្ដេចនឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជនច្រើននាក់ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ និងគន្ធព្វ តែងប្រព្រឹត្តតាមអធ្យាស្រ័យ របស់ព្រះតថាគតនោះ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសំដែងសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៣៤] សច្ចប្បដិញ្ញោ បុរិមាសុ ជាតិសុ
អទ្វេជ្ឈវាចោ អលិកំ វិវជ្ជយិ
ន សោ វិសំវាទយិតាបិ កស្សចិ
ភូតេន តច្ឆេន តថេន ភាសយិ[១] ។
សេតា សុសុក្កា សុមុទុ[២] តូលសន្និភា
ឧណ្ណា សុជាតា ភមុកន្តរេ អហុ
ន លោមកូបេសុ ទុវេ អជាយិសុំ[៣]
ឯកេកលោមូបចិតង្គវា អហុ ។
តំ លក្ខណញ្ញូ ពហវោ សមាគតា
ព្យាកំសុ ឧប្បាទនិមិត្តកោវិទា[៤]
ឧណ្ណា ច លោមា ច យថា សុសណ្ឋិតា
ឧបវត្តតិ ឦទិសកំ[៥] ពហុជនោ ។
គិហីបិ[៦] សន្តំ ឧបវត្តតិ ជនោ
ពហុ បុរត្ថា បកតេន កម្មុនា
អកិញ្ចនំ បព្វជិតំ អនុត្តរំ
ពុទ្ធំបិ សន្តំ ឧបវត្តតិ ជនោតិ ។

---

១ ឱ. តោសយិ ។ ២ ឱ. ម. មុទុ ។ ៣ អជាយឹសូតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៤ ឱ. ម. ឧប្បាទនិមិត្តកោវិទា ។ ៥ ឱ. ឯទិសកំ ។ ៦ ឱ. គិហិម្បិ ។

[៣៤] ក្នុងជាតិពីមុន ៗ ព្រះតថាគតអ្នកកាន់ពាក្យសត្យ មានវាចាគួរជឿ វៀរចាកពាក្យមិនពិត ព្រះតថាគតនោះ ជាអ្នកមិនក្លែងពោលពាក្យមិនពិត ចំពោះជនណាមួយឡើយ និយាយតែពាក្យពិត ទៀងទាត់ ត្រឹមត្រូវ ។ ព្រះតថាគតមានរោមប្រជុំចិញ្ចើមសម្បុរ-សក្បុស ទន់ល្វន់ ដូចជាសំឡីដុះត្រង់ចន្លោះចិញ្ចើមក្នុងរណ្ដៅរោមមួយ ៗ មិនដុះរោមពីរសរ-សៃឡើយ គឺព្រះតថាគតមានសរីរៈដុះរោមតែមួយសរសៃ ៗ ។ ពួកជនជាច្រើន ដែលជាអ្នកដឹងនូវលក្ខណៈ ឈ្លាសក្នុងការទាយនូវឧប្បាដនិងនិមិត្ត មកប្រជុំគ្នា ហើយទាយព្រះតថា-គតនោះថា នឹងមានជនជាច្រើន ប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់តថាគត ដែលជាអ្នកមានរោមប្រជុំចិញ្ចើមប្រតិស្ឋានល្អហើយបែបនេះ ។ បើព្រះតថាគតនៅជាគ្រហស្ថ នឹងមានជនជាច្រើនប្រព្រឹត្តតាមអធ្យាស្រ័យ ព្រោះកុសលកម្មដែលតថាគតបានធ្វើទុកមកពីកាលមុន ទោះបីព្រះតថាគតចេញទៅធ្វើជាបព្វជិត ឥតមានកង្វល់នឹងបានត្រាស់ជាព្រះពុទ្ធដ៏ប្រសើរ នឹងមានជនប្រព្រឹត្តតាមអធ្យាស្រ័យដូចគ្នា ។

លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

[៣៤] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ បិសុណំ វាចំ បហាយ[១] បិសុណាយ វាចាយ បដិវិរតោ អហោសិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ[២] អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ[៣] ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា[៤] សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា[៥] អហោសិ ។ សោ តស្ស កម្មស្ស កតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ ចត្តាឡីសទន្តោ ច[៦] ហោតិ អវិរឡទន្តោ ច[៧] ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។

---

១ ឱ. បិសុណាវាចម្បហាយ ។ ២ ឱ. ឥមេសម្ភេទាយ ។ ៣ ឱ. អមូសម្ភេទាយ ។ ៤ ឱ. អនុប្បាទាតា ។ ៥ ឱ. វាចម្ភាសិតា ។ ៦ ឱ. ចសទ្ទោ ន ទិស្សតិ ។ ៧ ឱ. អវិរទន្តោ ច ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

[៣៩] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលពីមុន ជាអ្នកលះបង់នូវវាចាស៊ិកសៀត វៀរស្រឡះហើយចាកវាចាស៊ិកសៀត ជាអ្នកឮពាក្យអំពីជនឯនេះ មិននាំទៅប្រាប់ជនឯនោះ ដើម្បីបំបែកជនទាំងពីរចំណែកនេះឡើយ ឬបានឮពាក្យអំពីជននោះ មិននាំមកប្រាប់ជនឯនេះ ដើម្បីបំបែកជនឯនោះឡើយ ជាអ្នកផ្សះផ្សានូវជន ដែលបាក់បែកគ្នាហើយ ជាអ្នកទំនុកបម្រុងនូវពួកជនដែលព្រមព្រៀងគ្នា ជាអ្នករីករាយនឹងការព្រមព្រៀង ត្រេកអរនឹងការព្រមព្រៀងគ្នា ពេញចិត្តនឹងការព្រមព្រៀងគ្នា និងពោលតែវាចា ដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានធ្មេញ ៤០ គត់ ១ មានធ្មេញជិតស្និទ្ធល្អ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។

រាជា សមានោ កឹ លភតិ អភេជ្ជបរិសោ ហោតិ អភេជ្ជស្ស ហោន្តិ បរិសា(១) ព្រាហ្មណគហបតិកា នេគមជានបទា គណកមហាមត្តា អនីកដ្ឋា ទោវារិកា អមច្ចា បារិសជ្ជា រាជានោ ភោគិកា កុមារា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ អភេជ្ជបរិសោ ហោតិ អភេជ្ជស្ស ហោន្តិ បរិសា ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ទេវា មនុស្សា អសុរា នាគា គន្ធព្វា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[៣៦] សវេភុតិយំ(២) សហិតភេទការឹ(៣)
ភេទប្បវឌ្ឍនវិវាទការឹ(៤)
កលហប្បវឌ្ឍនអកិច្ចការឹ(៥)
សហិតានំ ភេទជននឹ(៦) ន ភណិ(៧) ។
អវិវាទវឌ្ឍនការឹ សុគិរំ(៨)

---

១ ឱ. បរិសាតិ ន ទិស្សតិ ។ ២ ឱ. ម. វេភូតិយំ ។ ៣-៤-៥ ម... ការី ។ ៦ ម. ភេទជននំ ។ ៧ ឱ. ន ភណី ។ ៨ ឱ. អវិវាទវឌ្ឍនការី ចិរំ ។

កាលបើបានជាស្ដេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមិនបែកបាក់បរិស័ទ ឯបរិស័ទរបស់ស្ដេច ដែលមិនបែកបាក់គ្នានោះ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្រ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្ដេចចំណុះ អ្នកមានភោគសម្បត្តិនិងព្រះរាជកុមារ កាលបើនៅជាស្ដេច នឹងបាននូវរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងមានបរិស័ទ មិនបែកបាក់គ្នា បរិស័ទរបស់ព្រះតថាគតដែលមិនបែកបាក់គ្នានោះ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធនឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសំដែងសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៣៦] ព្រះតថាគតនោះ មិនបានពោលនូវពាក្យមិនពិត
ពាក្យដែលបង្កហេតុឲ្យបែកបាក់ ចាកការព្រមព្រៀង ពាក្យ
ដែលធ្វើសេចក្ដីបែកបាក់គ្នា នឹងទាស់ទែងគ្នា ឲ្យចម្រើន
ពាក្យដែលធ្វើជម្លោះ និងអំពើមិនគួរ ឲ្យចម្រើននិងពាក្យ
ដែលនាំឲ្យជនដែលមានបំណាងព្រមព្រៀង ឲ្យបែកបាក់គ្នា ។

ភិន្នាន សន្ធិជននី អកណិ
កាលហំ ជនស្ស បនុជិ សមគ្គី
សត្តេហិ(១) ននូតិ បមោនតិ ច
សុគតិសុ សោ ផលវិចាកំ
អនុភវតិ តត្ថ មោនតិ
ននា ឥន ហោន្តិ អវិរឡា(២) សហិតា
ចតុរោ នសស្ស មុខជា សុសណ្ឋិតា ។
យនិ ខត្តិយោ ភវតិ ភូមិបតិ
អភិភេនយស្ស(៣) បរិសា ភវតិ
សមណោ ច ហោតិ វិរជោ វិមលោ(៤)
បរិសាស្ស ហោតិ អនុគតា អចលាតិ ។

[៣៧] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ

១ ឱ. ម. សហិតេហិ ។ ២ ឱ. អវិវរា ។ ៣ ឱ. អវិហេចិយាស្ស ។ ម. អវិហេទិយាស្ស ។
៤ ម. វីតមលោ ។

ព្រះតថាគត ពោលតែពាក្យល្អ ជាពាក្យធ្វើសេចក្តីមិនវិវាទឲ្យចម្រើន និងពាក្យផ្សះផ្សាជនដែលបែកបាក់គ្នាហើយ ព្រះតថាគត បន្ទោបង់នូវជម្លោះរបស់ជន ទាំងធ្វើឲ្យព្រមព្រៀងគ្នា ព្រះតថាគត តែងរីករាយ ត្រេកអរមួយអន្លើដោយសត្វទាំងឡាយ ព្រះតថាគតបានទៅសោយផលវិបាកក្នុងសុគតិរីករាយក្នុងសុគតិនោះ លុះច្យុតចាកឋានសួគ៌ (មកកើត) ក្នុងមនុស្សលោកនេះ ក៏មានធ្មេញជិតស្និទ្ធល្អ និងមានធ្មេញ ៤០ គត់ ប្រតិស្ឋានដោយល្អនៅក្នុងមាត់ ។ បើព្រះតថាគតនៅ (គ្រប់គ្រងគេហដ្ឋាន) នឹងបានជាក្សត្រិយ៍គ្រប់គ្រងផែនដី មានបរិស័ទមិនបែកបាក់គ្នាឡើយ ទោះបីជាសមណៈក៏ជាអ្នកឥតមានធូលី ឥតមានមន្ទិល គឺរាគាទិក្កិលេសឡើយ ជាអ្នកមានបរិស័ទ តាមចោមរោម មិនញាប់ញ័រឡើយ ។

[៣៧] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលពីមុន ជាអ្នកបានលះបង់នូវផរុសវាចា វៀរស្រឡះហើយ ចាកផរុសវាចា

អហោសិ យា សា វាចា នេលា កណ្ណសុខា បេ-មនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជ-នមនាបា តថារូបឹ វាចំ ភាសិតា អហោសិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ បហូតជិវ្ហោ ច ហោតិ ព្រហ្មស្សរោ ច ករវិកភាណី ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ អាទេយ្យវាចោ ហោតិ អាទិយន្តស្ស[១] វចនំ ព្រាហ្មណគហបតិកា នេគមជានបទា គណ-កមហាមត្តា អនីកដ្ឋា ទោវារិកា អមច្ចា បារិសជ្ជា រាជានោ ភោគិកា កុមារា រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ

១ ឱ. ម. អាទិយន្តិស្ស ។

ជាអ្នកនិយាយតែពាក្យដែលឥតទោស ពាក្យដែលជាសុខដល់ត្រចៀកគេ គួរឲ្យស្រឡាញ់ គួរឲ្យតាំងទុកក្នុងហឫទ័យ ជាសំដីអ្នកក្រុង ទាំងជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំ កសាង នូវកុសលកម្មនោះ ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈ ទាំងពីរនេះ គឺជាអ្នកមានអណ្តាតវែង ១ មានសូរសព្ទសំឡេងគ្រាំងគ្រអៅ ដូចជាសំឡេងព្រហ្ម កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រ-ពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានវាចាគួរឲ្យអ្នកផងកាន់តាម គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្រ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យបរិស័ទ ស្តេចចំណុះ អ្នកមានភោគសម្បត្តិ នឹងព្រះរាជកុមារ តែងកាន់តាមពាក្យរបស់ព្រះតថាគតនោះ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី

## ៤៧

លក្ខណសុត្តេ តថាគតបុព្វាធិការគាថា

អាទេយ្យវាចោ ហោតិ អាទិយន្តស្ស[១] វចនំ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ ទេវា ម-នុស្សា អសុរា នាគា គន្ធព្វា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

[៣៨] អក្កោសភណ្ឌនវិហេសការឹ
ឧព្វាធការំ[២] ពហុជនប្បមទ្ទនំ
អពាឡ្ហគិរំ[៣] សោ ន ភណិ ផរុសំ
មធុរំ ភណិ សុសហិតំ[៤] សខិលំ ។
មនសោ បិយា ហទយគាមិនិយោ[៥]
វាចា សោ ឯរយតិ កណ្ណសុខា
វាចា សុចិណ្ណផលមនុភវិ[៦]
សគ្គេសុ វេទយិថ[៧] បុញ្ញផលំ
វិទិត្វា[៨] សោ សុចរិតស្ស ផលំ

១ ឱ. ម. អាទិយន្តិស្ស ។ ២ ឱ. ឧព្វាយិកំ ។ ម. ឧព្វាធិកំ ។ ៣ ឱ. អពាឡ្ហំ គិរំ ។ ៤ ឱ. សុសំហិតំ ។ ៥ ឱ. ហទយំ គាមិនិយោ ។ ៦ ឱ. សុចិណ្ណផលមានុភវិ ។ ៧ ឱ. វេទ-យថ ។ ៨ ឱ. វេទិត្វា ។

គឺនឹងបានជាអ្នកមានវាចា គួរឲ្យអ្នកផងកាន់តាម គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ តែងកាន់តាមពាក្យរបស់ព្រះតថាគតនោះ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសំដែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៣៨] ព្រះតថាគតនោះ មិនបានពោលពាក្យអាក្រក់ក្រៃលែង ដែលជាពាក្យជេរ ជាពាក្យបង្កហេតុឲ្យទាស់ទែងគ្នាបៀតបៀនគ្នា ពាក្យដែលធ្វើឲ្យឈឺចិត្ត ពាក្យជាគ្រឿងមើលងាយនូវជនច្រើនឡើយ ព្រះតថាគត ពោលតែពាក្យផ្អែមល្ហែម ទន់ភ្លន់ ប្រកបដោយប្រយោជន៍ ។ ព្រះតថាគតនោះ ពោលតែពាក្យ ដែលជាទីស្រឡាញ់ពេញចិត្ត គួរតម្កល់ទុកក្នុងហឫទ័យ នាំមកនូវសេចក្តីសុខ ដល់ត្រចៀក (របស់មនុស្សដែលបានស្តាប់) ព្រះតថាគត បានសោយផលនៃបុណ្យ ក្នុងឋានសួគ៌ បានសោយផលនៃអំពើសុចរិត

ព្រហ្មស្សរត្តមិជជ្ឈគមា
ជិវ្ហាស្ស ហោតិ វិបុលា បុថុលា[១]
អាទេយ្យវាក្យវចនោ ភវតិ
គិហិនោបិ ឥជ្ឈតិ យថា ភណតោ
អថ ចេ[២] បព្វជតិ សោ មនុជោ
អាទិយន្តស្ស វចនំ ជនតា
ពហុនោ ពហុំ សុភណិតំ[៣] ភណតោតិ ។

[៣៩] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ អហោ-សិ កាលវាទី ភូតវាទី ធម្មវាទី អត្ថវាទី វិនយវាទី[៤]

---

១ ឱ. ថូលា ។ ២ ឱ. ចេបិ ។ ៣ ឱ. ភណិតំ ។ ៤ ឱ. អត្ថវាទី ធម្មវាទី វិនយវាទី ។

លុះព្រះតថាគត ច្យុតមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវភាពជាអ្នកមានសំឡេង ដូចសំឡេងព្រហ្ម អណ្តាតរបស់ព្រះតថាគតនោះ ធំទូលាយ ព្រះតថាគត មានពាក្យដែលគួរឲ្យអ្នកផងកាន់តាម សូម្បីកាលព្រះតថាគត នៅជាគ្រហស្ថនិយាយយ៉ាងណាទៅហើយ ក៏តែងនាំឲ្យសម្រេចប្រយោជន៍យ៉ាងនោះ បើព្រះតថាគតនោះ ជាមនុស្សចេញទៅបួស ក៏មានពួកជនជឿកាន់តាមពាក្យ របស់ព្រះតថាគតនោះ ដែលជាអ្នកពោលនូវពាក្យល្អច្រើន ។

[៣៩] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលមុន ជាអ្នកលះបង់នូវសម្ផប្បលាបៈ (ពាក្យរោយរាយ) វៀរស្រឡះហើយចាកសម្ផប្បលាបៈ ជាអ្នកពោលតាមកាលគួរ ពោលតែពាក្យពិត ពោលពាក្យប្រកបដោយហេតុ ពោលពាក្យប្រកបដោយផល ពោលពាក្យទូន្មាន

និធានវតឹ វាចំ ភាសិតា[១] កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ។ បេ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមំ មហាបុរិសលក្ខណំ បដិលភតិ សីហហនុ ហោតិ ។ សោ តេន លក្ខណេន សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ។ បេ ។ រាជា សមានោ កឹ លភតិ អប្បធំសិកោ[២] ហោតិ កេនចិ មនុស្សភូតេន បច្ចត្ថិកេន បច្ចាមិត្តេន រាជា សមានោ ឥទំ លភតិ ។ បេ ។ ពុទ្ធោ សមានោ កឹ លភតិ អប្បធំសិកោ ហោតិ អព្ភន្តរេហិ វា ពាហិរេហិ វា បច្ចត្ថិកេហិ បច្ចាមិត្តេហិ រាគេន វា ទោសេន វា មោហេន វា សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

១ ឱ. ភាសិតា អហោសិ ។ ២ អប្បធំសិយោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

លក្ខណសូត្រ ពោលអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត

ពោលពាក្យដែលគួរឲ្យអ្នកផង តម្កល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយគ្រឿងអាង មានទីបំផុត ប្រកបដោយប្រយោជន៍ ត្រូវតាមកាល ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំនូវកុសលកម្ម ។ បេ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានចង្កាមានសណ្ឋានដូចជាចង្កានៃរាជសីហ៍ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។ បេ ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នក ដែលមនុស្សជាសឹកសត្រូវបច្ចាមិត្តនីមួយ មិនអាចកំចាត់បង់បានឡើយ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។ បេ ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នក ដែលសត្រូវបច្ចាមិត្តខាងក្នុង ឬខាងក្រៅ គឺរាគៈក្តី ទោសៈក្តី មោហៈក្តី សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក មិនអាចធ្វើព្រះតថាគត ឲ្យឃ្លាត (ចាកគុណ ឫទ្ធិ) បានឡើយ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានសំដែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៤០] ន សម្ផប្បលាបំ ន វុទ្ធតត្តិ(១)
អវិកិណ្ណវចនព្យបថោ ច អហោសិ
អហិតមបិ ច អបនុទិ ហិតមបិ ច
ពហុជនសុខញ្ច អភណិ ។
តំ កត្វាន ឥតោ ចុតោ ទិវមុបបជ្ជិ(២)
សុកតផលវិបាកមនុភោសិ(៣)
ចវិយ បុនរិធាគតោ សមានោ
ទ្វិទុក្កមវរតរហនុត្តមលត្ថ ។
រាជា ហោតិ សុទុប្បធំសិយោ មនុជិន្ទោ
មនុជាធិបតិ មហានុភាវោ
តិទិវបុរវរសមោ ភវតិ
សុរវរតរោរិវ ឥន្ទោ ។
គន្ធព្វាសុរសក្ករក្ខសេភិ(៤) សុរេភិ
ន ហិ ភវតិ សុប្បធំសិយោ តថត្តោ

១ ឱ. ន មុទ្ធតំ ។ ២ ឱ. ទិព្វំ ឧប្បជ្ជិ ។ ៣ ឱ. សុកតផលវិបាកមនុភោសិ ។
៤ ម. គន្ធព្វាសុរយក្ខរក្ខសេភិ ។

[៤០] ព្រះតថាគត មិនពោលពាក្យឥតប្រយោជន៍ មិនពោលពាក្យរាយមាយ ជាអ្នកមានគន្ធងនៃពាក្យមិនរោយរាយ ព្រះតថាគត តែងបន្ទោបង់នូវពាក្យ ដែលឥតប្រយោជន៍ផង ពោលតែពាក្យមានប្រយោជន៍ ដែលជាពាក្យនាំមកនូវសេចក្តីសុខដល់ជនច្រើនផង ។ ព្រះតថាគត ធ្វើនូវកុសលកម្មនោះហើយ លុះច្យុតចាកមនុស្សលោកនេះ បានទៅកើតក្នុងឋានសួគ៌ បានសោយនូវផលវិបាករបស់កម្មដែលធ្វើល្អ លុះច្យុត (ចាកឋានសួគ៌) នោះមកកាន់អត្តភាពជាមនុស្សនេះវិញ ក៏បាននូវភាពជាអ្នកមានចង្កា ដូចចង្កាសីហៈ ដែលជាសត្វប្រសើរជាងពួកសត្វជើង ៤ ។ ព្រះតថាគត ជាស្តេចកំពូលនៃមនុស្ស ជាធំជាងមនុស្ស មានអានុភាពច្រើន ទោះបីអ្នកណា ៗ ក៏មិនអាចញាំញីបានឡើយ ព្រះតថាគត ស្មើដោយព្រះឥន្ទ្រ ដែលប្រសើរ ក្នុងភពឈ្មោះតាវត្តិង្ស ទាំងក្មៀវក្លាប្រសើរក្រៃលែង ដូចជាព្រះឥន្ទ្រាធិរាជដូច្នោះឯង ។ ព្រះតថាគត ជាអ្នកមានអត្តភាពដូច្នោះ ទោះបីគន្ធព្វ អសុរ សក្កទេវរាជ រក្ខទេពទាំងឡាយ ដែលក្លៀវក្លា ក៏មិនអាចញាំញីបាន

លក្ខណសុត្តេ តថាគតបុព្វាធិការកថា

យមិ ភវតិ[១] តថាវិជោ ឥជ

និសា ច បតិ និសា ច វិនិសា ចាតិ ។

[៤១] យំបិ ភិក្ខវេ តថាគតោ បុរិមំ ជាតឹ បុរិមំ ភវំ បុរិមំ និកេតំ បុព្វេ មនុស្សភូតោ សមានោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិកំ កប្បេសិ តុលាកូដកំសកូដមានកូដឧក្កោដនវញ្ចននិកតិសាវិយោគា[២] ឆេទនវធពន្ធនវិបរាមោសអាលោបសាហសាការា បដិវិរតោ អហោសិ ។ សោ តស្ស កម្មស្ស កតត្តា ឧបចិតត្តា ឧស្សន្នត្តា វិបុលត្តា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ សោ តត្ថ អញ្ញេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហាតិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន យសេន ទិព្វេន សុខេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ

---

១ ឱ. ភវតិ គិហិ ។ ២ ឱ. តុលាកូដកំសកូដមានកូដឧក្កោដនវញ្ចននិកតិសាចិយោគា ។

លក្ខណសូត្រ ពោលអំពីការកសាងបុព្វកម្មនៃព្រះតថាគត

*បើអ្នកណាមានលក្ខណៈ ដូចជាព្រះតថាគតនោះ ក្នុងលោកនេះ នឹងបានជាធំក្នុងទិស គឺទិសតូច និងទិសធំ ។*

[៤១] *ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្ស ក្នុងកាលពីមុន បានលះបង់នូវមិច្ឆាជីវៈ (ការចិញ្ចឹមជីវិតខុស) ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ជាអ្នកបានវៀរចាកការបញ្ឆោតឬបន្លំ ដោយជញ្ជីង បញ្ឆោតដោយមាស បញ្ឆោតដោយរង្វាល់រង្វាស់ បង្ខុសបំភាន់ បញ្ឆោតបោកប្រាសនិងបន្លំ ដោយរបស់ប្លម វៀរចាកកិរិយាកាត់នូវអវយវៈ មានដៃជាដើម សម្លាប់ ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់ កំហែងយកទ្រព្យ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំ កសាងកុសលកម្មនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ។ ព្រះតថាគតនោះ គ្របសង្កត់នូវទេវតាឯទៀត ក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ គឺអាយុទិព្វ ១ សម្បុរទិព្វ ១ យសទិព្វ ១ សុខទិព្វ ១ អធិបតីទិព្វ ១ រូបទិព្វ ១ សំឡេងទិព្វ ១*

និព្ពុហិ គន្ធេហិ និព្ពុហិ រសេហិ និព្ពុហិ ផោដ្ឋព្ពេហិ ។ សោ តតោ ចុតោ ឥត្ថត្តំ អាគតោ សមានោ ឥមានិ ទ្វេ មហាបុរិសលក្ខណានិ បដិលភតិ សមធន្តោ ច ហោតិ សុសុក្កទាឋោ ច ។ សោ តេហិ លក្ខណេហិ សមន្នាគតោ សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនប-ទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ ។ តស្សិមានិ សត្ត រតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណា-យករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បឋវឹ សាគរបរិយន្តំ អខីលំ អនិមិត្តំ អកណ្ដកំ

ក្លិនទិព្វ ១ រសទិព្វ ១ ផ្សព្វទិព្វ ១ ។ លុះព្រះតថាគតនោះ ច្យុត ចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិ-សលក្ខណៈទាំងឡាយពីរនេះ គឺជាអ្នកមានធ្មេញជិតស្និទ្ធល្អ ១ មានចង្កូម (ទាំង ៤) សស្អាត ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិប្រកបដោយធម៌ សោយរាជ្យដោយធម៌ មានជ័យជំនះផ្សាយរាជអំណាច រហូតដល់ផែនដីដែលមានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ដល់នូវភាពជាអ្នកមាំមួន ក្នុងជនបទ ប្រកបដោយរតន៍ ៧ ប្រការ ។ រតន៍ ៧ ប្រការនេះរបស់ស្ដេចនោះ គឺចក្ករតន៍ ១ ហត្ថិរតន៍ ១ អស្សរតន៍ ១ មណិរតន៍ ១ ឥត្ថីរតន៍ ១ គហបតិរតន៍ ១ បរិនាយករតន៍ ១ រួមត្រូវជារតន៍ ៧ ប្រការ ។ បុត្ររបស់ស្ដេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកក្លៀវក្លា អាចញាំញីនូវសេនា របស់ស្ដេចឯទៀតបាន ។ ទ្រង់ប្រាបប្រាមគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំ-ផុត ឲ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្ទាគឺចោរឡើយ

៦៣

លក្ខណសុត្តេ តថាគតបុញ្ញាធិការកថា

ឥទ្ធំ ផីតំ ខេមំ សិវំ និរព្ពុទំ អកណ្ដកេន អសបត្តេន ធម្មេន សមេន អភិវិជិយ អជ្ឈាវសតិ រាជា សមានោ កឹ លភតិ សុចិបរិវារោ ហោតិ សុចិស្ស ហោន្តិ បរិវារា ព្រាហ្មណគហបតិកា នេគមជានបទា គណ-កមហាមត្តា អនីកដ្ឋា ទោវារិកា អមច្ចា បារិសជ្ជា រាជានោ ភោគិកា កុមារា រាជា សមានោ ឥទំ លភតិ ។ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ ពុទ្ធោ សមានោ កឹ លភតិ សុចិបរិវារោ ហោតិ សុចិស្ស ហោន្តិ បរិវារា ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបា-សិកាយោ ទេវា មនុស្សា អសុរា នាគា គន្ធព្វា ពុទ្ធោ សមានោ ឥទំ លភតិ ។ ឯតមត្ថំ ភគវា អវោច ។ តត្ថេតំ វុច្ចតិ

ជាផែនដីស្ដុកស្ដម្ភ មាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ដ៏ស្មើ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ កាលបើនៅជាស្ដេច នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបរិវារស្អាតបាត ឯបរិវារស្អាតបាត របស់ស្ដេចចក្រពត្តិនោះ គឺ ពួកព្រាហ្មណ៍គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្រ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្ដេចចំណុះ អ្នកមានភោគសម្បត្តិ និងព្រះរាជកុមារ កាលបើនៅជាស្ដេច នឹងបានរបស់នេះឯង ។ បើព្រះតថាគត ចេញចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក (នោះ) មានដំបូលគឺរាគាទិក្កិលេសបើកចេញហើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបរិវារស្អាតបាត ឯបរិវារស្អាតបាតរបស់តថាគតនោះ គឺ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសម្ដែងនូវសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[៤២] មិច្ឆាជីវញ្ច អវស្សជិ(១) សមេន
វុត្តឹ សុចិនា សោ ជនយិត្ថ ធម្មិកេន
អហិតមបិ ច អបនុទិ ហិតមបិ ច
ពហុជនសុខញ្ច អចរិ ។
សគ្គេ វេទយតិ នរោ សុផលានិ(២)
ករិត្វា និបុណេភិ វិទូភិ សព្ភិ(៣)
វណ្ណិតានិ តិទិវបុរវរសមោ
អភិរមតិ រតិខិឌ្ឌាសមង្គី ។
អលទ្ធាន មនុស្សកំ(៤) ភវំ តតោ ចវិយ(៥)
បុន(៦) សុកតផលវិបាកសេសេន
បដិលភតិ លបនជំ សមមបិ
សុចិ ច សុវិសុទ្ធសុសុក្កំ(៧) ។
តំ វេយ្យញ្ជនិកា សមាគតា ពហវោ
ព្យាកំសុ និបុណា(៨) សម្មតា មនុជា(៩)

---

១ អវោស្សជីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. សុខប្ផលានិ ។ ៣ ឱ. សមភិ ។ ៤ ឱ. លទ្ធា មានុសកំ ។ ម. លទ្ធា ន មានុសកំ ។ ៥ ម. ចវិត្វាន ។ ៦ ឱ. ន ។ ៧ ឱ. សុវិសុទ្ធំ សុវិសុក្កំ ។ ម. សុចិ សុសុក្កំ ។ ៨ ឱ. ម. និបុណ ។ ៩ ឱ. មនុជិន្ទា ។

[៤២] ព្រះតថាគតនោះ បានលះបង់ការចិញ្ចឹមជីវិតខុស បានបំពេញសេចក្តីប្រព្រឹត្តដោយស្អាតល្អ ជាធម៌ដ៏ស្មោះស្មើផង បានកម្ចាត់បង់នូវកម្មដែលឥតប្រយោជន៍ផង ប្រព្រឹត្តនូវកម្មដែលមានប្រយោជន៍ ទាំងនាំមកនូវសេចក្តីសុខដល់ជនច្រើនផង ។ ព្រះតថាគតជានរជនបានធ្វើនូវអំពើមានផលដ៏ល្អ ដែលពួកសប្បុរសជាអ្នកប្រាជ្ញមានប្រាជ្ញាល្អិតតែងសរសើរ ហើយទើបសោយនូវសេចក្តីសុខក្នុងឋានសួគ៌ ព្រះតថាគត ជាអ្នកស្មើដោយសក្កទេវរាជ ដែលជាកំពូលនៃទេវតា ក្នុងភពឈ្មោះតាវត្តិង្ស តែងត្រេកអរនឹងមូលមិត្រដោយសេចក្តីរីករាយ និងសេចក្តីសុខសម្រាន្ត ។ លុះព្រះតថាគត ច្យុតចាកឋានសួគ៌នោះ បានមកកើតជាមនុស្សនេះម្តងទៀត ក៏បាននូវធ្មេញរាបស្មើល្អផង នូវចង្កូម (ទាំង ៤) ស្អាតល្អផង ព្រោះសេសនៃផលវិបាក របស់កម្មដែលបានធ្វើល្អហើយ ។ ពួកមនុស្សជាច្រើន ជាអ្នកដឹងនូវលក្ខណៈដែលសន្មតថាជាអ្នកមានប្រាជ្ញាល្អិត មកប្រជុំគ្នាទាយព្រះ

៦៤

លក្ខណសុត្តេ តថាគតបុព្វាធិការគាថា

សុចិជនបរិវារគណោ ភវតិ
ទិជ(១) សមសុក្កសុចិសោភនង្គោ ។
រញ្ញោ ហោតិ ពហុជនោ សុចិបរិវារោ
មហតិមំ មហិមនុសាសតោ ច(២)
បសយ្ហ ន ច ជនបទតុទនំ
ហិតមបិ ច ពហុជនសុខំ(៣) ចរន្តិ
អថ ចេ(៤) បព្វជតិ ភវតិ វិបាបោ
សមណោ សមិតរជោ វិវដច្ឆទោ
វិគតទរថកិលមថោ ឥមំបិ ច
បរំបិ បរមំបិ ច បស្សតិ(៥) លោកំ ។
តស្សោវាទករា ពហុគិហី ច
បព្វជិតា ច អសុចិ(៦) វិគរហិត-

---

១ ឱ. ទិជា ។ ២ ឱ. មហាតិមហីអនុសាសតោ ។ ម. មហាតឹ មហីអនុសាសតោ ។ ៣ ម. ពហុជនសុខញ្ច ។ ៤ ម. អថខោ ច ។ ៥ ឱ. ឥមម្បិ ច បរម្បិ ច បស្សតិ ។ ម. ឥមមបិ ច បរមបិ ច បស្សតិ ។ ៦ ឱ. អសុចិ ។

តថាគតនោះថា ព្រះតថាគតដែលមានព្រះទន្តស្មើ-សស្អាតល្អ រមែងមានពួកជនស្អាតជាបរិវារ ។ បើព្រះតថាគតនៅសោយរាជ្យ នឹងបានជនច្រើនជាបរិវារស្អាតល្អ ព្រះតថាគតប្រៀនប្រដៅនូវមនុស្សលើផែនដីធំនេះ គ្របសង្កត់សង្កិន មិនឲ្យមានគ្រឿងចាក់ដោតដល់ជនបទឡើយ ព្រះតថាគតប្រព្រឹត្តនូវអំពើជាប្រយោជន៍ ទាំងជាសេចក្ដីសុខដល់ជនច្រើន បើព្រះតថាគត ចេញទៅបួស រមែងជាអ្នកបន្សាត់បង់នូវបាប ជាអ្នកស្ងប់រម្ងាប់ មានធូលីគឺរាគាទិក្កិលេសស្ងប់រម្ងាប់ហើយ មានកិលេសដូចជាដំបូល បើកចេញហើយ ជាអ្នកប្រាសចាកសេចក្ដីក្រវល់ក្រវាយ និងសេចក្ដីលំបាកកាយ តែងឃើញនូវលោកនេះ និងលោកខាងមុខ ។ ពួកគ្រហស្ថនិងបព្វជិតជាច្រើន ដែលជាអ្នកធ្វើតាមឱវាទ របស់ព្រះតថាគតនោះ តែងជាអ្នកប្រាសចាកសេចក្ដីសៅហ្មង ព្រោះថា

៦៦

សុត្តន្តបិដកេ ទីឃនិកាយស្ស បាដិកវគ្គោ

ធុនិតបាបស្ស ហិ សុចីភិ[១] បរិវុតោ

ភវតិ មលខិលកលិកិលេសេបនុទេតីតិ[២] ។

ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ

ភាសិតំ អភិនន្ទុន្តិ[៣] ។

លក្ខណសុត្តំ សត្តមំ[៤] និដ្ឋិតំ ។

---

១ ឱ. វិគរហិតំ ធុនន្តិ បាបំ សហិ សុចិ ។ ម... សុចិភិ ។ ២ ឱ. ម. មលខិលកលិកិលេសេបនុទេតីតិ ។ ៣ ឱ. ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តីតិ ន ទិស្សន្តិ ។ ៤ ឱ. លក្ខណសុត្តន្តំ និដ្ឋិតំ ។

ព្រះតថាគតមានបាប បន្សាត់ចោលហើយនោះ រមែង មានតែពួកមនុស្សស្អាតល្អ ដែលជាអ្នកកម្ចាត់បង់នូវមន្ទិល និងដង្គត់គឺរាគាទិក្កិលេស នូវកំហុសគឺទោស និងកិលេស ទាំងពួង មកចោមរោមជុំវិញ ។

លុះព្រះមានព្រះភាគ បានសំដែងលក្ខណសូត្រនេះ ចប់ហើយ ។ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ លក្ខណសូត្រ ទី ៧ ។

# សិង្គាលកសុត្តំ អដ្ឋមំ

[៤៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន សិង្គាលកោ[១] គហបតិបុត្តោ កាលស្សេវ វុដ្ឋាយ រាជគហា និក្ខមិត្វា អល្លវត្ថោ អល្លកេសោ បញ្ជលិកោ បុថុទ្ទិសា នមស្សតិ បុរត្ថិមំ ទិសំ ទក្ខិណំ ទិសំ បច្ឆិមំ ទិសំ ឧត្តរំ ទិសំ ហេដ្ឋិមំ ទិសំ ឧបរិមំ ទិសំ ។

[៤៤] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ភគវា សិង្គាលកំ គហបតិបុត្តំ កាលស្សេវ វុដ្ឋាយ រាជគហា និក្ខមិត្វា អល្ល-វត្ថំ អល្លកេសំ បញ្ជលិកំ បុថុទ្ទិសា នមស្សន្តំ

---

១ សិគាលកោតិបិ បាឋោ ។

# សិង្គាលកសូត្រទី ៨

[៤៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង កូនគហបតីឈ្មោះសិង្គាលកៈ[១] ក្រោកឡើងអំពីព្រឹក មានសំពត់ស្បៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ប្រណម្យអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ ។

[៤៤] លំដាប់នោះឯង ព្រះមានព្រះភាគ ស្តេចទ្រង់ស្បង់និងបាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសិង្គាលកគហបតិបុត្ត ក្រោកឡើងអំពីព្រឹក មានសំពត់ស្បៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ កំពុងផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន

---

១ ហៅថា សិគាលកៈ ក៏មាន ដូចគ្នានឹងពាក្យថា មហឹសៈ និងមហិសៈ សិរីសបៈ និងសិរិសបៈជាដើម ឃើញថាហៅបានដូចគ្នាទាំងពីរយ៉ាង ។

បុរត្ថិមំ ទិសំ ទក្ខិណំ ទិសំ បច្ឆិមំ ទិសំ ឧត្តរំ ទិសំ ហេដ្ឋិមំ ទិសំ ឧបរិមំ ទិសំ ទិស្វាន[១] សិង្គាលកំ គហបតិបុត្តំ ឯតទវោច កិន្នុ ត្វំ គហបតិបុត្ត កាលស្សេវ វុដ្ឋាយ រាជគហា និក្ខមិត្វា អល្លវត្ថោ អល្លកេសោ បញ្ជលិកោ បុថុទ្ទិសា នមស្សសិ បុរត្ថិមំ ទិសំ ។ បេ ។ ឧបរិមំ ទិសន្តិ ។ បិតា មម[២] ភន្តេ កាលំ ករោន្តោ ឯវំ[៣] អវច ទិសា តាត នមស្សេយ្យាសីតិ សោ ខោ អហំ ភន្តេ បិតុ វចនំ សក្ករោន្តោ គរុករោន្តោ មានេន្តោ បូជេន្តោ កាលស្សេវ វុដ្ឋាយ រាជគហា និក្ខមិត្វា អល្លវត្ថោ អល្លកេសោ បញ្ជលិកោ បុថុទ្ទិសា នមស្សាមិ បុរត្ថិមំ ទិសំ ។ បេ ។ ឧបរិមំ ទិសន្តិ ។ ន ខោ គហបតិបុត្ត អរិយស្ស វិនយេ ឯវំ ឆ ទិសា នមស្សិតព្វាតិ ។ យថាកថំ បន ភន្តេ អរិយស្ស វិនយេ ឆ ទិសា នមស្សិតព្វា សាធុ មេ ភន្តេ ភគវា តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ ឆ ទិសា នមស្សិតព្វាតិ ។

---

១ ឱ. ម. ទិស្វា ។ ២ ឱ. ម. មំ ។ ៣ ឱ. ឯវន្តិ ន ទិស្សតិ ។

គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ លុះទ្រង់ឃើញហើយ ទើបទ្រង់ត្រាស់សួរសិង្គាលកគហបតិបុត្ត ដូច្នេះថា នែគហបតិបុត្ត ហេតុអ្វី ទើបអ្នកក្រោកអំពីព្រឹក មានសំពត់ស្មៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ។ បេ ។ ទិសខាងលើ ។ សិង្គាលកគហបតិបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើមរណកាល បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ហៃបា អ្នកត្រូវតែថ្វាយបង្គំទិសទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ធ្វើសក្ការៈគោរព រាប់អាន បូជា នូវពាក្យរបស់បិតា បានជាក្រោកឡើង អំពីព្រឹក មានសំពត់ស្មៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយដ៏ច្រើន គឺទិសខាងកើត ។ បេ ។ ទិសខាងលើ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែគហបតិបុត្ត ក្នុងវិន័យរបស់ព្រះអរិយៈ គេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាងដូច្នេះទេ ។ សិង្គាលកគហបតិបុត្តក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចំណែកក្នុងអរិយវិន័យ គេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន បើក្នុងវិន័យរបស់ព្រះអរិយគេគប្បីថ្វាយបង្គំ ចំពោះទិសទាំង ៦ យ៉ាងណា សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដល់ខ្ញុំព្រះអង្គដូច្នោះចុះ ។

៦៩

## សិង្គាលកសុត្តេ ចត្តារោ កម្មក្កិលេសា

[៤៨] តេនហិ គហបតិបុត្ត សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ សិង្គាលកោ គហបតិបុត្តោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច យតោ ខោ គហបតិបុត្ត អរិយស្សាវកស្ស ចត្តារោ កម្មក្កិលេសា បហីនា ហោន្តិ ចតូហិ[១] ឋានេហិ បាបកម្មំ ន ករោតិ ឆ ច ភោគានំ អបាយមុខានិ ន សេវតិ សោ ឯវំ ចុទ្ទសបាបកាបគតោ ឆទិសាបដិច្ឆាទី ហោតិ[២] ឧភោលោកវិជយាយ បដិបន្នោ ហោតិ តស្ស អយញ្ចេវ លោកោ អារទ្ធោ ហោតិ បរោ ច លោកោ ។ សោ[៣] កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ កតមស្ស ចត្តារោ កម្មក្កិលេសា បហីនា ហោន្តិ ។ បាណាតិបាតោ ខោ គហបតិបុត្ត កម្មក្កិលេសោ អទិន្នាទានំ កម្មក្កិលេសោ

១ ឱ. ចតូហិ ច ។ ២ ឱ. ម. ហោតីតិ ន ទិស្សតិ ។ ៣ ឱ. សោតិ ន ទិស្សតិ ។

សិង្គាលកសូត្រ កម្មក្កិលេស ៤ យ៉ាង

[៤៥] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែគហបតិបុត្ត បើដូច្នោះ អ្នកចូរស្តាប់ចុះ ចូរកំណត់ទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ប្រាប់ ។ សិង្គាលកគហបតិបុត្ត ក៏ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមាន ព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតិបុត្ត អរិយសាវ័ក លះបង់នូវកម្មក្កិ-លេស (អំពើដ៏សៅហ្មង) ៤ ប្រការផង មិនធ្វើនូវបាបកម្ម (អំពើអាក្រក់) ព្រោះហេតុ ៤ យ៉ាងផង មិនសេពនូវអបាយមុខ (គឺប្រធាននៃសេចក្តី វិនាស) នៃភោគៈ ៦ យ៉ាងផង អរិយសាវ័កនោះ លោកវៀរចាកបាបធម៌ ទាំង ១៤ យ៉ាងនេះ ឈ្មោះថាជាអ្នកបិទបាំងទិសទាំង ៦ ប្រតិបត្តិ ដើម្បីជម្នះ ក្នុងលោកទាំងពីរ គឺលោកនេះ ក៏អរិយសាវ័កនោះ បានប្រារព្ធ គឺថា បានពេញចិត្តហើយ លោកខាងមុខ ក៏ពេញចិត្តទៀត ។ លុះអរិយសាវ័ក នោះ ទម្លាយរាងកាយទៅ រមែងកើតក្នុងមនុស្សសុគតិសួគ៌ទេវលោក ។ កម្មក្កិលេស ៤ ប្រការ ដែលអរិយសាវ័កនោះ លះបង់ហើយដូចម្តេច ។ ម្នាលគហបតិបុត្ត ការធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង (សម្លាប់សត្វ) ជា កម្មក្កិលេស ១ ការកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ជាកម្មក្កិលេស ១

កាមេសុ មិច្ឆាចារោ កម្មក្កិលេសោ មុសាវាទោ កម្មក្កិលេសោ ឥមស្ស ចត្តារោ កម្មក្កិលេសា បហីនា ហោន្តីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន(១) សុគតោ អថាបរំ ឯតទវោច សត្ថា

[៤៦] បាណាតិបាតោ អទិន្នាទានំ
មុសាវាទោ បវុច្ចតិ(២)
បរទារគមនញ្ចេវ
ន បសំសន្តិ បណ្ឌិតាតិ ។

[៤៧] កតមេហិ ចតូហិ ឋានេហិ បាបកម្មំ ន ករោតិ ឆន្ទាគតឹ គច្ឆន្តោ បាបកម្មំ ករោតិ ទោសាគតឹ គច្ឆន្តោ បាបកម្មំ ករោតិ មោហាគតឹ គច្ឆន្តោ បាប-កម្មំ ករោតិ ភយាគតឹ គច្ឆន្តោ បាបកម្មំ ករោតិ ។ យតោ ខោ គហបតិបុត្ត អរិយស្សាវកោ នេវ ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ

១ ឱ. វត្វា ឯវំ សព្វត្ថ ។ ២ ឱ. ម. ច វុច្ចតិ ។

ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាកម្មក្កិលេស ១ ការនិយាយពាក្យកុហក ជាកម្មក្កិលេស ១ កម្មក្កិលេស ៤ ប្រការនេះ ដែលអរិយសាវ័កនោះ បានលះបង់ហើយ ។ ព្រះមានព្រះភាគ បានសំដែងពាក្យនេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់សំដែងពាក្យនេះហើយ ទើបសំដែងគាថាព័ន្ធនេះ តទៅទៀតថា

[៤៦] ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយកុ-
ហក ១ សេពគរិយាបុគ្គលដទៃ ១ ហៅថា (កម្មក្កិលេស)
បណ្ឌិតទាំងឡាយ មិនសរសើរឡើយ ។

[៤៧] អរិយសាវ័ក មិនធ្វើនូវបាបកម្ម ព្រោះហេតុ ៤ យ៉ាង ដូចម្តេចខ្លះ បុថុជ្ជនលុះអគតិព្រោះស្រឡាញ់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះស្អប់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះល្ងង់ ក៏ធ្វើបាបកម្ម លុអគតិព្រោះខ្លាច ក៏ធ្វើបាបកម្ម ។ ម្នាលគហបតិបុត្ត អរិយសាវ័ក មិនលុះអគតិព្រោះស្រឡាញ់ មិនលុះអគតិព្រោះស្អប់ មិនលុះអគតិព្រោះល្ងង់

៧១

សិង្គាលកសុត្តេ ឆអបាយមុខកថា

ន ភយាគតឹ គច្ឆតិ ។ ឥមេហិ ចតូហិ ឋានេហិ បាបកម្មំ ន ករោតីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[៣៨] ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ អតិវត្តតិ
និហីយតិ តស្ស យសោ
កាឡបក្ខេវ ចន្ទិមា ។
ឆន្ទា ទោសា ភយា មោហា
យោ ធម្មំ នាតិវត្តតិ
អាបូរតិ តស្ស យសោ
សុក្កបក្ខេវ ចន្ទិមាតិ ។

[៤៩] កតមានិ ច ភោគានំ អបាយមុខានិ ន សេវតិ ។ សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគោ ខោ គហបតិបុត្ត ភោគានំ អបាយមុខំ

មិនលុះអគតិព្រោះខ្លាច ព្រោះហេតុទាំង ៤ ណា ។ អរិយសាវ័កនោះ ឈ្មោះថា មិនធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាងនេះ ។ ព្រះមានព្រះភាគ បានសំដែងពាក្យនេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់សំដែងពាក្យ នេះហើយ ទើបសំដែងគាថាព័ន្ធនេះ តទៅទៀតថា

[៤៨] អ្នកណា ប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះសេចក្តីវង្វេង យសរបស់អ្នកនោះ រមែងសាបសូន្យទៅ ដូចព្រះចន្ទខាង រនោច ។ អ្នកណា មិនប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តី ស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះ សេចក្តីវង្វេង យសរបស់អ្នកនោះ រមែងពេញបរិបូណ៌ ដូចព្រះចន្ទខាងខ្នើត ។

[៤៩] អរិយសាវ័ក មិនសេពនូវធម៌ ជាប្រធាននៃសេចក្តី វិនាសភោគៈ ៦ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលគហបតិបុត្ត កិរិយា ប្រកបរឿយ ៗ នូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជា ហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ជាប្រធាននៃសេចក្តីវិនាសភោគៈ ១

វិកាលវិសិខាចរិយានុយោគោ ភោគានំ អបាយមុខំ សមជ្ជាភិចរណំ ភោគានំ អបាយមុខំ ជូតប្បមាទដ្ឋានានុយោគោ ភោគានំ អបាយមុខំ បាបមិត្តានុយោគោ ភោគានំ អបាយមុខំ អាលស្សានុយោគោ ភោគានំ អបាយមុខំ ។

[៥០] ឆ ខោ មេ គហបតិបុត្ត អាទីនវា សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគេ សន្ទិដ្ឋិកា ធនជានិ[១] កលហប្បវឌ្ឍនី រោគានំ អាយតនំ អកិត្តិសញ្ជននី ហិរិកោបិននិទំសនី[២] បញ្ញាយ ទុព្វលីករណី ត្វេវ ឆដ្ឋំ បទំ[៣] ភវតិ ។ ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគេ ។

[៥១] ឆ ខោ មេ គហបតិបុត្ត អាទីនវា វិកាលវិសិខាចរិយានុយោគេ អត្តាបិស្ស អគុត្តោ អរក្ខិតោ ហោតិ បុត្តទារោបិស្ស អគុត្តោ អរក្ខិតោ ហោតិ

១ ឱ. ធនញ្ជានិ ។ ២ ឱ. កោបីននិទំសនី ។ ម. កោបិននិទំសនី ។ ៣ ម. ឆដ្ឋបទំ ។

បានប្រកបរឿយ ៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ជាប្រធាន នៃសេចក្តីវិនាសភោគៈ ១ ការដើរមើលមហោស្រពជាប្រធាន នៃសេចក្តីវិនាសភោគៈ ១ ការប្រកបរឿយ ៗ នូវហេតុជាទីតាំង នៃសេចក្តីប្រមាទ គឺលេងល្បែងភ្នាល់ ជាប្រធាន នៃសេចក្តីវិនាសភោគៈ ១ ការសេពគប់នូវបាបមិត្ត ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ការប្រកបរឿយ ៗ នូវសេចក្តីខ្ជិល ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។

[៥០] ម្នាលគហបតិបុត្ត ទោសក្នុងកិរិយាប្រកបរឿយ ៗ នូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទនេះមាន ៦ យ៉ាង គឺវិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង ១ ការកឱ្យកើតជម្លោះ ១ ហេតុនាំឲ្យកើតរោគទាំងឡាយ ១ ការនាំឲ្យខូចឈ្មោះ ១ ការបង្ហាញកេរ្តិ៍ខ្មាស ១ ហេតុជាគម្រប់ ៦ គឺធ្វើបញ្ញាឲ្យមានកម្លាំងថយ ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំង នៃសេចក្តីប្រមាទមាន ៦ យ៉ាងនេះឯង ។

[៥១] ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវការដើរទៅតាមច្រកល្ហកខុសកាលនេះមាន ៦ យ៉ាង គឺអ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាខ្លួន ១ អ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាកូនប្រពន្ធ ១

សិង្គាលកសុត្តេ ឆអបាយមុខកថា

សាបតេយ្យំបិស្ស អគុត្តំ អរក្ខិតំ ហោតិ សង្កិយោ ច ហោតិ តេសុ តេសុ ឋានេសុ អភូតវចនញ្ច តស្មឹ រូហតិ ពហូនញ្ច ទុក្ខធម្មានំ បុរក្ខិតោ[១] ហោតិ ។ ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា វិកាលវិសិខាចរិយានុយោគេ ។

[៤២] ឆ ខោ មេ គហបតិបុត្ត អាទីនវា សមជ្ជាភិចរណេ ក្វ[២] នច្ចំ ក្វ[៣] គីតំ ក្វ[៤] វាទិតំ ក្វ[៥] អក្ខាតំ[៦] ក្វ ចាណិស្សរំ ក្វ កុម្ភថូនន្តិ ។ ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា សមជ្ជាភិចរណេ ។

---

១ ឱ. បុរក្ខតោ ។ ២-៣-៤-៥ ឱ. កុវំ ។ ៦ ឱ. ម. អក្ខានំ ។

សិង្គាលកសូត្រ ពោលអំពីអបាយមុខ ៦ យ៉ាង

អ្នកនោះឈ្មោះថា មិនគ្រប់គ្រង មិនរក្សាទ្រព្យសម្បត្តិ ១ សេចក្ដីរង្កៀស តែងកើតមានក្នុងកន្លែង (ដែលខ្លួនទៅដល់) នោះ ៗ ១ ពាក្យមិនពិត តែងធ្លាក់មកត្រូវលើបុគ្គលនោះ[១] ១ បុគ្គលនោះឈ្មោះថា បំពេញនូវធម៌ជាទុក្ខច្រើន ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវកិរិយាត្រាច់ទៅតាមច្រកល្ហកខុសកាលមាន ៦ យ៉ាងនេះឯង ។

[៥២] ម្នាលគហបតិបុត្ត ទោសក្នុងការដើរ មើលល្បែងមហោស្រពនេះ ៦ យ៉ាង គឺរបាំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ការប្រគំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ គេប្រជុំនិយាយរឿងព្រេង ឥតប្រយោជន៍ (មានរឿងចម្បាំងនៃមហាភារតៈ និងរឿងនាងសិតាជាដើម) ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ល្បែងវាយគង[២]ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ល្បែងវាយរនាតក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងកិរិយាដើរមើលល្បែងមហោស្រពមាន ៦ យ៉ាងនេះឯង ។

---

១ រមែងត្រូវគេចោទបង្កាច់ក្នុងអំពើដែលខ្លួនមិនបានធ្វើសោះ ព្រោះជាន់ដានចោរ ។
២ បើតាមព្យញ្ជនៈគួរប្រែថា ល្បែងលេងទះទៃ គឺច្រៀងប្របកែ ។

[៩៣] ឆ ខោ មេ គហបតិបុត្ត អាទីនវា ជូតប្បមាទដ្ឋានានុយោគេ ជយំ វេរំ បសវតិ ជិនោ វិត្តមនុសោចតិ[១] សន្ទិដ្ឋិកា ធនជានិ[២] សភាគតស្ស វចនំ ន រូហតិ មិត្តាមច្ចានំ បរិភូតោ ហោតិ អាវាហវិវាហកានំ អប្បត្ថិតោ ហោតិ អក្ខធុត្តោ បុរិសបុគ្គលោ នាលំ ទារភរណាយាតិ[៣] ។ ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា ជូតប្បមាទដ្ឋានានុយោគេ ។

[៩៤] ឆ ខោ មេ គហបតិបុត្ត អាទីនវា បាបមិត្តានុយោគេ យេ ធុត្តា យេ សោណ្ឌា យេ បិបាសា យេ នេកតិកា យេ វញ្ចនិកា យេ សាហសិកា ត្យាស្ស មិត្តា ហោន្តិ តេ សហាយា ។ ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា បាបមិត្តានុយោគេ ។

---

១ ឱ. ចិត្តមនុសោចតិ ។ ២ ឱ. ធនញ្ជានិ ។ ៣ ឱ. ទារាភរណាយាតិ ។

[៥៣] ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ នេះមាន ៦ យ៉ាង គឺបុគ្គលនោះ បើឈ្នះគេ តែងបានពៀរ ១ បើចាញ់គេ តែងសោកស្តាយទ្រព្យសម្បត្តិ ១ វិនាសទ្រព្យសម្បត្តិ ដែលឃើញជាក់ស្តែងទាន់ភ្នែក ១ កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ ១ ពួកមិត្តអាមាត្យ តែងបោះបង់ចោល ១ ជាបុគ្គលដែលគេមិនត្រូវការដណ្តឹង ឬឲ្យកូនស្រី ព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់ មិនអាចចិញ្ចឹមប្រពន្ធបានទេ ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំង នៃសេចក្តីប្រមាទមាន ៦ យ៉ាងនេះឯង ។

[៥៤] ម្នាលគហបតិបុត្ត ទោសក្នុងការសេពគប់ នូវបាបមិត្តនេះមាន ៦ យ៉ាង គឺពួកជនដែលជាអ្នកលេងល្បែងភ្នាល់ ១ ជនដែលជាអ្នកលេង[១]ស្រី ១ ជនដែលជាអ្នកលេងផឹកសុរា ១ ជនដែលជាអ្នកបោកប្រាសបញ្ឆោតអ្នកដទៃ ដោយរបស់ក្លែង ១ ជនដែលជាអ្នកបំបាត់ប្រវញ្ចន៍អ្នកដទៃ ក្នុងទីចំពោះមុខ ១ ជនដែលជាអ្នកឆក់ដណ្តើមទ្រព្យអ្នកដទៃ ១ ជនទាំងនោះជាមិត្តជាសំឡាញ់របស់ជននោះ ។ ម្នាលគហបតិបុត្ត ទោសក្នុងការសេពគប់នូវបាបមិត្ត មាន ៦ យ៉ាងនេះឯង ។

---

១ អ្នកលេងមាន ៤ យ៉ាង គឺអ្នកលេងស្រី ១ អ្នកលេងភត្ត ១ អ្នកលេងផឹកស្រា ១ អ្នកលេងមើមឈើ មានស៊ីមើមដំឡូងជាដើម ១ ។

៧៤

### សិង្គាលកសុត្តេ ឆអបាយមុខកថា

[៤៤] ឆ ខោ មេ គហបតិបុត្ត អាទីនវា អាលស្សានុយោគេ អតិសីតន្តិ កម្មំ ន ករោតិ អតិឧណ្ហន្តិ កម្មំ ន ករោតិ អតិសាយន្តិ កម្មំ ន ករោតិ អតិបាតោតិ កម្មំ ន ករោតិ អតិច្ឆាតោស្មីតិ កម្មំ ន ករោតិ អតិបិបាសិតោស្មីតិ កម្មំ ន ករោតិ តស្ស ឯវំ កិច្ចាបទេសពហុលស្ស វិហរតោ អនុប្បន្នា ចេវ ភោគា នុប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ ។ ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា អាលស្សានុយោគេតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[៤៦] ហោតិ បានសខា នាម
ហោតិ សម្មិយសម្មិយោ

សិង្គាលកសូត្រ ពោលអំពីអបាយមុខ ៦ យ៉ាង

[៩៥] ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវសេចក្តីខ្ជិលនេះមាន ៦ យ៉ាងគឺ មិនធ្វើការងារ ដោយអាងថា ត្រជាក់ណាស់ ១ មិនធ្វើការងារ ដោយអាងថា ក្តៅណាស់ ១ មិនធ្វើការងារដោយអាងថា ល្ងាចណាស់ ១ មិនធ្វើការងារដោយអាងថា ព្រឹកណាស់ ១ មិនធ្វើការ-ងារ ដោយអាងថា ឃ្លានណាស់ ១ មិនធ្វើការងារ ដោយអាងថា ស្រេកណាស់ ១ កាលបើជនអ្នកខ្ជិលច្រអូសនោះ ច្រើនដោយការពោលអាងកិច្ចយ៉ាងនេះ ភោគៈទាំងឡាយដែលមិនទាន់កើត ក៏ខានកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវសេចក្តីរេចរឹលទៅវិញផង ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវសេចក្តីខ្ជិលមាន ៦ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់បានសំដែងធម៌នេះហើយ ព្រះសុគតជាសាស្តា លុះសំដែងធម៌នេះហើយ ទ្រង់សំដែងគាថាព័ន្ធនេះ តទៅទៀតថា

[៩៦] បុគ្គលខ្លះ ជាមិត្តសំឡាញ់បានតែក្នុងរោងសុរាក៏មាន
បុគ្គលខ្លះថា សំឡាញ់ ៗ តែនៅចំពោះមុខក៏មាន បុគ្គលណា

យោ ច អត្ថេសុ ជាតេសុ
សហាយោ ហោតិ សោ សខា ។
ឧស្សូរសេយ្យា បរទារសេវនា
វេរប្បសង្គោ[១] ច អនត្ថតា ច
បាបា ច មិត្តា សុកទរិយតា ច
ឯតេ ឆ ឋានា បុរិសំ ធំសយន្តិ ។
បាបមិត្តោ បាបសខោ
បាបអាចារគោចរោ[២]
អស្មា លោកា បរម្ហា ច
ឧភយា ធំសតេ នរោ ។
អក្ខិត្ថិយោ វារុណី នច្ចគីតំ
ទិវាសោប្បំ បារិចរិយា អកាលេ
បាបា ច មិត្តា សុកទរិយតា ច
ឯតេ ឆ ឋានា បុរិសំ ធំសយន្តិ ។

---

១ ម. វេរប្បសគោ ។ ២ ឱ. បាបាចារគោចរោ ។

កាលបើប្រយោជន៍ (ខ្លួន) កើតឡើង ទើបធ្វើជាសំឡាញ់ បុគ្គលនោះមកជាសំឡាញ់នឹងខ្លួនក៏មាន ។ កិរិយាដេកដល់ថ្ងៃ ១ ធ្វើសេវនកិច្ចនឹងប្រពន្ធអ្នកដទៃ ១ ភាវៈជាអ្នកមានពៀរច្រើន ១ ភាវៈជាអ្នកធ្វើអំពើឥតប្រយោជន៍ ១ បាបមិត្ត ១ ភាវៈជាអ្នកកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នុ៎ះ រមែងបំផ្លាញបុរស (ឲ្យវិនាស) ។ នរជនដែលមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ មានមារយាទនិងគោចរអាក្រក់ តែងវិនាសចាកលោកទាំងពីរ គឺលោកនេះ និងលោកខាងមុខ ។ ល្បែងភ្នាល់ ល្បែងស្រី និងល្បែងសុរា ១ របាំនិងចម្រៀង ១ ការដេកថ្ងៃ ១ ការឲ្យគេបម្រើខ្លួនក្នុងកាលមិនគួរ ១ ពួកមិត្តអាក្រក់ ១ ភាវៈជាអ្នកមានសេចក្ដីកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នេះតែងបំផ្លាញបុរសឲ្យវិនាស ។

## ៧៧

សិង្គាលកសុត្តេ ឆ អបាយមុខកថា

អក្ខេហិ ទិព្វន្តិ សុរំ បិវន្តិ
យន្តិត្ថិយោ បាណសមា បរេសំ
និហីនសេវី ន ច វុឌ្ឍិសេវី(១)
និហីយតិ កាឡបក្ខេវ ចន្ទិមា(២) ។
យោ វារុណិ(៣) អទនោ អកិច្ចនោ(៤)
បិបាសោសិ អត្ថបាគតោ(៥)
ឧទកមិវ ឥណំ វិគាហតិ
អាកុលំ កាហតិ(៦) ខិប្បមត្តនោ ។
ន ទិវាសុប្បសីលេន
រត្តិនុដ្ឋានទេស្សិនា(៧)
និច្ចំ មត្តេន សោណ្ឌេន
សក្កា អាវសិតុំ ឃរំ ។
អតិសីតំ អតិឧណ្ហំ
អតិសាយមិទំ អហុ
ឥតិ វិស្សដ្ឋកម្មន្តេ(៨)

១ ឱ. វុទ្ធសេវី ។ ម. ពុទ្ធិសេវី ។ ២ ឱ. ម. ចន្ទោ ។ ៣ ឱ. ម. វារុណី ។ ៤ ឱ. ម. អកិញ្ចនោ ។ ៥ ឱ. បិបាសោ បិពម្បាគតោ ។ ម. បិសមប្បាគតោ ។ ៦ ម. កាហិតិ ។ ៧ ឱ. រត្តិនុដ្ឋានទស្សិនា ។ ម. រត្តិមុដ្ឋានទេស្សិនា ។ ៨ ឱ. វិស្សដ្ឋកម្មន្តោ ។

## សិង្គាលកសូត្រ ពោលអំពីអបាយមុខ ៦ យ៉ាង

ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ចនឹងស្រីដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោកទាប (ខាតលក្ខណ៍) មិនសេពគប់នឹងបុគ្គលដែលមានសេចក្តីចម្រើន (គ្រប់លក្ខណ៍) យសរបស់ពួកជននោះតែងសាបសូន្យដូចព្រះចន្ទខាងរនោច ។ ជនដែលជាអ្នកផឹកសុរា ជាអ្នកខ្សត់ទ្រព្យ ជាអ្នកឥតមានកន្លល់ដោយការផឹករបិញ្ចឹមជីវិតមានតែស្រវឹងជានិច្ច ប្រាសចាកសេចក្តីចម្រើន លិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះទៅក្នុងទឹក បុគ្គលនោះ តែងធ្វើការផឹកឲ្យវឹកវរដល់ខ្លួនដោយឆាប់ ។ បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នលលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមនុស្សដែលលះបង់ចោលនូវការផឹក ដោយពោលអាងថា វេលានេះ

អត្ថា អច្ចេន្តិ មាណវេ ។
យោ ច សីតញ្ច ឧណ្ហញ្ច
តិណា ភិយ្យោ ន មញ្ញតិ
ករំ បុរិសកិច្ចានិ
សោ សុខា ន វិហាយតីតិ ។

[៤៧] ចត្តារោមេ គហបតិបុត្ត អមិត្តា មិត្តប្បដិរូបកា វេទិតព្វា អញ្ញទត្ថុហារោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អនុប្បិយភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ។

[៤៨] ចតូហិ ខោ គហបតិបុត្ត ឋានេហិ អញ្ញទត្ថុហារោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អញ្ញទត្ថុហារោ ហោតិ អប្បេន ពហុមិច្ឆតិ ភយស្ស កិច្ចំ ន[១] ករោតិ

១ ឱ. ម. នសទ្ទោ ន ទិស្សតិ ។

ត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ ។ ជនណា មួយធ្វើនូវកិច្ចការ របស់បុរស មិនអើពើនូវត្រជាក់និងក្តៅ ក្រៃលែងជាងស្មៅ (ទៅទៀត) ជននោះ រមែងមិនសាបសូន្យ ចាកសេចក្តីសុខឡើយ ។

[៩៧] ម្នាលគហបតិបុត្ត អ្នកត្រូវស្គាល់ពួកមនុស្ស ដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ៤ ពួកនេះគឺ អ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួនថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ អ្នកត្រូវស្គាល់មនុស្សល្អតែសំដីថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ អ្នកត្រូវស្គាល់មនុស្ស ដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្តថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ អ្នកត្រូវស្គាល់មនុស្សជាសំឡាញ់ ក្នុងការវិនាសភោគៈទាំងឡាយថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ ។

[៩៨] ម្នាលគហបតិបុត្ត មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម (នោះ) អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺមិត្តគិតយកតែប្រយោជន៍ខ្លួន ១ មិត្តប្រាថ្នាយករបស់ច្រើនដោយ (ឲ្យ) របស់តិចតួច ១ ទាល់តែមានភ័យទើបជួយធ្វើកិច្ចរបស់មិត្ត ១

សេវតិ អត្ថការណា ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ខោ ឋានេហិ អញ្ញទត្ថុហារោ អមិត្តោ មិត្តប្បដិ-រូបកោ វេទិតព្វោ ។

[៥៩] ចតូហិ ខោ គហបតិបុត្ត ឋានេហិ វចីបរ-មោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អតីតេន បដិ-សន្ថរតិ អនាគតេន បដិសន្ថរតិ និរត្ថកេន សង្គណ្ហា-តិ បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ។

[៦០] ចតូហិ ខោ គហបតិបុត្ត ឋានេហិ អនុប្បិយ-ភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ចាបកម្មំ បិស្ស[១] អនុជានាតិ កល្យាណំបិស្ស[២] អនុជានាតិ សម្មុខស្ស វណ្ណំ ភាសតិ បរម្មុខស្ស អវណ្ណំ ភាសតិ ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុប្បិ-យភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ។

១ ឱ. បាបកម្បិស្ស ។ ២ ឱ. កល្យាណម្បិស្ស ។

សេពគប់មិត្ត ព្រោះហេតុតែប្រយោជន៍ ១ ។ ម្នាលគហបតិបុត្ត មិត្តគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

[៥៩] ម្នាលគហបតិបុត្ត មិត្តល្អតែសំដី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ គឺមិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ ១ ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក ១ សង្គ្រោះដោយអំពើឥតប្រយោជន៍ ១ កាលកិច្ចទាំងឡាយ កើតឡើងក្វាម ៗ ក៏សំដែងអាងរបស់ខូចខាត[១] ១ ម្នាលគហបតិបុត្ត មិត្តល្អតែសំដី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

[៦០] ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺបើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម ១ មិត្តធ្វើអំពើល្អក៏យល់ព្រមតាម ១ ពណ៌នាគុណមិត្ត តែក្នុងទីចំពោះមុខ ១ ពោលទោសមិត្ត ក្នុងទីកំបាំងមុខ ១ ។ ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

---

១ ពឹងការអ្វីមិនបាន បើត្រូវពឹងរកអ្វី ៗ ក៏ប្រាប់ថា របស់នោះ ខូចនេះបាត់នោះជាដើម ។

[៦១] ចតូហិ ខោ គហបតិបុត្ត ឋានេហិ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ វិកាលវិសិខាចរិយានុយោគេ សហាយោ ហោតិ សមជ្ជាភិចរណោ សហាយោ ហោតិ ជូតប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ[១] ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[៦២] អញ្ញទត្ថុហរោ មិត្តោ
យោ ច មិត្តោ វចីបរមោ
អនុប្បិយញ្ច យោ អាហុ
អបាយេសុ ច យោ សខា
ឯតេ អមិត្តេ ចត្តារោ
ឥតិ វិញ្ញាយ បណ្ឌិតោ

១ ឱ. វេទិតព្វោតិ ។

[៦១] ម្នាលគហបតិបុត្ត មនុស្សជាសំឡាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយ ៗ នូវការផឹកទឹកស្រវឹង គឺសុរាមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ជាសំឡាញ់ក្នុងការប្រកបរឿយ ៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ១ ជាសំឡាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព ១ ជាសំឡាញ់ក្នុងកិរិយាប្រកបរឿយ ៗ នូវល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលគហបតិបុត្ត មនុស្សជាសំឡាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញូម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់បានសំដែងសេចក្តីនេះ លុះព្រះសុគតជាសាស្តាសំដែងសេចក្តីនេះហើយ ទើបទ្រង់សំដែងពាក្យគាថាព័ន្ធ តទៅទៀតថា

[៦២] បុគ្គលដែលជាមិត្ត គិតយកតែប្រយោជន៍ខ្លួន ១
បុគ្គលដែលជាមិត្តល្អតែសំដី ១ បុគ្គលដែលនិយាយចាក់
បណ្តោយឲ្យគាប់ចិត្ត ១ បុគ្គលដែលជាសំឡាញ់ក្នុងផ្លូវ
វិនាស ១ បណ្ឌិតដឹងថា បុគ្គលទាំង ៤ ពួកនុ៎ះ មិនមែនជាមិត្ត

សិង្គាលកសុត្តេ ចត្តារោ មិត្តា សុហទា

### អារកា បរិវជ្ជេយ្យ
### មគ្គំ បដិភយំ យថាតិ ។

[៦៣] ចត្តារោមេ គហបតិបុត្ត មិត្តា សុហទា វេទិតព្វា ឧបការកោ[១] មិត្តោ សុហទោ វេទិតព្វោ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោ ។

[៦៤] ចតូហិ ខោ គហបតិបុត្ត ឋានេហិ ឧបការកោ[២] មិត្តោ សុហទោ វេទិតព្វោ បមត្តំ រក្ខតិ បមត្តស្ស សាបតេយ្យំ រក្ខតិ ភីតស្ស បដិសរណំ[៣] ហោតិ ឧប្បន្នេសុ កិច្ចេសុ ករណីយេសុ[៤] តទ្ទិគុណំ ភោគំ អនុប្បទេតិ[៥] ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ ឧបការកោ មិត្តោ សុហទោ វេទិតព្វោ ។

---

១-២ ឱ. ម. ឧបការោ ។ ៣ ឱ. ម. សរណំ ។ ៤ ឱ. ម. កិច្ចករណីយេសុ ។ ៥ ឱ. អនុប្បាទេតិ ។

ហើយ គប្បីចៀសវាងឲ្យឆ្ងាយ ដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ ។

[៦៣] ម្នាលគហបតិបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថាជាមិត្តមានសន្ដានល្អ គឺមិត្តមានឧបការៈ អ្នកត្រូវដឹងថាជាមិត្តមានសន្ដានល្អ ១ មិនរួមសុខទុក្ខ អ្នកត្រូវដឹងថាជាមិត្តមានសន្ដានល្អ ១ មិនប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថាជាមិត្តមានសន្ដានល្អ ១ មិត្តមានសេចក្ដីឈឺឆ្អាល អ្នកត្រូវដឹងថាជាមិត្តមានសន្ដានល្អ ១ ។

[៦៤] ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ រក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្ដីភិតភ័យ ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្ដល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ។ ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

[៦៥] ចតូហិ ខោ គហបតិបុត្ត ឋានេហិ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ គុយ្ហមស្ស អាចិក្ខតិ គុយ្ហមស្ស បរិគុយ្ហតិ អាបទាសុ ន វិជហតិ ជីវិតំបិស្ស អត្ថាយ បរិច្ចត្តំ ហោតិ ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ ។

[៦៦] ចតូហិ ខោ គហបតិបុត្ត ឋានេហិ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ បាបា និវារេតិ កល្យាណេ និវេសេតិ អស្សុតំ សាវេតិ សគ្គស្ស មគ្គំ អាចិក្ខតិ ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ ។

[៦៧] ចតូហិ ខោ គហបតិបុត្ត ឋានេហិ អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោ អភវេនស្ស ន នន្ទតិ ភវេនស្ស នន្ទតិ អវណ្ណំ ភណមានំ និវារេតិ វណ្ណំ ភណមានំ បសំសតិ ។ ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុកម្បកោ

[៦៥] ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នា ក្នុងគ្រាមានវិបត្តិ ១ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្ត (ស៊ូប្តូរជីវិត) ១ ។ ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

[៦៦] ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ ហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវឋានសួគ៌ ១ ។ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

[៦៧] ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺ ជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរព្រោះមិត្តបានសេចក្តីចម្រើន ១ ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត ១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ។ ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមាន

៨៣

សិង្គាលកសុត្តេ និគមគាថា

មិត្តោ សុហទោ វេទិតព្វាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[៦៨] ឧបការោ ច យោ មិត្តោ
សុខទុក្ខោ ច យោ សខា
អត្ថក្ខាយី ច យោ មិត្តោ
យោ ច មិត្តានុកម្បកោ ។
ឯតេបិ មិត្តេ ចត្តារោ
ឥតិ វិញ្ញាយ បណ្ឌិតោ
សក្កច្ចំ បយិរុបាសេយ្យ
មាតា បុត្តំវ ឱរសំ ។
បណ្ឌិតោ សីលសម្បន្នោ
ជលំ អគ្គីវ ភាសតិ

ភោគេ សំហរមានស្ស ភមរស្សេវ ឥរីយតោ ។
ភោគា សន្និចយំ យន្តិ វម្មិកោវុបចីយតិ
ឯវំ ភោគេ សមាហរិត្វា[១] អលមត្តោ កុលេ គិហី ។
ចតុធា វិភជេ ភោគេ ស វេ មិត្តានិ គន្ថតិ
ឯកេន ភោគេ កុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ

១ ឱ. ម. សមាហន្ត្វា ។

សន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់បានសំដែងសេចក្តីនេះ លុះព្រះសុគតជាសាស្តា ត្រាស់សេចក្តីនេះហើយ ទើបទ្រង់សំដែងពាក្យជាគាថាព័ន្ធ តទៅទៀតថា

[៦៨] មិត្តដែលមានឧបការៈ សំឡាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្តីឈឺឆ្អាល បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះថា ជាមិត្តមែនទែន ហើយគប្បីចូលទៅអង្គុយជិតស្និទ្ធស្នាល ដូចជាមាតានិងបុត្តដែលកើតពីទ្រូង ។ អ្នកប្រាជ្ញបរិបូណ៌ដោយសីល តែងរុងរឿងដូចជាភ្លើងដែលភ្លឺដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរដូចជាឃ្មុំដូច្នោះឯង ។ ភោគៈទាំងឡាយតែងដល់នូវការពូនជាគំនរ ដូចជាដំបូកដែលកណ្តៀរ-កពូនដូច្នោះឯង គ្រហស្ថក្នុងត្រកូល បានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាច (តាំងខ្លួន) ។ កុលបុត្រដែលចែកភោគៈទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារពីរចំណែក ទាំងតម្កល់ទុកនូវ

ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតីតិ ។

[៦៩] កថញ្ច គហបតិបុត្ត អរិយសាវកោ ឆទ្ទិសាបដិច្ឆាទី ហោតិ ។ ឆ ឥមា(១) គហបតិបុត្ត ទិសា វេទិតព្វា បុរត្ថិមា ទិសា មាតាបិតរោ វេទិតព្វា ទក្ខិណា ទិសា អាចរិយា វេទិតព្វា បច្ឆិមា ទិសា បុត្តទារា វេទិតព្វា ឧត្តរា ទិសា មិត្តាមច្ចា វេទិតព្វា ហេដ្ឋា(២) ទិសា ទាសកម្មករា(៣) វេទិតព្វា ឧបរិមា ទិសា សមណព្រាហ្មណា វេទិតព្វា ។

[៧០] បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុបដ្ឋាតព្វា ភតោ នេសំ ភរិស្សាមិ

---

១ ឱ. ឆ យិមា ។ ២ ឱ. ម. ហេដ្ឋិមា ។ ៣ ឱ. ទាសកម្មករា បោរិសា ។

ចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ (ទៅខាងមុខ) កុលបុត្រនោះទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន[១] ។

[៦៩] ម្នាលគហបតិបុត្ត អរិយសាវ័ក បិទបាំងទិសទាំង ៦ ដូចម្តេច ។ ម្នាលគហបតិបុត្ត អ្នកត្រូវដឹងទិសទាំង ៦ ដូច្នេះគឺ មាតាបិតា អ្នកត្រូវដឹងថា ទិសខាងកើត ១ អាចារ្យ អ្នកត្រូវដឹងថា ទិសខាងត្បូង ១ កូននិងប្រពន្ធ អ្នកត្រូវដឹងថា ទិសខាងលិច ១ មិត្តអាមាត្យ អ្នកត្រូវដឹងថា ទិសខាងជើង ១ ទាសៈនិងកម្មករ[២] អ្នកត្រូវដឹងថា ទិសខាងក្រោម ១ សមណព្រាហ្មណ៍ អ្នកត្រូវដឹងថា ទិសខាងលើ ១ ។

[៧០] ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបំរុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺកូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១

១ ចំណែកទីមួយបរិភោគប្រើប្រាស់ចាយវាយ ចំណែកទី ២ ទី ៣ ប្រកបការងារ គឺប្រកបកសិកម្មនិងពាណិជ្ជកម្មផ្សេង ៗ ចំណែកជាគម្រប់ ៤ ទុកសម្រាប់ការពារអន្តរាយផ្សេង ៗ មានអន្តរាយអំពីស្តេចជាដើម ។ ម្យ៉ាងទៀត ឲ្យរំលែកអំពីចំណែកទាំង ៤ នោះធ្វើកុសលឬឲ្យជាថ្លៃគ្រឿងស្លៀកពាក់ និងឈ្នួលកោរកាត់ (អដ្ឋកថា) ។ ២ ខ្ញុំកំដរនិងអ្នកធ្វើការស៊ីឈ្នួល ។

កិច្ចំ នេសំ ករិស្សាមិ កុលវំសំ ឋបេស្សាមិ ទាយជ្ជំ បដិបជ្ជាមិ អថវា បន[១] បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមីតិ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុបដ្ឋិតា បញ្ចហិ ខោ[២] ឋានេហិ បុត្តំ អនុកម្បន្តិ បាបា និវារេន្តិ កល្យាណេ និវេសេន្តិ សិប្បំ សិក្ខាបេន្តិ បដិរូបេន ទារេន សញ្ញោជេន្តិ សមយេ ទាយជ្ជំ និយ្យាទេន្តិ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ បុត្តំ អនុកម្បន្តិ ឯវមស្ស ឯសា បុរត្ថិមា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ។

[៧១] បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ អន្តេវាសិនា ទក្ខិណា ទិសា អាចរិយា បច្ចុបដ្ឋាតព្វា ឧដ្ឋានេន ឧបដ្ឋានេន សុស្សុសាយ[៣] ចារិចរិយាយ

---

១ ឱ. អថ ច បន ។ ២ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។ ៣ ឱ. សុស្សូសាយ ។

នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូន ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្ដឹងករិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុង ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាងនេះ ទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេមឥតមានភយន្តរាយយ៉ាងនេះ ។

[៧១] ម្នាលគហបតិបុត្ត អាចារ្យជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងគឺ ដោយការក្រោកឡើងទទួល ១ ដោយការគាល់បម្រើ ១ ដោយការជឿស្ដាប់ឱវាទ ១ ដោយការបម្រើតូច ៗ

សក្កច្ចំ សិប្បំ បដិគ្គហណេន ។ ឥមេហិ ខោ គហ-បតិបុត្ត បញ្ចហិ ឋានេហិ អន្តេវាសិនា ទក្ខិណា ទិ-សា អាចរិយា បច្ចុបដ្ឋិតា បញ្ចហិ ឋានេហិ អន្តេវាសឹ អនុកម្បន្តិ សុវិនីតំ វិនេន្តិ សុគ្គហិតំ គាហាបេន្តិ សព្វសិប្បេសុ តំ សមក្ខាយិនោ ភវន្តិ មិត្តាមច្ចេសុ បដិវេទេន្តិ(១) ទិសាសុ បរិត្តាណំ ករោន្តិ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ អន្តេវាសិនា ទក្ខិណា ទិសា អាចរិយា បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ អន្តេវាសឹ អនុកម្បន្តិ ឯវមស្ស ឯសា ទក្ខិ-ណា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ។

[៧២] បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ សាមិកេន បច្ឆិមា ទិសា ភរិយា បច្ចុបដ្ឋាតព្វា សម្មាននាយ អវិមាននាយ(២) អនតិចរិយាយ ឥស្សរិយវោស្សគ្គេន អលង្ការានុប្បទានេន ។

១ ឱ. បរិវេទេន្តិ ។ ម. បដិយោទេន្តិ ។ ២ ឱ. អនវមាននាយ ។

(មានឲ្យទឹកលុបមុខនិងឈើស្ទន់ជាដើម) ១ ដោយការរៀនសិល្បសាស្ត្រ ដោយគោរព ១ ។ ម្នាលគហបតិបុត្ត អាចារ្យជាទិសខាងត្បូង ដែលសិស្សប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្ស ដោយស្ថាន ៥ យ៉ាងវិញ គឺដឹកនាំល្អ ១ ឲ្យរៀនល្អ ១ ប្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់ ១ តែងលើកតំកើងក្នុងទីប្រជុំមិត្តអាមាត្យ ១ ធ្វើសេចក្ដីការពារក្នុងទិសទាំងឡាយ ១ ។ ម្នាលគហបតិបុត្ត ពួកអាចារ្យជាទិសខាងត្បូង ដែលសិស្សប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងនេះ ទិសខាងត្បូងនោះ ដែលសិស្សបានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[៧២] ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាង គឺ ដោយការរាប់អានជាភរិយាពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឲ្យជាធំ (ក្នុងការផ្ទះ) ១ ដោយការឲ្យគ្រឿងតែងខ្លួន ១ ។

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ សាមិ-កេន បច្ឆិមា ទិសា ភរិយា បច្ចុបដ្ឋិតា បញ្ចហិ ឋានេហិ សាមិកំ អនុកម្បន្តិ សុសំវិហិតកម្មន្តា ច ហោតិ សុសង្គហិតបរិជនា ច អនតិចារិនី ច សម្ភតញ្ច[១] អនុរក្ខតិ ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ សាមិកេន បច្ឆិមា ទិសា ភរិយា បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ សាមិកំ អនុកម្បន្តិ ឯវមស្ស ឯសា បច្ឆិមា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ។

[៧៣] បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ កុលបុត្តេន ឧត្តរា ទិសា មិត្តាមច្ចា បច្ចុ-បដ្ឋាតព្វា ទានេន បិយវជ្ជេន អត្ថចរិយាយ

១ ឱ. សម្ភតំ ។ ម. សម្ភតំ ច ។

សិង្គាលកសូត្រ ទិសទាំង ៦ និយាយអំពីទិសខាងជើង

ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺចាត់ចែងការងារដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១ មិនប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១ ឈ្លាសមិនខ្ជិលច្រអូស ក្នុងកិច្ចការសព្វគ្រប់ ១ ។ ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាងនេះ ទិសខាងលិចនោះ ដែលស្វាមីបិទបាំងហើយ ជាទិសមានសេចក្តីក្សេមឥតមានភយន្តរាយយ៉ាងនេះ ។

[៧៣] ម្នាលគហបតិបុត្ត មិត្តអាមាត្យជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការឲ្យរបស់ ១ ដោយការនិយាយតែពាក្យគាប់ចិត្ត ១ ដោយការប្រព្រឹត្ត ឲ្យជាប្រយោជន៍ ១

សមានត្តតាយ អវិសំវាទនតាយ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ កុលបុត្តេន ឧត្តរា ទិសា មិត្តាមច្ចា បច្ចុបដ្ឋិតា បញ្ចហិ ឋានេហិ កុលបុត្តំ អនុកម្បន្តិ បមត្តំ រក្ខន្តិ បមត្តស្ស សាបតេយ្យំ រក្ខន្តិ ភីតស្ស សរណំ ហោន្តិ អាបទាសុ ន វិជហន្តិ អបរបជំបិស្ស[១] បដិបូជេន្តិ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ កុលបុត្តេន ឧត្តរា ទិសា មិត្តាមច្ចា បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ កុលបុត្តំ អនុកម្បន្តិ ឯវមស្ស ឯសា ឧត្តរា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ។

[៧៤] បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ អយិរកេន ហេដ្ឋិមា ទិសា ទាសកម្មករា បច្ចុបដ្ឋាតព្វា យថាពលំ កម្មន្តំ សំវិធានេន[២] ភត្តវេត្តនានុប្បទានេន

---

១ ឱ. អបរបជំ ច បិស្ស ។ ម. អបរបជាចស្ស ។ ២ ឱ. ម. កម្មន្តសំវិធានេន ។

ដោយការប្រព្រឹត្តខ្លួនស្មើ ១ ដោយការមិនកុហកបញ្ឆោត ១ ។ ម្នាលគហបតិបុត្ត មិត្តអាមាត្យជាទិសខាងជើង ដែលកុលបុត្តប្រតិបត្តិដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាង គឺ រក្សាមិត្តដែលធ្វេសប្រហែស ១ ជួយថែទាំទ្រព្យសម្បត្តិ របស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងរបស់មិត្តដែលមានភ័យ ១ មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ ១ រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ១ ។ ម្នាលគហបតិ-បុត្ត មិត្តអាមាត្យជាទិសខាងជើង ដែលកុលបុត្តប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៥ យ៉ាងនេះ ទិសខាងជើងនុ៎ះ ដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[៧៤] ម្នាលគហបតិបុត្ត ទាសៈនិងកម្មករ ជាទិសខាងក្រោម ចៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាង គឺ ដោយការចាត់ចែងការងារសមគួរតាមកម្លាំង ១ ដោយការឲ្យនូវភត្តាហារនិងថ្លៃឈ្នួល ១

តិលានុបដ្ឋានេន អច្ឆរិយានំ រសានំ សំវិភាគេន សម-
យេ វោស្សគ្គេន ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ
ឋានេហិ អយិរកេន ហេដ្ឋិមា ទិសា ទាសកម្មករា
បច្ចុបដ្ឋិតា បញ្ចហិ ឋានេហិ អយិរកំ អនុកម្បន្តិ
បុព្វុដ្ឋាយិនោ ច ហោន្តិ បច្ឆានិបាតិនោ ច ទិន្នាទាយិ-
នោ[១] ច សុកតកម្មករា ច កិត្តិវណ្ណហរា ច ។ ឥមេ-
ហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ អយិរកេន
ហេដ្ឋិមា ទិសា ទាសកម្មករា បច្ចុបដ្ឋិតា ឥមេហិ
បញ្ចហិ ឋានេហិ អយិរកំ អនុកម្បន្តិ ឯវមស្ស ឯសា
ហេដ្ឋិមា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ។

[៧៨] បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ
កុលបុត្តេន ឧបរិមា ទិសា សមណព្រាហ្មណា
បច្ចុបដ្ឋាតព្វា មេត្តេន កាយកម្មេន មេត្តេន វចី-
កម្មេន មេត្តេន មនោកម្មេន អនាវដទ្វារតាយ
អាមិសានុប្បទានេន ។ ឥមេហិ ខោ គហបតិបុត្ត

១ ឱ. ទិន្នទាយិនោ ។

ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់ ១ ដោយការចែករំលែកនូវរបស់មានរសត្រកាលចំឡែក ១ ដោយការឲ្យឈប់សម្រាកក្នុងសម័យគួរ ១ ។ ម្នាលគហបតិបុត្ត ទាសៈនិងកម្មករជាទិសខាងក្រោម ដែលចៅហ្វាយនាយទំនុកបម្រុងដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះចៅហ្វាយនាយដោយស្ថាន ៥ យ៉ាង គឺក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ ១ ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ ១ កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ ១ ធ្វើការងាររបស់ចៅហ្វាយនាយ ដោយយកចិត្តទុកដាក់ ១ នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅថ្លែងក្នុងទីនោះ ៗ ១ ។ ម្នាលគហបតិ-បុត្ត ទាសៈនិងកម្មករជាទិសខាងក្រោម ដែលចៅហ្វាយនាយទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះចៅហ្វាយនាយដោយស្ថាន ៥ យ៉ាងនេះ ទិសខាងក្រោមនុ៎ះ ដែលចៅហ្វាយនាយបានបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[៧៥] ម្នាលគហបតិបុត្ត សមណព្រាហ្មណ៍ជាទិសខាងលើ កុល-បុត្តត្រូវផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាង គឺដោយកាយកម្មប្រកបដោយមេត្តា ១ ដោយវចីកម្មប្រកបដោយមេត្តា ១ ដោយមនោកម្មប្រកបដោយមេត្តា ១ ជាអ្នកមិនបិទទ្វារ[១]ផ្ទះ ១ ដោយកិរិយាឲ្យអាមិសទាន ១ ។ ម្នាលគហបតិបុត្ត

១ អដ្ឋកថា ថា ទ្វារផ្ទះបើកទាំងអស់ក្ដី បិទទាំងអស់ក្ដី បើមិនឲ្យអ្វី ឬធ្វើល្អ អ្វីដល់អ្នកមានសីលសោះក៏ឈ្មោះថាបិទទ្វារផ្ទះដែរ បើឲ្យឬធ្វើល្អអ្វីដល់អ្នកមានសីល ក៏ឈ្មោះថាបើកហើយ ។

បញ្ចហិ ឋានេហិ កុលបុត្តេន ឧបរិមា ទិសា សមណព្រាហ្មណា បច្ចុបដ្ឋិតា ឆហិ ឋានេហិ កុលបុត្តំ អនុកម្បន្តិ បាបា និវារេន្តិ កល្យាណេ និវេសេន្តិ កល្យាណេន មនសា[១] អនុកម្បន្តិ អស្សុតំ សាវេន្តិ សុតំ បរិយោទបេន្តិ សគ្គស្ស មគ្គំ អាចិក្ខន្តិ ។ ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ កុលបុត្តេន ឧបរិមា ទិសា សមណព្រាហ្មណា បច្ចុបដ្ឋិតា ឥមេហិ ឆហិ ឋានេហិ កុលបុត្តំ អនុកម្បន្តិ ឯវមស្ស ឯសា ឧបរិមា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[៧៦] មាតាបិតា ទិសា បុព្វា
អាចរិយា ទក្ខិណា ទិសា
បុត្តទារា ទិសា បច្ឆា
មិត្តាមច្ចា ច ឧត្តរា

---

១ ឱ. កល្យាណមនសា ។

សមណព្រាហ្មណ៍ជាទិសខាងលើ ដែលកុលបុត្តទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៦ គឺហាមឃាត់កុលបុត្តចាកអំពើអាក្រក់ ១ ឲ្យតាំងនៅតែក្នុងអំពើល្អ ១ អនុគ្រោះដោយចិត្តដ៏ល្អ ១ ឲ្យបានស្តាប់ពាក្យដែលមិនធ្លាប់ស្តាប់ ១ បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយ ១ ប្រាប់ផ្លូវសួគ៌ ១ ។ ម្នាលគហបតិបុត្ត សមណ-ព្រាហ្មណ៍ជាទិសខាងលើ ដែលកុលបុត្តផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៦ នេះ ទិសខាងលើនុ៎ះដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភ័យអន្តរាយយ៉ាងនេះ ។ ព្រះមានព្រះភាគបានសំដែងសេចក្តីនេះ ព្រះសុគតជាសាស្តា លុះសំដែងសេចក្តីនេះហើយ ទ្រង់ត្រាស់ពាក្យជាគាថាព័ន្ធតទៅទៀតថា

[៧៦] មាតាបិតា ជាទិសខាងកើត អាចារ្យ ជាទិសខាងត្បូង កូនប្រពន្ធជាទិសខាងលិច មិត្តអាមាត្យជាទិសខាងជើង

៩១

សិង្គាលកសុត្តេ ហេដ្ឋិមា ទិសា ឧបរិមា ទិសា

ទាសកម្មករា ហេដ្ឋា
ឧទ្ធំ សមណព្រាហ្មណា
ឯតា ទិសា នមស្សេយ្យ
អលមត្តោ កុលេ គិហី ។
បណ្ឌិតោ សីលសម្បន្នោ
សណ្ហោ ច បដិភាណវា
និវាតវុត្តិ អត្ថទ្ធោ
តាទិសោ លភតេ យសំ
ឧដ្ឋានកោ អនលសោ
អាបទាសុ ន វេធតិ
អច្ឆិទ្ទវុត្តិ មេធាវី
តាទិសោ លភតេ យសំ ។
សង្គាហកោ មិត្តករោ
វទញ្ញូ វីតមច្ឆរោ
នេតា វិនេតា អនុនេតា
តាទិសោ លភតេ យសំ ។

សិង្គាលកសូត្រ និយាយអំពីទិសខាងក្រោមនិងទិសខាងលើ

ទាសៈនិងកម្មករ ជាទិសខាងក្រោម សមណព្រាហ្មណ៍ជាទិសខាងលើ គ្រហស្ថក្នុងត្រកូល ដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុ៎ះ ។ បណ្ឌិត[១] បរិបូណ៌ដោយសីល មានវាចាដ៏ពីរោះ មានប្រាជ្ញាវៃ[២] មានកិរិយាប្រព្រឹត្តឱនលំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គលមានសភាពដូច្នោះ រមែងបានយស បុគ្គលមានព្យាយាមរឿសរវៃ មិនខ្ជិលច្រអូស រមែងមិនញាប់ញ័រក្នុងអន្តរាយទាំងឡាយ បុគ្គលមានកិរិយាប្រព្រឹត្តឥតចន្លោះ មានប្រាជ្ញាវាងវៃ បុគ្គលមានសភាពដូច្នោះ រមែងបានយស ។ បុគ្គលមានសេចក្តីសង្គ្រោះ ជាអ្នកចងចិត្ត ជាអ្នកដឹងដំណើរពាក្យ[៣] ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ជាអ្នកនាំពន្យល់ការណ៍ផ្សេង ៗ ជាអ្នកណែនាំរឿយ ៗ បុគ្គលមានសភាពដូច្នោះរមែងបានយស ។

---

១-២ អដ្ឋកថា បណ្ឌិតមានប្រាជ្ញាវៃ ក្នុងស្ថានជាទីសំពះទិស ។ ៣ សំដៅយកមនុស្សនាំពាក្យខ្លួនដែលបានថាឲ្យរបស់អ្វី ដល់សំឡាញ់ហើយក៏ឲ្យទាល់តែបាន ដឹងចិត្តសំឡាញ់ថាចង់បានអ្វី ក៏ឲ្យរបស់នោះឬដឹងថាសំឡាញ់ខ្វះខាតអ្វី ក៏ឲ្យរបស់នោះ ។

ទានញ្ច បិយវជ្ជញ្ច
អត្ថចរិយា ច យា ឥធ
សមានតា[១] ច ធម្មេសុ
តត្ថ តត្ថ យថារហំ ។
ឯតេ ខោ សង្គហា លោកេ
រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ
ន មាតា បុត្តការណា
លភេថ មានំ បូជំ វា
បិតា វា បុត្តការណា ។
យស្មា ច សង្គហា ឯតេ
សមបេក្ខន្តិ[២] បណ្ឌិតា
តស្មា មហត្តំ បប្បោន្តិ
បាសំសា ច ភវន្តិ តេតិ ។

---

១ ឱ. ម. សមានត្តតា ។ ២ ឱ. ម. សមវេក្ខន្តិ ។

ទាន ១ ពាក្យពីរោះ ១ សេចក្តីប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ការៈជាអ្នកមានចិត្តស្មើ ក្នុងធម៌ទាំងឡាយ និងក្នុងបុគ្គលនោះ ៗ តាមសមគួរ ១ ។ សង្គហធម៌ទាំងនេះ (មានក្នុងលោក ទើបលោកប្រព្រឹត្តទៅបាន) ដូចជារថមានប្រែកទប់ ទើបប្រព្រឹត្តទៅបានដូច្នោះឯង បើសង្គហធម៌ទាំងនេះ មិនមានហើយ មាតាក្តី បិតាក្តី ក៏មិនបាននូវសេចក្តីរាប់អាននិងការបូជា អំពីកិច្ចដែលកូនត្រូវធ្វើ ។ ព្រោះហេតុតែអ្នកប្រាជ្ញទាំងឡាយ សំឡឹងឃើញសង្គហធម៌ទាំងនោះ ដោយប្រពៃ ហេតុនោះ បានជាលោកដល់នូវភាវៈជាធំផង គួរគេសរសើរផង ។

៩៣

## សិង្គាលកសុត្តេ សិង្គាលកស្ស ថោមនា ច សរណគមនញ្ច

[៧៧] ឯវំ វុត្តេ សិង្គាលកោ គហបតិបុត្តោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។

សិង្គាលកសុត្តំ អដ្ឋមំ និដ្ឋិតំ[១] ។

---

១ ឱ. សិង្គាលោវាទសុត្តន្តំ ។ ម. សិង្គាលកសុត្តន្តំ អដ្ឋមំ ។

[៧៧] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សិង្គាលកគហបតិបុត្ត បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាមនុស្សផ្ងាររបស់ដែលគេផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជា គេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុទាំងឡាយ រមែងឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាសរណៈ ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះរៀងទៅ ។

ចប់ សិង្គាលកសូត្រ ទី ៨ ។

# អាដានាដិយសុត្តំ នវមំ

[៧៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ ចត្តារោ មហារាជា មហតិយា ច យក្ខសេនាយ មហតិយា ច គន្ធព្វសេនាយ មហតិយា ច កុម្ភណ្ឌសេនាយ មហតិយា ច នាគសេនាយ ចតុទ្ទិសំ រក្ខំ ឋបេត្វា ចតុទ្ទិសំ គុម្ពំ ឋបេត្វា ចតុទ្ទិសំ ឱវរណំ ឋបេត្វា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ គិជ្ឈកូដំ[១] ឱភាសេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ តេបិ ខោ យក្ខា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា

១ ម. គិជ្ឈកូដំ បព្វតំ ។

# អាដានាដិយសូត្រ ទី ៩

[៧៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ លំដាប់នោះឯង ស្តេចធំទាំង ៤ អង្គ តាំងការរក្សាទុកក្នុងទិសទាំង ៤ តាំងកងពលទុក ក្នុងទិសទាំង ៤ តាំងបុគ្គលជាអ្នកត្រួតត្រាទុក ក្នុងទិសទាំង ៤ ដោយសេនាយក្ខដ៏ច្រើន ដោយសេនាគន្ធព្វដ៏ច្រើន ដោយសេនាកុម្ភណ្ឌដ៏ច្រើន ដោយសេនានាគដ៏ច្រើន កាលវេលារាត្រី (បឋមយាម) កន្លងទៅហើយ (ស្តេចទាំងនោះ) មានពន្លឺដ៏រុងរឿង ញ៉ាំងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯយក្ខទាំងឡាយនោះ ពួកខ្លះ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែអង្គុយប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ

ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ណាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។

[៧៩] ឯកមន្តំ និសិន្នោ ខោ វេស្សវណោ មហារាជា ភគវន្តំ ឯតទវោច សន្តិ ហិ ភន្តេ ឧឡារា យក្ខា ភគវតោ អប្បសន្នា សន្តិ ហិ ភន្តេ ឧឡារា យក្ខា ភគវតោ បសន្នា សន្តិ ហិ ភន្តេ មជ្ឈិមា យក្ខា ភគវតោ អប្បសន្នា សន្តិ ហិ ភន្តេ មជ្ឈិមា យក្ខា ភគវតោ បសន្នា សន្តិ ហិ ភន្តេ នីចា យក្ខា ភគវតោ អប្បសន្នា សន្តិ ហិ ភន្តេ នីចា យក្ខា ភគវតោ បសន្នា ។ យេភុយ្យេន ខោ បន ភន្តេ យក្ខា អប្បសន្នាយេវ ភគវតោ តំ កិស្ស ហេតុ ភគវា ហិ ភន្តេ ចាណាតិចាតា វេរមណិយា ធម្មំ ទេសេតិ អទិន្នាទានា វេរមណិយា ធម្មំ ទេសេតិ

ក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែប្រកាសនាមនិងគោត្រ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែអង្គុយស្ងៀម ក្នុងទីដ៏សមគួរ ។

[៧៩] ស្ដេចជាធំឈ្មោះ វេស្សវ័ណ គង់នៅក្នុងទីដ៏សមគួរ ហើយក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្ដាល មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្ដាល ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាប មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាប ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ឯយក្ខដែលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគច្រើនណាស់ ការនោះ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាត ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកអទិន្នាទាន

កាមេសុ មិច្ឆាចារា វេរមណិយា វណ្ណំ ភាសតិ មុសាវាទា វេរមណិយា វណ្ណំ ភាសតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណិយា វណ្ណំ ភាសតិ ។ យេភុយ្យេន ខោ បន ភន្តេ យក្ខា អប្បដិវិរតាយេវ បាណាតិបាតា អប្បដិវិរតា អទិន្នាទានា អប្បដិវិរតា កាមេសុ មិច្ឆាចារា អប្បដិវិរតា មុសាវាទា អប្បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា តេសន្តំ ហោតិ អប្បិយំ អមនាបំ ។ សន្តិ ហិ ភន្តេ ភគវតោ សាវកា អរញ្ញេ វនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានិ សារុប្បានិ តត្ថ សន្តិ ឧឡារា យក្ខា និវាសិនោ យេ ឥមស្មឹ ភគវតោ បាវចនេ អប្បសន្នា តេសំ បសាទាយ ឧគ្គណ្ហាតុ ភន្តេ ភគវា អាដានាដិយំ រក្ខំ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ

ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកកាមេសុមិច្ឆាចារ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកមុសាវាទ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងយក្ខទាំងឡាយ ច្រើនតែមិនវៀរចាកបាណាតិបាតសោះ មិនវៀរចាកអទិន្នាទានសោះ មិនវៀរចាកកាមេសុមិច្ឆាចារសោះ មិនវៀរចាកមុសាវាទសោះ មិនវៀរចាកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទសោះ បានជាពួកយក្ខទាំងនោះ មិនគាប់ចិត្ត មិនពេញចិត្តនិងការវៀរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកសាវ័ករបស់ព្រះមានព្រះភាគ អាស្រ័យនូវសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ មានសូរសព្ទតិចតួចសំឡេងគឹកកងរំពងតិច ប្រាសចាកសំដីរបស់មនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស ជាទីគួរដល់ការលាក់ខ្លួនពួនអាត្មាបាន ពួកយក្ខជាន់ខ្ពស់តែងនៅជានិច្ចក្នុងព្រៃនោះ (គេ) មិនជ្រះថ្លាក្នុងសាសនា របស់ព្រះមានព្រះភាគនេះ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ សូមព្រះមានព្រះភាគប្រៀនប្រដៅ នូវព្រះបរិត្តសម្រាប់រក្សាក្នុងនគរឈ្មោះអាដានាដា ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា

### អាដានាដិយសុត្តេ សត្តសម្មាសម្ពុទ្ធានំ នមក្ការគាថា

គុត្តិយា រក្ខាយ អវិហឹសាយ ផាសុវិហារាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ វេស្សវណោ មហារាជា ភគវតោ អធិវាសនំ វិទិត្វា តាយំ វេលាយំ ឥមំ អាដានាដិយំ រក្ខំ អភាសិ

[៨០] វិបស្សិស្ស នមត្ថុ ច-
ក្ខុមន្តស្ស សិរីមតោ
សិខិស្សបិ នមត្ថុ
សព្វភូតានុកម្បិនោ ។
វេស្សភុស្ស នមត្ថុ
ន្ហាតកស្ស តបស្សិនោ
នមត្ថុ កកុសន្ធស្ស

ដើម្បីឲ្យយក្ខទាំងនោះជ្រះថ្លា ដើម្បីការគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅសប្បាយ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ ស្តេចជាធំឈ្មោះវេស្សវណ្ណ ជ្រាបនូវការទទួលនិមន្តព្រះមានព្រះភាគ ហើយទើបសំដែងនូវព្រះបរិត្ត សម្រាប់រក្សាដែលជាប់ទាក់ទង ក្នុងអាដានាដានគរនេះ ក្នុងវេលានោះ ។

[៨០] សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមវិបស្សី ព្រះអង្គមានចក្ខុ[១] ព្រះអង្គមានសិរី សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី ។ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមវេស្សភូ ព្រះអង្គជម្រះកិលេសចេញហើយ ព្រះអង្គមានតបធម៌ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកកុសន្ធៈ ព្រះអង្គញាំញី

---

១ អដ្ឋកថា ថា ព្រះពុទ្ធទាំង ៧ ព្រះអង្គសុទ្ធតែមានចក្ខុដូចគ្នា ។ នាមដទៃទៀតមានអនុគ្រោះសត្វទាំងពួងជាដើមក្តី នាមជាអសំខេយ្យដទៃក្តី ក៏មានក្នុងព្រះពុទ្ធគ្រប់ព្រះអង្គដែរ តែក្នុងទីនេះបានជាផ្សេងគ្នា ព្រោះព្រះបាទវេស្សវ័ណនមស្ការ តាមចាំបាន តាមនឹកឃើញ ។

មារសេនប្បមទ្ទិនោ ។
កោណាគមនស្ស នមត្ថុ
ព្រាហ្មណស្ស វុសីមតោ
កស្សបស្ស នមត្ថុ
វិប្បមុត្តស្ស សព្វធិ ។
អង្គីរសស្ស នមត្ថុ
សក្យបុត្តស្ស សិរីមតោ
យោ ឥមំ ធម្ម[១]មទេសេសិ
សព្វទុក្ខា បនូទនំ ។
យេ ចាបិ និព្វុតា លោកេ
យថាភូតំ វិបស្សិសុំ
តេ ជនា អបិសុណា[២]
មហន្តា វីតសារទា ។
ហិតំ ទេវមនុស្សានំ
យំ នមស្សន្តិ គោតមំ

---

១ ម. ធម្មំ ។ ២ ម. អបិសុណាថ ។

នូវមារព្រមទាំងសេនានៃមារ ។ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកោនាគមនៈ ព្រះអង្គមានបាបបន្សាត់បង់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ[១] សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកស្សបៈ ព្រះអង្គរួចផុតស្រឡះចាកកិលេសទាំងពួងហើយ ។ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធជាសក្យបុត្ត ទ្រង់មានព្រះកាយផ្សាយចេញនូវព្រះរស្មី ទ្រង់មានសិរី ដែលសំដែងធម៌នេះ ជាគ្រឿងបន្ទោបង់សេចក្តីទុក្ខទាំងពួង ។ មួយទៀត ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គណា ព្រះអង្គរលត់កិលេសហើយ ទ្រង់ឃើញច្បាស់នូវធម៌ តាមសេចក្តីពិត ក្នុងលោក ព្រះសម្មាសម្ពុទ្ធទាំងនោះ ជាព្រះខីណាស្រព ព្រះអង្គមិនមានសេចក្តីញុះញង់ស៊កសៀត (ទ្រង់ប្រសើរដោយគុណ) មិនក្ញៀវក្ញា (ដោយកិលេស) ។ ទេវតានិងមនុស្សទាំងឡាយ

១ ព្រះអង្គសម្រេចសោឡសកិច្ចរួចហើយ គឺព្រះអង្គលះកិលេសអស់ហើយ ។

៩៩

អាដានាដិយសុត្តេ  សុរិយាទិច្ចស្ស  ឧគ្គមនំ

វិជ្ជាចរណសម្បន្នំ
មហន្តំ  វីតសារទំ  ។
[៨១]  យតោ  ឧគ្គច្ឆតិ  សុរិយោ
អាទិច្ចោ  មណ្ឌលី  មហា
យស្ស  ចុគ្គច្ឆមានស្ស
សំវរីបិ  និរុជ្ឈតិ  ។
យស្ស  ចុគ្គតេ  សុរិយេ
ទិវសោតិ  បវុច្ចតិ
រហទោបិ  តត្ថ  គម្ភីរោ
សមុទ្ទោ  សរិតោទកោ
ឯវន្តំ  តត្ថ  ជានន្តិ
សមុទ្ទោ  សរិតោទកោ  ។
ឥតោ  សា  បុរិមា  ទិសា
ឥតិ  នំ  អាចិក្ខតី  ជនោ
យំ  ទិសំ  អភិបាលេតិ
មហារាជា  យសស្សិ  សោ
គន្ធព្វានំ  អាធិបតិ

តែងនមស្ការព្រះសម្មាសម្ពុទ្ធ ជាគោតមគោត្រ ព្រះអង្គជាប្រយោជន៍ ដល់ទេវតានិងមនុស្សទាំងឡាយ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់ប្រសើរដោយគុណ ព្រះអង្គឥតមានសេចក្តីព្រឺស្ញើប ។

[៨១] ព្រះអាទិត្យមានរស្មីដ៏ក្លៀវក្លា រះឡើងអំពីទីណា មានមណ្ឌលធំ (ក្នុងទីនោះ) កាលព្រះអាទិត្យរះឡើងហើយ រាត្រីក៏បាត់ទៅ ។ មួយទៀត កាលព្រះអាទិត្យរះឡើងហើយ មហាជននាំគ្នាហៅថាថ្ងៃ សូម្បីអន្លង់ទឹកក្នុងទីដែលព្រះអាទិត្យរះឡើងនោះ ជាសមុទ្រដ៏ជ្រៅ មានទឹកហូរទៅ (ពីនទីផ្សេង ៗ) ជនទាំងឡាយតែងសំគាល់នូវអន្លង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យរះឡើងនោះ ថាជាសមុទ្រមានទឹកហូរទៅយ៉ាងនេះ ។ ស្តេចជាធំ ដ៏ទ្រង់យស ទ្រង់រក្សាទិសណា មហាជនតែងហៅទិសនោះ ថាបុរិមទិស អំពីភ្នំសិនេរុនោះ ទ្រង់ជាអធិបតីលើគន្ធព្វទាំងឡាយ មានព្រះ

ធតរដ្ឋោ ឥតិ នាមសោ
រមតី នច្ចគីតេហិ
គន្ធព្វេហិ បុរក្ខតោ ។
បុត្តាបិ តស្ស ពហវោ
ឯកនាមាតិ មេ សុតំ
អសីតិ ទស ឯកោ ច
ឥន្ទនាមា មហព្វលា
តេ ចាបិ ពុទ្ធំ ទិស្វាន
ពុទ្ធំ អាទិច្ចពន្ធុនំ
ទូរតោ វ នមស្សន្តិ
មហន្តំ វីតសារទំ ។
នមោ តេ បុរិសាជញ្ញ
នមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ
អមនុស្សាបិ តំ វន្ទន្តិ ។
សុតំ នេតំ អភិណ្ហសោ

នាមថាធតរដ្ឋ មានពួកគន្ធព្វហែហម ទ្រង់ត្រេកត្រអាល ដោយរបាំនិងចម្រៀង ។ ព្រះរាជបុត្តរបស់ស្តេចជាធំនោះមាន ច្រើនដល់ម៉្លោះ ខ្ញុំព្រះអង្គបានស្តាប់មកថា មាននាមដូច ៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គ សឹងមាននាមថាឥន្ទៈ មានកម្លាំង ច្រើន ឯព្រះរាជបុត្តទាំងនោះ ឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់អំពីការដេកលក់គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ ។ បពិត្រ ព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះ ព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូម នមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែង ថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គបានស្តាប់ មកយ៉ាងនេះរឿយ ៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គ

អាដានាដិយសុត្តេ ទក្ខិណទិសាយ វិរុឡ្ហោ មហារាជា

តស្មា ឯវំ វទេម្ហសេ[១]
ជិនំ វន្ទថ គោតមំ
ជិនំ វន្ទាម គោតមំ
វិជ្ជាចរណសម្បន្នំ
ពុទ្ធំ វន្ទាម គោតមំ ។
[៨២] យេន បេតា បវុច្ចន្តិ
បិសុណា បិដ្ឋិមំសិកា
បាណាតិបាតិនោ លុទ្ទា
ចោរា នេកតិកា ជនា ។
ឥតោ សា ទក្ខិណា ទិសា
ឥតិ នំ អាចិក្ខតី ជនោ
យំ ទិសំ អភិបាលេតិ
មហារាជា យសស្សិ សោ
កុម្ភណ្ឌានំ អាធិបតិ
វិរុឡ្ហោ ឥតិ នាម សោ

១ ឱ. វទេមសេ ។

តែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយថ្វាយបង្គំព្រះជិនស្រី ដែលជាគោតមគោត្រឬ (ព្រះរាជបុត្តទាំងនោះតបថា) យើងខ្ញុំទាំងឡាយថ្វាយបង្គំព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយ ថ្វាយបង្គំព្រះពុទ្ធគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ។

[៨២] ជនជាអ្នកមានពាក្យញុះញង់ស៊កសៀត ជាអ្នកតិះដៀលគេក្នុងទីកំបាំងមុខ ដូចជាជនអ្នកស៊ីសាច់ខ្នង ជាអ្នកសម្លាប់សត្វ ជាអ្នកធ្វើអំពើអាក្រក់ ជាចោរ ជាមនុស្សមានកល-លល្បួង ជនទាំងនោះលុះធ្វើកាលកិរិយាទៅហើយ គេតែងថា (ឲ្យនាំទៅ) តាមទិសណា[១] ។ ស្តេចជាធំទ្រង់យសទ្រង់រក្សានូវទិសណា មហាជនតែងនាំគ្នាហៅទិសនោះថា ទក្ខិណទិស (រាប់) អំពីភ្នំសិនេរុមក ស្តេចនោះជាអធិបតីលើកុម្ភណ្ឌទាំងឡាយ ទ្រង់ព្រះនាមវិរុឡ្ហៈ ដែលមានពួកកុម្ភណ្ឌ

---

១ គេតែងនាំមនុស្សអាក្រក់ធ្វើទោសឬ សម្លាប់ផុតចោលនៅទិសខាងត្បូង (អដ្ឋកថា) ។

រមតី នច្ចគីតេហិ
កុម្ភណ្ឌេហិ បុរក្ខតោ ។
បុត្តាបិ តស្ស ពហវោ
ឯកនាមាតិ មេ សុតំ
អសីតិ ទស ឯកោ ច
ឥន្ទនាមា មហព្វលា
តេ ចាបិ ពុទ្ធំ ទិស្វាន
ពុទ្ធំ អាទិច្ចពន្ធុនំ
ទូរតោ វ នមស្សន្តិ
មហន្តំ វីតសារទំ ។
នមោ តេ បុរិសាជញ្ញ
នមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ
អមនុស្សាបិ តំ វន្ទន្តិ ។
សុតំ នេតំ អភិណ្ហសោ
តស្មា ឯវំ វទេម្ហសេ
ជិនំ វន្ទថ គោតមំ

ចោមរោមហើយ ទ្រង់ត្រេកអរដោយរបាំ និងចម្រៀងទាំង-ឡាយ ។ ព្រះរាជបុត្តរបស់ស្តេចនោះមានច្រើនក៏មែន តែខ្ញុំព្រះអង្គបានស្តាប់មកថា មានព្រះនាមដូច ៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គ សុទ្ធតែមានព្រះនាមថាឥន្ទៈ ទ្រង់មានកម្លាំងច្រើន ក៏ឯព្រះរាជបុត្តទាំងនោះ ឃើញព្រះអាទិច្ចវង្សព្រះអង្គភ្ញាក់ហើយអំពីការដេកលក់គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គ សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ខ្ញុំព្រះអង្គស្តាប់មកយ៉ាងនេះរឿយ ៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គនិយាយយ៉ាងនេះថា អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រីជាគោតមគោត្របុ

១០៣

អាដានាដិយសុត្តេ សុរិយាទិច្ចស្ស ឧគ្គមនំ

ជិនំ វន្ទាម គោតមំ

វិជ្ជាចរណសម្បន្នំ

ពុទ្ធំ វន្ទាម គោតមំ

[៨៣] យត្ថ ចោគ្គច្ឆតិ សុរិយោ

អាទិច្ចោ មណ្ឌលី មហា

យស្ស ចោគ្គច្ឆមានស្ស

ទិវសោបិ និរុជ្ឈតិ

យស្ស ចោគ្គតេ សុរិយេ

សំវរីតិ បវុច្ចតិ ។

រហទោបិ តត្ថ គម្ភីរោ

សមុទ្ទោ សរិតោទកោ

ឯវន្តំ តត្ថ ជានន្តិ

សមុទ្ទោ សរិតោទកោ ។

ឥតោ សា បច្ឆិមា ទិសា

ឥតិ នំ អាចិក្ខតី ជនោ

យំ ទិសំ អភិបាលេតិ

មហារាជា យសស្សិ សោ

(ព្រះរាជបុត្តទាំងនោះតបថា) យើងខ្ញុំទាំងឡាយថ្វាយបង្គំព្រះជិនស្រីជាគោតមគោត្រ យើងខ្ញុំទាំងឡាយថ្វាយបង្គំព្រះសម្ពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ។

[៨៣] ព្រះអាទិត្យមានរស្មីដ៏ភ្លៀវក្លា អស្តង្គតទៅក្នុងទីណា មានមណ្ឌលដ៏ធំក្នុងទីនោះ កាលដែលព្រះអាទិត្យអស្តង្គតទៅហើយ ពេលថ្ងៃក៏អស់ទៅ កាលបើព្រះអាទិត្យអស្តង្គតទៅហើយ មហាជននាំគ្នាហៅថា យប់ ។ សូម្បីអន្លង់ទឹកត្រង់កន្លែងដែលព្រះអាទិត្យអស្តង្គត នោះជាសមុទ្រដ៏ជ្រៅមានទឹកហូរទៅ ជនទាំងឡាយ តែងសំគាល់នូវអន្លង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យ អស្តង្គតនោះថាជាសមុទ្រមានទឹកហូរទៅយ៉ាងនេះ ។ ស្តេចជាធំទ្រង់យស ទ្រង់រក្សាទិសណា មហាជន តែងហៅទិសនោះថា បច្ចិមទិស អំពីភ្នំសិនេរុមក ស្តេចជាធំនោះជា

ណាគានំ អាធិបតិ

វិរូបក្ខោ ឥតិ ណាមសោ

រមតី នច្ចគីតេហិ

ណាគេហិ បុរក្ខតោ ។

បុត្តាបិ តស្ស ពហវោ

ឯកណាមាតិ មេ សុតំ

អសីតិ ទស ឯកោ ច

ឥន្ទណាមា មហព្ពលា

តេ ចាបិ ពុទ្ធំ ទិស្វាន

ពុទ្ធំ អាទិច្ចពន្ធុនំ

ទូរតោ វ នមស្សន្តិ

មហន្តំ វីតសារទំ ។

នមោ តេ បុរិសាជញ្ញ

នមោ តេ បុរិសុត្តម

កុសលេន សមេក្ខសិ

អមនុស្សាបិ តំ វន្ទន្តិ ។

អធិបតីលើនាគទាំងឡាយ ទ្រង់ព្រះនាមថា វិរូបក្ខៈដែលមានពួកនាគចោមរោមហើយ ទ្រង់ត្រេកអរដោយពួករបាំនិងចម្រៀង ។ ព្រះរាជបុត្តទាំងឡាយរបស់ស្តេចវិរូបក្ខៈនោះមានច្រើនក៏មែន តែខ្ញុំព្រះអង្គបានស្តាប់មកថា មានឈ្មោះដូច ៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គក៏ព្រះនាមថាឥន្ទៈ សុទ្ធតែមានកម្លាំងច្រើន ឯព្រះរាជបុត្តទាំងនោះ លុះឃើញព្រះសម្ពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់ហើយចាកការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នាំគ្នានមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គ ជា-បុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ទ្រង់ទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។

អាដានាដិយសុត្តេ ឧត្តរកុរុអាទិកថា

សុតំ នេតំ អភិណ្ហសោ
តស្មា ឯវំ វទេម្ហសេ
ជិនំ វន្ទថ គោតមំ
ជិនំ វន្ទាម គោតមំ ។
វិជ្ជាចរណសម្បន្នំ
ពុទ្ធំ វន្ទាម គោតមំ ។
[៨៤] យេន ឧត្តរកុរូ រម្មា[១]
មហានេរុ សុទស្សនោ
មនុស្សា តត្ថ ជាយន្តិ
អមមា អបរិគ្គហា ។
ន តេ ពីជំ បវប្បន្តិ
នបិ នីយន្តិ នង្គលា
អកដ្ឋបាកិមំ សាលឹ
បរិភុញ្ជន្តិ មានុសា
អកណំ អថុសំ សុទ្ធំ
សុគន្ធំ តណ្ឌុលប្ផលំ

១ ម. ឧត្តរកុរុវ្ហោ ។

ពួកខ្ញុំព្រះអង្គ បានស្តាប់មកយ៉ាងនេះរឿយ ៗ ព្រោះហេតុនោះ ខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយនមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ ឬ (ព្រះរាជ-បុត្តទាំងនោះតបថា) យើងខ្ញុំទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយនមស្ការព្រះពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ។ [៨៤] ឧត្តរកុរុទ្វីប ជាទីរីករាយ មានភ្នំសិនេរុដ៏ធំគួរជាទីមើល(១) តាំងនៅក្នុងទីណា ពួកមនុស្សកើតក្នុងឧត្តរកុរុទ្វីបនោះ ឥតមានប្រកាន់របស់អ្វីថាជារបស់ខ្លួនឡើយ ។ មនុស្សទាំងអម្បាលនោះ មិនចាំបាច់ព្រោះពូជ មិនចាំបាច់នាំនង្គ័លចេញទៅ (ដោយគិតថាអាត្មាអញនឹងភ្ជួរក្នុងទីនោះ ៗ) បរិភោគតែស្រូវសាលី ដែលកើតឯងក្នុងព្រៃ ជាស្រូវមិនមានកុណ្ឌក មិនមានអង្កាម ស្អាតមានក្លិនក្រអូប ផ្លែចេញជាអង្ករ

---

១ ភ្នំសិនេរុគួរជាទីមើល ព្រោះប្រដាប់ដោយរតនវត្ថុ ដូច្នេះ គឺទិសខាងកើតប្រដាប់ដោយប្រាក់ ទិសខាងត្បូងប្រដាប់ដោយកែវមណី ទិសខាងលិចប្រដាប់ដោយកែវផ្លេក ទិសខាងជើងប្រដាប់ដោយមាស (អដ្ឋកថា) ។

តុណ្ឌិកាកិរេ[១] បចិត្វាន
តតោ ភុញ្ជន្តិ ភោជនំ ។
ការី ឯកខុរំ[២] កត្វា
អនុយន្តិ ទិសោ ទិសំ
បសុំ ឯកខុរំ កត្វា
អនុយន្តិ ទិសោ ទិសំ ។
ឥត្ថី[៣] វាហនំ កត្វា
អនុយន្តិ ទិសោ ទិសំ
បុរិសំ[៤] វាហនំ កត្វា
អនុយន្តិ ទិសោ ទិសំ ។
កុមារី[៥] វាហនំ កត្វា
អនុយន្តិ ទិសោ ទិសំ
កុមារំ[៦] វាហនំ កត្វា
អនុយន្តិ ទិសោ ទិសំ
តេ យានេ អភិរូហិត្វា
សព្វា ទិសា អនុបរិយន្តិ

---

១ ឱ. តុណ្ឌិកីរេ ។ ២ ឱ. គារិមេកខុរំ ។ ៣ ឱ. ឥត្ថិ ។ ៤ ឱ. បុរិស ។ ៥ ឱ. កុមារិ ។ ៦ ឱ. កុមារ ។

មនុស្សទាំងឡាយដាក់អង្ករនោះក្នុងឆ្នាំង ចម្អិនដោយភ្លើងឥតផ្សេង[១] មិនមានរងើក ទើបនាំគ្នាបរិភោគភោជនអំពីឆ្នាំងនោះ ។ មនុស្សទាំងនោះ ទឹមនូវមេគោមានក្រចកតែមួយ (ដូចក្រចកសេះ) បរទៅសព្វទិស ទឹមបសុសត្វ (សត្វជើងបួនក្រៅពីមេគោ) មានក្រចកតែមួយ បរទៅសព្វទិស ។ យកស្រីធ្វើជាវាហនៈត្រាច់ទៅសព្វទិស យកបុរស[២] ធ្វើជាវាហនៈត្រាច់ទៅសព្វទិស ។ យកកុមារីធ្វើជាវាហនៈត្រាច់ទៅសព្វទិស យកកុមារធ្វើជាវាហនៈហើយត្រាច់ទៅសព្វទិស ។ មនុស្សទាំងអម្បាលនោះ នាំគ្នាឡើងយាន ត្រាច់ទៅក្នុងទិសទាំងពួង

---

១ សេចក្តីដំណាលថា មនុស្សក្នុងស្រុកនោះ តែងយកថ្មកែវ ៣ ដុំ ឈ្មោះជោតិបាសាណធ្វើជាដុំចង្ក្រានហើយយកឆ្នាំងតម្កល់លើដុំចង្ក្រាននោះ ស្រាប់តែមានចំហាយភ្លើងក្តៅឡើងអំពីថ្មនោះ ធ្វើឲ្យឆ្អិនតែម្តង ។ ២ ទឹមបុរសក្នុងយាន តែគេមិនអាចយកមនុស្សជាសម្មាទិដ្ឋិមកទឹមទេ គេច្រើនចាប់តែមនុស្សមិលក្ខជាតិ អ្នកនៅក្នុងបច្ចន្តប្រទេសមកទឹមក្នុងយានហើយបរទៅ ។ (អដ្ឋកថា) ។

អាដានាដិយសុត្តេ ហត្ថិយានាទិកថា

បចារា តស្ស រាជិនោ ។
ហត្ថិយានំ អស្សយានំ
ទិព្វំ[១] យានំ ឧបដ្ឋិតំ
បាសាទា សិវិកា ចេវ
មហារាជស្ស យសស្សិនោ ។
តស្ស ច នគរា អហុ
អន្តលិក្ខេ សុមាបិតា
អាដានាដា កុសិនាដា បរកុសិនាដា
នាដបរិយា[២] បរកុសិតនាដា ។
ឧត្តរេន កបិវន្តោ
ជនោឃមបរេន ច
នវនវតិយោ អម្ពរអម្ពរវតិយោ
អាឡកមន្ទា នាម រាជធានី
កុវេរស្ស ខោ បន មារិស
មហារាជស្ស វិសាណា នាម រាជធានី
តស្មា កុវេរោ មហារាជា

១ ម. ទិព្វ ។ ២ ឱ. នាដបុរិយា ។ ម. នាដសុរិយា ។

អាដានាដិយសូត្រ និយាយអំពីយានដំរីជាដើម

ពួកស្រីទាំងឡាយ ជាអ្នកបម្រើស្ដេចនោះ ។ យានដំរី យានសេះ យានជាទិព្វ[១] ប្រាសាទនិងវរ ក៏មានសម្រាប់ស្ដេចជាធំដ៏ទ្រង់យស ។ មួយទៀត ស្ដេចនោះទ្រង់កសាងនគរទុកក្នុងអាកាស គឺអាដានាដានគរ កុសិនាដានគរ បរកុសិនា-ដានគរ នាដបរិយានគរ បរកុសិតនាដានគរ ។ សាងនគរឈ្មោះកបិវន្តក្នុងទិសខាងជើង ក្នុងចំណែកទិសដទៃទៀតបានសាងនគរឈ្មោះជនោឃៈ ឈ្មោះនវនវតិយៈ ឈ្មោះអម្ពរ-អម្ពរវតិយៈនិងរាជធានី ឈ្មោះអាឡកមន្ទា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ស្ដេចជាធំឈ្មោះកុវេរៈ មានរាជធានីឈ្មោះវិសា-ណា ព្រោះហេតុនោះ ស្ដេចជាធំ ទ្រង់ព្រះនាមកុវេរៈ

១ យានជាទិព្វមានច្រើនយ៉ាងកើតប្រាកដដល់ពួកជនទាំងនោះ ប្រសិនណាជាជនទាំងនោះអង្គុយត្រង់ទីដំណេកឬលើតាំង លើវរ (គ្រែស្នែង) ជាដើម ក៏ចរទៅបាន ។ យាននេះ កើតសម្រាប់ស្ដេចដែលមានបុណ្យមានអានុភាពម្ដង ៗ ឬសម្រាប់ទេវតាប៉ុណ្ណោះ (អដ្ឋកថា) ។

វេស្សវណោតិ បវុច្ចតិ ។
បច្ចេសន្តោ បកាសេន្តិ
តតោលា តត្តលា តតោតលា
ឱជសី តេជសី តតោជសី
សុរោ រាជា អរិដ្ឋោ នេមី ។
រហទោបិ តត្ថ ធរណី នាម
យតោ មេឃា បវស្សន្តិ
វស្សាយតោ បតាយន្តិ
សភាបិ តត្ថ ភគលវតី នាម
យត្ថ យក្ខា បយិរុបាសន្តិ ។
តត្ថ និច្ចផលា រុក្ខា
នានាទិជគណាយុតា
មយូរកោញ្ចាភិរុទា
កោកិលាភិហិ វគ្គុភិ ។
ជីវញ្ជីវកសទ្ទេត្ថ[១]
អថោ ឱដ្ឋវចិត្តកា

១ ឱ. ជីវំ ជីវកសទ្ទេត្ថ ។

មហាជននាំគ្នាហៅថា វេស្សវណ្ណ ។ ពួកយក្ខឈ្មោះ តតោលា តត្តលា តតោតលា ឱជសី តេជសី តតោ-ជសី សុរោ រាជា សុរោរាជា អរិដ្ឋ នេមិ អរិដ្ឋ-នេមិ តែងត្រួតត្រា[១] ប្រកាសនូវប្រយោជន៍ផ្សេង ៗ ។ មួយទៀត ភ្លៀងនាំទឹកអំពីស្រះបោក្ខរណីណា ហើយបង្អុរចុះ ភ្លៀងហូរចេញអំពីទីណា ត្រង់ទីនោះឯង មានអន្លង់ទឹកឈ្មោះធរណី ពួកយក្ខតែងអង្គុយប្រជុំគ្នាក្នុងទីណា ត្រង់ទីនោះឯងមានសភា[២] ឈ្មោះភគលវតី ។ ត្រង់ទីនោះមានដើមឈើផ្លែជានិច្ច ដេរដាស ដោយហ្វូងបក្សីផ្សេង ៗ កងរំពងដោយសំឡេងសត្វក្ងោក សត្វក្រៀល (ព្រមទាំង) ពួកតាវ៉ៅមានសំឡេងពីរោះ ។ សំឡេងបក្សីឈ្មោះជីវញ្ជីវក ក៏មានក្នុងទីនុ៎ះ មួយទៀត ពួកបក្សីឈ្មោះឱដ្ឋវចិត្តកៈ

១ យក្ខអ្នករក្សាដែនទាំង ១២ នាក់ តែងត្រួតត្រាប្រាប់ពន្យល់នូវការជាប្រយោជន៍ផ្សេង ៗ ហើយប្រាប់សេចក្តីដល់ពួកយក្ខអ្នករក្សាទ្វារទាំង ១២ នាក់ យក្ខរក្សាទ្វារទាំងនោះ ក៏នាំសេចក្តីនោះទៅក្រាបបង្គំទូលដល់ស្តេចវេស្សវណ្ណ (អដ្ឋកថា) ។ ២ សំដៅយកមណ្ឌបកែវទំហំ ១២ យោជន៍ដែលព័ទ្ធព័ទ្ធដោយវល្លិឈ្មោះភគលវតិ ទៀបឆ្នេរស្រះបោក្ខរណីនោះ (អដ្ឋកថា) ។

១០៩

អាដានាដិយសុត្តេ អាដានាដិយា រក្ខា

កុក្កុដកា កុឡីរកា
វនេ បោក្ខរសាតកា ។
សុកសាលិកសទ្ទេត្ថ
ទណ្ឌមាណវកានិ ច
សោភតិ សព្វកាលំ សា
កុវេរនឡិនី សទា ។
ឥតោ សា ឧត្តរា ទិសា
ឥតិ នំ អាចិក្ខតី ជនោ
យំ ទិសំ អភិបាលេតិ
មហារាជា យសស្សិ សោ ។
យក្ខានំ[១] អាធិបតិ
កុវេរោ ឥតិ នាមសោ
រមតី នច្ចគីតេហិ
យក្ខេហិ[២] បុរក្ខតោ ។
បុត្តាបិ តស្ស ពហវោ

១ ម. យក្ខានញ្ច ។ ២ ម. យក្ខេហេវ ។

ហ្វូងមាន់ព្រៃ ក្តាមនិងហ្វូងសត្វបោក្ខរសាតកៈ ក៏អាស្រ័យនៅក្នុងត្រពាំងឈូក ។ ម្យ៉ាងទៀត សំឡេងសត្វសេកនិងសារិកាក៏មានក្នុងទីនោះ មានទាំងពួកបក្សីឈ្មោះទណ្ឌមានវកៈ[១] ស្រះឈូករបស់ស្តេចកុវេរៈនោះ ជាស្រះល្អសព្វកាលឥតចន្លោះ ។ ស្តេចជាធំទ្រង់យស ទ្រង់អភិបាលទិសណា មហាជនតែងនាំគ្នាហៅទិសនោះថា ឧត្តរទិស រាប់អំពីភ្នំសិនេរុមក ។ ព្រះអង្គជាអធិបតីលើពួកយក្ខ ទ្រង់ព្រះនាមថា កុវេរៈ ដែលមានពួកយក្ខចោមរោមហើយ ទ្រង់ត្រេកត្រអាលដោយពួករបាំនិងចម្រៀង ។ ពួកព្រះរាជបុត្តរបស់ព្រះអង្គ ក៏មានច្រើន

១ សេចក្តីដំណាលថា សត្វនោះកាន់ដំបងមាសដោយដៃទាំងពីរ ជើងជាន់លើស្លឹកឈូកមួយ ហើយទម្លាក់ដំបងមាសចុះត្រង់ចន្លោះស្លឹកឈូក ហើយហើរទៅ ។

១១០



ឯកនាមាតិ មេ សុតំ
អសីតិ ទស ឯកោ ច
ឥន្ទនាមា មហព្ពលា ។
តេ ចាបិ ពុទ្ធំ ទិស្វាន
ពុទ្ធំ អាទិច្ចពន្ធុនំ
ទូរតោ វ នមស្សន្តិ
មហន្តំ វីតសារទំ ។
នមោ តេ បុរិសាជញ្ញ
នមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ
អមនុស្សាបិ តំ វន្ទន្តិ ។
សុតំ នេតំ អភិណ្ហសោ
តស្មា ឯវំ វទេម្ហសេ
ជិនំ វន្ទថ គោតមំ
ជិនំ វន្ទាម គោតមំ
វិជ្ជាចរណសម្បន្នំ
ពុទ្ធំ វន្ទាម គោតមន្តិ ។

តែខ្ញុំព្រះអង្គបានស្តាប់មកថា មានព្រះនាមដូច ៗ គ្នា ព្រះរាជ-បុត្តទាំង ៩១ ព្រះអង្គ មានព្រះនាមថាឥន្ទៈ ទ្រង់មានកម្លាំងច្រើន ។ ឯព្រះរាជបុត្តទាំងនោះ លុះបានឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់ហើយចាកការដេកលក់គឺអវិជ្ជា ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នាំគ្នានមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តមខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំង-ឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ធូរផង់ ។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយ ៗ ព្រោះហេតុនោះពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយនមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្របុ្ក ព្រះរាជបុត្តទាំងនោះតបថា យើងទាំងឡាយនមស្ការចំពោះព្រះជិនស្រី ជា-គោតមគោត្រ យើងទាំងឡាយនមស្ការចំពោះព្រះពុទ្ធ ជា-គោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ។

### អាដានាដិយសុត្តេ អាដានាដិយា រក្ខា

[៨៥] អយំ ខោ សា មារិស អាដានាដិយា រក្ខា ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ គុត្តិយា រក្ខាយ អវិហឹសាយ ផាសុវិហារាយាតិ ។ យស្ស កស្សចិ មារិស ភិក្ខុស្ស វា ភិក្ខុនិយា វា ឧបាសកស្ស វា ឧបាសិកាយ វា អយំ អាដានាដិយា រក្ខា សុគ្គហិតា ភវិស្សតិ សមត្តា បរិយាបុតា តញ្ចេ អមនុស្សោ យក្ខោ វា យក្ខិនី វា យក្ខបោតកោ វា យក្ខបោតិកា វា យក្ខមហាមត្តោ វា យក្ខបារិសជ្ជោ វា យក្ខបចារោ វា គន្ធព្វោ វា គន្ធព្វី វា គន្ធព្វបោតកោ វា គន្ធព្វបោតិកា វា គន្ធព្វមហាមត្តោ វា គន្ធព្វបារិសជ្ជោ វា គន្ធព្វបចារោ វា កុម្ភណ្ឌោ វា កុម្ភណ្ឌី វា កុម្ភណ្ឌបោតកោ វា កុម្ភណ្ឌបោតិកា វា កុម្ភណ្ឌមហាមត្តោ វា កុម្ភណ្ឌបារិសជ្ជោ វា កុម្ភណ្ឌបចារោ វា នាគោ វា នាគិនី វា នាគបោតកោ វា នាគបោតិកា វា នាគមហាមត្តោ វា នាគបារិសជ្ជោ វា នាគបចារោ វា បទុដ្ឋចិត្តោ ភិក្ខុំ វា

អាដានាដិយសូត្រ ការរក្សាជាប់ទាក់ទងក្នុងអាដានាដានគរ

[៨៥] បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ការរក្សាជាប់ទាក់ទងក្នុងអាដានា-ដានគរនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅសប្បាយរបស់ពួកភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិកា ។ ការរក្សាជាប់ទាក់ទងក្នុងអាដានាដានគរនេះ ដែលបុគ្គលណាមួយ ទោះបីជាភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិកា រៀនដោយប្រពៃ រៀនដោយសព្វគ្រប់ ជម្រះអត្ថនិងព្យញ្ជនៈឲ្យបរិបូណ៌ បើអមនុស្ស ទោះបីជាយក្ខក្តី យក្ខិនីក្តី កូនប្រុសរបស់យក្ខក្តី កូនស្រីរបស់យក្ខក្តី អាមាត្យធំរបស់យក្ខក្តី បរិស័ទរបស់យក្ខក្តី អ្នកបម្រើរបស់យក្ខក្តី គន្ធព្វប្រុសក្តី គន្ធព្វស្រីក្តី កូនប្រុសរបស់គន្ធព្វក្តី កូនស្រីរបស់គន្ធព្វក្តី អាមាត្យធំរបស់គន្ធព្វក្តី បរិស័ទរបស់គន្ធព្វក្តី អ្នកបម្រើរបស់គន្ធព្វក្តី កុម្ភណ្ឌប្រុសក្តី កុម្ភណ្ឌស្រីក្តី កូនប្រុសរបស់កុម្ភណ្ឌក្តី កូនស្រីរបស់កុម្ភណ្ឌក្តី អាមាត្យធំរបស់កុម្ភណ្ឌក្តី បរិស័ទរបស់កុម្ភណ្ឌក្តី អ្នកបម្រើរបស់កុម្ភណ្ឌក្តី នាគឈ្មោលក្តី នាគញីក្តី កូនឈ្មោលរបស់នាគក្តី កូនញីរបស់នាគក្តី អាមាត្យធំរបស់នាគក្តី បរិស័ទរបស់នាគក្តី នាគជាអ្នកបម្រើក្តី ដែលជា

ភិក្ខុនឹ វា ឧបាសកំ វា ឧបាសិកំ វា គច្ឆន្តំ វា អនុគច្ឆេយ្យ ឋិតំ វា ឧបតិដ្ឋេយ្យ និសិន្នំ វា ឧបនិសីទេយ្យ និបន្នំ វា ឧបនិបជ្ជេយ្យ ។ ន មេ សោ មារិស អមនុស្សោ លភេយ្យ គាមេសុ វា និគមេសុ វា សក្ការំ វា គរុការំ វា ។ ន មេ សោ មារិស អមនុស្សោ លភេយ្យ អាឡកមន្ទាយ ឯាម[១] រាជធានិយា វត្ថុំ វា វាសំ វា ។ ន មេ សោ មារិស អមនុស្សោ លភេយ្យ យក្ខានំ សមិតឹ គន្តុំ ។ អបិស្សុ នំ មារិស អមនុស្សា អនវយ្ហម្បិ[២] ករេយ្យុំ អវិវយ្ហំ ។ អបិស្សុ នំ មារិស អមនុស្សា អត្តាហិ[៣] បរិបុណ្ណាហិ បរិភាសាហិ បរិភាសេយ្យុំ ។ អបិស្សុ នំ មារិស អមនុស្សា រិត្តម្បិ[៤] បត្តំ សីសេ និក្កុជ្ជេយ្យុំ ។ អបិស្សុ នំ មារិស អមនុស្សា សត្តធាបិស្ស មុទ្ធំ ផាលេយ្យុំ សន្តិ ហិ មារិស អមនុស្សា

---

១ ឱ. នាមសទ្ទោ ន ទិស្សតិ ។ ២ ឱ. អនាវយ្ហម្បិ ។ ម. អនវយ្ហំ បិ ។ ៣ ឱ. អត្តាហិ បិ ។ ៤ ម. រិត្តំ បិស្ស ។

អ្នកមានចិត្តប្រទូស្តនូវបុគ្គលនោះ ហើយដើរតាមភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាដែលកំពុងដើរ ឬឈរជិតភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិ-កា ដែលកំពុងឈរ ឬអង្គុយជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលកំពុងអង្គុយ ឬដេកជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលកំពុងដេក ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មួយទៀត អមនុស្សនោះមិនគប្បីបានសក្ការៈនិងសេចក្តីគោរពក្នុងស្រុក ឬនិគមទាំងឡាយនៃខ្ញុំឡើយ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សនោះមិនគប្បីបានទីផ្ទះ ឬការនៅជានិច្ច ក្នុងរាជធានីឈ្មោះអាលកមន្ទារបស់ខ្ញុំឡើយ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សនោះ មិនគប្បីបានចូលកាន់ទីប្រជុំរបស់ពួកយក្ខទាំងឡាយនៃខ្ញុំឡើយ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មួយទៀត អមនុស្សទាំងឡាយ មិនគប្បីធ្វើអាវាហមង្គល ឬវិវាហមង្គលនឹងអមនុស្សនោះទេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយ គប្បីផ្តាសាអមនុស្សនោះ ដោយពាក្យផ្តាសាទាំងឡាយ ពេញបន្ទុកប្រៀបធៀបដោយខ្លួន (អាក្រក់) ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយ គប្បីផ្កាប់បាត្រទទេលើក្បាលនៃអមនុស្សនោះ ។ មួយទៀត អមនុស្សទាំងឡាយ គប្បីបំបែកក្បាលអមនុស្សនោះជា ៧ ភាគ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មានអមនុស្ស

១១៣



ចណ្ឌា រុទ្ធា រភសា តេ នេវ មហារាជានំ អាទិយន្តិ ន មហារាជានំ បុរិសកានំ អាទិយន្តិ ន មហារាជានំ បុរិសកានំ បុរិសកានំ អាទិយន្តិ ។ តេ ខោ តេ មារិស អមនុស្សា មហារាជានំ អវរុទ្ធា នាម វុច្ចន្តិ ។ សេយ្យថាបិ មារិស រញ្ញោ មាគធស្ស វិជិតេ ចោរា[១] តេ នេវ រញ្ញោ មាគធស្ស អាទិយន្តិ ន រញ្ញោ មាគធស្ស បុរិសកានំ អាទិយន្តិ ន រញ្ញោ មាគធស្ស បុរិសកានំ បុរិសកានំ អាទិយន្តិ តេ ខោ តេ មារិស មហាចោរា រញ្ញោ មាគធស្ស អវរុទ្ធា នាម វុច្ចន្តិ ឯវមេវ ខោ មារិ-ស សន្តិ ហិ[២] អមនុស្សា ចណ្ឌា រុទ្ធា រភសា តេ នេវ មហារាជានំ អាទិយន្តិ ន មហារាជានំ បុរិសកានំ អាទិយន្តិ ន មហារាជានំ បុរិសកានំ បុរិសកានំ អាទិយន្តិ តេ ខោ តេ មារិស អមនុស្សា មហារាជានំ អវរុទ្ធា នាម វុច្ចន្តិ ។ យោ ហិ កោចិ មារិស អម-នុស្សោ យក្ខោ វា យក្ខិនី វា យក្ខបោតកោ វា

១ ឱ. ម. មហាចោរា ។ ២ ឱ. ម. ហិសទ្ទោ ន ទិស្សតិ ។

ទាំងឡាយក្រោធពិរោធក្រៃលែងជាងហេតុ អមនុស្សទាំងឡាយនោះ មិនធ្វើតាមអាជ្ញានៃស្តេចជាធំ មិនធ្វើតាមអាជ្ញានៃយក្ខ ជាសេនាបតី ២៨ នាក់របស់ស្តេចជាធំនោះ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយរបស់ស្តេចជាធំនោះ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយនោះ ៗ ឯង គេតែងហៅថាជាសត្រូវនឹងស្តេចជាធំ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកចោរក្នុងដែននៃស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃសេនាបតីរបស់ស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃសេនាបតី ជាអ្នកប្រៀប្រដៅរបស់ស្តេចមគធៈ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកមហាចោរទាំងអម្បាលនោះ គេតែងហៅថាជាសត្រូវនឹងស្តេចមគធៈយ៉ាងណាមិញ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មានអមនុស្សទាំង-ឡាយ ជាអ្នក្រោធពិរោធក្រៃលែងជាងហេតុ អមនុស្សទាំងនោះ មិនធ្វើតាមអាជ្ញានៃស្តេចជាធំ មិនធ្វើតាមអាជ្ញានៃសេនាបតីរបស់ស្តេចជាធំ មិនធ្វើតាមអាជ្ញាពួកយក្ខសេនាបតីជាអ្នកប្រៀនប្រដៅ របស់ស្តេចជាធំ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយនោះ ៗ ឯង គេតែងហៅថាជាសត្រូវនឹងស្តេចជាធំយ៉ាងដូច្នោះឯង ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ប្រសិនបើអមនុស្សណាមួយ ជាយក្ខប្រុសក្តី យក្ខស្រីក្តី កូនប្រុសរបស់យក្ខក្តី

១១៤



យក្ខបោតិកា វា យក្ខមហាមត្តោ វា យក្ខបារិសជ្ជោ វា យក្ខបចារោ វា គន្ធព្វោ វា គន្ធព្វី វា គន្ធព្វបោតកោ វា គន្ធព្វបោតិកា វា គន្ធព្វមហាមត្តោ វា គន្ធព្វបារិសជ្ជោ វា គន្ធព្វបចារោ វា កុម្ភណ្ឌោ វា កុម្ភណ្ឌី វា កុម្ភណ្ឌបោតកោ វា កុម្ភណ្ឌបោតិកា វា កុម្ភណ្ឌមហាមត្តោ វា កុម្ភណ្ឌបារិសជ្ជោ វា កុម្ភណ្ឌបចារោ វា នាគោ វា នាគិនី វា នាគបោតកោ វា នាគបោតិកា វា នាគមហាមត្តោ វា នាគបារិសជ្ជោ វា នាគបចារោ វា បទុដ្ឋចិត្តោ ភិក្ខុំ វា ភិក្ខុនឹ វា ឧបាសកំ វា ឧបាសិកំ វា គច្ឆន្តំ វា អនុគច្ឆេយ្យ ឋិតំ វា ឧបតិដ្ឋេយ្យ និសិន្នំ វា ឧបនិសីទេយ្យ និបន្នំ វា ឧបនិបជ្ជេយ្យ ។ ឥមេសំ យក្ខានំ មហាយក្ខានំ សេនាបតីនំ មហាសេនាបតីនំ ឧជ្ឈាបេតព្វំ វិក្កន្ទិតព្វំ វិរវិតព្វំ អយំ យក្ខោ គណ្ហាតិ អយំ យក្ខោ អាវិសតិ អយំ យក្ខោ ហេឋេតិ អយំ យក្ខោ វិហេឋេតិ អយំ យក្ខោ ហឹសតិ អយំ យក្ខោ វិហឹសតិ អយំ យក្ខោ ន មុញ្ចតីតិ ។

កូនស្រីរបស់យក្ខក្តី មហាមាត្ររបស់យក្ខក្តី បរិស័ទរបស់យក្ខក្តី អ្នកបម្រើរបស់យក្ខក្តី គន្ធព្វប្រុសក្តី គន្ធព្វស្រីក្តី កូនប្រុសរបស់គន្ធព្វក្តី កូនស្រីរបស់គន្ធព្វក្តី មហាមាត្យរបស់គន្ធព្វក្តី បរិស័ទរបស់គន្ធព្វក្តី អ្នកបម្រើរបស់គន្ធព្វក្តី កុម្ភណ្ឌប្រុសក្តី កុម្ភណ្ឌស្រីក្តី កូនប្រុសកុម្ភណ្ឌក្តី កូនស្រីកុម្ភណ្ឌក្តី អាមាត្យរបស់កុម្ភណ្ឌក្តី បរិស័ទរបស់កុម្ភណ្ឌក្តី អ្នកបម្រើរបស់កុម្ភណ្ឌក្តី នាគឈ្មោលក្តី នាគញីក្តី កូនឈ្មោលរបស់នាគក្តី កូនញីរបស់នាគក្តី អាមាត្យរបស់នាគក្តី បរិស័ទរបស់នាគក្តី អ្នកបម្រើរបស់នាគក្តី ជាអ្នកមានចិត្តប្រទូស្ត ដើរទៅតាមភិក្ខុ ឬភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងដើរ ឬឈរជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងឈរ ឬអង្គុយជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងអង្គុយ ឬដេកជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងដេក ។ អមនុស្សនោះ ត្រូវបុគ្គលពោលទោស កន្ទក់កន្ទេញ ត្រូវស្រែកប្តឹងដល់ពួកយក្ខ ពួកយក្ខជាធំ ពួកសេនាបតី ពួកសេនាបតីជាធំ ទាំងអម្បាលនេះ ថា យក្ខនេះចាប់គេ យក្ខនេះចូលគេ យក្ខនេះបៀតបៀនគេ យក្ខនេះបៀតបៀនផ្សេង ៗ យក្ខនេះធ្វើទុក្ខគេ យក្ខនេះធ្វើឲ្យគេលំបាក យក្ខនេះមិនលែងគេ ។

[៨៦] កតមេសំ យក្ខានំ មហាយក្ខានំ សេនា-
បតីនំ មហាសេនាបតីនំ ។

ឥន្ទោ សោមោ វរុណោ ច
ភារទ្វាជោ បជាបតិ
ចន្ទនោ កាមសេដ្ឋោ ច
កិន្នុឃណ្ឌុ និឃណ្ឌុ ច ។
បនាទោ ឱបមញ្ញោ ច
ទេវសូតោ ច មាតលិ
ចិត្តសេនោ ច គន្ធព្វោ
នឡោរាជា ជនោសភោ[១] ។
សាតាគិរោ ហេមវតោ
បុណ្ណកោ ករតិយោ គុលោ
សិវកោ មុចលិន្ទោ[២] ច
វេស្សាមិត្តោ យុគន្ធរោ ។
គោបាលោ សុប្បគេធោ[៣] ច
ហិរិ នេត្តិ[៤] ច មន្ទិយោ

១ ឱ. ម. ជនេសភោ ។ ២ ឱ. ម. មុចលិន្ទោ ។ ៣ ម. សុប្បរោធោ ។
៤ ឱ. ហិរី នេត្តី ។

[៨៦] ដល់ពួកយក្ខ ពួកមហាយក្ខ ពួកសេនាបតី ពួកមហាសេនាបតី ដូចម្ដេចខ្លះ ។

យក្ខឈ្មោះឥន្ទៈ ១ សោមៈ ១ វរុណៈ ១ ភារទ្វាជៈ ១ បជាបតិ ១ ចន្ទនៈ ១ កាមសេដ្ឋៈ ១ កិន្នុឃណ្ឌុ ១ និឃណ្ឌុ ១ ។ បនាទៈ ១ ឱបមញ្ញៈ ១ ទេវសូតៈ ១ មាតលិ ១ ចិត្តសេនៈ ១ គន្ធព្វៈ ១ នឡោរាជៈ ១ ជនោសភៈ ១ ។ សាតាគិរៈ ១ ហេមវតៈ ១ បុណ្ណកៈ ១ ករតិយៈ ១ គុលៈ ១ សិវកៈ ១ មុច្ចលិន្ទៈ ១ វេស្សាមិត្តៈ ១ យុគន្ធរៈ ១ ។ គោបាលៈ ១ សុប្បគេធៈ ១ ហិរិ ១ នេត្តិ ១ មន្ទិយៈ ១

បញ្ចាលចណ្ឌោ[១] អាលវកោ
បជុណ្ណោ សុមុខោ[២] ទធិមុខោ
មណិ មានិចរោ ទីឃោ
អថោ សេរិសកោ សហា[៣] ។

[៨៧] ឥមេសំ យក្ខានំ មហាយក្ខានំ សេនាបតីនំ មហាសេនាបតីនំ ឧជ្ឈាបេតព្វំ វិក្កន្ទិតព្វំ វិរវិតព្វំ អយំ យក្ខោ គណ្ហាតិ អយំ យក្ខោ អាវិសតិ អយំ យក្ខោ ហេឋេតិ អយំ យក្ខោ វិហេឋេតិ អយំ យក្ខោ ហឹសតិ អយំ យក្ខោ វិហឹសតិ អយំ យក្ខោ ន មុញ្ចតីតិ ។

[៨៨] អយំ ខោ សា មារិស អាដានាដិយា រក្ខា ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ គុត្តិយា រក្ខាយ អវិហឹសាយ ផាសុវិហារាយាតិ ។ ហន្ទ ចទានិ មយំ មារិស គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ តុម្ហេ មហារាជានោ កាលំ មញ្ញថាតិ ។

បញ្ចាលចន្ទៈ ១ អាលវកៈ ១ បជុណ្ណៈ ១ សុមុខៈ ១ ទធិមុខៈ ១ មណិ ១ មានិចរៈ ១ ទីឃៈ ១ សេរិសកៈ ១ ។

[៨៧] ត្រូវពោលទោស ត្រូវកន្ទក់កន្ទេញ ត្រូវស្រែកប្តឹងដល់ពួកយក្ខ ពួកមហាយក្ខ ពួកសេនាបតី ពួកមហាសេនាបតី ទាំងអម្បាលនេះថា យក្ខនេះចាប់គេ យក្ខនេះចូលគេ យក្ខនេះធ្វើគេឲ្យលំបាក យក្ខនេះមិនលែងគេ ។

[៨៨] បពិត្រព្រះអង្គអ្នកនិទុក្ខ ការរក្សាជាប់តមកអំពីអាដានាដានគរនេះឯង ប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ពួកភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិកា ។ បពិត្រព្រះអង្គអ្នកនិទុក្ខ ល្មើយឥឡូវនេះ ពួកខ្ញុំព្រះអង្គមានរវល់ច្រើន មានកិច្ចគួរធ្វើច្រើន ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំលា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បពិត្រមហារាជទាំងឡាយ ចូរព្រះអង្គកំណត់កាលគួរ ក្នុងកាលឥឡូវនេះចុះ ។

[៨៩] អថខោ ចត្តារោ មហារាជា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយឹសុ ។ តេបិ ខោ យក្ខា ឧដ្ឋាយាសនា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ នាមគោត្តំ សាវេត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ តុណ្ហីភូតា តត្ថេវន្តរធាយឹសុ ។

[៩០] អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ ចត្តារោ មហារាជា មហតិយា ច យក្ខសេនាយ មហតិយា ច គន្ធព្វសេនាយ មហតិយា ច កុម្ភណ្ឌសេនាយ មហតិយា ច នាគសេនាយ ចតុទ្ទិសំ រក្ខំ ឋបេត្វា ចតុទ្ទិសំ គុម្ពំ ឋបេត្វា ចតុទ្ទិសំ ឱវរណំ ឋបេត្វា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ គិជ្ឈកូដំ ឱភាសេត្វា

អាដានាដិយសូត្រ ពោលអំពីរឿងរ៉ាវនៃស្តេចធំទាំង ៤ ជាដើម

[៨៩] លំដាប់នោះ ស្តេចធំទាំង ៤ អង្គក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់ទៅក្នុងទីនោះឯង ។ យក្ខទាំងអម្បាលនោះ លុះក្រោកចាកអាសនៈហើយ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែប្រកាសនាមនិងគោត្រ របស់ខ្លួនហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែនៅស្ងៀមហើយ ក៏បាត់ទៅក្នុងទីនោះ ។

[៩០] លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញ ពួកស្តេចធំទាំង ៤ តាំងការរក្សាក្នុងទិសទាំង ៤ តាំងពលទុកក្នុងទិសទាំង ៤ តាំងអ្នកត្រួតត្រាទុកក្នុងទិសទាំង ៤ ដោយសេនាយក្ខដ៏ច្រើន សេនាគន្ធព្វដ៏ច្រើន សេនាកុម្ភណ្ឌដ៏ច្រើន សេនានាគដ៏ច្រើន លុះវេលារាត្រីកន្លងទៅហើយ ស្តេចទាំងនោះមានពន្លឺរុងរឿង ញុំាងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺ

យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវា-
ទេត្វា ឯកមន្តំ និសីទឹសុ ។ តេបិ ខោ ភិក្ខវេ យក្ខា
អប្បេកច្ចេ មំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេ-
កច្ចេ មយា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ
សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ
យេនាហំ តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ
អប្បេកច្ចេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ
អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ
និសិន្នោ ខោ ភិក្ខវេ វេស្សវណោ មហារាជា មំ ឯត-
ទវោច សន្តិ ហិ ភន្តេ ឧឡារា យក្ខា ភគវតោ
អប្បសន្នា សន្តិ ហិ ភន្តេ ឧឡារា យក្ខា ភគវតោ
បសន្នា សន្តិ ហិ ភន្តេ មជ្ឈិមា យក្ខា ភគវតោ អប្ប-
សន្នា សន្តិ ហិ ភន្តេ មជ្ឈិមា យក្ខា ភគវតោ បសន្នា
សន្តិ ហិ ភន្តេ នីចា យក្ខា ភគវតោ អប្បសន្នា
សន្តិ ហិ ភន្តេ នីចា យក្ខា ភគវតោ បសន្នា

ស្វាងហើយ ក៏នាំគ្នាចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ យក្ខទាំងអម្បាលនោះឯង ពួកខ្លះថ្វាយបង្គំតថាគត ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែប្រណម្យអញ្ជលី ចំពោះតថាគត អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែប្រកាសនាមនិងគោត្រ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែអង្គុយស្ងៀម ៗ ក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចជាធំទ្រង់ព្រះនាមវេស្សវ័ណ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្តាលខ្លះ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្តាលជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាប មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាប ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន

១១៩

## អាដានាដិយសុត្តេ   ចតុម្មហារាជាទិប្បវត្តិកថា

យេកុយ្យេន ខោ បន ភន្តេ យក្ខា អប្បសន្នាយេវ ភគវតោ តំ កិស្ស ហេតុ ភគវា ហិ ភន្តេ បាណាតិបាតា វេរមណិយា ធម្មំ ទេសេតិ អទិន្នាទានា វេរមណិយា ធម្មំ ទេសេតិ កាមេសុ មិច្ឆាចារា វេរមណិយា ធម្មំ ទេសេតិ មុសាវាទា វេរមណិយា ធម្មំ ទេសេតិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណិយា ធម្មំ ទេសេតិ ។ យេកុយ្យេន ខោ បន ភន្តេ យក្ខា អប្បដិវិរតាយេវ បាណាតិបាតា អប្បដិវិរតា អទិន្នាទានា អប្បដិវិរតា កាមេសុ មិច្ឆាចារា អប្បដិវិរតា មុសាវាទា អប្បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា តេសន្តំ ហោតិ អប្បិយំ អមនាបំ សន្តិ ហិ ភន្តេ ភគវតោ សាវកា អរញ្ញេ វនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ តត្ថ សន្តិ ឧឡារា យក្ខា និវាសិនោ យេ ឥមស្មឹ ភគវតោ បាវចនេ អប្បសន្នា តេសំ បសាទាយ ឧគ្គណ្ហាតុ ភន្តេ ភគវា

បពិត្រព្រះអង្គដ៏ចម្រើន ឯយក្ខដែលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគ មានច្រើនណាស់ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាត ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកអទិន្នាទាន ទ្រង់សំដែងធម៌ដើម្បីឲ្យវៀរចាកកាមេសុ-មិច្ឆាចារ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកមុសាវាទ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែយក្ខទាំងឡាយច្រើនណាស់ ដែលមិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទសោះ (ព្រោះហេតុនោះ) អំពើវៀរនោះ មិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់យក្ខទាំងឡាយនោះ បពិត្រព្រះអង្គដ៏ចម្រើន មានសាវ័ករបស់ព្រះមានព្រះភាគ អាស្រ័យនៅសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ មានសូរសព្ទតិកកង់រំពង់តិច ប្រាសចាកសំដីរបស់មនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស គួរជាទីលាក់ខ្លួនពួនអាត្មាបាន ពួកយក្ខជាន់ខ្ពស់ តែងនៅជានិច្ចក្នុងព្រៃនោះក៏មាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់បង្រៀន

អាដានាដិយំ រក្ខំ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ គុត្តិយា រក្ខាយ អវិហឹសាយ ផាសុវិហារ-យាតិ ។ អធិវាសេសិ ខោ អហំ ភិក្ខវេ តុណ្ហីភាវេន ។ អថខោ ភិក្ខវេ វេស្សវណោ មហារាជា មំ អធិវាសនំ វិទិត្វា តាយំ វេលាយំ ឥមំ អាដានាដិយំ រក្ខំ អភាសិ

[៩១] វិបស្សិស្ស នមត្ថុ

ចក្ខុមន្តស្ស សិរីមតោ

សិខិស្សបិ នមត្ថុ

សព្វភូតានុកម្បិនោ ។ បេ ។

(សោយេវ បុរិមោ បេយ្យាលោ[១] វិត្ថារេតព្វោ) ។ អយំ ខោ សា មារិស អាដានាដិយា រក្ខា ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ គុត្តិយា រក្ខាយ អវិហឹសាយ ផាសុវិហារាយាតិ ។

---

១ ឱ. ម. បុរិមបេយ្យាលេន ។

ព្រះបរិត្តសម្រាប់រក្សាក្នុងអាដានាដានគរ ដើម្បីឲ្យពួកយក្ខដែលមិនទាន់ជ្រះថ្លា ក្នុងសាសនាព្រះមានព្រះភាគនេះ បានជ្រះថ្លាឡើង ដើម្បីការគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិកា ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានទទួលនិមន្តដោយតុណ្ហីភាព ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ស្តេចជាធំឈ្មោះវេស្សវ័ណ ជ្រាបច្បាស់នូវតថាគតទទួលនិមន្តហើយ ក៏ប្រកាសព្រះបរិត្តសម្រាប់រក្សា ក្នុងអាដានាដានគរនេះ ក្នុងវេលានោះថា

[៩១] សូមនមស្ការចំពោះព្រះពុទ្ធ ទ្រង់ព្រះនាមវិបស្សី
ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការចំពោះ
ព្រះពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះ
ដល់សត្វទាំងពួងជាប្រក្រតី ។ បេ ។

(បេយ្យាលៈ ដែលមានហើយក្នុងខាងដើមនោះឯង បណ្ឌិត គប្បីឲ្យពិស្តារចុះ) ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ការរក្សាជាប់ទាក់ទង ក្នុងអាដានាដានគរនេះ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។

អាដានាដិយសុត្តេ ចតុម្មហារាជាទិប្បវត្តិកថា

ហន្ទចានិ មយំ មារិស កច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ តុម្ហេ មហារាជានោ កាលំ មញ្ញថាតិ ។ អថខោ ភិក្ខវេ ចត្តារោ មហារាជា ឧដ្ឋាយាសនា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយឹសុ ។ តេបិ ខោ ភិក្ខវេ យក្ខា ឧដ្ឋាយាសនា ។ អប្បេកច្ចេ មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ មយា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ យេនាហំ តេនញ្ជលិម្បណាមេត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ នាមគោត្តំ សាវេត្វា តត្ថេវន្តរធាយឹសុ អប្បេកច្ចេ តុណ្ហីភូតា តត្ថេវន្តរធាយឹសុ ។ ឧគ្គណ្ហាថ ភិក្ខវេ អាដានាដិយំ រក្ខំ បរិយាបុណាថ ភិក្ខវេ អាដានាដិយំ រក្ខំ ធារេថ ភិក្ខវេ

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ណ្ហើយឥឡូវនេះ ពួកខ្ញុំព្រះអង្គមានរវល់ច្រើន មានកិច្ចគួរធ្វើច្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំលា ។ តថាគតពោលតបថា បពិត្រមហារាជ សូមព្រះអង្គទ្រង់កំណត់កាលគួរ ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ស្តេចជាធំទាំង ៤ ក្រោកចាកអាសនៈ ហើយថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយក៏បាត់ទៅ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ យក្ខទាំងអម្បាលនោះឯង លុះក្រោកចាកអាសនៈ ហើយ ពួកខ្លះថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយក៏បាត់ទៅ ក្នុងទីនោះ ពួកខ្លះគ្រាន់តែពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែប្រណម្យអញ្ជលីចំពោះតថាគតហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែប្រកាសនាមនិងគោត្រ ហើយក៏បាត់ទៅ ក្នុងទីនោះ ពួកខ្លះគ្រាន់តែស្ងៀម ៗ ហើយក៏បាត់ទៅ ក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររៀនព្រះបរិត្ត សម្រាប់រក្សាក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទន្ទេញឲ្យចាំស្ទាត់នូវព្រះបរិត្តសម្រាប់រក្សា ក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ

១២២



អាដានាដិយំ រក្ខំ អត្ថសញ្ហិតាយំ ភិក្ខវេ អាដា-នាដិយា រក្ខា ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបា-សិកានំ គុត្តិយា រក្ខាយ អវិហិំសាយ ផាសុវិហារា-យាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

អាដានាដិយសុត្តំ នវមំ និដ្ឋិតំ[១] ។

---

១ ឱ. ម. អាដានាដិយសុត្តំ នវមំ ។

អ្នកទាំងឡាយ ចូរចាំទុកនូវព្រះបរិត្ត សម្រាប់រក្សាក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ ការរក្សាក្នុងអាដានាដានគរនេះ ប្រកបដោយប្រយោជន៍ ប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅជាសុខ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ។ ភិក្ខុទាំងនោះ មានចិត្តត្រេកអរទទួល អនុមោទនានឹងភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ អាដានាដិយសូត្រទី ៩ ។

# សង្គីតិសុត្តំ ទសមំ

[៩២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មល្លេសុ ចារិកញ្ចរមានោ[១] មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ យេន បាវា[២] នាម មល្លានំ នគរំ តទវសរិ ។ តត្រ សុទំ ភគវា បាវាយំ វិហរតិ ចុន្ទស្ស កម្មារបុត្តស្ស អម្ពវនេ ។

[៩៣] តេន ខោ បន សមយេន បាវេយ្យកានំ មល្លានំ ឧព្ភតកំ នាម[៣] នវំ សណ្ឋាគារំ[៤] អចិរការិតំ ហោតិ អនជ្ឈាវុត្ថំ សមណេន វា ព្រាហ្មណេន វា កេនចិ វា មនុស្សភូតេន ។ អស្សោសុំ ខោ បាវេយ្យកា មល្លា ភគវា កិរ មល្លេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ បាវំ អនុប្បត្តោ បាវាយំ វិហរតិ ចុន្ទស្ស កម្មារបុត្តស្ស អម្ពវនេតិ ។ អថខោ បាវេយ្យកា មល្លា យេន ភគវា តេនុបសង្កមឹសុ

១ ឱ. ចារិកំ ចរមានោ ។ ២ ម. បាវំ ។ ៣ ឱ. ឧព្ភដកំ នាម ។ ៤ ម. សន្ធាគារំ ។

# សង្គីតិសូត្រ ទី ១០

[៩២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនមល្លៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ទ្រង់ស្តេចទៅដល់ក្រុងឈ្មោះ បាវា របស់មល្លក្សត្រទាំងឡាយ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងអម្ពវ័នរបស់នាយចុន្ទកម្មារបុត្ត (ជាកូនជាងលោហជាតិ) ទៀបក្រុងបាវានោះ ។

[៩៣] សម័យនោះឯង ពួកមល្លក្សត្រនៅក្នុងក្រុងបាវា បានសាងនូវសណ្ឋាគារថ្មី ៗ ឈ្មោះឧព្ភតកៈ មិនទាន់អស់កាលយូរប៉ុន្មាន សមណៈ ឬព្រាហ្មណ៍ ឬជាតិមនុស្សណាមួយ ក៏មិនទាន់បាននៅអាស្រ័យនៅឡើយ ។ ពួកមល្លក្សត្រអ្នកនៅក្នុងក្រុងបាវា បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរមកកាន់ចារិកក្នុងដែនមល្លៈ ជាមួយនឹងភិក្ខុ-សង្ឃជាច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ទ្រង់ស្តេចមកដល់ក្រុងបាវា គង់នៅក្នុងអម្ពវ័ន របស់នាយចុន្ទកម្មារបុត្ត ទៀបក្រុងបាវា ។ ទើបពួកមល្លក្សត្រ អ្នកនៅក្នុងក្រុងបាវា បានចូលទៅគាល់ព្រះមានព្រះភាគ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ បាវេយ្យកា មល្លា ភគវន្តំ ឯតទវោចុំ ឥទ ភន្តេ បាវេយ្យកានំ មល្លានំ ឧព្ភតកន្នាម[១] នវំ សន្ធាគារំ អចិរការិតំ ហោតិ អនជ្ឈាវុត្ថំ សមណេន វា ព្រាហ្មណេន វា កេនចិ វា មនុស្សភូតេន តញ្ច[២] ខោ ភន្តេ ភគវា បឋមំ បរិភុញ្ជតុ ភគវតា បឋមំ បរិភុត្តំ បច្ឆា បាវេយ្យកា មល្លា បរិភុញ្ជិស្សន្តិ តទស្ស[៣] បាវេយ្យកានំ មល្លានំ ទីឃរត្តំ ហិតាយ សុខាយាតិ ។ អធិវាសេសិ ខោ[៤] ភគវា តុណ្ហីភាវេន ។ អថខោ បាវេយ្យកា មល្លា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន សន្ធាគារំ តេនុបសង្កមឹសុ ឧបសង្កមិត្វា សព្វសន្ថរិំ សន្ធាគារំ[៥] សន្ថរិត្វា[៦] អាសនានិ បញ្ញាបេត្វា ឧទកមណិកំ បតិដ្ឋាបេត្វា តេលប្បទីបំ អារោបេត្វា

---

១ ឱ. ឧព្ភដកំ នាម ។ ២ ឱ. តំ ។ ម. តញ្ច ។ ៣ ឱ. បាវេយ្យកា មល្លា បរិភុញ្ជិស្សន្តិ តទស្សាតិ ន ទិស្សតិ ។ ៤ ឱ. ម. ខោសទ្ទោ ។ ន ទិស្សតិ ។ ៥ ម. សព្វសន្ថរិសន្ថតំ សន្ធាគារំ ។ ៦ ឱ. សន្ថរាបេត្វា ។

លុះចូលទៅដល់ហើយ បានអភិវាទព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះពួកមល្លក្សត្រអ្នកក្រុងបាវា អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ពួកមល្លក្សត្រអ្នកក្រុងបាវា បានសាងនូវសណ្ឋាគារថ្មី ឈ្មោះឧព្ភតកៈ មិនទាន់អស់កាលយូរប៉ុន្មានក្នុងទីនេះ សមណៈ ឬព្រាហ្មណ៍ ឬជាតិមនុស្សណាមួយ ក៏មិនទាន់បាននៅអាស្រ័យនៅឡើយ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ទ្រង់ប្រើប្រាស់សណ្ឋាគារនោះ ជាមុនចុះ លុះព្រះមានព្រះភាគ ប្រើប្រាស់ជាមុនរួចហើយ ពួកមល្លក្សត្រអ្នកក្រុងបាវា នឹងបានប្រើប្រាស់ជាខាងក្រោយ ការប្រើប្រាស់នោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ពួកមល្លក្សត្រអ្នកក្រុងបាវា អស់កាលជាយូរអង្វែង ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះឯង ពួកមល្លក្សត្រអ្នកក្រុងបាវាដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលហើយ ក៏ក្រោកចាកអាសនៈហើយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅរកសណ្ឋាគារ លុះចូលទៅដល់ហើយ បានក្រាលកម្រាល ក្នុងសណ្ឋាគារពេញទាំងអស់ ហើយតាក់តែងអាសនៈទាំងឡាយ តម្កល់ក្អមទឹក អុចប្រទីបប្រេងរួចហើយ ក៏នាំគ្នាចូល

យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តេ[១] ចាវេយ្យកា មល្លា ភគវន្តំ ឯតទវោចុំ សព្វ-សន្ថរិសន្ថតំ[២] ភន្តេ សណ្ឋាគារំ អាសនានិ បញ្ញត្តានិ ឧទកមណិកោ បតិដ្ឋាបិតោ តេលប្បទីបោ អារោ-បិតោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។

[៩៤] អថខោ ភគវា និវាសេត្វា បត្តចីវរមា-ទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន សណ្ឋាគារំ តេនុប-សង្កមិ ឧបសង្កមិត្វា ចាទេ បក្ខាលេត្វា សណ្ឋាគារំ បវិសិត្វា មជ្ឈិមំ ថម្ភំ និស្សាយ បុរត្ថាភិមុខោ និសីទិ ។ ភិក្ខុសង្ឃោបិ ខោ ចាទេ បក្ខាលេត្វា សណ្ឋាគារំ បវិសិត្វា បច្ឆិមំ ភិត្តឹ និស្សាយ បុរត្ថាភិមុខោ និសីទិ ភគវន្តំយេវ បុរក្ខិត្វា[៣] ចាវេយ្យកាបិ ខោ មល្លា ចាទេ បក្ខាលេត្វា សណ្ឋាគារំ បវិសិត្វា បុរត្ថិមំ ភិត្តឹ និស្សាយ

១ ឱ. តេសទ្ទោ ន ទិស្សតិ ។ ២ ឱ. ម. សព្វសន្ថរឹ សន្ថតំ ។ ៣ បរក្ខិត្វាតិបិ បាឋោ ។

ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានអភិវាទព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះពួកមល្លក្សត្រអ្នកក្រុងបាវាឋិតនៅក្នុងទីដ៏សមគួរ ហើយក្រាបបង្គំទូលព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស សណ្ឋាគារ យើងខ្ញុំព្រះអង្គក្រាលដោយកម្រាលសព្វគ្រប់ បានតាក់តែងអាសនៈទាំងឡាយហើយ បានតម្កល់ក្អមទឹកទុកហើយ បានអុចប្រទីបប្រេងរួចហើយ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគសំគាល់នូវកាលគួរ ក្នុងកាលឥឡូវនេះ ។

[៩២] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់និងបាត្រចីវរហើយ ចូលទៅកាន់សណ្ឋាគារ ជាមួយនឹងភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់លាងព្រះបាទទាំងគូហើយ ទ្រង់ចូលទៅកាន់សណ្ឋាគារ គង់ផ្អែកនឹងសសរកណ្ដាល បែរព្រះភក្ត្រទៅទិសខាងកើត ។ ចំណែកខាងភិក្ខុសង្ឃ ក៏លាងបាទា ហើយចូលទៅកាន់សណ្ឋាគារ អង្គុយប្របជញ្ជាំងខាងលិច បែរមុខទៅទិសខាងកើត ឆ្ពោះមុខទៅរកព្រះមានព្រះភាគ ចំណែកខាងពួកមល្លក្សត្រ នៅក្នុងក្រុងបាវាក៏លាងព្រះបាទ ចូលទៅកាន់សណ្ឋាគារ អង្គុយប្របជញ្ជាំងខាងកើត

បច្ឆិមាភិមុខា និសីទឹសុ ភគវន្តំយេវ បុរក្ខិត្វា[១] ។ អថខោ ភគវា ចាវេយ្យកេ មល្លេ ពហុទេវ រត្តឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេ-ជេត្វា សម្បហំសេត្វា ឧយ្យោជេសិ អភិក្កន្តា ខោ វាសេដ្ឋា រត្តិ យស្សទានិ កាលំ មញ្ញថាតិ ។ ឯវំ ភន្តេតិ ខោ ចាវេយ្យកា មល្លា ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។

[៩៥] អថខោ ភគវា អចិរបក្កន្តេសុ ចាវេយ្យ-កេសុ[២] មល្លេសុ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ វិគតថីនមិទ្ធោ ខោ សារីបុត្ត ភិក្ខុសង្ឃោ បដិភាតុ[៣] សារីបុត្ត ភិក្ខូនំ ធម្មិយា កថាយ[៤] បិដ្ឋិ មេ អាគិលាយតិ តមហំ អាយមេយ្យាមីតិ[៥] ។ ឯវំ ភន្តេតិ ខោ អាយស្មា សារីបុត្តោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា

---

១ បរក្ខិត្វាតិបិ បាឋោ ។ ២ ឱ. បាវេយ្យកេសូតិ ន ទិស្សតិ ។ ៣ ឱ. ម. បដិភាតុ តំ ។ ៤ ឱ. ម. ធម្មីកថា ។ ៥ ឱ. ម. អាយមិស្សាមីតិ ។

បែរមុខទៅទិសខាងលិច ឆ្ពោះមុខទៅរកព្រះមានព្រះភាគដែរ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកមល្លក្សត្រអ្នកក្រុងបាវា ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដល់យប់ជ្រៅ ហើយទ្រង់តឿនថា ម្នាលវាសេដ្ឋគោត្រទាំងឡាយ យប់ជ្រៅណាស់ហើយ ចូរអ្នកទាំងឡាយ សំគាល់កាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ពួកមល្លក្សត្រអ្នកក្រុងបាវា ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ អភិវាទព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

[៩៥] លំដាប់នោះឯង កាលដែលពួកមល្លក្សត្រ អ្នកក្រុងបាវា ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ទតឃើញភិក្ខុសង្ឃនៅស្ងៀមស្ងាត់ ក៏ត្រាស់ហៅព្រះសារីបុត្តមានអាយុមកថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកសេចក្តីងងុយងោកងក់ហើយ ម្នាលសារីបុត្ត ចូរអ្នកពន្យល់ភិក្ខុទាំងឡាយដោយធម្មីកថាចុះ តថាគតរោយខ្នងណាស់ តថាគតនឹងតម្រង់ខ្នង (បន្តិច) ។ ព្រះសារីបុត្ត ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះឯង ព្រះមានព្រះភាគ

១២៧

## សង្គីតិសុត្តេ និគណ្ឋនាដបុត្តកាលកិរិយា

ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា ។

[៩៦] តេន ខោ បន សមយេន និគណ្ឋោ នាដ-បុត្តោ បាវាយំ អធុនា កាលកតោ ហោតិ ។ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេឡ្ហកជាតា[១] ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិចរន្តិ[២] ន ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ[៣] កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្ស-សិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតំ មេ អសហិតន្តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណន្តេ វិបរាវត្តំ អា-រោបិតោ តេ វាទោ និគ្គហិតោ ត្វមសិ បរាជប-

១ ឱ. ម. ទ្វេធិកជាតា ។ ២ ម. វិហរន្តិ ។ ៣ ឱ. ម. អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ ។

ទ្រង់ឲ្យក្រាលសង្ឃាដី មានជាន់ ៤ ហើយទ្រង់សម្រេចសីហសេយ្យា ដោយចំហៀងព្រះកាយខាងស្តាំ តម្រួតព្រះបាទលើព្រះបាទ មានព្រះសតិសម្បជញ្ញៈ ធ្វើនូវឧដ្ឋានសញ្ញាទុកក្នុងព្រះហឫទ័យ ។

[៩៦] សម័យនោះឯង និគ្គណ្ឋនាដបុត្ត ទើបធ្វើមរណកាលថ្មី ៗ ក្នុងក្រុងបាវា ។ ដោយកាលកិរិយានៃនិគ្គណ្ឋនាដបុត្តនោះ ពួកនិគ្រន្ថ (ជាសិស្ស) ក៏បែកគ្នាទៅជាពីរពួក កើតប្រកួតប្រកាន់ ឈ្លោះប្រកែកទាស់ទែង ពោលពាក្យចាក់ដោតគ្នានិងគ្នា ដោយលំពែងគឺមាត់ថា អ្នកឯងមិនចេះធម្មវិន័យនេះទេ អ្នកឯងនឹងចេះធម្មវិន័យនេះ ដូចម្តេចបាន អ្នកឯងប្រតិបត្តិខុសទេ យើងជាអ្នកប្រតិបត្តិត្រូវ ពាក្យយើងមានប្រយោជន៍ ពាក្យអ្នកឯងឥតប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកឯងនិយាយក្រោយវិញ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកឯងនិយាយមុនវិញ ពាក្យដែលអ្នកឯងចេះចាំមកជាយូរអង្វែងហើយ ក៏សុទ្ធតែជាពាក្យខុសទទេ ទោសក្នុងវាទៈរបស់អ្នកឯង យើងបានលើកឡើងហើយ អ្នកឯងយើងសង្កត់សង្កិនបានហើយ ចូរអ្នកឯងទៅសិក្សា

មោក្ខាយ[១] និព្វេឋេហិ វា សចេ បហោសីតិ ។ វធោយេវេកោ[២] មញ្ញេ និគណ្ឋេសុ នាដបុត្តិយេសុ អនុវត្តតិ[៣] ។ យេបិ[៤] និគណ្ឋស្ស នាដបុត្តស្ស សាវកា គិហី ឱទាតវសនា តេបិ និគណ្ឋេសុ នាដបុត្តិយេសុ និព្វិន្នរូបា[៥] វិរត្តរូបា[៦] បដិវានរូបា យថា តំ ទុរក្ខាតេ[៧] ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ភិន្នថូបេ អប្បដិសរណេ ។ អថខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ និគណ្ឋោ អាវុសោ នាដបុត្តោ បាវាយំ អធុនា កាលកតោ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេឡ្ហកជាតា[៨] ។ បេ ។

១ ឱ. និគ្គហីតោសិ បរវាទបមោក្ខាយ ។ ២ ឱ. វធោយេវខោ ។ ៣ ឱ. វត្តតិ ។ ៤ ឱ. យេបិ តេ ។ ៥ ម. និព្វិន្នរូបា ។ ៦ ឱ. វិរត្តរូបាតិ ន ទិស្សតិ ។ ៧ ឱ. ទុរក្ខាតេ ។ ៨ ឱ. ម. ទ្វេធិកជាតា ។

ដើម្បីដោះស្រាយនូវទោសក្នុងវាទៈ ឬបើអ្នកឯងអង់អាច ចូរដោះចេញ (ចាកសេចក្តីខុសចុះ) ។ សេចក្តីស្លាប់តែមួយ ក៏ហាក់ដូចជាប្រព្រឹត្ត តាមពួកនិគ្រន្ថដែលជាសិស្សរបស់នាដបុត្ត ។ ពួកសាវ័ករបស់និគ្គណ្ឋ-នាដបុត្តណា ដែលជាគ្រហស្ថ ស្លៀកពាក់សំពត់-ស ពួកសាវ័កទាំងនោះ ក៏មានសេចក្តីនឿយណាយ ធុញទ្រាន់ ជិនឆ្អន់នឹងពួកនិគ្រន្ថ ដែលជាសិស្សរបស់នាដបុត្ត ដូចពួកជនដែលមានសេចក្តីនឿយណាយ ធុញទ្រាន់ ជិនឆ្អន់នឹងធម្មវិន័យ ដែលគេពោលទុក ដោយអាក្រក់ ដែលគេសំដែងទុកដោយអាក្រក់ មិនមែននិយ្យានិកធម៌ មិនមែនប្រព្រឹត្ត ទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនមែនជាធម្មវិន័យ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងទុកហើយ ជាធម្មវិន័យមានទីពឹងបែកធ្លាយហើយ ជាធម្មវិន័យ មិនមានទីពឹងឡើយ ។ លំដាប់នោះឯង ព្រះសារីបុត្តមានអាយុហៅ ភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ និគ្គណ្ឋនាដបុត្ត ធ្វើ មរណកាលហើយថ្មី ៗ ក្នុងក្រុងបាវា ដោយកាលកិរិយានៃនិគ្គណ្ឋនាដបុត្ត នោះ ពួកនិគ្រន្ថ ក៏បែកគ្នាទៅជាពីរពួក ។ បេ ។ ជាធម្មវិន័យមាន

១២៩

## សង្គីតិសុត្តេ អទ្ធនិយព្រហ្មចរិយកថា

ភិន្នថូបេ អប្បដិសរណោ ឯវញ្ចេតំ អាវុសោ ហោតិ[១] ទុរក្ខាតេ ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ។ អយំ ខោ បនាវុសោ អម្ហាកំ ភគវតា ធម្មោ ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ តត្ថ សព្វេហេវ សង្គាយិតព្វំ ន វិវទិតព្វំ យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមោ ចាវុសោ អម្ហាកំ[២] ភគវតា ធម្មោ ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ តត្ថ សព្វេហេវ សង្គាយិតព្វំ

---

១ ឱ. ហោតីតិ ន ទិស្សតិ ។ ២ ឱ. អស្មាកំ ។

ទីពឹងបែកធ្លាយហើយ ជាធម្មវិន័យមិនមានទីពឹងឡើយ ម្នាលអាវុសោទាំងឡាយ ដំណើរនោះប្រព្រឹត្តទៅក្នុងធម្មវិន័យ ដែលបុគ្គលពោលទុកអាក្រក់ហើយ ដែលបុគ្គលប្រកាសទុកអាក្រក់ហើយ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ មិនមែនជាធម៌វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទុកយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌នេះឯង ព្រះមានព្រះភាគនៃយើងទាំងឡាយ បានពោលទុកល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងទុកហើយ គួរតែយើងទាំងអស់គ្នាសង្គាយនា[១] ក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះឋិតថេរតាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះឯងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលព្រះមានព្រះភាគនៃយើងទាំងឡាយពោលទុកល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយនោះ ដូចម្ដេចខ្លះ គួរយើងទាំងអស់គ្នាសង្គាយនាក្នុងធម៌

១ ប្រែថា និយាយ ឬពោល ដោយសេចក្ដីព្រមព្រៀងគ្នា ។

ន វិវទិតព្វំ យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

[៩៧] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកោ ធម្មោ សម្មទក្ខាតោ តត្ថ សព្វេហេវ សង្គាយិតព្វំ ន វិវទិតព្វំ យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមោ ឯកោ ធម្មោ ។ សព្វេ សត្តា អាហារដ្ឋិតិកា សព្វេ សត្តា សង្ខារដ្ឋិតិកា ។ អយំ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន

នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះ ឋិតថេរតាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះឯងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

[៩៧] ម្នាលអាវុសោទាំងឡាយ ធម៌ ១ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ គួរតែយើងទាំងអស់គ្នា សង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះ ឋិតថេរតាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ១ នោះ តើដូចម្តេច ។ ពួកសត្វទាំងអស់ឋិតនៅបានព្រោះអាស្រ័យអាហារ ពួកសត្វទាំងអស់ឋិតនៅបាន ព្រោះអាស្រ័យសង្ខារ[១] ។ ម្នាលអាវុសោទាំងឡាយ នេះឯងជាធម៌ ១ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុក

១ សំដៅយកអវិជ្ជា តណ្ហា កម្ម អាហារជាដើម ។

១៣១

សង្គីតិសុត្តេ សង្គីតិយទុកំ

ឯកោ ធម្មោ សម្មទក្ខាតោ តត្ថ សព្វេហេវ សង្គាយិ-
តព្វំ ន វិវទិតព្វំ យថយិទំ ព្រហ្មចរិយំ អស្ស ចិរដ្ឋិ-
តិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ
លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវ-
មនុស្សានំ ។

សង្គីតិយឯកកំ និដ្ឋិតំ[1] ។

[៩៨] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា
បស្សតា អរហតា សម្មាសម្ពុទ្ធេន ទ្វេ ធម្មា សម្ម-
ទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថា-
យ ហិតាយ សុខាយ ទេវមនុស្សានំ ។ កាត-
មេ ទ្វេ ធម្មា[2] ។ នាមញ្ច រូបញ្ច ។ អវិជ្ជា ច

១ ឱ. ម. សង្គីតិយឯកកំ និដ្ឋិតន្តិ ន ទិស្សតិ ។ ២ ឱ. ម. កតមេ ទ្វេ ។

ហើយដោយប្រពៃ យើងទាំងអស់គ្នាគួរតែសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះ ឋិតថេរតាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ពួកធម៌មួយ ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[៩៨] ម្នាលអាវុសោទាំងឡាយ មានធម៌ពីរ ៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ យើងទាំងអស់គ្នាគួរតែសង្គាយនាក្នុងធម៌នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ពួកធម៌ពីរ ៗ តើអ្វីខ្លះ ។ ពួកធម៌ពីរ ៗ នោះគឺ នាម[១] ១ រូប[២] ១ ។ អវិជ្ជា[៣] ១

១ ប្រែថាញ៉ាំងគ្នានិងគ្នាឲ្យទន់ទៅក្នុងអារម្មណ៍ បានដល់អរូបក្ខន្ធទាំង ៤ គឺវេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ និងព្រះនិព្វាន ។ ២ ប្រែថា វិនាស ថា លំបាក ដោយក្តៅត្រជាក់ជាដើម បានដល់មហាភូតរូបទាំង ៤ និងឧបាទាយរូប ២៤ ។ ៣ សេចក្តីមិនដឹងក្នុងអរិយសច្ចមានទុក្ខសច្ចជាដើម ។

ភវតណ្ហា ច ។ ភវទិដ្ឋិ ច វិភវទិដ្ឋិ ច ។ អហិរិកញ្ច អនោត្តប្បញ្ច ។ ហិរិ ច ឱត្តប្បញ្ច ។ ទោវចស្សតា ច បាបមិត្តតា ច ។ សោវចស្សតា ច កល្យាណ-មិត្តតា ច ។ អាបត្តិកុសលតា ច អាបត្តិវុដ្ឋាន-កុសលតា ច ។ សមាបត្តិកុសលតា ច សមា-បត្តិវុដ្ឋានកុសលតា ច ។ ធាតុកុសលតា ច មន-សិការកុសលតា ច ។ អាយតនកុសលតា ច បដិច្ចសមុប្បាទកុសលតា ច ។ ឋានកុសលតា ច អដ្ឋានកុសលតា ច ។ អាជ្ជវញ្ច មទ្ទវញ្ច[១] ។ ខន្តិ ច សោរច្ចញ្ច ។ សាខល្យញ្ច បដិសន្ថា-រោ ច ។ អវិហឹសា ច សោចេយ្យញ្ច ។ មុដ្ឋ-ស្សច្ចញ្ច អសម្បជញ្ញញ្ច ។ សតិ ច សម្បជញ្ញញ្ច ។

១ ឱ. អជ្ជវញ្ច លជ្ជវញ្ច ។ ម. អជ្ជវញ្ច មទ្ទវញ្ច ។ អដ្ឋកថាយម្បន អាជ្ជវំ លជ្ជវន្តិ ទិស្សតិ ។

*ភវតណ្ហា[១] ១ ។ ភវទិដ្ឋិ[២] ១ វិភវទិដ្ឋិ[៣] ១ ។ សេចក្តីមិនខ្មាសបាប ១ សេចក្តីមិនក្តៅនឹងបាប ឬមិនខ្លាចបាប ១ ។ សេចក្តីខ្មាសបាប ១ សេចក្តីក្តៅនឹងបាប ១ ។ ភាវៈជាអ្នកដែលគេប្រដៅក្រ ១ ភាវៈជាអ្នកមានមិត្តអាក្រក់ ១ ។ ភាវៈជាអ្នកដែលគេប្រដៅងាយ ១ ភាវៈជាអ្នកមានមិត្តល្អ ១ ។ សេចក្តីឈ្លាសក្នុងអាបត្តិ ១ សេចក្តីឈ្លាសក្នុងការចេញចាកអាបត្តិ ១ ។ សេចក្តីឈ្លាសក្នុងសមាបត្តិ ១ សេចក្តីឈ្លាសក្នុងការចេញចាកសមាបត្តិ ១ ។ សេចក្តីឈ្លាសក្នុងធាតុ ១ សេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត ១ ។ សេចក្តីឈ្លាសក្នុងអាយតនៈ ១ សេចក្តីឈ្លាសក្នុងបដិច្ចសមុប្បាទធម៌ ១ ។ សេចក្តីឈ្លាសក្នុងហេតុ ១ សេចក្តីឈ្លាសក្នុងមិនមែនហេតុ ១ ។ សេចក្តីស្លូតត្រង់ ១ ចិត្តទន់ ១ ។ សេចក្តីអត់ធ្មត់ ១ ការប្រព្រឹត្តល្អ ឬស្លូតមិនកោងកាច ១ ។ ពាក្យពីរោះ ១ ការទទួលរាក់ទាក់ ១ ។ សេចក្តីមិនបៀតបៀន[៤] ១ សេចក្តីស្អាត[៥] ១ ។ សេចក្តីភ្លាំងភ្លាត់សតិ ១ មិនដឹងខ្លួន ១ ។ សេចក្តីរឭក ១ ដឹងខ្លួន ១ ។*

---

១ សេចក្តីប្រាថ្នា សេចក្តីត្រេកត្រអាលក្នុងភព ។ ២ បានដល់សស្សតទិដ្ឋិ សេចក្តីយល់ឃើញថា លោកទៀង ។ ៣ បានដល់ឧច្ឆេទទិដ្ឋិ សេចក្តីយល់ឃើញថា សត្វស្លាប់ទៅសូន្យមិនកើតទៀតឡើយ ។ ៤ បានដល់ករុណា គឺសេចក្តីអាណិត អនុគ្រោះសព្វសត្វ ។ ៥ បានដល់មេត្តា គឺសេចក្តីរាប់អានស្រឡាញ់សព្វសត្វ ។

១៣៣

សង្គីតិសុត្តេ សង្គីតិយទុកំ

ឥន្ទ្រិយេសុ អគុត្តទ្វារតា ច ភោជនេ អមត្តញ្ញុតា ច ។ ឥន្ទ្រិយេសុ គុត្តទ្វារតា ច ភោជនេ មត្តញ្ញុតា ច ។ បដិសង្ខានពលញ្ច ភាវនាពលញ្ច ។ សតិពលញ្ច សមាធិពលញ្ច ។ សមថោ ច វិបស្សនា ច ។ សមថនិមិត្តញ្ច បគ្គាហនិមិត្តញ្ច ។ បគ្គាហោ ច អវិក្ខេបោ ច ។ សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច ។ សីលសម្បទា ច ទិដ្ឋិសម្បទា ច[១] ។ សីលវិសុទ្ធិ ច ទិដ្ឋិវិសុទ្ធិ ច ។ ទិដ្ឋិវិសុទ្ធិ ខោ បន យថាទិដ្ឋិស្ស ច បធានំ ។ សំវេគោ ច សំវេជនីយេសុ ឋានេសុ សំវិគ្គស្ស ច យោនិសោ បធានំ ។ អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ អប្បដិវានិតា ច បធានស្មឹ ។ វិជ្ជា ច វិមុត្តិ ច ។

---

១ ឱ. សីលសម្បទា ច ទិដ្ឋិសម្បទា ច ។ សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច ។

សង្គីតិសូត្រ ពួកធម៌ពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

*ភាវៈជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាវៈជាអ្នកមិនដឹងប្រមាណក្នុងភោជន ១ ។ ភាវៈជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាវៈជាអ្នកដឹងប្រមាណក្នុងភោជន ១ ។ កម្លាំងគឺប្រាជ្ញាជាគ្រឿងពិចារណា ១ កម្លាំងគឺភាវនា[១] ១ ។ កម្លាំងគឺសតិ ១ កម្លាំងគឺសមាធិ ១ ។ សមថៈ (ធម៌សម្រាប់រម្ងាប់ចិត្ត) ១ វិបស្សនា (ប្រាជ្ញាឃើញច្បាស់នូវនាមរូប) ១ ។ សមថនិមិត្ត[២] ១ បគ្គហនិមិត្ត[៣] ១ ។ សេចក្តីព្យាយាម[៤] ១ សេចក្តីមិនរាយមាយ[៥] ១ ។ សីលវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ សីលសម្បទា ១ ទិដ្ឋិសម្បទា ១ ។ សេចក្តីបរិសុទ្ធនៃសីល ១ សេចក្តីបរិសុទ្ធនៃទិដ្ឋិ ១ ។ សេចក្តីបរិសុទ្ធនៃទិដ្ឋិ គឺញាណទស្សនៈ ១ សេចក្តីព្យាយាមនៃបុគ្គលដែលមានសេចក្តីយល់ឃើញតាមពិត[៦] ១ ។ សេចក្តីសង្វេគក្នុងហេតុ[៧] ទាំងឡាយគួរសង្វេគ ១ សេចក្តីព្យាយាម[៨] ដោយឧបាយរបស់បុគ្គលអ្នកមានចិត្តសង្វេគ ១ ។ សេចក្តីមិនសន្តោសក្នុងកុសលធម៌ទាំងឡាយ ១ ។ មិនរួញរាក្នុងសេចក្តីព្យាយាម ១ ។ វិជ្ជា[៩] ១ វិមុត្តិ[១០] ១ ។*

---

១ សំដៅយកពោជ្ឈង្គទាំង ៧ ប្រការ ។ ២ ហេតុនៃសេចក្តីរម្ងាប់ចិត្ត បានដល់សម្មាសមាធិ ។ ៣ ហេតុនៃសេចក្តីព្យាយាម បានដល់សម្មាវាយាមៈ ។ ៤ បានដល់សម្មាវាយាមៈ ។ ៥ បានដល់សម្មាសមាធិ ។ ៦ សេចក្តីព្យាយាមដែលប្រកបដោយញាណទស្សនៈនោះ ។ ៧ បានដល់ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ។ ៨ បានដល់សម្មប្បធានទាំង ៤ ។ ៩ បានដល់វិជ្ជា ៣ ។ ១០ បានដល់វិមុត្តិពីរ គឺចិត្តស្សអធិមុត្តិ សេចក្តីរួចចាកនីវរណធម៌នៃចិត្ត បានដល់អដ្ឋសមាបត្តិ ១ ព្រះនិព្វាន ១ ។

ខយេ ញាណំ អនុប្បាទេ ញាណំ ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មា-សម្ពុទ្ធេន ទ្វេ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ សុខាយ ទេវមនុស្សានន្តិ[១] ។

សង្គីតិយទុកំ និដ្ឋិតំ[២] ។

[៩៩] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តយោ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កាតមេ តយោ ធម្មា[៣] ។ តីណិ អកុសលមូលានិ លោភោ អកុសលមូលំ ទោសោ អកុសលមូលំ មោហោ អកុសលមូលំ ។ តីណិ កុសលមូលានិ អលោភោ

១ ឱ. ម. ទេវមនុស្សានំ ។ ២ ឱ. ម. សង្គីតិយទុកំ និដ្ឋិតន្តិ ន ទិស្សតិ ។ ៣ ឱ. ម. កតមេ តយោ ។

សេចក្តីដឹងក្នុងអរិយមគ្គជាគ្រឿងអស់ទៅនៃកិលេស ១ សេចក្តីដឹងក្នុងអរិយផល ដែលធ្វើសត្វមិនឲ្យកើតឡើងដោយបដិសន្ធិ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងជាពួកធម៌ពីរ ៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ យើងទាំងអស់គ្នា គួរតែសង្គាយនាក្នុងធម៌នោះ ។ បេ ។ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌ពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[៩៩] ម្នាលអាវុសោទាំងឡាយ មានពួកធម៌បី ៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ គួរតែយើងទាំងអស់គ្នា សង្គាយនាក្នុងធម៌នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ពួកធម៌បី ៗ តើអ្វីខ្លះ ។ ពួកធម៌បី ៗ គឺឫសអកុសល ៣ យ៉ាង គឺលោភៈជាឫសនៃអកុសល ១ ទោសៈជាឫសនៃអកុសល ១ មោហៈជាឫសនៃអកុសល ១ ។ ឫសកុសល ៣ យ៉ាងគឺ អលោភៈ

សង្គីតិសុត្តេ សង្គីតិយត្តិកំ

កុសលមូលំ អទោសោ កុសលមូលំ អមោហោ កុសលមូលំ ។ តីណិ ទុច្ចរិតានិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ តីណិ សុចរិតានិ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ។ តយោ អកុសលវិតក្កា កាមវិតក្កោ ព្យាបាទវិតក្កោ[១] វិហឹសាវិតក្កោ ។ តយោ កុសលវិតក្កា នេក្ខម្មវិតក្កោ អព្យាបាទវិតក្កោ អវិហឹសាវិតក្កោ ។ តយោ អកុសលសង្កប្បា កាមសង្កប្បោ ព្យាបាទសង្កប្បោ វិហឹសាសង្កប្បោ ។ តយោ កុសលសង្កប្បា នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ ។ តិស្សោ អកុសលសញ្ញា កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ។ តិស្សោ កុសលសញ្ញា នេក្ខម្មសញ្ញា អព្យាបាទសញ្ញា

១ ឱ. វ្យាបាទវិតក្កោ ។

ឫសនៃកុសល ១ អទោសៈ ជាឫសនៃកុសល ១ អមោហៈ ជាឫសនៃកុសល ១ ។ ទុច្ចរិត ៣ យ៉ាង គឺ ទុច្ចរិតដោយកាយ ១ ទុច្ចរិតដោយវាចា ១ ទុច្ចរិតដោយចិត្ត ១ ។ សុចរិត ៣ យ៉ាង គឺ សុចរិតដោយកាយ ១ សុចរិតដោយវាចា ១ សុចរិតដោយចិត្ត ១ ។ សេចក្តីត្រិះរិះជាអកុសល ៣ យ៉ាង គឺ សេចក្តីត្រិះរិះប្រកបដោយកាម ១ សេចក្តីត្រិះរិះប្រកបដោយព្យាបាទ ១ សេចក្តីត្រិះរិះប្រកបដោយការបៀតបៀន ១ ។ សេចក្តីត្រិះរិះជាកុសល ៣ យ៉ាង គឺ សេចក្តីត្រិះរិះប្រកបដោយការចេញចាកកាម ១ សេចក្តីត្រិះរិះប្រកបដោយការមិនព្យាបាទ ១ សេចក្តីត្រិះរិះប្រកបដោយការមិនបៀតបៀន ១ ។ តម្រិះជាអកុសល ៣ យ៉ាង គឺ តម្រិះប្រកបដោយកាម ១ តម្រិះប្រកបដោយការព្យាបាទ ១ តម្រិះប្រកបដោយការបៀតបៀន ១ ។ តម្រិះជាកុសល ៣ យ៉ាង គឺ តម្រិះប្រកបដោយការចេញចាកកាម ១ តម្រិះប្រកបដោយការមិនព្យាបាទ ១ តម្រិះប្រកបដោយការមិនបៀតបៀន ១ ។ សេចក្តីសំគាល់ជាអកុសល ៣ យ៉ាង គឺ សេចក្តីសំគាល់ប្រកបដោយកាម ១ សេចក្តីសំគាល់ប្រកបដោយព្យាបាទ ១ សេចក្តីសំគាល់ប្រកបដោយការបៀតបៀន ១ ។ សេចក្តីសំគាល់ជាកុសល ៣ យ៉ាង គឺ សេចក្តីសំគាល់ប្រកបដោយការចេញចាកកាម ១ សេចក្តីសំគាល់ប្រកបដោយការមិនព្យាបាទ ១

អវិហឹសាសញ្ញា ។ តិស្សោ អកុសលធាតុយោ កាម-
ធាតុ ព្យាបាទធាតុ វិហឹសាធាតុ ។ តិស្សោ កុសល-
ធាតុយោ នេក្ខម្មធាតុ អព្យាបាទធាតុ អវិហឹសាធា-
តុ ។ អបរាបិ តិស្សោ ធាតុយោ កាមធាតុ រូបធាតុ
អរូបធាតុ ។ អបរាបិ តិស្សោ ធាតុយោ រូបធាតុ
អរូបធាតុ និរោធធាតុ ។ អបរាបិ តិស្សោ ធាតុយោ
ហីនធាតុ មជ្ឈិមធាតុ បណីតធាតុ[១] ។ តិស្សោ
តណ្ហា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ អបរាបិ
តិស្សោ តណ្ហា កាមតណ្ហា រូបតណ្ហា អរូបតណ្ហា ។

---

១ ឱ. ហីនា ធាតុ មជ្ឈិមា ធាតុ បណីតា ធាតុ ។

សេចក្ដីសំគាល់ប្រកបដោយការមិនបៀតបៀន ១ ។ ធាតុជាអកុសល ៣ យ៉ាង គឺ ធាតុប្រកបដោយកាម[១] ១ ធាតុប្រកបដោយព្យាបាទ ១ ធាតុប្រកបដោយការបៀតបៀន ១ ។ ធាតុជាកុសល ៣ យ៉ាង គឺ ធាតុប្រកបដោយការចេញចាកកាម[២] ១ ធាតុប្រកបដោយការមិនព្យាបាទ ១ ធាតុប្រកបដោយការមិនបៀតបៀន ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺ ធាតុប្រកបដោយកាម[៣] ១ ធាតុប្រកបដោយរូប ១ ធាតុប្រកបដោយអរូប ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺ ធាតុប្រកបដោយរូប ១ ធាតុប្រកបដោយអរូប ១ ធាតុប្រកបដោយសេចក្ដីរលត់ គឺ ព្រះនិព្វាន ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺ ធាតុយ៉ាងទាប[៤] ១ ធាតុយ៉ាងកណ្ដាល[៥] ១ ធាតុយ៉ាងឧត្ដម[៦] ១ ។ តណ្ហា ៣ យ៉ាង គឺ កាមតណ្ហា[៧] ១ ភវតណ្ហា[៨] ១ វិភវតណ្ហា[៩] ១ ។ តណ្ហា ៣ យ៉ាងដទៃទៀត គឺ កាមតណ្ហា ១ រូបតណ្ហា[១០] ១ អរូបតណ្ហា[១១] ១ ។

---

១ ក្នុងទីនេះសំដៅយកមិច្ឆាសង្កប្ប គឺតម្រិះខុស ។ ២ ក្នុងទីនេះសំដៅយកសម្មាសង្កប្ប គឺតម្រិះត្រូវ ។ ៣ ធាតុក្នុងទីនេះ សំដៅយកភព ។ ៤ សំដៅយកអកុសលចិត្តុប្បាទទាំង ១២ ។ ៥ សំដៅយកតេភូមិកធម៌ ក្រៅពីអកុសលចិត្តុប្បាទនោះ ។ ៦ សំដៅយកនវលោកុត្តរធម៌ ។ ៧ បានដល់តម្រេកដែលប្រព្រឹត្តទៅក្នុងកាមគុណទាំង ៥ ។ ៨ សេចក្ដីអាល័យក្នុងឈាន ក្នុងរូបភពនិងអរូបភព ឬតម្រេកប្រកបដោយសស្សតទិដ្ឋិ ។ ៩ តម្រេកប្រកបដោយឧច្ឆេទទិដ្ឋិ ។ ១០ ឆន្ទរាគក្នុងរូបភព ។ ១១ ឆន្ទរាគក្នុងអរូបភព ១ ។

១៣៧



អបរាបិ តិស្សោ តណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា ។ តីណិ សញ្ញោជនានិ សក្កា- យទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ។ តយោ អាសវា កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ តយោ ភវា កាមភវោ រូបភវោ អរូបភវោ ។ តិស្សោ ឯសនា កាមេសនា ភវេសនា ព្រហ្មចរិ- យេសនា ។ តិស្សោ វិធា សេយ្យោហមស្មីតិ វិធា សទិសោហមស្មីតិ វិធា ហីនោហមស្មីតិ វិធា ។ តយោ អទ្ធា អតីតោ អទ្ធា អនាគតោ អទ្ធា បច្ចុប្បន្នោ អទ្ធា ។ តយោ អន្តា សក្កាយោ

តណ្ហា ៣ យ៉ាងដទៃទៀត គឺ រូបតណ្ហា ១ អរូបតណ្ហា ១ និរោធ-តណ្ហា[១] ១ ។ សញ្ញោជនៈ ៣ យ៉ាង គឺ សក្កាយទិដ្ឋិ[២] ១ វិចិកិច្ឆា[៣] ១ សីលព្វតបរាមាស[៤] ១ ។ អាសវៈ ៣ យ៉ាង គឺ កាមាសវៈ[៥] ១ ភវា-សវៈ[៦] ១ អវិជ្ជាសវៈ[៧] ១ ។ ភព ៣ យ៉ាង គឺ កាមភព[៨] ១ រូប-ភព[៩] ១ អរូបភព[១០] ១ ។ ការស្វែងរក ៣ យ៉ាង គឺ ការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្មចរិយធម៌[១១] ១ ។ មានៈ ៣ យ៉ាង គឺ មានះថាអាត្មាអញប្រសើរជាងគេ ១ មានះថាអាត្មាអញស្មើនឹងគេ ១ មានះថាអាត្មាអញអន់ជាងគេ ១ ។ កាល ៣ យ៉ាង គឺ អតីតកាល ១ អនាគតកាល ១ បច្ចុប្បន្នកាល ១ ។ អន្តៈ គឺចំណែក ៣ យ៉ាង គឺ

---

១ តម្រេកប្រកបដោយឧច្ឆេទទិដ្ឋិ ។ ២ សេចក្តីយល់ខុសមាននៅក្នុងកាយ គឺខន្ធទាំង ៥ មានរូបក្ខន្ធជាដើម ។ ៣ សេចក្តីសង្ស័យក្នុងគុណព្រះរត្នត្រ័យជាដើម ។ ៤ សេចក្តីប្រកាន់ខុសដោយសីលនិងវ័ត គឺប្រកាន់សីលនិងវ័តខាងក្រៅព្រះពុទ្ធសាសនា ដែលមិនបរិសុទ្ធថាបរិសុទ្ធវិញ ។ ៥ ក្នុងគម្ពីរធម្មសង្គណិថា សេចក្តីត្រេកត្រអាលក្នុងកាមហៅថា កាមាសវៈ ។ ៦ សេចក្តីត្រេកត្រអាលក្នុងភពហៅថា ភវាសវៈ ។ ៧ សេចក្តីមិនដឹងក្នុងអរិយសច្ចទាំង ៤ ជាដើមហៅថា អវិជ្ជា ។ ឯអាសវសព្ទនេះ ប្រែថា ត្រាំនៅអស់កាលយូរ ។ ៨ ប្រទេសជាទីកើតនៃសត្វដែលមានអារម្មណ៍ប្រកបដោយកាម រាប់តាំងអំពីអវីចិនរក រហូតដល់កាមាវចរទេវ-លោក ។ ៩ ប្រទេសជាទីកើតនៃសត្វដែលប្រកបដោយរូបជ្ឈាន គឺរូបព្រហ្មទាំង ១៦ ជាន់ ។ ១០ ប្រទេសជាទីកើតនៃសត្វដែលប្រកបដោយអរូបជ្ឈាន គឺអរូបព្រហ្មទាំង ៤ ជាន់ ។ ១១ បានដល់មិច្ឆាទិដ្ឋិ មានសស្សតទិដ្ឋិជាដើម ។

អដ្ឋោ សក្កាយសមុទយោ អដ្ឋោ សក្កាយនិរោធោ អដ្ឋោ ។ តិស្សោ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ តិស្សោ ទុក្ខតា ទុក្ខទុក្ខតា សង្ខារទុក្ខតា វិបរិណាមទុក្ខតា ។ តយោ រាសី មិច្ឆត្តនិយតោ រាសិ សម្មត្តនិយតោ រាសិ អនិយតោ រាសិ ។ តិស្សោ កង្ខា អតីតំ វា អទ្ធានំ អារព្ភ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ អនាគតំ វា អទ្ធានំ អារព្ភ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ឯតរហិ វា បច្ចុប្បន្នំ អទ្ធានំ អារព្ភ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ តីណិ តថាគតស្ស អរក្ខេយ្យានិ បរិសុទ្ធកាយសមាចារោ អាវុសោ តថាគតោ នត្ថិ តថាគតស្ស កាយទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ

សក្កាយ[១]ជាចំណែក ១ ធម៌ជាគ្រឿងកើត[២]នៃសក្កាយជាចំណែក ១ ធម៌ជាគ្រឿងរលត់[៣]នៃសក្កាយជាចំណែក ១ ។ វេទនា ៣ យ៉ាងគឺ សុខវេ-ទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ សេចក្តីលំបាក ៣ យ៉ាងគឺ លំបាកព្រោះសេចក្តីទុក្ខ[៤] ១ លំបាកព្រោះសង្ខារ[៥] ១ លំបាកព្រោះសេចក្តីប្រែប្រួល[៦] ១ ។ គំនរ ៣ យ៉ាង គឺ សភាវៈខុសដ៏ទៀងទាត់[៧] ជាគំនរ ១ សភាវៈត្រូវដ៏ទៀងទាត់[៨]ជាគំនរ ១ សភាវៈមិនទៀងទាត់[៩]ជាគំនរ ១ ។ សេចក្តីសង្ស័យ ៣ យ៉ាងគឺ បុគ្គលរមែងសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះស្រឡះព្រោះប្រារព្ធនូវអតីតកាល ១ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះស្រឡះព្រោះប្រារព្ធនូវអនាគតកាល ១ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះស្រឡះព្រោះប្រារព្ធនូវបច្ចុប្បន្នកាល ១ ។ អំពើដែលព្រះតថាគត មិនចាំបាច់រក្សា ឬរវាំងមាន ៣ យ៉ាងគឺ ម្នាលអាវុសោទាំងឡាយ ព្រះតថាគតមានកាយសមាចារបរិសុទ្ធ ព្រះតថាគត គប្បីរក្សា នូវកាយទុច្ចរិតណាថា

---

១ បានដល់ឧបាទានក្ខន្ធទាំង ៥ ។ ២ បានដល់បុរិមតណ្ហា ។ ៣ បានដល់ព្រះនិព្វាន ។ ៤ បានដល់ទុក្ខវេទនា ។ ៥ បានដល់ឧបេក្ខាវេទនា ។ ៦ បានដល់សុខវេទនា បានសេចក្តីថា បើសេចក្តីសុខប្រែប្រួលទៅហើយ សេចក្តីទុក្ខក៏ត្រឡប់កើតឡើងវិញ ។ ៧ បានដល់និយ-តមិច្ឆាទិដ្ឋិ និងអនន្តរិយកម្មទាំង ៥ ។ ៨ បានដល់អរិយមគ្គទាំង ៤ ។ ៩ បានដល់ធម៌ដទៃចាកធម៌ទាំង ៣ ពួកនោះ គឺនិយតមិច្ឆាទិដ្ឋិ ១ អនន្តរិយកម្ម ១ អរិយមគ្គ ១ ។

មា មេ ឥទំ បរេ អញ្ញាសីតិ បរិសុទ្ធវចីសមាចារោ អាវុសោ តថាគតោ នត្ថិ តថាគតស្ស វចីទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរេ អញ្ញាសីតិ បរិសុទ្ធមនោសមាចារោ អាវុសោ តថាគតោ នត្ថិ តថាគតស្ស មនោទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរេ អញ្ញាសីតិ ។ តយោ កិញ្ចនា រាគោ កិញ្ចនំ ទោសោ កិញ្ចនំ មោហោ កិញ្ចនំ ។ តយោ អគ្គី រាគគ្គិ ទោសគ្គិ មោហគ្គិ ។ អបរេបិ តយោ អគ្គី អាហុនេយ្យគ្គិ ទក្ខិណេយ្យគ្គិ គហបតគ្គិ[១] ។ តិវិធេន រូបសង្គហោ សនិទស្សនសប្បដិឃរូបំ អនិទស្សនសប្បដិឃរូបំ អនិទស្សនអប្បដិឃរូបំ[២] ។

---

១ ឱ. ម. គហបតគ្គិ ទក្ខិណេយ្យគ្គិ ។ ២ ឱ. ម. សនិទស្សនសប្បដិឃំ រូបំ អនិទស្សនសប្បដិឃំ រូបំ អនិទស្សនអប្បដិឃំ រូបំ ។

អ្នកដទៃ កុំបីដឹងនូវកាយទុច្ចរិតរបស់អញនេះ កាយទុច្ចរិតនោះមិនមានដល់ព្រះតថាគតឡើយ ១ ម្នាលអាវុសោទាំងឡាយ ព្រះតថាគតមានវចីសមាចារបរិសុទ្ធ ព្រះតថាគតគប្បីរក្សានូវវចីទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវវចីទុច្ចរិតរបស់អញនេះ វចីទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ ១ ម្នាលអាវុសោទាំងឡាយ ព្រះតថាគត មានមនោសមាចារបរិសុទ្ធ ព្រះតថាគត គប្បីរក្សានូវមនោទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវមនោទុច្ចរិតរបស់អញនេះ មនោទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ ១ ។ កង្វល់ ៣ យ៉ាង គឺ រាគៈជាកង្វល់ ១ ទោសៈជាកង្វល់ ១ មោហៈជាកង្វល់ ១ ។ ភ្លើង ៣ យ៉ាង ភ្លើងគឺរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ ។ ភ្លើង ៣ យ៉ាងដទៃទៀត ភ្លើងគឺអាហុនេយ្យបុគ្គល ១ ភ្លើងគឺទក្ខិណេយ្យបុគ្គល ១ ភ្លើងគឺគហបតី ១ ។ ការរាប់នូវរូបដោយចំណែក ៣ គឺ រូបប្រកបដោយការឃើញផង ប្រកបដោយការប៉ះពាល់ផង[១] ១ រូបមិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់[២] ១ រូបមិនប្រកបដោយការឃើញផង មិនប្រកបដោយការប៉ះពាល់ផង[៣] ១ ។

---

១ បានដល់រូបាយតនៈតែមួយយ៉ាង ។ ២ បានដល់អាយតនៈទាំង ៩ គឺចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ សទ្ទាយតនៈ ១ គន្ធាយតនៈ ១ រសាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ ។ ៣ បានដល់សុខុមរូបក្រៅអំពីអាយតនៈទាំង ១០ ។

តយោ សង្ខារា បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ ។ តយោ បុគ្គលា សេក្ខោ បុគ្គលោ អសេក្ខោ បុគ្គលោ នេវសេក្ខោ នាសេក្ខោ បុគ្គលោ ។ តយោ ថេរា ជាតិត្ថេរោ ធម្មត្ថេរោ សម្មតិត្ថេរោ ។ តីណិ បុញ្ញកិរិយាវត្ថូនិ ទានមយំ បុញ្ញកិរិយាវត្ថុ សីលមយំ បុញ្ញកិរិយាវត្ថុ ភាវនាមយំ បុញ្ញកិរិយាវត្ថុ ។ តីណិ ចោទនាវត្ថូនិ ទិដ្ឋេន សុតេន បរិសង្កាយ ។ តិស្សោ កាមុបបត្តិយោ សន្តាវុសោ

*សង្ខារ ៣ យ៉ាង គឺ បុញ្ញាភិសង្ខារ[១] ១ អបុញ្ញាភិសង្ខារ[២] ១ អានេញ្ជាភិសង្ខារ[៣] ១ ។ បុគ្គល ៣ ពួក គឺ បុគ្គលជាសេក្ខៈ[៤] ១ បុគ្គលជាអសេក្ខៈ[៥] ១ បុគ្គលមិនមែនជាសេក្ខៈមិនមែនជាអសេក្ខៈ[៦] ១ ។ ភិក្ខុចាស់មាន ៣ ពួក គឺ ចាស់ដោយជាតិ ១ ចាស់ដោយធម៌ ១ ចាស់ដោយការសន្មត ។ បុញ្ញកិរិយាវត្ថុ ៣ យ៉ាង គឺ បុញ្ញកិរិយាវត្ថុសម្រេចដោយទាន ១ បុញ្ញកិរិយាវត្ថុសម្រេចដោយសីល ១ បុញ្ញកិរិយាវត្ថុសម្រេចដោយភាវនា ១ ។ ហេតុនៃការចោទ ៣ យ៉ាង គឺ ដោយឃើញ[៧] ១ ដោយឮ[៨] ១ ដោយរង្កៀស[៩] ១ ។ ការសេពកាម ៣ យ៉ាង ម្នាលអាវុសោទាំងឡាយ*

---

១ បានដល់ចេតនា ១៣ គឺកាមាវចរកុសលចេតនា ៨ និងរូបាវចរកុសលចេតនា ៥ ប្រព្រឹត្តទៅដោយអំណាចភាវនា ។ ២ បានដល់អកុសលចេតនា ១២ ។ ៣ បានដល់អរូបាវចរកុសលចេតនា ៤ ប្រព្រឹត្តទៅដោយអំណាចភាវនា ។ ឯសង្ខារសព្ទនេះ ប្រែថា សភាវៈធ្វើនូវសហជាតធម៌និងសម្បរាយផលធម៌ឲ្យជាគំនរ ។ ៤ បានដល់បុគ្គល ៧ ពួក មានបុគ្គលដល់នូវសោតាបត្តិមគ្គជាដើម មានបុគ្គលដែលបានដល់នូវអរហត្តមគ្គជាទីបំផុត ។ ៥ បានដល់អរហត្តផល ។ ៦ បានដល់បុគ្គលជាបុថុជ្ជន ។ ៧ ឃើញនូវការល្មើសដោយមំសចក្ខុ ឬទិព្វចក្ខុ ហើយចោទ ។ ៨ ឮសំដីរបស់បុគ្គលដទៃដោយបកតិសោត ឬទិព្វសោត ហើយចោទ ។ ៩ ចោទដោយសេចក្ដីរង្កៀស ព្រោះឃើញ ព្រោះឮ ព្រោះប៉ះពាល់ ដោយឃានបសាទ ជិវ្ហាបសាទ កាយបសាទ ។

១៤១



សត្តា បច្ចុបដ្ឋិតកាមា តេ បច្ចុបដ្ឋិតេសុ កាមេសុ វសំ វត្តេន្តិ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា កាមុបបត្តិ សន្តាវុសោ សត្តា និម្មិតកាមា តេ និម្មិនិត្វា និម្មិនិត្វា[១] កាមេសុ វសំ វត្តេន្តិ សេយ្យថាបិ ទេវា និម្មានរតី អយំ ទុតិយា កាមុបបត្តិ សន្តាវុសោ សត្តា បរនិម្មិតកាមា តេ បរនិម្មិតេសុ កាមេសុ វសំ វត្តេន្តិ សេយ្យថាបិ ទេវា បរនិម្មិតវសវត្តី អយំ តតិយា កាមុបបត្តិ ។ តិស្សោ សុខុបបត្តិយោ សន្តាវុសោ សត្តា សុខំ ឧប្បាទេត្វា ឧប្បាទេត្វា សុខំ វិហរន្តិ សេយ្យថាបិ ទេវា ព្រហ្មកាយិកា អយំ បឋមា សុខុបបត្តិ សន្តាវុសោ សត្តា សុខេន អភិសន្នា បរិសន្នា បរិបូរា បរិប្ផុដា តេ

---

១ ឱ. និម្មេត្វា និម្មេត្វា ។

ពួកសត្វមានកាមទាំងឡាយ ពួកសត្វទាំងនោះ ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមទាំងឡាយដែលតាំងឡើង ដូចជាមនុស្សទាំងអស់ និងទេវតាពួក[១]ខ្លះ និងវិនិបាតិក[២]ពួកខ្លះ នេះជាការសេពកាមទី ១ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាមដែលខ្លួននិម្មិតហើយ ពួកសត្វទាំងនោះ លុះនិម្មិតហើយ ៗ ក៏ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមទាំងឡាយ ដូចជាពួកទេវតា ក្នុងជាន់និម្មានរតី នេះជាការសេពកាមទី ២ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាមដែលទេវតាដទៃនិម្មិតឲ្យ ពួកសត្វទាំងនោះ ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមទាំងឡាយ ដែលទេវតាដទៃនិម្មិតឲ្យ ដូចជាពួកទេវតាក្នុងជាន់បរនិម្មិតវសវត្តី នេះជាការសេពកាមទី ៣ ។ ការបានសេចក្តីសុខ ៣ យ៉ាង ម្នាលអាវុសោទាំងឡាយ មានពួកសត្វធ្វើនូវសេចក្តីសុខ[៣] ឲ្យកើតឡើងរឿយ ៗ ហើយទទួលនូវសេចក្តីសុខ (នោះ) ដូចជាពួកទេវតានៅក្នុងពួកព្រហ្មលោក នេះជាការបាននូវសេចក្តីសុខទី ១ ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលដោកជាំជ្រួតជ្រាបបរិបូណ៌ពាល់ត្រូវដោយសេចក្តីសុខហើយ ពួកសត្វទាំងនោះ

---

១ បានដល់កាមាវចរទេវតាទាំង ៤ ជាន់គឺ ចាតុម្មហារាជិកា ១ តាវតិង្ស ១ យាមា ១ តុសិត ១ ។ ២ បានដល់អបាយិកសត្វទាំង ៣ វៀរលែងនរកចេញ ។ ៣ អដ្ឋកថា ថា ធ្វើសេចក្តីសុខក្នុងបឋមជ្ឈានខាងក្រោមឲ្យកើត ហើយសោយនូវសេចក្តីសុខ ដែលកើតអំពីផលរបស់ឈានជាខាងលើ ។

កទាចិ ករហចិ ឧទានំ ឧទានេន្តិ អហោ សុខំ អហោ សុខន្តិ សេយ្យថាបិ ទេវា អាភស្សរា អយំ ទុតិយា សុខុបបត្តិ សន្តាវុសោ សត្តា សុខេន អភិសន្នា បរិសន្នា បរិបូរា បរិប្ផុដា តេ សន្តំយេវ សំតុសិតា[១] ចិត្តសុខំ បដិវេទេន្តិ[២] សេយ្យថាបិ ទេវា សុភកិណ្ហា[៣] អយំ តតិយា សុខុបបត្តិ ។ តិស្សោ បញ្ញា សេក្ខា បញ្ញា អសេក្ខា បញ្ញា នេវសេក្ខានាសេក្ខា បញ្ញា ។ អបរាបិ តិស្សោ បញ្ញា ចិន្តាមយា បញ្ញា សុតមយា បញ្ញា ភាវនាមយា បញ្ញា ។ តីណាវុធានិ សុតាវុធំ បវិវេកាវុធំ បញ្ញាវុធំ ។ តីណិន្ទ្រិយានិ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ

---

១ សន្តុសិតាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ឱ. តុសិតា ។ ២ ឱ. សុខំ បដិសំវេទេន្តិ ។ ៣ ឱ. សុភកិណ្ណា ។

ជូនកាលបន្លឺឧទានក្នុងកាលម្តង ៗ ថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎ ដូចជាពួកទេវតានៅក្នុងជាន់អាភស្សរព្រហ្មលោក នេះជាការបាននូវសេចក្តីសុខទី ២ ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលដោកជាំជ្រួតជ្រាបបរិបូណ៌ពាល់ត្រូវដោយសេចក្តីសុខហើយ ពួកសត្វទាំងនោះ សន្តោសនឹងសេចក្តីសុខដ៏ល្អិតប៉ុណ្ណោះ ទទួលសេចក្តីសុខក្នុងចិត្ត ដូចពួកទេវតានៅក្នុងជាន់សុភកិណ្ហព្រហ្មលោក នេះជាការបាននូវសេចក្តីសុខទី ៣ ។ បញ្ញា ៣ យ៉ាង គឺ បញ្ញាជារបស់សេក្ខបុគ្គល ១ បញ្ញាជារបស់អសេក្ខបុគ្គល ១ បញ្ញាជារបស់នេវសេក្ខានាសេក្ខបុគ្គល ១ ។ បញ្ញា ៣ យ៉ាងដទៃទៀត គឺបញ្ញាសម្រេចមកអំពីការគិត ១ បញ្ញាសម្រេចមកអំពីការស្តាប់ ១ បញ្ញាសម្រេចមកអំពីការចម្រើន ១ ។ អាវុធ ៣ យ៉ាង បានដល់អាវុធ គឺសុតៈ (ពុទ្ធវចនៈ) ១ អាវុធគឺសេចក្តីស្ងាត់[១] ១ អាវុធគឺបញ្ញា ១ ។ ឥន្ទ្រិយ ៣ យ៉ាង គឺ ឥន្ទ្រិយដែលកើតឡើងដល់បុគ្គលអ្នកប្រតិបត្តិដោយគិតថា អាត្មាអញនឹងបានដឹងនូវធម៌ដែលមិនទាន់បានដឹង (សោតាបត្តិមគ្គញ្ញាណ) ១ ឥន្ទ្រិយគឺញាណជាគ្រឿងដឹងច្បាស់ (សោតាបត្តិផលញ្ញាណ ។ ល ។ អរហត្តមគ្គញ្ញាណ) ១ ឥន្ទ្រិយគឺសេចក្តីដឹងក្នុងធម៌

---

១ ស្ងាត់កាយ ស្ងាត់ចិត្ត ស្ងាត់ចាកឧបធិ ។

១៤៣



អញ្ញាតាវិន្ទ្រិយំ ។ តីណិ ចក្ខូនិ មំសចក្ខុ ទិព្វចក្ខុ បញ្ញាចក្ខុ ។ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ តិស្សោ ភាវនា កាយភាវនា ចិត្តភាវនា បញ្ញាភាវនា ។ តីណិ អនុត្តរិយានិ[១] ទស្សនានុត្តរិយំ បដិបទានុត្តរិយំ វិមុត្តានុត្តរិយំ ។ តយោ សមាធី សវិតក្កវិចារោ[២] សមាធិ អវិតក្កវិចារមត្តោ[៣] សមាធិ អវិតក្កវិចារោ[៤] សមាធិ ។

---

១ ឱ. តីណានុត្តរិយានិ ។ ២ ឱ. សវិតក្កោ សវិចារោ ។ ៣ ឱ. អវិតក្កោ វិចារមត្តោ ។ ៤ ឱ. អវិតក្កោ អវិចារោ ។

*ដែលបុគ្គលគួរដឹងច្បាស់ ជាធម៌ដល់នូវទីបំផុតនៃកិច្ចដោយកិរិយាដឹង (អរហត្តផលញ្ញាណ) ១ ។ ចក្ខុ ៣ យ៉ាងគឺ មំសចក្ខុ[១] ១ ទិព្វចក្ខុ[២] ១ បញ្ញាចក្ខុ[៣] ១ ។ សិក្ខា ៣ យ៉ាង គឺ អធិសីលសិក្ខា[៤] ១ អធិចិត្តសិក្ខា[៥] ១ អធិប្បញ្ញាសិក្ខា[៦] ១ ។ ភាវនា ៣ យ៉ាង គឺ កាយភាវនា[៧] ១ ចិត្តភាវនា[៨] ១ បញ្ញាភាវនា[៩] ១ ។ អនុត្តរិយៈ ៣ យ៉ាង គឺ ទស្សនានុត្តរិយៈ[១០] ការឃើញដ៏ប្រសើរ ១ បដិបទានុត្តរិយៈ[១១] សេចក្តីប្រតិបត្តិដ៏ប្រសើរ ១ វិមុត្តានុត្តរិយៈ[១២] ការរួចចាកកិលេសដ៏ប្រសើរ ១ ។ សមាធិ ៣ យ៉ាង គឺ សមាធិប្រកបដោយវិតក្កវិចារៈ[១៣] ១ សមាធិមិនមានវិតក្កៈ មានត្រឹមតែវិចារៈ[១៤] ១ សមាធិមិនមានវិតក្កនិងវិចារៈ[១៥] ១ ។*

---

១ បានដល់ភ្នែកសាច់ធម្មតា គឺចក្ខុបសាទ ។ ២ បានដល់ញាណដែលអាស្រ័យនូវពន្លឺ ។ ៣ បានដល់លោកិយបញ្ញា និងលោកុត្តរបញ្ញា ។ ៤ បានដល់បាតិមោក្ខសំវរសីល ។ ៥ បានដល់ឈានជាទីតាំងនៃវិបស្សនា ។ ៦ បានដល់វិបស្សនា ។ ៧ បានដល់កាយរបស់ព្រះខីណាស្រពដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ។ ៨ បានដល់សមាបត្តិទាំង ៨ ។ ៩ បានដល់អរហត្តផលបញ្ញា ។ ១០ បានដល់វិបស្សនា ។ ១១ បានដល់មគ្គ ។ ១២ បានដល់ផល ។ ន័យមួយទៀតថា ទស្សនានុត្តរិយៈបានដល់ផល ។ បដិបទានុត្តរិយៈ បានដល់មគ្គ ។ វិមុត្តានុត្តរិយៈ បានដល់ព្រះនិព្វាន (អដ្ឋកថា) ។ ១៣ បានដល់បឋមជ្ឈាន ។ ១៤ បានដល់ទុតិយជ្ឈាន ។ ១៥ បានដល់តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន ។

អបរេបិ តយោ សមាធី សុញ្ញតោ សមាធិ អនិមិត្តោ សមាធិ អប្បណិហិតោ សមាធិ ។ តីណិ សោចេយ្យានិ កាយសោចេយ្យំ វចីសោចេយ្យំ មនោសោចេយ្យំ ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។ តីណិ កោសល្លានិ អាយកោសល្លំ អចាយកោសល្លំ ឧចាយកោសល្លំ ។ តយោ មទា អារោគ្យមទោ យោព្វនមទោ ជាតិមទោ ។ តីណាធិបតេយ្យានិ អត្តាធិបតេយ្យំ លោកាធិបតេយ្យំ ធម្មាធិបតេយ្យំ ។ តីណិ កថាវត្ថូនិ អតីតំ វា អទ្ធានំ អារព្ភ

សមាធិ ៣ យ៉ាងដទៃទៀត គឺ សុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ សេចក្តីស្អាត ៣ យ៉ាងគឺ សេចក្តីស្អាតដោយកាយ ១ សេចក្តីស្អាតដោយវាចា ១ សេចក្តីស្អាតដោយចិត្ត ១ ។ ច្បាប់[១] អ្នកប្រាជ្ញ ៣ យ៉ាង គឺ ច្បាប់អ្នកប្រាជ្ញផ្លូវកាយ ១ ច្បាប់អ្នកប្រាជ្ញផ្លូវវាចា ១ ច្បាប់អ្នកប្រាជ្ញផ្លូវចិត្ត ១ ។ សេចក្តីឈ្លាស ៣ យ៉ាង គឺ សេចក្តីឈ្លាសក្នុងការចម្រើន ១ សេចក្តីឈ្លាសក្នុងការវិនាស ១ សេចក្តីឈ្លាសក្នុងឧបាយ[២] ១ ។ សេចក្តីស្រវឹង ៣ យ៉ាង គឺ ស្រវឹងដោយការមិនមានរោគ ១ ស្រវឹងដោយវ័យ ១ ស្រវឹងដោយជាតិត្រកូល ១ ។ អធិបតេយ្យ ៣ យ៉ាង គឺ អត្តាធិបតេយ្យ[៣] ១ លោកាធិបតេយ្យ[៤] ១ ធម្មាធិបតេយ្យ[៥] ១ ។ កថាវត្ថុ ៣ យ៉ាង គឺ បុគ្គលប្រារព្ធអតីតកាល

---

១ សេចក្តីប្រតិបត្តិធ្វើមនុស្សឲ្យទៅជាអ្នកប្រាជ្ញ ។ ២ ហេតុរបស់ផលនោះ ៗ ។ ៣ ការធ្វើខ្លួនឲ្យជាធំហើយមិនធ្វើបាប ។ ៤ ការធ្វើលោកឲ្យជាធំហើយមិនធ្វើបាប ។ ៥ ការធ្វើលោកុត្តរធម៌ឲ្យជាធំហើយមិនធ្វើបាប ។ ក្នុងគម្ពីរវិសុទ្ធិមគ្គសីលនិទ្ទេសថា បុគ្គលមានប្រាថ្នានឹងលះបង់នូវអំពើដែលមិនសមគួរដល់ខ្លួន ហើយមានសេចក្តីគោរពក្នុងខ្លួនហើយប្រព្រឹត្តនូវសីលណា សីលនោះហៅថា អត្តាធិបតេយ្យសីល ។ បុគ្គលមានប្រាថ្នានឹងចៀសវាងពាក្យនិន្ទាអំពីសត្វលោក ហើយមានសេចក្តីគោរពចំពោះលោក ហើយប្រព្រឹត្តនូវសីលណា សីលនោះហៅថា លោកាធិបតេយ្យសីល ។ បុគ្គលមានប្រាថ្នានឹងបូជានូវធម៌ដ៏ថ្លៃថ្លា ហើយមានសេចក្តីគោរពក្នុងធម៌ ហើយប្រព្រឹត្តនូវសីលណា សីលនោះហៅថា ធម្មាធិបតេយ្យសីល ។

កថំ កាថេយ្យំ ឯវំ អហោសិ អតីតមទ្ធានន្តិ[១] អនាគតំ វា អទ្ធានំ អារព្ភ កថំ កាថេយ្យ ឯវំ ភវិស្សតិ អនាគតមទ្ធានន្តិ ឯតរហិ វា បច្ចុប្បន្នំ អទ្ធានំ អារព្ភ កថំ កាថេយ្យ ឯវំ ឯតរហិ បច្ចុប្បន្នន្តិ ។ តិស្សោ វិជ្ជា បុព្វេនិវាសានុស្សតិញ្ញាណំ វិជ្ជា សត្តានំ ចុតូបបាតេ ញាណំ វិជ្ជា អាសវានំ ខយេ ញាណំ វិជ្ជា ។ តយោ វិហារា ទិព្វោ[២] វិហារោ ព្រហ្មវិហារោ អរិយោ វិហារោ ។ តីណិ បាដិហារិយានិ ឥទ្ធិប្បាដិហារិយំ អាទេ-សនាបាដិហារិយំ អនុសាសនីបាដិហារិយំ ។ ឥ-មេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តយោ ធម្មា

---

១ ឱ. អតីតំ អទ្ធានន្តិ ។ ២ ឱ. ម. ទិព្វោ ។

និយាយពាក្យថា រឿងយ៉ាងនេះកើតមានក្នុងអតីតកាលហើយ ១ បុគ្គលប្រារព្ធអនាគតកាលនិយាយពាក្យថា រឿងយ៉ាងនេះនឹងមានក្នុងអនាគត-កាល ១ បុគ្គលប្រារព្ធបច្ចុប្បន្នកាលក្នុងកាលឥឡូវនេះ និយាយពាក្យថា រឿងយ៉ាងនេះកើតឡើងក្នុងកាលឥឡូវនេះ ១ ។ វិជ្ជា ៣ យ៉ាង គឺ ញាណជាគ្រឿងរឭកឃើញនូវខន្ធបញ្ចកៈ ដែលធ្លាប់នៅអាស្រ័យក្នុងកាលមុន ជាវិជ្ជា ១ សេចក្ដីដឹងក្នុងចុតិនិងបដិសន្ធិរបស់ពួកសត្វ ជាវិជ្ជា ១ សេចក្ដីដឹងក្នុងធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ ជាវិជ្ជា ១ ។ វិហារធម៌ (ធម៌ជាគ្រឿងនៅ) ៣ យ៉ាងគឺ ទិព្វវិហារ[១] ១ ព្រហ្មវិហារ[២] ១ អរិយវិហារ[៣] ១ ។ បាដិហារ្យ ៣ យ៉ាង គឺ ឥទ្ធិបាដិហារ្យ[៤] ១ អាទេសនាបាដិហារ្យ[៥] ១ អនុសាសនីបាដិ-ហារ្យ[៦] ១ ។ ម្នាលអាវុសោទាំងឡាយ ពួកធម៌បី ៗ ទាំងនេះឯង ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញ

---

១ បានដល់សមាបត្តិទាំង ៨ ។ ២ អប្បមញ្ញា ៤ គឺមេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។ ៣ ផលសមាបត្តិ ។ ៤ សេចក្ដីអស្ចារ្យដោយឫទ្ធិ ។ ៥ សេចក្ដីអស្ចារ្យដោយទាយចិត្តសត្វដទៃ ។ ៦ សេចក្ដីអស្ចារ្យដោយការប្រៀនប្រដៅដោយសីលសមាធិបញ្ញា ។ ចូរមើលក្នុងកេវដ្តសូត្រសីលក្ខន្ធវគ្គ ។

សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ន វិវ-
ទិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ
ទេវមនុស្សានំ ។

សង្គីតិយត្តិកំ និដ្ឋិតំ[១] ។

[១០០] អត្ថិ ខោ អាវុសោ តេន ភគវតា
ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ
ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ
។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។
កតមេ ចត្តារោ ។ ចត្តារោ សតិបដ្ឋានា ឥធាវុសោ
ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្ប-
ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-
នស្សំ ។ វេទនាសុ វេទនា ។ ចិត្តេ ចិត្តា ។

១ ឱ. ម. សង្គីតិយត្តិកំ និដ្ឋិតន្តិ ន ទិស្សតិ ។

ច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ គួរយើងទាំងអស់គ្នាសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ពួកធម៌បី ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[១០០] ម្នាលអាវុសោទាំងឡាយ ពួកធម៌បួន ៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ គួរយើងទាំងអស់គ្នា សង្គាយនាក្នុងធម៌នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ពួកធម៌បួន ៗ តើដូចម្តេច ។ សតិបដ្ឋាន ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណារឿយ ៗ នូវកាយក្នុងកាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងដោយល្អ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក[១] ១ ។ ពិចារណារឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ ១ ។ ពិចារណារឿយ ៗ នូវចិត្តក្នុងចិត្ត ១ ។

[១] សំដៅយកកាយ ឬឧបាទានក្ខន្ធទាំង ៥ ។

សង្គីតិសុត្តេ សង្គីតិយចតុក្កំ

ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[១០១] ចត្តារោ សម្មប្បធានា ឥធាវុសោ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

ពិចារណារឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងដោយល្អ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ១ ។

[១០១] សម្មប្បធាន ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈ[១] ឲ្យកើតឡើង សង្វាត ប្រារព្ធ ព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបិទអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធនូវសេចក្ដីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាតប្រារព្ធនូវសេចក្ដីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត បណ្ដុះបណ្ដាលកុសលធម៌ទាំងឡាយដែលមិនទាន់កើតឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធ នូវសេចក្ដីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីឲ្យកុសលធម៌ទាំងឡាយដែលកើតហើយ ឲ្យឋិតនៅមិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ជំទូលាយ ចម្រើនពេញលេញ ។

---

១ សេចក្ដីប្រាថ្នា ឬថាសេចក្ដីពេញចិត្តក្នុងកុសលធម៌ ។

[១០២] ចត្តារោ ឥទ្ធិបាទា ឥធាវុសោ ភិក្ខុ ឆន្ទសមាធិបធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិបធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិបធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិបធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[១០៣] ចត្តារិ ឈានានិ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិ-ចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្ប-ជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា

[១០២] ឥទ្ធិបាទ ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ[១] ដែលប្រកបដោយឆន្ទសមាធិ[២] និងបធានសង្ខារ[៣] ១ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិ-បាទដែលប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

[១០៣] ឈាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់នោះ ១ ភិក្ខុព្រោះស្ងប់ស្ងាត់ចាកវិតក្កៈវិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺ សទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈមានតែបីតិនិងសុខៈដែលកើតអំពីសមាធិគឺ បឋមជ្ឈាន ១ ភិក្ខុព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈ

---

១ ធម៌ជាជើងនៃឫទ្ធិ ឬថា ជាទីតាំងនៃឫទ្ធិ ។ ២ សមាធិមានឆន្ទៈជាហេតុ ឬថា សមាធិអាស្រ័យនូវឆន្ទៈ ។ ៣ បានដល់សម្មប្បធានទាំង ៤ ។

សង្គីតិសុត្តំ សង្គីតិយចតុក្កំ

អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។

[១០៤] ចតស្សោ សមាធិភាវនា អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ ។ អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ញាណទស្សនប្បដិលាភាយ សំវត្តតិ ។ អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ ។ អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ ។ កតមា ចាវុសោ[១] សមាធិភាវនា

---

១ ឱ. កតមាវុសោ ។

ទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ១ ភិក្ខុព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខគឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ១ ។

[១០៤] សមាធិភាវនា[១] ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១ ។ ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ[២] ១ ។ ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ ១ ។ ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនា

---

១ ការធ្វើសមាធិឲ្យដុះដាលឡើង ។ ២ បានដល់មគ្គញ្ញាណ ផលញ្ញាណ សព្វញ្ញុតញ្ញាណ បច្ចវេក្ខណញ្ញាណនិងវិបស្សនាញាណ ។

ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ ។ កតមា ចាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ញាណទស្សនប្បដិលាភាយ សំវត្តតិ ។ ឥធាវុសោ ភិក្ខុ អាលោកសញ្ញំ មនសិករោតិ ទិវាសញ្ញំ អធិដ្ឋាតិ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្ប-ភាសំ ចិត្តំ ភាវេតិ អយំ អាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ញាណទស្សនប្បដិលាភាយ សំវត្តតិ ។ កតមា ចាវុសោ សមាធិភាវនា ភា-វិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ ។

ដូចម្តេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនា ដូចម្តេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា[១] អធិដ្ឋាននូវទិវាសញ្ញាថា[២] ថ្ងៃយ៉ាងណា យប់យ៉ាងនោះ យប់យ៉ាងណា ថ្ងៃយ៉ាងនោះ មានចិត្តបើកចេញស្រឡះ ឥតមានអ្វីរួបរឹតបិទបាំង ចម្រើនចិត្តដែលប្រកបដោយពន្លឺ ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្តេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ ។

១ សេចក្តីសំគាល់ក្នុងពន្លឺ ។ ២ សេចក្តីសំគាល់ថាថ្ងៃ ។

១៤១

## សង្គីតិសុត្តេ  សង្គីតិយចតុក្កំ

ឥធាវុសោ ភិក្ខុនោ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ អយំ អាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ ។ កតមា ចាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ ។ ឥធាវុសោ ភិក្ខុ បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ។ ឥតិ វេទនា ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោ[១] អយំ អាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ ។

១ ឱ. អត្ថង្គមោតិ ។

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ វេទនាកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង សញ្ញាកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង វិតក្កៈកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្ដេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណារឿយ ៗ នូវសេចក្ដីកើតឡើងនិងសូន្យទៅក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការលត់ទៅនៃរូបដូច្នេះ ។ វេទនាដូច្នេះ ។ សញ្ញាដូច្នេះ ។ សង្ខារដូច្នេះ ។ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការលត់ទៅនៃវិញ្ញាណដូច្នេះ ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

[១០៥] ចតស្សោ អប្បមញ្ញា ឥធាវុសោ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា ។ មុទិតាសហគតេន ចេតសា ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាស-ហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។

[១០៥] អប្បមញ្ញា ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង[១] មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ១ ។ មានចិត្តប្រកបដោយករុណា ១ ។ មានចិត្តប្រកបដោយមុទិតា ១ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ១ ។

---

១ សំដៅយកទិសតូចទាំង ៤ គឺទិសអាគ្នេយ៍ ឦសាន និរតី ពាយព្យ ។

សង្គីតិសុត្តេ សង្គីតិយចតុក្កំ

[១០៦] ចត្តារោ អរូបា ឥធាវុសោ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១០៦] អរូបជ្ឈាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះការប្រព្រឹត្តកន្លងនូវរូបសញ្ញា[១] ដោយប្រការទាំងពួង ព្រោះការអស់បដិឃសញ្ញា[២] ព្រោះការលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា[៣] ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ១ ព្រោះប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ១ ព្រោះប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ១ ព្រោះប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំងបួន ១ ។

---

១ ប្រែថា សេចក្តីសំគាល់ក្នុងរូប ។ ឯរូបក្នុងទីនេះសំដៅយករូបាវចរជ្ឈានផង អារម្មណ៍របស់រូបាវចរជ្ឈាននោះផង ។ ២ ប្រែថា សេចក្តីសំគាល់កើតឡើងដោយការប៉ះពាល់ គឺចក្ខុប៉ះពាល់នឹងរូបជាដើម ។ ៣ គឺសញ្ញាផ្សេង ៗ គ្នា មាន ៤៤ គឺកាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយសញ្ញា ១១ ។

[១០៧] ចត្តារិ អបស្សេនានិ ឥធាវុសោ ភិក្ខុ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតិ ។

[១០៨] ចត្តារោ អរិយវំសា ឥធាវុសោ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិ-យា ច វណ្ណវាទី ន ច ចីវរហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច ចីវរំ ន បរិតស្សតិ លទ្ធា ច ចីវរំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរចីវរ-សន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ

[១០៧] អបស្សេនធម៌ គឺធម៌ជាទីពឹងផ្អែក ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយទើបសេពនូវរបស់ដែលគួរសេព[១] ១ ពិចារណាហើយ អត់សង្កត់នូវហេតុដែលគួរអត់សង្កត់[២] ១ (ពិចារណា) ហើយ វៀរនូវរបស់ដែលគួរវៀរ[៣] ១ (ពិចារណា) ហើយ បន្ទោបង់នូវហេតុដែលគួរបន្ទោបង់[៤] ១ ។

[១០៨] អរិយវង្ស[៥] ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោស ដោយចីវរណានីមួយ តែងសរសើរគុណនៃសេចក្តីសន្តោស ដោយចីវរណានីមួយ មិនដល់នូវការស្វែងរកដែលមិនសមគួរ ព្រោះហេតុតែចីវរ មិនអន្ទះអន្ទែង ព្រោះមិនបានចីវរ បានចីវរហើយមិនរីករាយ មិនជ្រុលជ្រប់ មិនបានឲ្យតណ្ហាគ្របសង្កត់ ជាអ្នកមានសេចក្តីឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញហើយបរិភោគ មិនលើកតម្កើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះសេចក្តីសន្តោស ដោយចីវរណានីមួយនោះឯង មួយទៀត ភិក្ខុណា ជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំ ក្នុងសេចក្តីសន្តោសនោះ ម្នាល

---

១ ការប្រើប្រាស់បច្ច័យមានចីវរជាដើម ។ ២ ការអត់ទ្រាំនូវហេតុមានត្រជាក់និងក្តៅជាដើម ។ ៣ ការចៀសវាងនូវសត្វកាចមានដំរីជាដើម ។ ៤ ការបន្ទោបង់នូវអកុសលធម៌ មានកាមវិតក្កៈជាដើម ។ ៥ ប្រវេណីនៃព្រះអរិយបុគ្គលមានព្រះពុទ្ធជាដើម ។

## សង្គីតិសុត្តេ សង្គីតិយចតុក្កំ

អយំ វុច្ចតាវុសោ ភិក្ខុ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ អាវុសោ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី ន ច បិណ្ឌបាតហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច បិណ្ឌបាតំ ន បរិតស្សតិ លទ្ធា ច បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទី-នវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតាវុសោ ភិក្ខុ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ច បរំ អាវុសោ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន ឥតរីតរសេ-នាសនសន្តុដ្ឋិយា ច វណ្ណវាទី ន ច សេនាសនហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច សេនាសនំ ន បរិតស្សតិ លទ្ធា ច សេនាសនំ អគធិតោ អមុច្ឆិ-

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

អាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាច្បាប់ទំលាប់ចាស់ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោស ដោយបិណ្ឌបាតណាទីមួយ តែងសរសើរគុណនៃសេចក្តីសន្តោស ដោយបិណ្ឌបាតណាទីមួយ មិនដល់នូវការស្វែងរកដែលមិនសមគួរ ព្រោះហេតុតែបិណ្ឌបាត មិនអន្ទះអន្ទែងព្រោះមិនបានបិណ្ឌបាត បានបិណ្ឌបាតហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនបានឲ្យតណ្ហាគ្របសង្កត់ ជាអ្នកមានសេចក្តីឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញហើយបរិភោគ មិនលើកតម្កើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះសេចក្តីសន្តោស ដោយបិណ្ឌបាតណាទីមួយនោះឯង ភិក្ខុណា ជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំក្នុងសេចក្តីសន្តោសនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាច្បាប់ទំលាប់ចាស់ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោស ដោយសេនាសនៈណាទីមួយ តែងសរសើរគុណនៃសេចក្តីសន្តោស ដោយសេនាសនៈណាទីមួយ មិនដល់នូវការស្វែងរកដែលមិនសមគួរ ព្រោះហេតុតែសេនាសនៈ មិនអន្ទះអន្ទែងព្រោះមិនបានសេនាសនៈ បានសេនាសនៈហើយ មិនរីករាយ មិនជ្រុលជ្រប់

១៨៦



តោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរសេនាសនសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតាវុសោ ភិក្ខុ ចោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ បុន ចបរំ អាវុសោ ភិក្ខុ បហានារាមោ ហោតិ បហានរតោ ភាវនារាមោ ហោតិ ភាវនារតោ តាយ ច បន បហានារាមតាយ បហានរតិយា ភាវនារាមតាយ ភាវនារតិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតាវុសោ ភិក្ខុ ចោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។

មិនបានឲ្យតណ្ហាគ្របសង្កត់ ជាអ្នកមានសេចក្តីឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញហើយបរិភោគ មិនលើកតម្កើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះសេចក្តីសន្តោស ដោយសេនាសនៈណានីមួយនោះឯង មួយទៀត ភិក្ខុណាជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំ ក្នុងសេចក្តីសន្តោសនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលអាវុសោទាំង-ឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានការលះកិលេសទាំងពួង ជាទីត្រេកអរ ជាអ្នកត្រេកអរហើយក្នុងការលះ មានការចម្រើន[១] ជាទីត្រេកអរ ជាអ្នកត្រេកអរហើយក្នុងការចម្រើន មិនលើកតម្កើងខ្លួនឯង មិនបង្អាប់អ្នកដទៃ ព្រោះតែខ្លួនមានការលះជាទីត្រេកអរ ជាអ្នកត្រេកអរហើយក្នុងការលះ មានការចម្រើនជាទីត្រេកអរ ត្រេកអរហើយក្នុងការចម្រើននោះឯង មួយវិញទៀត ភិក្ខុណាជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំក្នុងការត្រេកអរនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។

១ ចម្រើនគុណធម៌មាននេក្ខម្មៈជាដើម មានអរហត្តមគ្គជាទីបំផុត ។

១៨៧

## សង្គីតិសុត្តេ សង្គីតិយចតុក្កំ

[១០៩] ចត្តារិ បធានានិ សំវរប្បធានំ បហានប្បធានំ ភាវនាបធានំ អនុរក្ខនាបធានំ ។ កតមញ្ចាវុសោ សំវរប្បធានំ ។ ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ[១] អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ឥទំ វុច្ចតាវុសោ សំវរប្បធានំ ។

---

១ ឱ. យត្វាធិករណមេតំ ចក្ខុន្ទ្រិយំ ។

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១០៩] ការព្យាយាមជាគ្រឿងតម្កល់ ៤ យ៉ាង គឺការព្យាយាមក្នុងសេចក្តីសង្រួម ១ ការព្យាយាមក្នុងការលះ ១ ការព្យាយាមក្នុងការចម្រើន ១ ការព្យាយាមក្នុងការរក្សារឿយ ៗ ១ ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងសេចក្តីសង្រួម តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ទទួលរសដោយអណ្តាត ។ ពាល់ត្រូវសម្ផស្សដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ម្នាលអាវុសោទាំងឡាយនេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងសេចក្តីសង្រួម ។

កតមញ្ចាវុសោ បធានប្បធានំ ។ ឥធាវុសោ ភិក្ខុ ឧប្ប-ន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តី-ករោតិ[១] អនភាវង្គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ ។ បេ ។ ឧប្បន្នំ វិហឹសាវិតក្កំ នាធិវាសេតិ បជហតិ ។ បេ ។ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ[២] អនភាវង្គមេតិ ឥទំ វុច្ចតាវុសោ បធានប្បធានំ ។ កតមញ្ចាវុសោ ភាវ-នាបធានំ ។ ឥធាវុសោ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គ-បរិណាមឹ ។ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ។ វីរិយ-សម្ពោជ្ឈង្គំ ភាវេតិ ។ បីតិសម្ពោជ្ឈង្គំ ភាវេតិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ ។ សមាធិសម្ពោជ្ឈង្គំ ភាវេតិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ

---

១-២ ម. ព្យន្តី ករោតិ ។

ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងការលះ តើដូចម្តេច ។ ម្នាល-អាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបណ្តោយឲ្យកាមវិតក្កៈដែលកើតឡើងហើយឲ្យអាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន មិនបណ្តោយឲ្យព្យាបាទវិតក្កៈដែលកើតឡើងហើយ ។ បេ ។ មិនបណ្តោយឲ្យវិហឹសាវិតក្កៈ ដែលកើតឡើងហើយអាស្រ័យនៅបាន គឺលះបង់ ។ បេ ។ មិនបណ្តោយឲ្យអកុសលធម៌ទាំងឡាយដ៏អាក្រក់ដែលកើតឡើងហើយរឿយ ៗ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ធ្វើឲ្យវិនាស មិនឲ្យកើតមាន ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងការលះ ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងការចម្រើន តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេកធម៌ អាស្រ័យនូវវិរាគធម៌ អាស្រ័យនូវនិរោធធម៌ ជាធម៌បង្អោនទៅ ដើម្បីការលះកិលេស ។ ចម្រើនធម្មវិចយសម្ពោជ្ឈង្គ ។ ចម្រើនវិរិយសម្ពោជ្ឈង្គ ។ ចម្រើនបីតិសម្ពោជ្ឈង្គ ។ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ។ ចម្រើនសមាធិ-សម្ពោជ្ឈង្គ ។ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេកធម៌

វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ឥទំ វុច្ចតាវុសោ ភាវនាបធានំ ។ កតមញ្ចាវុសោ អនុ-រក្ខនាបធានំ ។ ឥធាវុសោ ភិក្ខុ ឧប្បន្នំ ភទ្ទកំ សមាធិនិមិត្តំ អនុរក្ខតិ អដ្ឋិកសញ្ញំ បុឡុវកសញ្ញំ វិនីលកសញ្ញំ វិច្ឆិទ្ទកសញ្ញំ ឧទ្ធុមាតកសញ្ញំ ឥទំ វុច្ចតាវុសោ អនុរក្ខនាបធានំ ។

[១១០] ចត្តារិ ញាណានិ ធម្មេ ញាណំ អន្វយេ ញាណំ បរិច្ឆេទញ្ញាណំ[១] សម្មតិញ្ញាណំ ។ អបរា-និបិ ចត្តារិ ញាណានិ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ[២] ។

១ ឱ. ម. បរិច្ឆេទេ ញាណំ ។ ២ ឱ. មគ្គេ ញាណំ ។

អាស្រ័យនូវវិរាគធម៌ ចម្រើននូវនិរោធធម៌ ជាធម៌បង្អោនទៅ ដើម្បីលះកិលេស ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងការចម្រើន ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងការរក្សារឿយៗ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ រក្សារឿយ ៗ នូវសមាធិនិមិត្តដ៏ល្អ ដែលកើតឡើងហើយ គឺអដ្ឋិកសញ្ញា[១] បុឡុវកសញ្ញា[២] វិនីលកសញ្ញា[៣] វិច្ឆិទ្ទកសញ្ញា[៤] ឧទ្ធុមាតកសញ្ញា[៥] ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងការរក្សារឿយ ៗ ។

[១១០] ញាណគឺសេចក្តីដឹង ៤ យ៉ាង គឺសេចក្តីដឹងក្នុងធម៌ គឺមគ្គផល ១ សេចក្តីដឹងក្នុងលំនាំរបស់ញាណនោះ ១ សេចក្តីដឹងក្នុងកិរិយាកំណត់ចិត្តរបស់បុគ្គលដទៃ ១ សេចក្តីដឹងក្នុងការសន្មត ១ ។ ញាណគឺសេចក្តីដឹង ៤ យ៉ាងដទៃទៀត គឺសេចក្តីដឹងក្នុងទុក្ខ ១ សេចក្តីដឹងក្នុងទុក្ខសមុទយ ១ សេចក្តីដឹងក្នុងទុក្ខនិរោធ ១ សេចក្តីដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ១ ។

---

១ សេចក្តីសំគាល់ក្នុងអដ្ឋិកអសុភ គឺអសុភដែលនៅតែរាងឆ្អឹង ។ ២ សេចក្តីសំគាល់ក្នុងបុឡុវកអសុភ គឺអសុភដែលមានដង្កូវចុះ ។ ៣ សេចក្តីសំគាល់ក្នុងវិនីលកអសុភ គឺអសុភដែលមានសម្បុរខៀវ ។ ៤ សេចក្តីសំគាល់ក្នុងវិច្ឆិទ្ទកអសុភ គឺអសុភដែលដាច់ពាក់កណ្តាលខ្លួន ។ ៥ សេចក្តីសំគាល់ក្នុងឧទ្ធុមាតកអសុភ គឺអសុភដែលហើមប៉ោង ។

[១១១] ចត្តារិ សោតាបត្តិយង្គានិ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ។

[១១២] ចត្តារិ សោតាបន្នស្ស អង្គានិ ឥធាវុសោ អរិយសាវកោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសធម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ សង្ឃេ

[១១១] អង្គនៃសោតាបត្តិមគ្គ ៤ យ៉ាង គឺការសេពគប់នូវសប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ១ សេចក្តីប្រតិបត្តិធម៌សមគួរដល់លោកុត្តរធម៌ ១ ។

[១១២] អង្គរបស់សោតាបន្នបុគ្គល ៤ យ៉ាង ម្នាលអាវុសោទាំង-ឡាយ អរិយសាវ័កក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិ-លេសហើយ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាគ្រូរបស់ទេវតានិងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងមកកាន់ភពថ្មីទៀត ដោយហេតុនេះ ១ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ ដែលបុគ្គលគប្បីឃើញ ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ចំពោះខ្លួន ១ ប្រកបដោយ

អវេច្ចប្បសាទេន សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុបសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ ។

[១១៣] ចត្តារិ សាមញ្ញផលានិ សោតាបត្តិផលំ សកទាគាមិផលំ អនាគាមិផលំ អរហត្តផលំ ។

សេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃថា ពួកសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិល្អហើយ ពួកសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិត្រង់ហើយ ពួកសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិគួរហើយ បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលបាន ៨ ពួកសាវ័ករបស់ព្រះមានព្រះភាគនេះ គួរទទួលនូវចតុបច្ច័យ ដែលគេនាំមកអំពីចម្ងាយហើយបូជា គួរទទួលនូវសក្ការៈ ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណា (ទាន) គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ១ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ គឺជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាភុជិស្សសីល (មិនមែនជាខ្ញុំតណ្ហា) ជាសីល ដែលអ្នកប្រាជ្ញសរសើរ ជាសីលមិនជ្រោកជ្រាកដោយតណ្ហានិងទិដ្ឋិ ជាសីលប្រព្រឹត្តទៅ ដើម្បីបាននូវសមាធិ ១ ។

[១១៣] សាមញ្ញផល[១] មាន ៤ យ៉ាង គឺ សោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។

១ ផលនៃសមណធម៌ ឬ ផលផ្នួស ។

[១១៤] ចតស្សោ ធាតុយោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

[១១៥] ចត្តារោ អាហារា កពឡីការោ[១] អាហារោ ឱឡារិកោ វា សុខុមោ វា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។

[១១៦] ចតស្សោ វិញ្ញាណដ្ឋិតិយោ រូបូចាយំ[២] អាវុសោ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ[៣] វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជតិ ។ វេទនូចាយំ វា អាវុសោ ។ សញ្ញូចាយំ វា អាវុសោ ។ សង្ខារូចាយំ វា អាវុសោ ។ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជតិ ។

---

១ ឱ. កពលឹការោ ។ ២ ឱ. ម. រូបូបាយំ វា ។ ៣ ឱ. នន្ទូបវេសនំ ។ ម. នន្ទូបសេចនំ ។

[១១៤] ធាតុ ៤ យ៉ាង គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។

[១១៥] អាហារ ៤ យ៉ាង គឺ អាហារគួរធ្វើឲ្យជាពំនូត[១] គ្រោតគ្រាតក្តី ល្អិតក្តី ១ ផស្សៈ[២] ជាអាហារទី ២ មនោសញ្ចេតនា[៣] ជាអាហារទី ៣ វិញ្ញាណ[៤] ជាអាហារទី ៤ ។

[១១៦] វិញ្ញាណដ្ឋិតិ (ធម្មជាតិជាទីតាំងនៅរបស់វិញ្ញាណ) ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ វិញ្ញាណដែលស្ថិតនៅ ក៏ស្ថិតនៅអាស្រ័យនឹងរូប មានរូបជាអារម្មណ៍ តាំងនៅក្នុងរូប ចូលទៅអាស្រ័យនូវសេចក្តីត្រេកអរ តែងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយ ១ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណអាស្រ័យវេទនា ១ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណអាស្រ័យសញ្ញា ១ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណដែលស្ថិតនៅ ក៏ស្ថិតនៅអាស្រ័យនឹងសង្ខារ មានសង្ខារជាអារម្មណ៍ តាំងនៅក្នុងសង្ខារ ចូលទៅអាស្រ័យនូវសេចក្តីត្រេកអរ តែងដល់នូវសេចក្តីចម្រើន លូតលាស់ធំទូលាយ ១ ។

---

១ បានដល់បាយនិងនំជាដើមតែងនាំមកនូវឱជដ្ឋមករូប ។ ២ បានដល់ផស្សៈទាំង ៦ មានចក្ខុសម្ផស្សជាដើមតែងនាំមកនូវវេទនាទាំង ៣ ។ ៣ បានដល់កុសលាកុសលចេតនាដែលអាស្រ័យនឹងចិត្ត ចេតនានោះចែកទៅជា ៣ គឺបុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ តែងនាំមកនូវបដិសន្ធិក្នុងភពទាំង ៣ ។ ៤ បានដល់វិញ្ញាណក្ខន្ធគឺចិត្តតែងនាំមកនូវនាមរូបក្នុងខណៈនៃបដិសន្ធិ ។

១៦៣

## សង្គីតិសុត្តេ សង្គីតិយចតុក្កំ

[១១៧] ចត្តារិ អគតិគមនានិ ឆន្ទាគតឹ គច្ឆតិ ទោសាគតឹ គច្ឆតិ មោហាគតឹ គច្ឆតិ ភយាគតឹ គច្ឆតិ ។

[១១៨] ចត្តារោ តណ្ហុប្បាទា ចីវរហេតុ វា អាវុសោ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ បិណ្ឌបាតហេតុ វា អាវុសោ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ សេនាសនហេតុ វា អាវុសោ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ អភិភវាភវហេតុ វា[១] អាវុសោ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។

[១១៩] ចតស្សោ បដិបទា ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។

[១២០] អបរាបិ ចតស្សោ បដិបទា អក្ខមា បដិបទា ខមា បដិបទា ទមា បដិបទា សមា បដិបទា ។

---

១ ឱ. ម. ឥតិ ភវាភវហេតុ វា ។

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១១៧] *ការលុះអគតិ ៤ យ៉ាង គឺ បុគ្គលលុះឆន្ទាគតិ ១ លុះទោសាគតិ ១ លុះមោហាគតិ ១ លុះភយាគតិ ១ ។*

[១១៨] *ការកើតឡើងនៃតណ្ហា ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ តណ្ហា កាលកើតឡើងដល់ភិក្ខុ តែងកើតឡើង ព្រោះហេតុតែចីវរ ១ ម្នាលអាវុសោទាំងឡាយ តណ្ហា កាលកើតឡើងដល់ភិក្ខុ តែងកើតឡើង ព្រោះហេតុតែបិណ្ឌបាត ១ ម្នាលអាវុសោទាំងឡាយ តណ្ហា កាលកើតឡើងដល់ភិក្ខុ តែងកើតឡើង ព្រោះហេតុតែសេនាសនៈ ១ ម្នាលអាវុសោទាំងឡាយ តណ្ហា កាលកើតឡើងដល់ភិក្ខុ តែងកើតឡើង ព្រោះហេតុតែវត្ថុថ្លៃថ្លាយ៉ាងក្រៃលែង ១*[១] *។*

[១១៩] *បដិបទា ៤ យ៉ាង គឺ បដិបទា ជាទុក្ខ ហើយត្រាស់ដឹងបានដោយយឺតយូរ ១ បដិបទា ជាទុក្ខ ហើយត្រាស់ដឹងបានដោយឆាប់រហ័ស ១ បដិបទា ជាសុខ តែត្រាស់ដឹងបានដោយយឺតយូរ ១ បដិបទា ជាសុខ ហើយត្រាស់ដឹងបានដោយឆាប់រហ័ស ១ ។*

[១២០] *បដិបទា ៤ យ៉ាងដទៃទៀត គឺ បដិបទា មិនអត់ធន់ (នឹងត្រជាក់ជាដើម) ១ បដិបទាអត់ធន់បាន ១ បដិបទាទូន្មាន (នូវឥន្ទ្រិយ) បាន ១ បដិបទារម្ងាប់ (វិតក្កៈ) បាន ១ ។*

---

១ បានដល់គិលានភេសជ្ជបច្ច័យ មានប្រេងទឹកឃ្មុំទឹកអំពៅជាដើម ។

[១៦១] ចត្តារិ ធម្មបទានិ អនភិជ្ឈា ធម្មបទំ អព្យាបាទោ ធម្មបទំ សម្មាសតិ ធម្មបទំ សម្មាសមាធិ ធម្មបទំ ។

[១៦២] ចត្តារិ ធម្មសមាទានានិ អត្ថាវុសោ ធម្មសមាទានំ បច្ចុប្បន្នំ ទុក្ខញ្ចេវ[១] អាយតិញ្ច ទុក្ខវិបាកំ អត្ថាវុសោ ធម្មសមាទានំ បច្ចុប្បន្នំ ទុក្ខញ្ចេវ អាយតិញ្ច សុខវិបាកំ អត្ថាវុសោ ធម្មសមាទានំ បច្ចុប្បន្នំ សុខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ អត្ថាវុសោ ធម្មសមាទានំ បច្ចុប្បន្នំ សុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។

[១៦៣] ចត្តារោ ធម្មក្ខន្ធា សីលក្ខន្ធោ សមាធិក្ខន្ធោ បញ្ញាខន្ធោ វិមុត្តិក្ខន្ធោ ។

១ ឱ. បច្ចុប្បន្នំ ទុក្ខំ ។ ម. បច្ចុប្បន្នទុក្ខំ ។

[១២១] ចំណែកធម៌ ៤ យ៉ាង គឺ សេចក្តីមិនលោភ ជាចំណែកធម៌ ១ សេចក្តីមិនព្យាបាទ ជាចំណែកធម៌ ១ ការនឹករឭកត្រូវ ជាចំណែកធម៌ ១ ការតាំងចិត្តទុកត្រូវ ជាចំណែកធម៌ ១ ។

[១២២] ការសមាទានធម៌ ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ ជាទុក្ខក្នុងបច្ចុប្បន្នផង មានផលជាទុក្ខតទៅខាងមុខ[១] ផង ១ ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ ជាទុក្ខក្នុងបច្ចុប្បន្ន តែមានផលជាសុខតទៅខាងមុខ[២] ១ ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ ជាសុខក្នុងបច្ចុប្បន្ន តែមានផលជាទុក្ខតទៅខាងមុខ[៣] ១ ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ ជាសុខក្នុងបច្ចុប្បន្នផង មានផលជាសុខតទៅខាងមុខ[៤]ផង ។

[១២៣] ធម្មក្ខន្ធ ៤ យ៉ាង គឺ សីលក្ខន្ធ[៥] ១ សមាធិក្ខន្ធ ១ បញ្ញាខន្ធ ១ វិមុត្តិក្ខន្ធ ។

---

១ បានដល់សេចក្តីប្រតិបត្តិរបស់ពួកអចេល ។ ២ ការប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធរបស់បុគ្គលដែលមានកិលេសក្រាស មិនអាចនឹងឈោងចាប់យកព្រះអរហត្តបាន ហើយក៏ស្រែកយំមានមុខទទឹកដោយទឹកភ្នែក ។ ៣ ការប្រព្រឹត្តធម៌របស់បុគ្គលដែលមានចិត្តធ្លាក់ចុះទៅ ក្នុងកាម ។ ៤ សាសនព្រហ្មចរិយរបស់បុគ្គលខ្លះ បើទុកជាមិនបាននូវបច្ច័យទាំង ៤ ក៏គង់នៅប្រកបដោយសេចក្តីសុខ ដោយអំណាចឈាននិងវិបស្សនា ។ ៥ ខន្ធក្នុងទីនេះ ប្រែថា គុណ សីលក្ខន្ធ ប្រែថា គុណគឺសីល ។

សង្គីតិសុត្តេ សង្គីតិយចតុក្កំ

[១២៤] ចត្តារិ ពលានិ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។

[១២៥] ចត្តារិ អធិដ្ឋានានិ បញ្ញាធិដ្ឋានំ សច្ចាធិដ្ឋានំ ចាគាធិដ្ឋានំ ឧបសមាធិដ្ឋានំ ។

[១២៦] ចត្តារោ បញ្ហាព្យាករណា[១] ឯកំសព្យាករណីយោ បញ្ហោ បដិបុច្ឆាព្យាករណីយោ បញ្ហោ វិភជ្ជព្យាករណីយោ បញ្ហោ ឋបនីយោ បញ្ហោ ។

[១២៧] ចត្តារិ កម្មានិ អត្ថាវុសោ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថាវុសោ កម្មំ សុក្កំ សុក្កវិបាកំ អត្ថាវុសោ កម្មំ កណ្ហសុក្កំ កណ្ហសុក្កវិបាកំ អត្ថាវុសោ កម្មំ អកណ្ហអសុក្កំ[២] អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។

---

១ ឱ. បញ្ហាវ្យាករណា ។ ២ ឱ. អកណ្ហំ អសុក្កំ ។

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងសង្គាយនា

[១២៤] កម្លាំង ៤ យ៉ាង គឺ កម្លាំងព្យាយាម ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។

[១២៥] អធិដ្ឋាន[១] ៤ យ៉ាង គឺ អធិដ្ឋាន គឺមគ្គផលបញ្ញា ១ អធិដ្ឋាន គឺវចីសច្ចៈ ១ អធិដ្ឋាន គឺការលះបង់នូវអាមិសៈ ១ អធិដ្ឋាន គឺការរម្ងាប់នូវកិលេស ១ ។

[១២៦] បញ្ហាព្យាករណ៍ (ការឆ្លើយប្រស្នា) ៤ យ៉ាង គឺ ប្រស្នាដែលគួរឆ្លើយទៅតែម្តង ១ ប្រស្នាដែលគួរសួរតបទៅវិញហើយទើបឆ្លើយ ១ ប្រស្នាដែលគួរឆ្លើយចែករលែកឲ្យពិស្តារ ១ ប្រស្នាដែលគួរបញ្ឈប់ទុក ១ ។

[១២៧] កម្ម ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ កម្មខ្មៅ[២]ឲ្យផលខ្មៅក៏មាន ១ ម្នាលអាវុសោទាំងឡាយ កម្ម-ស[៣]ឲ្យផល-សក៏មាន ១ ម្នាលអាវុសោទាំងឡាយ កម្មទាំងខ្មៅទាំងស[៤] ឲ្យផលទាំងខ្មៅទាំងសក៏មាន ១ ម្នាលអាវុសោទាំងឡាយ កម្មមិនខ្មៅមិនស[៥] ឲ្យផលទាំងមិនខ្មៅទាំងមិនស តែងប្រព្រឹត្តទៅដើម្បីអស់កម្ម ១ ។

---

១ ធម្មជាតជាទីតាំងនៃបុរសមានគុណដ៏ក្រៃលែង ។ ២ បានដល់អកុសលកម្មបថ ១០ ឲ្យផលខ្មៅគឺឲ្យទៅកើតក្នុងអបាយ ។ ៣ គឺកុសលកម្មបថ ១០ ឲ្យផល-សគឺឲ្យទៅកើតក្នុងសួគ៌ ។ ៤ គឺអកុសលនិងកុសលច្រឡំលាយគ្នា ឲ្យផលទាំងខ្មៅទាំងស គឺដូចជាសត្វខ្លះទៅកើតជាសត្វដំរីដោយអកុសល បានមកជាដំរីជាមង្គលគេឲ្យនៅជាសុខដោយកុសល សត្វខ្លះទៅកើតក្នុងរាជត្រកូលដោយកុសល តែត្រឡប់បានសេចក្តីទុក្ខវិញដោយអកុសល ។ ៥ បានដល់មគ្គញ្ញាណទាំង ៤ ។

[១២៨] ចត្តារោ សច្ឆិករណីយា ធម្មា បុព្ពេនិវាសោ សតិយា សច្ឆិករណីយោ សត្តានំ ចុតូបបាតោ ចក្ខុនា សច្ឆិករណីយោ អដ្ឋវិមោក្ខា កាយេន សច្ឆិករណីយា អាសវានំ ខយោ បញ្ញាយ សច្ឆិករណីយោ ។

[១២៩] ចត្តារោ ឱឃា កាមោឃោ ភវោឃោ ទិដ្ឋោឃោ អវិជ្ជោឃោ ។

[១៣០] ចត្តារោ យោគា កាមយោគោ ភវយោគោ ទិដ្ឋិយោគោ អវិជ្ជាយោគោ ។

[១៣១] ចត្តារោ វិសំយោគា[១] កាមយោគវិសំយោគោ ភវយោគវិសំយោគោ ទិដ្ឋិយោគវិសំយោគោ អវិជ្ជាយោគវិសំយោគោ ។

---

១ ម. វិសញ្ញោគា ។

[១២៨] ធម៌ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ៤ យ៉ាង គឺបុព្វេនិវាស (ដែលខ្លួនអាស្រ័យនៅក្នុងកាលមុន) ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិ ១ ចុតូបបាត (ចុតិនិងបដិសន្ធិ) របស់សត្វទាំងឡាយត្រូវធ្វើឲ្យជាក់ច្បាស់ដោយទិព្វចក្ខុ ១ វិមោក្ខ ៨ ប្រការ ត្រូវធ្វើឲ្យជាក់ច្បាស់ដោយនាមកាយ ១ ធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ ត្រូវធ្វើឲ្យជាក់ច្បាស់ដោយអរហត្តផលបញ្ញា ១ ។

[១២៩] ឱឃៈ (ធម៌ជាគ្រឿងពន្លិចសត្វ) ៤ យ៉ាងគឺកាមោឃៈ[១] ១ ភវោឃៈ[២] ១ ទិដ្ឋោឃៈ[៣] ១ អវិជ្ជោឃៈ[៤] ១ ។

[១៣០] យោគៈ (ធម៌ជាគ្រឿងប្រកបសត្វក្នុងវដ្តៈ) ៤ យ៉ាង គឺ កាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។

[១៣១] វិសំយោគៈ (ធម៌ជាគ្រឿងដោះសត្វ) ៤ យ៉ាង គឺ ធម៌ជាគ្រឿងដោះសត្វចាកកាមយោគៈ[៥] ១ ធម៌ជាគ្រឿងដោះសត្វចាកភវ-យោគៈ[៦] ១ ធម៌ជាគ្រឿងដោះសត្វចាកទិដ្ឋិយោគៈ[៧] ១ ធម៌ជាគ្រឿងដោះសត្វចាកអវិជ្ជាយោគ[៨] ១ ។

---

១ រាគៈប្រកបដោយកាមគុណទាំង ៥ ហៅថា កាមោឃៈ ។ ២ ឆន្ទរាគៈប្រព្រឹត្តទៅក្នុងរូបភពនិងអរូបភពហៅថា ភវោឃៈ ។ ១ ទៀតថា សេចក្តីអាល័យក្នុងឈានក្តី រាគៈប្រកបដោយសស្សតទិដ្ឋិក្តី ហៅថា ភវោឃៈដែរ ។ ៣ ទិដ្ឋិ ៦២ ហៅថា ទិដ្ឋោឃៈ ។ ៤ សេចក្តីមិនដឹងក្នុងអរិយសច្ចទាំង ៤ ហៅថា អវិជ្ជោឃៈ ។ ៥ សំដៅយក អសុភជ្ឈាន ឬអនាគាមិមគ្គ ។ ៦ អរហត្តមគ្គ ។ ៧ សោតាបត្តិមគ្គ ។ ៨ អរហត្តមគ្គ (អដ្ឋកថា) ។

សង្គីតិសុត្តេ  សង្គីតិយចតុក្កំ

[១៣២] ចត្តារោ គន្ថា អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរាមាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។

[១៣៣] ចត្តារិ ឧបាទានានិ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ។

[១៣៤] ចតស្សោ យោនិយោ អណ្ឌជយោនិ ជលាពុជយោនិ សំសេទជយោនិ ឱបបាតិកយោនិ ។

[១៣៥] ចតស្សោ គព្ភាវក្កន្តិយោ ឥធាវុសោ ឯកច្ចោ អសម្បជានោ[១] មាតុ កុច្ឆឹ ឱក្កមតិ[២] អសម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ អសម្បជានោ មាតុ កុច្ឆិស្មា[៣] និក្ខមតិ អយំ បឋមា គព្ភាវក្កន្តិ ។ បុន ចបរំ អាវុសោ ឥធេកច្ចោ សម្បជានោ[៤] មាតុ កុច្ឆឹ ឱក្កមតិ[៥] អសម្បជានោ មាតុ កុច្ឆិស្មឹ

---

១ ឱ. អសម្បជានោ ចេវ ។ ២ ឱ. កុច្ឆិយមោក្កមតិ ។ ៣ ម. កុច្ឆិម្ហា ។ ៤ ឱ. សម្បជានោ ហិ ខោ ។ ៥ ឱ. កុច្ឆិស្មិមោក្កមតិ ។

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១៣២] ធម៌ជាគ្រឿងចងព័ន្ធ ៤ យ៉ាង គឺ អភិជ្ឈាជាគ្រឿងចងព័ន្ធកាយ(១) ១ ព្យាបាទជាគ្រឿងចងព័ន្ធកាយ ១ សេចក្តីប្រកាន់ខុសដោយសីលនិងវ័តជាគ្រឿងចងព័ន្ធកាយ ១ សេចក្តីប្រកាន់មាំថា ពាក្យនេះជាពាក្យពិត ពាក្យដទៃជាពាក្យទទេ ជាគ្រឿងចងព័ន្ធកាយ ១ ។

[១៣៣] ធម្មជាតជាគ្រឿងប្រកាន់មាំ ៤ យ៉ាង គឺ កាមជាគ្រឿងប្រកាន់មាំ ១ មិច្ឆាទិដ្ឋិជាគ្រឿងប្រកាន់មាំ ១ ការប្រកាន់មាំដោយសីលព្វត ១ ការប្រកាន់មាំដោយពោលថាខ្លួន ១ ។

[១៣៤] កំណើត ៤ យ៉ាង គឺ កំណើតរបស់សត្វដែលកើតក្នុងស៊ុត ១ កំណើតរបស់សត្វដែលកើតក្នុងទឹក ១ កំណើតរបស់សត្វដែលកើតក្នុងទីស្អោកគ្រោក ១(២) កំណើតរបស់សត្វដែលអណ្តែតទៅកើតភ្លាម ១ ។

[១៣៥] ការចុះកាន់គភ៌ (របស់សត្វ) ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏មិនដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតាក៏មិនដឹងខ្លួន សម្រាលចាកផ្ទៃមាតាក៏មិនដឹងខ្លួនទៀត នេះជាការចុះកាន់គភ៌ទី ១(៣) ។ ម្នាលអាវុសោទាំងឡាយ មួយទៀតសត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាដឹងខ្លួន តែនៅក្នុងផ្ទៃមាតាមិនដឹងខ្លួន

---

១ សំដៅយកនាមកាយនិងរូបកាយ ។ ២ កំណើតរបស់សត្វដែលកើតលើទីដេកឬទីស្អោកគ្រោកមានត្រីស្អុយជាដើម ។ ៣ បានដល់លោកិយមនុស្សជាប្រក្រតី ។

ឋាតិ អសម្បជានោ មាតុ កុច្ឆិស្មា និក្ខមតិ អយំ ទុតិយា គព្ភាវក្កន្តិ ។ បុន ចបរំ អាវុសោ ឥធេកច្ចោ សម្បជានោ មាតុ កុច្ឆឹ ឱក្កមតិ សម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ អសម្បជានោ មាតុ កុច្ឆិស្មា និក្ខមតិ អយំ តតិយា គព្ភាវក្កន្តិ ។ បុន ចបរំ អាវុសោ ឥធេកច្ចោ សម្បជានោ មាតុ កុច្ឆឹ ឱក្កមតិ សម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ សម្បជានោ មាតុ កុច្ឆិស្មា និក្ខមតិ អយំ ចតុត្ថា គព្ភាវក្កន្តិ ។

[១៣៦] ចត្តារោ អត្តភាវប្បដិលាភា អត្ថាវុសោ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ អត្ត-សញ្ចេតនាយេវ កមតិ នោ បរសញ្ចេតនា ។ អត្ថា-វុសោ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ បរសញ្ចេតនាយេវ កមតិ នោ អត្តសញ្ចេតនា ។

សម្រាលចាកផ្ទៃមាតា ក៏មិនដឹងខ្លួនដែរ នេះជាការចុះកាន់ផ្ទៃមាតា[១] ទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏ដឹងខ្លួន នៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន តែសម្រាលចាកផ្ទៃមាតាមិនដឹងខ្លួន នេះជាការចុះកាន់គភ៌[២] ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏ដឹងខ្លួនទៀត នៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន សម្រាលចាកផ្ទៃមាតា ក៏ដឹងខ្លួន នេះជាការចុះកាន់គភ៌[៣] ទី ៤ ។

[១៣៦] ការបាននូវអត្តភាពមាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ចេតនារបស់ខ្លួន រមែងធ្វើខ្លួនឲ្យស្លាប់ ចេតនារបស់អ្នកដទៃពុំបានធ្វើឲ្យស្លាប់ឡើយ ក្នុងការបាននូវអត្តភាពណា ការបាននូវអត្តភាពនោះ រមែងមាន[៤] ១ ។ ម្នាលអាវុសោទាំងឡាយ ចេតនារបស់អ្នកដទៃ រមែងធ្វើខ្លួនឲ្យស្លាប់ ចេតនារបស់ខ្លួនមិនបានធ្វើឲ្យស្លាប់ឡើយ ក្នុងការបាននូវអត្តភាពណា ការបាននូវអត្តភាពនោះ រមែងមាន ១ ។

---

១ បានដល់អសីតិមហាសាវ័ក ។ ២ បានដល់អគ្គសាវ័កទាំងពីរ និងព្រះបច្ចេកពោធិសត្វ ។ ៣ បានដល់ព្រះសព្វញ្ញុពោធិសត្វ ។ ៤ បានដល់កំណើត ខិឌ្ឌាបទោសិកទេវតា ជាទេវតាវិនាសខ្លួនដោយល្បែងហៅថា ស្លាប់ដោយចេតនារបស់ខ្លួន មិនស្លាប់ដោយចេតនារបស់អ្នកដទៃ ។

អត្តាវុសោ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ អត្តសញ្ចេតនា ចេវ សោ[១] កមតិ បរសញ្ចេតនា ច ។ អត្ថាវុសោ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ នេវ អត្តសញ្ចេតនា កមតិ នោ បរសញ្ចេតនា ។

[១៣៧] ចតស្សោ ទក្ខិណាវិសុទ្ធិយោ អត្ថាវុសោ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ អត្ថាវុសោ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ។ អត្ថាវុសោ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ អត្ថាវុសោ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។

១ ឱ. ម. ចេវ ។

ម្នាលអាវុសោទាំងឡាយ ចេតនារបស់ខ្លួន រមែងធ្វើខ្លួនឲ្យស្លាប់ ទាំងចេតនារបស់អ្នកដទៃ ក៏រមែងធ្វើឲ្យស្លាប់ ក្នុងការបាននូវអត្តភាពណា ការបាននូវអត្តភាពនោះ រមែងមាន[១] ១ ។ ម្នាលអាវុសោទាំងឡាយ ចេតនារបស់ខ្លួន ក៏មិនធ្វើឲ្យស្លាប់ ចេតនារបស់អ្នកដទៃ ក៏មិនធ្វើឲ្យស្លាប់ដែរ ក្នុងការបាននូវអត្តភាពណា ការបាននូវអត្តភាពនោះ រមែងមាន[២] ១ ។

[១៣៧] សេចក្ដីបរិសុទ្ធរបស់ទក្ខិណា[៣] មាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីទាយក (អ្នកឲ្យ) មិនបរិសុទ្ធអំពីបដិគ្គាហក (អ្នកទទួល) ១ ។ ម្នាលអាវុសោទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក ១ ។ ម្នាលអាវុសោទាំងឡាយ ទក្ខិណាមិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក ១ ។ ម្នាលអាវុសោទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផង ១ ។

---

១ បានដល់កំណើតមនោបទោសិកទេវតា ជាទេវតាវិនាសដោយចិត្តរបស់ខ្លួនឯង ។
២ បានដល់កំណើតទាំងឡាយ មានចាតុម្មហារាជិកទេវតាជាដើម ជាទេវតាមិនស្លាប់ដោយចេតនារបស់ខ្លួននិងចេតនារបស់បុគ្គលដទៃ ។ ៣ ជាឈ្មោះរបស់ទាន (អដ្ឋកថា) ។

[១៣៨] ចត្តារិ សង្គហវត្ថូនិ ទានំ បិយវជ្ជំ[១] អត្ថចរិយា សមានត្តតា ។

[១៣៩] ចត្តារោ អនរិយវោហារា មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ ។

[១៤០] ចត្តារោ អរិយវោហារា មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី ។

[១៤១] អបរេបិ ចត្តារោ អនរិយវោហារោ អទិដ្ឋេ ទិដ្ឋវាទិតា អស្សុតេ សុតវាទិតា អមុតេ មុតវាទិតា អវិញ្ញាតេ វិញ្ញាតវាទិតា ។

[១៤២] អបរេបិ ចត្តារោ អរិយវោហារា អទិដ្ឋេ អទិដ្ឋវាទិតា អស្សុតេ អស្សុតវាទិតា អមុតេ អមុតវាទិតា អវិញ្ញាតេ អវិញ្ញាតវាទិតា ។

---

១ ឱ. ម. បេយ្យវជ្ជំ ។

[១៣៨] សង្គហវត្ថុ[១] មាន ៤ យ៉ាង គឺ ការឲ្យ ១ ការចរចាពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តឲ្យជាប្រយោជន៍ ១ ភាវៈជាបុគ្គលមានខ្លួនស្មោះស្មើ[២] ១ ។

[១៣៩] វោហារមិនមែនជារបស់ព្រះអរិយៈ មាន ៤ យ៉ាង គឺ ពាក្យកុហក ១ សំដីញុះញង់ ១ សំដីទ្រគោះ ១ សំដីពោយពាយឥតប្រយោជន៍ ១ ។

[១៤០] វោហារជារបស់ព្រះអរិយៈ មាន ៤ យ៉ាង គឺ ការវៀរចាកពាក្យកុហក ១ ការវៀរចាកសំដីញុះញង់ ១ ការវៀរចាកសំដីទ្រគោះ ១ ការវៀរចាកសំដីពោយពាយ ឥតប្រយោជន៍ ១ ។

[១៤១] វោហារមិនមែនជារបស់ព្រះអរិយៈ មាន ៤ យ៉ាងដទៃទៀត គឺ មិនឃើញ ថាឃើញ ១ មិនឮ ថាឮ ១ មិនប៉ះពាល់[៣] ថាប៉ះពាល់ ១ មិនដឹងច្បាស់ ថាដឹងច្បាស់ ១ ។

[១៤២] វោហារជារបស់ព្រះអរិយៈ មាន ៤ យ៉ាងដទៃទៀត គឺ មិនឃើញ ថាមិនឃើញ ១ មិនឮ ថាមិនឮ ១ មិនប៉ះពាល់ ថាមិនប៉ះពាល់ ១ មិនដឹងច្បាស់ ថាមិនដឹងច្បាស់ ១ ។

---

១ ហេតុនៃការសង្គ្រោះ ។ ២ ការរួមសុខរួមទុក្ខជាមួយគ្នា មានអង្គុយលើអាសនៈជាមួយគ្នា ដេកលើគ្រែជាមួយគ្នា និងបរិភោគជាមួយគ្នាជាដើម ។ ៣ សំដៅយកការហិតក្លិន ដោយច្រមុះ លិទ្ធជញ្ជាប់ដោយអណ្តាត ពាល់ត្រូវសម្ផស្សដោយកាយ ។

សង្គីតិសុត្តេ សង្គីតិយចតុក្កំ

[១៤៣] អបរេបិ ចត្តារោ អនរិយវោហារា ទិដ្ឋេ អទិដ្ឋវាទិតា សុតេ អស្សុតវាទិតា មុតេ អមុតវាទិតា វិញ្ញាតេ អវិញ្ញាតវាទិតា ។

[១៤៤] អបរេបិ ចត្តារោ អរិយវោហារា ទិដ្ឋេ ទិដ្ឋវាទិតា សុតេ សុតវាទិតា មុតេ មុតវាទិតា វិញ្ញាតេ វិញ្ញាតវាទិតា ។

[១៤៥] ចត្តារោ បុគ្គលា ឥធាវុសោ ឯកច្ចោ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគ-មនុយុត្តោ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាប-នានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុ-យោគមនុយុត្តោ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ នេវ អត្តន្តបោ ហោតិ ន អត្តបរិតាបនានុយោគ-មនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគ-មនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ

សង្គីតិសូត្រ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១៨៣] វោហារមិនមែនជារបស់ព្រះអរិយៈ មាន ៤ យ៉ាង ដទៃទៀត គឺ ឃើញ ថាមិនឃើញ ១ ឮ ថាមិនឮ ១ បានប៉ះពាល់ ថាមិនបានប៉ះពាល់ ១ ដឹងច្បាស់ ថាមិនដឹងច្បាស់ ១ ។

[១៨៤] វោហារជារបស់ព្រះអរិយៈ មាន ៤ យ៉ាង ដទៃទៀត គឺ ឃើញ ថាឃើញ ១ ឮ ថាឮ ១ ប៉ះពាល់ ថាប៉ះពាល់ ១ ដឹងច្បាស់ ថាដឹងច្បាស់ ។

[១៨៥] បុគ្គលមាន ៤ ពួក ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើខ្លួនឲ្យក្ដៅ ប្រកបព្យាយាម ដើម្បីធ្វើខ្លួនឲ្យក្ដៅ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើបុគ្គលដទៃឲ្យក្ដៅ ប្រកបព្យាយាម ដើម្បីធ្វើបុគ្គលដទៃឲ្យក្ដៅ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើខ្លួនឲ្យក្ដៅ ប្រកបព្យាយាម ដើម្បីធ្វើខ្លួនឲ្យក្ដៅផង ធ្វើបុគ្គលដទៃឲ្យក្ដៅ ប្រកបព្យាយាម ដើម្បីធ្វើបុគ្គលដទៃឲ្យក្ដៅផង ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនធ្វើខ្លួនឲ្យក្ដៅ មិនប្រកបព្យាយាម ដើម្បីធ្វើខ្លួនឲ្យក្ដៅ មិនធ្វើបុគ្គលដទៃឲ្យក្ដៅ មិនប្រកបព្យាយាម ដើម្បីធ្វើបុគ្គលដទៃឲ្យក្ដៅ បុគ្គលនោះឈ្មោះថា មិនធ្វើខ្លួនឲ្យក្ដៅ មិនធ្វើបុគ្គលដទៃឲ្យក្ដៅ ជាអ្នកលែងមានសេចក្ដីស្រេកឃ្លាន

ជម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។

[១៤៦] អបរេបិ ចត្តារោ បុគ្គលា ឥធាវុសោ ឯកច្ចោ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធាវុសោ[១] ឯកច្ចោ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ អត្តហិតាយ ចេវ បដិបន្នោ ហោតិ បរហិតាយ ច ។

[១៤៧] អបរេបិ ចត្តារោ បុគ្គលា តមោ តម-បរាយនោ តមោ ជោតិបរាយនោ ជោតិ តមបរា-យនោ ជោតិ ជោតិបរាយនោ ។

---

១ ឱ. ឥធ បនាវុសោ ។

មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់កើតហើយ ទទួលនូវសេចក្តីសុខ មានខ្លួនដូចជាព្រហ្មនៅក្នុងបច្ចុប្បន្ននេះ ១ ។

[១៨៦] បុគ្គលមាន ៤ ពួកដទៃទៀត ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ មិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។

[១៨៧] បុគ្គលមាន ៤ ពួកដទៃទៀត គឺ បុគ្គលងងឹត មានងងឹតប្រព្រឹត្តទៅខាងមុខទៀត[១] ១ បុគ្គលងងឹត តែមានពន្លឺប្រព្រឹត្តទៅខាងមុខ[២] ១ បុគ្គលមានពន្លឺ តែមានងងឹតប្រព្រឹត្តទៅខាងមុខ[៣] ១ បុគ្គលមានពន្លឺ មានពន្លឺប្រព្រឹត្តទៅខាងមុខទៀត[៤] ១ ។

---

១ បុគ្គលកើតក្នុងត្រកូលថោកទាប ហើយប្រព្រឹត្តទុច្ចរិតទៀត ។ ២ បុគ្គលកើតក្នុងត្រកូលថោកទាប តែប្រព្រឹត្តសុចរិត ។ ៣ បុគ្គលកើតក្នុងត្រកូលខ្ពង់ខ្ពស់ តែប្រព្រឹត្តទុច្ចរិត ។ ៤ បុគ្គលកើតក្នុងត្រកូលខ្ពង់ខ្ពស់ ហើយប្រព្រឹត្តសុចរិត ។

សង្គីតិសុត្តេ សង្គីតិយបញ្ចកំ

[១៤៨] អបរេបិ ចត្តារោ បុគ្គលា សមណមចលោ សមណបទុមោ សមណបុណ្ឌរីកោ សមណេសុ[១] សមណសុខុមាលោ ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គា-យិតព្វំ ។ បេ ។ អត្ថាយ ហិតាយ ទេវមនុស្សានំ ។

សង្គីតិយចតុក្កំ និដ្ឋិតំ[២] ។

[១៤៩] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បញ្ច ធម្មា សម្ម-ទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ បញ្ច ។ បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។

---

១ ឱ. សមណេសូតិ ន ទិស្សតិ ។ ២ ម. សង្គីតិយចតុក្កំ និដ្ឋិតន្តិ ន ទិស្សតិ ។ ឱ. បឋមកភាណវារំ និដ្ឋិតំ ។

សង្គីតិសូត្រ ពួកធម៌ប្រាំ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១៨៨] បុគ្គលមាន ៤ ពួកដទៃទៀត គឺ សមណៈមិនកម្រើក[១] ១ សមណៈដូចផ្កាឈូកក្រហម[២] ១ សមណៈដូចផ្កាឈូកស[៣] ១ សមណៈជាអ្នកទន់ល្អិតល្អក្នុងពួកសមណៈ[៤] ១ ។ ម្នាលអាវុសោទាំងឡាយ ពួកធម៌បួន ៗ នេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ យើងទាំងអស់គ្នាគួរសង្គាយនាក្នុងធម៌នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[១៨៩] ម្នាលអាវុសោទាំងឡាយ ពួកធម៌ប្រាំ ៗ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ យើងទាំងអស់គ្នា គួរសង្គាយនាក្នុងធម៌ទាំងនោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ពួកធម៌ប្រាំ ៗ តើដូចម្តេច ។ ខន្ធ ៥ យ៉ាង គឺ រូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ ។

---

១ សោតាបន្នសមណៈ ។ ២ សកទាគាមិសមណៈ ។ ៣ អនាគាមិសមណៈ ។ ៤ អរហន្តសមណៈ ។

[១៨០] បញ្ចុបាទានក្ខន្ធា រូបុបាទានក្ខន្ធោ វេទ-
នុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទា-
នក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។

[១៨១] បញ្ច កាមគុណា ចក្ខុវិញ្ញេយ្យា រូបា
ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា
រជនីយា ។ សោតវិញ្ញេយ្យា សទ្ទា ។ ឃានវិញ្ញេយ្យា
គន្ធា ។ ជិវ្ហាវិញ្ញេយ្យា រសា ។ កាយវិញ្ញេយ្យា
ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូប-
សញ្ហិតា រជនីយា ។

[១៨២] បញ្ច គតិយោ និរយោ តិរច្ឆានយោនិ
បេតវិសយោ មនុស្សា ទេវា ។

[១៨៣] បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុល-
មច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។

[១៥០] ឧបាទានក្ខន្ធ ៥ យ៉ាង គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

[១៥១] កាមគុណ ៥ យ៉ាង គឺ រូបទាំងឡាយដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ អាស្រ័យនូវកាម ជាហេតុនៃសេចក្តីត្រេកអរ ១ ។ សំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ១ ។ ក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ ១ ។ រសទាំងឡាយ ដែលគប្បីដឹងដោយអណ្តាត ១ ។ សម្ផស្សទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ អាស្រ័យនូវកាមជាហេតុនៃសេចក្តីត្រេកអរ ១ ។

[១៥២] គតិ ៥ យ៉ាង គឺ នរក ១ កំណើតតិរច្ឆាន ១ ប្រេតវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។

[១៥៣] សេចក្តីកំណាញ់ ៥ យ៉ាង គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ[១] ១ កំណាញ់ធម៌ ១ ។

---

១ ថា កំណាញ់សេចក្តីសរសើរ ឬកំណាញ់ព័ណ៌សម្បុរក៏បាន ។

## សង្គីតិសុត្តេ សង្គីតិយបញ្ចកំ

[១៥៤] បញ្ច នីវរណានិ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ។

[១៥៥] បញ្ច ឱរម្ភាគិយានិ សញ្ញោជនានិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ កាមច្ឆន្ទោ ព្យាបាទោ ។

[១៥៦] បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។

[១៥៧] បញ្ច សិក្ខាបទានិ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី ។

[១៥៨] បញ្ច អភព្វដ្ឋានានិ អភព្វោ អាវុសោ ខីណាសវោ ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេតុំ អភព្វោ ខីណាសវោ ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ អាទាតុំ អភព្វោ ខីណាសវោ ភិក្ខុ មេថុនំ ធម្មំ បដិសេវិតុំ

សង្គីតិសូត្រ ពួកធម៌ប្រាំ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១៥៤] នីវរណៈ ៥ យ៉ាង គឺ កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។

[១៥៥] សំយោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាង គឺ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ។

[១៥៦] សំយោជនៈ ជាចំណែកខាងលើ ៥ យ៉ាង គឺ រូបរាគ ១ អរូបរាគ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។

[១៥៧] សិក្ខាបទ ៥ យ៉ាង គឺ ការវៀរចាកការសម្លាប់សត្វ ១ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ១ ។

[១៥៨] អភព្វដ្ឋាន (ហេតុដែលមិនគួរ) ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុជាខីណាស្រពមិនគួរ ដើម្បីក្លែងញុំាងសត្វឲ្យធ្លាក់ចុះចាកជីវិត ១ ភិក្ខុជាខីណាស្រពមិនគួរ ដើម្បីកាន់យកទ្រព្យដែលគេមិនឲ្យដោយចំណែកគឺចិត្តលួច ១ ភិក្ខុជាខីណាស្រពមិនគួរ ដើម្បីសេពមេថុនធម្ម ១

អភព្វោ ខីណាសវោ ភិក្ខុ សម្បជានមុសា ភាសិតុំ អភព្វោ ខីណាសវោ ភិក្ខុ សន្និធិការកំ កាមេ បរិ-កុញ្ជិតុំ សេយ្យថាបិ បុព្វេ អាគារិកភូតោ[១] ។

[១៥៩] បញ្ច ព្យសនានិ ញាតិព្យសនំ ភោគព្យ-សនំ រោគព្យសនំ សីលព្យសនំ ទិដ្ឋិព្យសនំ ។ នាវុ-សោ សត្តា ញាតិព្យសនហេតុ វា ភោគព្យសនហេតុ វា រោគព្យសនហេតុ វា កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ សីលព្យស-នហេតុ វា អាវុសោ សត្តា ទិដ្ឋិព្យសនហេតុ វា កា-យស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។

[១៦០] បញ្ច សម្បទា ញាតិសម្បទា ភោគស-ម្បទា អារោគ្យសម្បទា សីលសម្បទា ទិដ្ឋិសម្បទា ។

១ ឱ. អគារិយភូតោ ។

ភិក្ខុជាខីណាស្រពមិនគួរពោលសម្បជានមុសាវាទ ១ ភិក្ខុជាខីណាស្រពមិនគួរបរិភោគនូវរបស់ដែលខ្លួនធ្វើសេចក្តីសន្សំទុកនិងកាមទាំងឡាយ ដូចកាលខ្លួននៅជាគ្រហស្ថក្នុងកាលពីដើម ១ ។

[១៥៩] សេចក្តីវិនាស ៥ យ៉ាង គឺ សេចក្តីវិនាសញាតិ ១ សេចក្តីវិនាសភោគសម្បត្តិ ១ សេចក្តីវិនាសព្រោះរោគ ១ សេចក្តីវិនាសសីល ១ សេចក្តីវិនាសទិដ្ឋិ ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែសេចក្តីវិនាសញាតិក្តី ព្រោះហេតុតែសេចក្តីវិនាសភោគៈក្តី ព្រោះហេតុតែសេចក្តីវិនាសដោយរោគក្តី (នោះទេ) ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ៗ កើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែសេចក្តីវិនាសសីល ឬ ព្រោះហេតុតែសេចក្តីវិនាសទិដ្ឋិ ។

[១៦០] សេចក្តីបរិបូណ៌ ៥ យ៉ាង គឺ បរិបូណ៌ដោយញាតិ ១ បរិបូណ៌ដោយភោគៈ ១ បរិបូណ៌ដោយភាពមិនមានរោគ ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយទិដ្ឋិ ១ ។

នាវុសោ សត្តា ញាតិសម្បទាហេតុ វា ភោគសម្បទាហេតុ វា អារោគ្យសម្បទាហេតុ វា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សីលសម្បទាហេតុ វា អាវុសោ សត្តា ទិដ្ឋិសម្បទាហេតុ វា កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។

[១៦១] បញ្ច អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ឥធាវុសោ ទុស្សីលោ សីលវិបន្នោ បមាទាធិករណំ មហន្តឹ ភោគជានឹ និគច្ឆតិ អយំ បឋមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ អាវុសោ ទុស្សីលស្ស សីលវិបន្នស្ស បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ អាវុសោ ទុស្សីលោ សីលវិបន្នោ យំ យទេវ[១] បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ

១ ម. យញ្ញទេវ ។

ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះហេតុតែបរិបូណ៌ដោយញាតិក្តី ព្រោះហេតុតែបរិបូណ៌ដោយភោគៈក្តី ព្រោះហេតុតែបរិបូណ៌ដោយភាពមិនមានរោគក្តី នោះទេ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងបានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះហេតុតែបរិបូណ៌ដោយសីល ឬព្រោះហេតុតែបរិបូណ៌ដោយទិដ្ឋិ ។

[១៦១] ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ក្នុងលោកនេះ បុគ្គលទ្រុស្តសីល វិបត្តិចាកសីលនេះ តែងដល់នូវសេចក្តីវិនាសនៃសម្បត្តិយ៉ាងធំ មានសេចក្តីប្រមាទ ជាហេតុ នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិត្តិសព្ទអាក្រក់របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងផ្សាយទៅសព្វទិស នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ចូលទៅរកបរិស័ទណា ៗ ទោះខត្តិយ-

យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ អយំ តតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ អាវុសោ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ អាវុសោ ទុស្សីលោ សីលវិបន្នោ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ អយំ បញ្ចមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។

[១៦២] បញ្ច អានិសំសា សីលវតោ សីលសម្បទាយ ឥធាវុសោ សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អយំ បឋមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ អាវុសោ សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ អាវុសោ សីលវា សីលសម្បន្នោ យំ យទេវ បរិសំ ឧបសង្កមតិ

បរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី រមែងមិនក្លៀវក្លា មានមុខឱនចុះ នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងវង្វេងធ្វើមរណកាល នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលទី ៥ ។

[១៦២] អានិសង្សនៃសីលសម្បទា ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ក្នុងលោកនេះ បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងបាននូវគំនរទ្រព្យច្រើន មានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីល បរិបូណ៌ដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីលទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល ចូលទៅរកបរិស័ទណា ៗ ទោះ

យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ អយំ តតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ អាវុសោ សីលវា សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ អាវុសោ សីលវា សីលសម្បន្នោ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ អយំ បញ្ចមោ អានិសំសោ សីលវតោ សីលសម្បទាយ ។

[១៦៣] ចោទកេន អាវុសោ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋបេត្វា បរោ ចោទេតព្វោ កាលេន វក្ខាមិ នោ អកាលេន ភូតេន វក្ខាមិ នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន អត្ថសញ្ហិតេន វក្ខាមិ នោ អនត្ថសញ្ហិតេន

បីជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណ-បរិស័ទក្តី រមែងក្លៀវក្លា មិនមានមុខឱនចុះ នេះជាអានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីលទី ៣ ។ ម្នាលអាវុសោទាំងឡាយមួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងមិនវង្វេងធ្វើមរណកាល នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត បុគ្គលមានសីលបរិបូណ៌ដោយសីល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅតែងបានទៅកើតក្នុងសុគតិសួគ៌ទេវលោក នេះជាអានិសង្សនៃសីលសម្ប-ទា របស់បុគ្គលមានសីលទី ៥ ។

[១៦៣] ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតម្កល់ធម៌ ៥ យ៉ាងទុកក្នុងខ្លួនហើយសឹមចោទភិក្ខុដទៃ ដោយគិតថា អាត្មាអញនឹងនិយាយក្នុងកាលគួរ មិននិយាយក្នុងកាលមិនគួរ ១ អាត្មាអញនិយាយដោយពាក្យពិត មិននិយាយដោយពាក្យមិនពិត ១ អាត្មាអញនិយាយ ដោយពាក្យផ្អែមល្ហែមមិននិយាយដោយពាក្យទ្រគោះ ១ អាត្មាអញនិយាយ ដោយពាក្យប្រកបដោយប្រយោជន៍ មិននិយាយ ដោយពាក្យមិនប្រកបដោយ

មេត្តចិត្តេន វក្ខាមិ នោ ទោសន្តរោតិ ។ ចោទកេន អាវុសោ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋបេត្វា បរោ ចោទេតព្វោ ។

[១៦៤] បញ្ច បធានិយង្គានិ ឥធាវុសោ ភិក្ខុ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ

ប្រយោជន៍ ១ អាត្មាអញនិយាយ ដោយចិត្តប្រកបដោយមេត្តា មិននិយាយដោយចិត្តប្រកបដោយទោស ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកចោទមានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតម្កល់ធម៌ ៥ ប្រការនេះ ទុកក្នុងខ្លួនហើយទើបចោទភិក្ខុដទៃបាន ។

[១៦៤] អង្គនៃភិក្ខុដែលមានសេចក្តីព្យាយាមមាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេសហើយ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូរបស់ទេវតានិងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងមកកាន់ភពថ្មីទៀត ដោយហេតុនេះ ៗ ១ ជាអ្នកមិនមានអាពាធ មិនមានសេចក្តីទុក្ខ ប្រកបដោយតេជោធាតុ ចាស់ល្មមមិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម ១ មិនមែនជាអ្នកលេងបោកប្រាស មិនមានមាយា ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវខ្លួនគួរតាមពិត ក្នុងសំណាក់ព្រះសាស្តា ឬក្នុងសំណាក់សព្រហ្មចារីទាំងឡាយ

សង្គីតិសុត្តេ សង្គីតិយបញ្ចកំ

អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហ-
បរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។

[១៦៤] បញ្ច សុទ្ធាវាសា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា ។

ដែលជាអ្នកចេះដឹង ១ ជាបុគ្គលប្រារព្ធព្យាយាម ដើម្បីលះបង់នូវធម៌ជាអកុសល ដើម្បីញុំាងកុសលធម៌ឲ្យដុះដាលឡើង ជាបុគ្គលមានកម្លាំងចិត្ត មានសេចក្តីសង្វាតដ៏មាំ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំង-ឡាយ ១ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាដែលអាចនឹងកំណត់[១] នូវសេចក្តីកើតនិងសេចក្តីរលត់បាន ជាបញ្ញាដ៏បរិសុទ្ធ ជាបញ្ញាអាចទម្លុះទម្លាយនូវគំនរនៃលោភៈជាដើម ជាបញ្ញាញុំាងសត្វឲ្យដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ១ ។

[១៦៥] សុទ្ធាវាស[២] មាន ៥ យ៉ាង គឺ អវិហៈ ១ អតប្បៈ ១ សុទស្សៈ ១ សុទស្សី ១ អកនិដ្ឋ ១ ។

---

១ បានខាងឧទយព្វយញ្ញាណ ក្នុងវិបស្សនា ។ ២ ទីនៅរបស់សត្វដ៏បរិសុទ្ធ គឺព្រះអនាគាមីនិងព្រះខីណាស្រព ។

[១៦៦] បញ្ច អនាគាមិនោ អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី ។

[១៦៧] បញ្ច ចេតោខីលា ឥធាវុសោ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ យោ សោ អាវុសោ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ

[១៦៦] អនាគាមិបុគ្គល ៥ ពួក គឺ លោកដែលបរិនិព្វានក្នុងពាក់កណ្តាលអាយុ[១] ១ លោកដែលបរិនិព្វានដោយកន្លងហួសពាក់កណ្តាលអាយុ[២] ១ លោកដែលបរិនិព្វានដោយមិនមានសេចក្តីព្យាយាម[៣] ១ លោកដែលបរិនិព្វានដោយសេចក្តីព្យាយាមយ៉ាងខ្លាំង[៤] ១ លោកដែលមានខ្សែខាងលើហើយទៅកាន់អកនិដ្ឋភព[៥] ១ ។

[១៦៧] ចេតោខីលៈ (សេចក្តីរឹងត្អឹងរបស់ចិត្ត) មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះ មិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិលេស

---

១ បុគ្គលដែលមិនកន្លងពាក់កណ្តាលអាយុ ហើយដល់នូវព្រះអរហត្តជាទីរំលត់នូវកិលេសក្នុងពាក់កណ្តាលអាយុ ។ ២ បុគ្គលដែលប្រព្រឹត្តកន្លងពាក់កណ្តាលអាយុហើយដល់នូវព្រះអរហត្តជាទីរំលត់នូវកិលេស ។ ៣ បុគ្គលដែលមិនលំបាកដោយសេចក្តីព្យាយាម ហើយដល់នូវព្រះអរហត្តជាទីរំលត់នូវកិលេសដោយស្រួល ។ ៤ បុគ្គលដែលលំបាកដោយសេចក្តីព្យាយាម ហើយដល់នូវព្រះអរហត្តជាទីរំលត់នូវកិលេសដោយលំបាក ។ ៥ បុគ្គលដែលកើតក្នុងជាន់សុទ្ធាវាសទាំង ៥ តាំងអំពីអវិហាៈរហូតដល់អកនិដ្ឋភព ។

១៨៣

សង្គីតិសុត្តេ សង្គីតិយបញ្ចកំ

អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតោខីលោ ។ បុនចបរំ អាវុសោ ភិក្ខុ ធម្មេ កង្ខតិ ។ សង្ឃេ កង្ខតិ ។ សិក្ខាយ កង្ខតិ វិចិកិច្ឆតិ ។ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ ។ យោ សោ អាវុសោ ភិក្ខុ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ

ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ ចិត្ត របស់ភិក្ខុណា មិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បី ព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ នេះជាសេចក្តី រឹងត្អឹងនៃចិត្តទី ១ របស់ភិក្ខុនោះ ។ ម្នាលអាវុសោទាំងឡាយ មួយ ទៀត ភិក្ខុសង្ស័យ ក្នុងព្រះធម៌ ១ ។ ភិក្ខុសង្ស័យ ក្នុងព្រះសង្ឃ ១ ។ សង្ស័យ ងឿងឆ្ងល់ ក្នុងសិក្ខា ១ ។ ភិក្ខុក្រោធ អាក់អន់ចិត្ត មានចិត្ត ត្រូវទោសៈខ្ទាំងខ្ទប់ មានចិត្តរឹងត្អឹងក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាជាបុគ្គលក្រោធ អាក់អន់ចិត្ត មាន ចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មានចិត្តរឹងត្អឹង ក្នុងសព្រហ្មចារីបុគ្គលទាំង-ឡាយ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិ-លេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ

បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុ-
យោគាយ សាតច្ចាយ បធានាយ[១] អយំ បញ្ចមោ
ចេតោខីលោ ។

[១៦៨] បញ្ច ចេតសោ វិនិពន្ធា ឥធាវុសោ ភិក្ខុ
កាមេសុ[២] អវិគតរាគោ[៣] ហោតិ អវិគតច្ឆន្ទោ អវិ-
គតបេ្បមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគត-
តណ្ហោ ។ យោ សោ អាវុសោ ភិក្ខុ កាមេសុ អវិគតរា-
គោ ហោតិ អវិគតច្ឆន្ទោ អវិគតបេ្បមោ អវិគតបិបាសោ
អវិគតបរិឡាហោ អវិគតតណ្ហោ តស្ស ចិត្តំ ន នមតិ
អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ

---

១ ឱ. យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយាតិ ន ទិស្សន្តិ ។ ២ ឱ. កាមេ ។ ៣ ម. អវីតរាគោ ។

ចិត្តរបស់ភិក្ខុណា មិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ នេះជាសេចក្តីរឹងត្អឹងនៃចិត្តទី ៥ របស់ភិក្ខុនោះ ។

[១៦៨] ចំណងរបស់ចិត្តមាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំង-ឡាយ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិ-លេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ

សង្គីតិសុត្តេ សង្គីតិយបញ្ចកំ

យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតសោ វិនិពន្ធោ ។ បុន ចបរំ អាវុសោ ភិក្ខុ កាយេ អវីតរាគោ ហោតិ ។ សង្ខិត្តំ ។ រូបេ អវីតរាគោ ហោតិ ។ សង្ខិត្តំ ។ បុន ចបរំ អាវុសោ ភិក្ខុ យាវ-ទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរតិ ។ បុន ចបរំ អាវុសោ ភិក្ខុ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ។ យោ សោ អាវុសោ ភិក្ខុ អញ្ញតរំ ទេវនិកា-យំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា

ចិត្តរបស់ភិក្ខុណាមិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ នេះជាចំណងនៃចិត្តទី ១ របស់ភិក្ខុនោះ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ។ សេចក្តីបំប្រួញ ។ ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងរូប ។ សេចក្តីបំប្រួញ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុបរិភោគត្រាតែឆ្អែតពេញពោះ ហើយប្រកបរឿយ ៗ នូវសេចក្តីសុខក្នុងទីដេក នូវសេចក្តីសុខ (ព្រោះដេកប្រែប្រួលខាងស្តាំខាងឆ្វេង) នូវសេចក្តីសុខ ព្រោះដេកលក់លង់ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះប្រាថ្នានូវពួកទេវតាជាន់ណាមួយថា ដោយសីលឬវ័ត ដោយសេចក្តីព្យាយាមឬព្រហ្មចារ្យនេះឯង សូមឲ្យអាត្មាអញបានជាទេវតា (មានសក្តិធំ) ឬទេវតា (មានសក្តិតូច) ណាមួយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះប្រាថ្នានូវពួកទេវតាណាមួយថា ដោយសីល

វាតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតសោ វិនិពន្ធោ ។

[១៦៩] បញ្ចិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ។

[១៧០] អបរានិបិ បញ្ចិន្ទ្រិយានិ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[១៧១] អបរានិបិ បញ្ចិន្ទ្រិយានិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។

[១៧២] បញ្ច និស្សារណីយា ធាតុយោ ឥធាវុសោ ភិក្ខុនោ កាមេ មនសិករោតោ កាមេសុ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ នេក្ខម្មំ ខោ បនស្ស មនសិករោតោ នេក្ខម្មេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ

ឬវ័ត ដោយព្យាយាម ឬព្រហ្មចារ្យនេះឯង សូមឲ្យអាត្មាអញបានជាទេវតា (មានសក្តិធំ) ឬទេវតា (មានសក្តិតូច) ណាមួយ ចិត្តរបស់ភិក្ខុនោះ រមែង មិនឱនទៅ ដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយ ៗ ដើម្បីព្យាយាមជាប់តទៅ នេះជាចំណងរបស់ចិត្តទី ៥ ។

[១៦៩] ឥន្ទ្រិយមាន ៥ យ៉ាង គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ។

[១៧០] ឥន្ទ្រិយមាន ៥ ដទៃទៀត គឺ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[១៧១] ឥន្ទ្រិយមាន ៥ ដទៃទៀត គឺ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។

[១៧២] និស្សារណីយធាតុ (ធាតុដែលគួររលាស់ចេញ) មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ កាលដែលភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅ ក្នុងកាមទាំងឡាយ តែបើកាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវនេក្ខម្មៈ (ការចេញចាកកាម) ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅចុះស៊ប់ក្នុងនេក្ខម្មៈ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថាទៅល្អហើយ អប់រំល្អហើយ

១៨៧

សង្គីតិសុត្តេ សង្គីតិយបញ្ហកំ

សុភាវិតំ សុវុឌ្ឋិតំ សុវិមុត្តំ វិសំយុត្តំ កាមេហិ យេ ច កាមប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា[១] មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ កាមានំ និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ព្យាបាទំ មនសិករោតោ ព្យាបាទេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អព្យាបាទំ ខោ បនស្ស មនសិករោតោ អព្យាបាទេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុឌ្ឋិតំ សុវិមុត្តំ វិសំយុត្តំ ព្យាបាទេន យេ ច ព្យាបាទប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា[២] មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ ព្យាបាទស្ស និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ

១-២ ឱ. ម. វិឃាតា បរិឡាហា ។

ចេញល្អហើយ រួចស្រឡះហើយ ប្រាសចេញហើយចាកកាមទាំងឡាយ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ក្តៅក្រហាយ តែងកើតឡើងព្រោះកាមជាបច្ច័យ ភិក្ខុនោះ រួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវកាមទាំង-ឡាយ ដែលព្រះមានព្រះភាគសំដែងហើយ ១ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវព្យាបាទ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងព្យាបាទ តែបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសេចក្តីមិនព្យាបាទ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការមិនព្យាបាទ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះល្អហើយ ប្រាសចេញហើយចាកព្យាបាទ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ ក្តៅក្រហាយ តែងកើតឡើងព្រោះព្យាបាទជាបច្ច័យ ភិក្ខុនោះរួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវព្យាបាទ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលដែល

វិហេសំ មនសិករោតោ វិហេសាយ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អវិហេសំ ខោ បនស្ស មនសិករោតោ អវិហេសាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ វិហេសាយ យេ ច វិហេសប្បច្ចយា[១] ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ វិហេសាយ និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ រូបេ[២] មនសិករោតោ រូបេសុ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អរូបំ ខោ បនស្ស មនសិករោតោ អរូបេ[៣] ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ រូបេហិ យេ ច រូបប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ

---

១ ឱ. វិហេសាបច្ចយា ។ ២ ឱ. រូបំ ។ ៣ ឱ. អរូបេសុ ។

ភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីបៀតបៀន ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងការបៀតបៀន តែបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការមិនបៀតបៀន ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការមិនបៀតបៀន ចិត្តរបស់ភិក្ខុនោះ ឈ្មោះថាទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះល្អហើយ ប្រាសចេញហើយចាកការបៀតបៀន អាសវៈទាំងឡាយណា ជាសការៈចង្អៀតចង្អល់ ក្តៅក្រហាយ តែងកើតឡើងព្រោះការបៀតបៀនជាបច្ច័យ ភិក្ខុនោះ រួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវការបៀតបៀន ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវរូបទាំងឡាយ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងរូបទាំងឡាយ តែបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវអរូប ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអរូប ចិត្តរបស់ភិក្ខុនោះ ឈ្មោះថាទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចល្អហើយ ប្រាសចេញហើយចាករូបទាំងឡាយ អាសវៈទាំងឡាយណា ជាសការៈចង្អៀតចង្អល់ ក្តៅក្រហាយ តែងកើតឡើងព្រោះរូបជាបច្ច័យ ភិក្ខុនោះ

តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ វូ-
បាទានំ និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ
សក្កាយំ មនសិករោតោ សក្កាយេ ចិត្តំ ន បក្ខន្ទតិ
ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ សក្កាយនិរោធំ
ខោ បនស្ស មនសិករោតោ សក្កាយនិរោធេ ចិត្តំ
បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ
សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ សក្កា-
យេន យេ ច សក្កាយប្បច្ចយា ឧប្បជ្ជន្តិ អាសវា
វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ
វេទេតិ ឥទមក្ខាតំ សក្កាយស្ស និស្សរណំ ។

[១៧៣] បញ្ច វិមុត្តាយតនានិ ឥធាវុសោ ភិក្ខុនោ
សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ[១] ស-
ព្រហ្មចារី ។ យថា យថា អាវុសោ ភិក្ខុនោ សត្ថា ធម្មំ
ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ[២] សព្រហ្មចារី តថា

---

១-២ ឱ. ម. គរុដ្ឋានិកោ ។

រួចហើយចាករូបទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវរូបទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវសក្កាយៈ (បញ្ចក្ខន្ធ) ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងសក្កាយៈ តែបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវការរលត់ទៅនៃសក្កាយៈ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការរលត់ទៅនៃសក្កាយៈ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថាទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះហើយ ប្រាសចេញហើយចាកសក្កាយៈ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ ក្តៅក្រហាយ តែងកើតឡើងព្រោះសក្កាយៈជាបច្ច័យ ភិក្ខុនោះ រួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវសក្កាយៈ ដែលព្រះមានព្រះភាគសំដែងហើយ ១ ។

[១៧៣] វិមុត្តាយតនៈ (ហេតុជាគ្រឿងរួច) មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះសាស្តា ឬសព្រហ្មចារីបុគ្គលណាមួយ ដែលគួរដល់ឋានៈជាគ្រូ រមែងសំដែងធម៌ដល់ភិក្ខុ ក្នុងសាសនានេះ ។ ម្នាលអាវុសោទាំងឡាយ ព្រះសាស្តា ឬ សព្រហ្មចារីបុគ្គលណាមួយ ដែលគួរដល់ឋានៈជាគ្រូ រមែងសំដែងធម៌ ដល់ភិក្ខុយ៉ាងណា ៗ

តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច ។ តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ បឋមំ វិមុត្តាយតនំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ន ហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ ។ សង្ខិត្តំ ។ អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ ។ បេ ។ អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ

ភិក្ខុនោះរមែងជាអ្នកដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះ ៗ ។ បាមោជ្ជៈ (សេចក្តីរីករាយ) រមែងកើតដល់ភិក្ខុនោះដែលជាអ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ លុះភិក្ខុមានសេចក្តីរីករាយហើយ បីតិក៏រមែងកើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាម-កាយក៏ស្ងប់រម្ងាប់ ភិក្ខុមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ លុះប្រកបសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ នេះជាវិមុត្តាយតនៈទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះសាស្តាឬសព្រហ្មចារីបុគ្គលណាមួយ ដែលគួរដល់ឋានៈជាគ្រូ មិនសំដែងធម៌ដល់ភិក្ខុទេ តែថាភិក្ខុនោះ រមែងសំដែងធម៌ដែលខ្លួនបានស្តាប់មកហើយយ៉ាងណា បានរៀនមកហើយយ៉ាងណា ដោយសេចក្តីពិស្តារដល់ជនទាំងឡាយដទៃ ។ សេចក្តីបំប្រួញ ។ តែថាភិក្ខុនោះ ធ្វើនូវការស្វាធ្យាយនូវធម៌ ដែលខ្លួនបានស្តាប់មកហើយយ៉ាងណា បានរៀនមកហើយយ៉ាងណា ដោយសេចក្តីពិស្តារ ។ បេ ។ តែថាភិក្ខុនោះ ត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ដោយចិត្ត ជញ្ជឹងក្នុងចិត្តរឿយ ៗ ចំ-ពោះធម៌ដែលខ្លួនបានស្តាប់មកហើយយ៉ាងណា រៀនមកហើយយ៉ាងណា

។ បេ ។ អបិច ខ្វាស្ស អញ្ញតរំ សមាធិនិមិត្តំ សុគ្គហិតំ ហោតិ សុមនសិកាតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ ។ យថា យថា អាវុសោ ភិក្ខុនោ អញ្ញតរំ សមាធិនិមិត្តំ សុគ្គហិតំ ហោតិ សុមនសិកាតំ សូប-ធារិតំ សុប្បដិវិទ្ធំ បញ្ញាយ តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច ។ តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កា-យោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិ-នោ ចិត្តំ សមាធិយតិ ឥទំ បញ្ចមំ វិមុត្តាយតនំ ។

[១៧៤] បញ្ច វិមុត្តិបរិបាចនិយា សញ្ញា អនិច្ច-សញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ។ ឥមេ ខោ អាវុសោ

ៗ បេ ៗ តែថា សមាធិនិមិត្តណាមួយ ក៏ភិក្ខុនោះរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ពិចារណាដោយល្អ ចាក់ធ្លុះដោយល្អ ដោយប្រាជ្ញាបាន ។ ម្នាលអាវុសោទាំងឡាយ សមាធិនិមិត្តណាមួយ ដែលភិក្ខុរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ពិចារណាដោយល្អ ចាក់ធ្លុះដោយល្អ ដោយប្រាជ្ញាយ៉ាងណា ៗ ភិក្ខុនោះ រមែងជាអ្នកដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះយ៉ាងនោះ ៗ ។ កាលភិក្ខុនោះបានដឹងច្បាស់នូវអត្ថ បានដឹងច្បាស់នូវធម៌ហើយ បាមោជ្ជៈរមែងកើតឡើង លុះបាមោជ្ជៈកើតឡើងហើយ បីតិរមែងកើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏រមែងស្ងប់រម្ងាប់ ភិក្ខុមាននាមកាយស្ងប់រម្ងាប់ហើយ តែងទទួលនូវសេចក្ដីសុខ កាលភិក្ខុទទួលសេចក្ដីសុខហើយ ចិត្តក៏តម្កល់នៅមាំ នេះជាវិមុត្តាយតនៈទី ៥ ។

[១៧៤] សញ្ញា (សេចក្ដីសំគាល់) ញ៉ាំងវិមុត្តិ[១] ឲ្យចាស់ក្លាមាន ៥ យ៉ាង គឺ សេចក្ដីសំគាល់ថា មិនទៀង ១ សេចក្ដីសំគាល់ថាទុក្ខក្នុងរបស់មិនទៀង ១ សេចក្ដីសំគាល់ថា មិនមែនរបស់ខ្លួនក្នុងរបស់ប្រកបដោយទុក្ខ ១ សេចក្ដីសំគាល់ក្នុងធម៌ជាគ្រឿងលះ ១ សេចក្ដីសំគាល់ក្នុងធម៌ជាគ្រឿងនឿយណាយ ១ ។ ម្នាលអាវុសោទាំងឡាយ

១ សំដៅយកព្រះអរហត្ត ។

តេន ភគវតា ជានតា បស្សតា អរហតា សម្មា-សម្ពុទ្ធេន បញ្ច ធម្មា សម្មទក្ខាតា តត្ថ សព្ពេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

សង្គីតិយបញ្ចកំ និដ្ឋិតំ[១] ។

[១៧៥] អត្ថិ ខោ អាវុសោ តេន ភគវតា ។ បេ ។ សម្មាសម្ពុទ្ធេន ឆ ធម្មា សម្មទក្ខាតា តត្ថ សព្ពេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ ឆ ។ ឆ អជ្ឈត្តិកានិ អា-យតនានិ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ។

[១៧៦] ឆ ពាហិរានិ អាយតនានិ រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ ធម្មាយតនំ ។

---

១ ឱ. ម. សង្គីតិយបញ្ចកំ និដ្ឋិតន្តិ ន ទិស្សតិ ។

ពួកធម៌ប្រាំ ៗ នេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ យើងទាំងអស់គ្នា គប្បីសង្គាយនាក្នុងធម៌ទាំងនោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌ប្រាំ ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[១៧៥] ម្នាលអាវុសោទាំងឡាយ ពួកធម៌ប្រាំមួយ ៗ ដែលព្រះមានព្រះភាគអង្គនោះ ។ បេ ។ ជាសម្មាសម្ពុទ្ធទ្រង់សំដែងទុកដោយប្រពៃ យើងទាំងអស់គ្នា គប្បីសង្គាយនាក្នុងធម៌ទាំងនោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ពួកធម៌ប្រាំមួយ ៗ តើដូចម្តេច ។ អាយតនៈខាងក្នុង ៦ យ៉ាង គឺ អាយតនៈគឺភ្នែក ១ អាយតនៈគឺត្រចៀក ១ អាយតនៈគឺច្រមុះ ១ អាយតនៈគឺអណ្តាត ១ អាយតនៈគឺកាយ ១ អាយតនៈគឺចិត្ត ១ ។

[១៧៦] អាយតនៈខាងក្រៅ ៦ យ៉ាង គឺ អាយតនៈគឺរូប ១ អាយតនៈគឺសំឡេង ១ អាយតនៈគឺក្លិន ១ អាយតនៈគឺរស ១ អាយតនៈគឺផ្សព្វ ១ អាយតនៈគឺធម៌[១] ១ ។

---

១ បានដល់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងអនិទស្សនរូប (រូបមើលមិនឃើញ) និងអបដិឃរូប (រូបប៉ះពាល់មិនបាន) និងអសង្ខតធាតុ (និព្វាន) ។ អាយតនវិភង្គ អភិធម្ម ។

១៩៣

សង្គីតិសុត្តេ សង្គីតិយច្ឆក្កំ

[១៧៧] ឆ វិញ្ញាណកាយា ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ ។

[១៧៨] ឆ ផស្សកាយា ចក្ខុសម្ផស្សោ ។ បេ ។ មនោសម្ផស្សោ ។

[១៧៩] ឆ វេទនាកាយា ចក្ខុសម្ផស្សជា វេទនា ។ បេ ។ មនោសម្ផស្សជា វេទនា ។

[១៨០] ឆ សញ្ញាកាយា រូបសញ្ញា ។ បេ ។ ធម្មសញ្ញា ។

[១៨១] ឆ សញ្ចេតនាកាយា រូបសញ្ចេតនា ។ បេ ។ ធម្មសញ្ចេតនា ។

[១៨២] ឆ តណ្ហាកាយា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។

[១៧៧] ប្រជុំនៃវិញ្ញាណ ៦ យ៉ាង គឺ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។

[១៧៨] ប្រជុំនៃផស្សៈ ៦ យ៉ាង គឺ ចក្ខុសម្ផ័ស្ស ១ ។ បេ ។ មនោសម្ផ័ស្ស ១ ។

[១៧៩] ប្រជុំនៃវេទនា ៦ យ៉ាង គឺ វេទនាកើតអំពីចក្ខុសម្ផ័ស្ស ១ ។ បេ ។ វេទនាកើតអំពីមនោសម្ផ័ស្ស ១ ។

[១៨០] ប្រជុំនៃសញ្ញា ៦ យ៉ាង គឺ រូបសញ្ញា ១ ។ បេ ។ ធម្មសញ្ញា ១ ។

[១៨១] ប្រជុំនៃសញ្ចេតនា[១] ៦ យ៉ាង គឺ រូបសញ្ចេតនា ១ ។ បេ ។ ធម្មសញ្ចេតនា ១ ។

[១៨២] ប្រជុំនៃតណ្ហា ៦ យ៉ាង គឺ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ។

---

១ បានដល់សង្ខារក្ខន្ធ ។ សញ្ចេតនា ប្រែថា គិត, ចំណុចចិត្ត, ក្លែង, តាក់តែង, ធ្វើ ។

[១៨៣] ឆ អគារវា ឥធាវុសោ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយ អគារវោ វិហរតិ អប្បតិស្សោ អប្បមាទេ អគារវោ វិហរតិ អប្បតិស្សោ បដិសន្ថារេ អគារវោ វិហរតិ អប្បតិស្សោ ។

[១៨៤] ឆ សគារវា[១] ឥធាវុសោ ភិក្ខុ សត្ថរិ សគារវោ វិហរតិ សប្បតិស្សោ ធម្មេ សគារវោ វិហរតិ សប្បតិស្សោ សង្ឃេ សគារវោ វិហរតិ សប្បតិស្សោ សិក្ខាយ សគារវោ វិហរតិ សប្បតិស្សោ អប្បមាទេ សគារវោ វិហរតិ សប្បតិស្សោ បដិសន្ថារេ សគារវោ វិហរតិ សប្បតិស្សោ ។

---

១ ឱ. ម. គារវា ។

[១៨៣] អគារវៈ (សេចក្តីមិនគោរព) ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តា ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃ ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងសិក្ខា ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងអប្បមាទធម៌ ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងបដិសន្ថារៈ ១ ។

[១៨៤] សគារវៈ (សេចក្តីគោរព) ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងព្រះសាស្តា ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងព្រះធម៌ ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងព្រះសង្ឃ ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងសិក្ខា ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងអប្បមាទធម៌ ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ក្នុងបដិសន្ថារៈ ១ ។

១៩៤

សង្គីតិសុត្តេ សង្គីតិយច្ឆក្កំ

[១៨៥] ឆ សោមនស្សុបវិចារា ចក្ខុនា រូបំ ទិស្វា សោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ ។ សោតេន សទ្ទំ សុត្វា... ។ ឃានេន គន្ធំ ឃាយិត្វា... ។ ជិវ្ហាយ រសំ សាយិត្វា... ។ កាយេន ផោដ្ឋព្វំ ផុសិត្វា... ។ មនសា ធម្មំ វិញ្ញាយ សោមនស្សដ្ឋានិយំ ធម្មំ ឧបវិចរតិ ។

[១៨៦] ឆ ទោមនស្សុបវិចារា ចក្ខុនា រូបំ ទិស្វា ទោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ ។ សោតេន សទ្ទំ សុត្វា... ។ ឃានេន គន្ធំ ឃាយិត្វា... ។ ជិវ្ហាយ រសំ សាយិត្វា... ។ កាយេន ផោដ្ឋព្វំ ផុសិត្វា... ។ មនសា ធម្មំ វិញ្ញាយ ទោមនស្សដ្ឋានិយំ ធម្មំ ឧបវិចរតិ ។

សង្គីតិសូត្រ ពួកធម៌ប្រាំមួយ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[១៨៥] សោមនស្សុបវិចារ (ធម៌ជាគ្រឿងគន់គិតប្រកបដោយសោមនស្ស) ៦ យ៉ាង គឺ បុគ្គលឃើញរូបដោយភ្នែក ក៏គន់គិតនូវរូបដែលគួរជាទីតាំនៃសោមនស្ស ១ ។ ស្តាប់សម្លេងដោយត្រចៀក... ១ ។ ធុំក្លិនដោយច្រមុះ... ១ ។ ទទួលរសដោយអណ្តាត... ១ ។ ពាល់ត្រូវផ្សព្វដោយកាយ... ១ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ក៏គន់គិតនូវធម្មារម្មណ៍ ដែលគួរជាទីតាំងនៃសោមនស្ស ១ ។

[១៨៦] ទោមនស្សុបវិចារ (ធម៌ជាគ្រឿងគន់គិតប្រកបដោយទោមនស្ស) ៦ យ៉ាង គឺ បុគ្គលឃើញរូបដោយភ្នែក ក៏គន់គិតនូវរូបដែលគួរជាទីតាំងនៃទោមនស្ស ១ ។ ស្តាប់សម្លេងដោយត្រចៀក... ១ ។ ធុំក្លិនដោយច្រមុះ... ១ ។ ទទួលរសដោយអណ្តាត... ១ ។ ពាល់ត្រូវផ្សព្វដោយកាយ... ១ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ក៏គន់គិតនូវធម្មារម្មណ៍ ដែលគួរជាទីតាំងនៃទោមនស្ស ១ ។

[១៨៧] ឆ ឧបេក្ខូបវិចារា ចក្ខុនា រូបំ ទិស្វា ឧបេក្ខដ្ឋានិយំ រូបំ ឧបវិចរតិ ។ សោតេន សទ្ទំ សុត្វា... ។ ឃានេន គន្ធំ ឃាយិត្វា... ។ ជិវ្ហាយ រសំ សាយិត្វា... ។ កាយេន ផោដ្ឋព្វំ ផុសិត្វា... ។ មនសា ធម្មំ វិញ្ញាយ ឧបេក្ខដ្ឋានិយំ ធម្មំ ឧបវិចរតិ ។

[១៨៨] ឆ សារាណីយា ធម្មា ឥធាវុសោ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ ស-ព្រហ្មចារីសុ អាវិ ចេវ រហោ ច អយំ[១] ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុនោ មេត្តំ វចីកម្មំ ។ មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយំបិ ធម្មោ សារាណីយោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ

១ ឱ. អយម្បិ ។

[១៨៧] ឧបេក្ខូបវិចារ (ធម៌ជាគ្រឿងគន់គិតប្រកបដោយឧបេក្ខា) ៦ យ៉ាង គឺ បុគ្គលឃើញរូបដោយភ្នែក ក៏គន់គិតនូវរូប ដែលជាទីតាំងនៃឧបេក្ខា ១ ។ ស្តាប់សម្លេងដោយត្រចៀក... ១ ។ ធុំក្លិនដោយច្រមុះ... ១ ។ ទទួលរសដោយអណ្តាត... ១ ។ ពាល់ត្រូវផ្សព្វដោយកាយ... ១ ។ ដឹងច្បាស់ នូវធម្មារម្មណ៍ដោយចិត្ត ក៏គន់គិតនូវធម្មារម្មណ៍ ដែលគួរជាទីតាំងនៃឧបេក្ខា ១ ។

[១៨៨] សារាណីយធម៌ (ធម៌គួររលឹក) ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់នូវកាយកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររលឹក ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីសាមគ្គី ដើម្បីឯកីភាព (ភាពតែពួកមួយ) ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុតម្កល់នូវ-វចីកម្មប្រកបដោយមេត្តា ១ ។ ភិក្ខុ តម្កល់នូវមនោកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររលឹក ។ បេ ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ១ ។ ម្នាល

សង្គីតិសុត្តេ សង្គីតិយឆក្កំ

ភិក្ខុ យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ
បត្តបរិយាបន្នមត្តំបិ តថារូបេហិ លាភេហិ អប្បដិវិ-
ភត្តភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សា-
ធារណភោគី អយំបិ ធម្មោ សារាណីយោ ។ បេ ។
ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ
យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អស-
ពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុបសត្ថានិ
អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេសុ សី-
លេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ
អាវិ ចេវ រហោ ច អយំបិ ធម្មោ សារាណី-
យោ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។

អាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកបរិភោគ មិនចែកមុខរបស់ ឬបុគ្គល[១] ដោយលាភទាំងឡាយ ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅសូម្បីលាភត្រឹមតែរបស់ដែលមានក្នុងបាត្រ គឺជាអ្នកមានការបរិភោគ ជាសាធារណៈ ដោយសព្រហ្មចារីទាំងឡាយ ដែលមានសីល នេះជាធម៌គួររលឹក ។ បេ ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីលស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយ ដែលជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហានិងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររលឹក ។ បេ ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ។

---

១ អដ្ឋកថា ថា មានពីរយ៉ាង គឺ ចែកមុខអាមិស ថា អាត្មាអញនឹងឲ្យវត្ថុប៉ុណ្ណេះ មិនឲ្យប៉ុណ្ណេះ ១ ចែកមុខបុគ្គលថា ឲ្យដល់អ្នកនោះ មិនឲ្យដល់អ្នកនោះ ១ ។ ការបរិភោគវៀរចាកហេតុទាំងពីរនេះ ឈ្មោះថា បរិភោគមិនចែកមុខរបស់ឬបុគ្គល គឺ ខ្លួនបរិភោគយ៉ាងណា ក៏ឲ្យគេយ៉ាងនោះ ហើយមិនរើសមុខបុគ្គលផង ។

បុន ចបរំ អាវុសោ ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយំបិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។

[១៨៩] ឆ វិវាទមូលានិ ឥធាវុសោ ភិក្ខុ កោធនោ ហោតិ ឧបនាហី ។ យោ សោ អាវុសោ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរីការី[១] ហោតិ ។ យោ សោ អាវុសោ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។

១ ឱ. ម. បរិបូរការី ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសេចក្តីយល់ឃើញស្មើគ្នានឹងសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររលឹក ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្រ្គោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសាមគ្គី ដើម្បីឯកីភាព ។

[១៨៩] មូលហេតុនៃសេចក្តីវិវាទ ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាមានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ភិក្ខុនោះមិនមានសេចក្តីគោរពកោតក្រែង ក្នុងព្រះសាស្តាខ្លះ មិនមានសេចក្តីគោរពកោតក្រែង ក្នុងព្រះធម៌ខ្លះ មិនមានសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃខ្លះ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ក្នុងសិក្ខាខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាមួយ មិនមានសេចក្តីគោរព កោតក្រែង ក្នុងព្រះសាស្តា ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។

១៩៩

សង្គីតិសុត្តេ  សង្គីតិយច្ចក្កំ

សិក្ខាយ ន បរិបូរីការី[១] ហោតិ ។ សោ សង្ឃេ វិវាទំ ជនេតិ យោ សោ ហោតិ វិវាទោ ពហុជនអហិតាយ ពហុជនអសុខាយ ពហុជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ[២] តុម្ហេ អាវុសោ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ ។ តត្រ តុម្ហេ អាវុសោ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ[៣] តុម្ហេ អាវុសោ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ ។ តត្រ តុម្ហេ អាវុសោ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ បុន ចបរំ អាវុសោ ភិក្ខុ មក្ខី ហោតិ បឡាសី ។ ឥស្សុកី ហោតិ មច្ឆរី ។

---

១ ឱ. ម. បរិបូរការី ។ ២-៣ ឯវរូបំ ចេ ។

ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ក្នុងសិក្ខា ។ ភិក្ខុនោះ រមែងបង្កវិវាទក្នុងសង្ឃ ដែលជាវិវាទកើតឡើង ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ បើលោកទាំងឡាយឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ខាងក្នុង ឬខាងក្រៅហើយ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយត្រូវព្យាយាម ដើម្បីលះមូលហេតុនៃវិវាទ ដ៏លាមកនោះចេញ ។ ម្នាលអាវុសោទាំងឡាយ បើលោកទាំងឡាយ មិនឃើញមូលហេតុនៃវិវាទមានសភាពយ៉ាងនេះ ខាងក្នុង ឬខាងក្រៅទេ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយត្រូវប្រតិបត្តិ ដើម្បីមិនឲ្យមូលហេតុនៃវិវាទ ដ៏លាមកនោះជាប់តាមតទៅ ។ ការលះមូលហេតុនៃវិវាទដ៏លាមកនុ៎ះ រមែងមានយ៉ាងនេះ ការមិនមានមូលហេតុនៃវិវាទដ៏លាមកនុ៎ះ ជាប់តាមតទៅ រមែងមានយ៉ាងនេះ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណនិងវាយឫកស្មើ ១ ។ ជាអ្នកមានសេចក្តីឫស្យានិងកំណាញ់ ១ ។

សឋោ ហោតិ មាយាវី ។ ចាបិច្ឆោ ហោតិ មិច្ឆា-
ទិដ្ឋិ ។ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី[១]
ទុប្បដិនិស្សគ្គី ។ យោ សោ អាវុសោ ភិក្ខុ
សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី
សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ
ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ
អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន
បរិបូរីការី ហោតិ ។ យោ សោ អាវុសោ
ភិក្ខុ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ
ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ[២]
ន បរិបូរីការី ។ សោ សង្ឃេ វិវាទំ ជនេតិ
យោ សោ ហោតិ វិវាទោ ពហុជនអហិតាយ
ពហុជនអសុខាយ ពហុជនស្ស អនត្ថាយ អហិតាយ
ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ អាវុសោ
វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យា-
ថ ។ តត្រ តុម្ហេ អាវុសោ តស្សេវ ចាប-
កស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។

១ ឱ. ម. អធានគ្គាហី ។ ២ ឱ. ម. សិក្ខាយ ។

ជាអ្នកអួតអាង មានពុតត្បុត ១ ។ ជាអ្នកមានប្រាថ្នាលាមក មានទិដ្ឋិខុស ១ ។ ជាអ្នកស្ទាបអង្អែលតែទិដ្ឋិរបស់ខ្លួន ជាអ្នកប្រកាន់មាំ កម្រនឹងលះបង់បាន ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាជាអ្នកស្ទាបអង្អែលតែទិដ្ឋិរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់បានដោយក្រ ភិក្ខុនោះរមែងមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តាខ្លះ មិនគោរព មិនកោតក្រែង ក្នុងព្រះធម៌ខ្លះ មិនគោរព មិនកោតក្រែង ក្នុងព្រះសង្ឃខ្លះ មិនជាអ្នកធ្វើឲ្យបរិបូរណ៌ក្នុងសិក្ខាខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាមួយជាអ្នកមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តាខ្លះ ក្នុងព្រះធម៌ខ្លះ ។ បេ ។ ក្នុងព្រះសង្ឃខ្លះ ។ បេ ។ មិនធ្វើឲ្យពេញលេញក្នុងសិក្ខាខ្លះ ។ ភិក្ខុនោះរមែងបង្កវិវាទក្នុងសង្ឃ ដែលជាវិវាទកើតឡើង ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ខាងក្នុងឬខាងក្រៅហើយ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ត្រូវព្យាយាមលះមូលហេតុនៃវិវាទដ៏លាមកនោះឯងចេញ ។

ឯវរូបញ្ចេ តុម្ហេ អាវុសោ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ ។ តត្រ តុម្ហេ អាវុសោ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។

[១៩០] ឆ ធាតុយោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ។

[១៩១] ឆ និស្សារណីយា ធាតុយោ ឥធាវុសោ ភិក្ខុ ឯវំ វទេយ្យ មេត្តា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ ព្យាបាទោ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ

ម្នាលអាវុសោទាំងឡាយ បើលោកទាំងឡាយ មិនពិចារណាឃើញមូល-ហេតុនៃវិវាទមានសភាពយ៉ាងនេះ ខាងក្នុង ឬខាងក្រៅទេ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីមិនឲ្យមានមូលហេតុនៃវិវាទដ៏លាមកនោះឯង ជាប់តាមតទៅបាន ។ ការលះមូលហេតុនៃវិវាទដ៏លាមកនុ៎ះ រមែងមានយ៉ាងនេះ ការមិនមានមូល-ហេតុនៃវិវាទដ៏លាមកជាប់តាមតទៅ រមែងមានយ៉ាងនេះ ១ ។

[១៩០] ធាតុ ៦ យ៉ាង គឺ ធាតុដី ១ ធាតុទឹក ១ ធាតុភ្លើង ១ ធាតុខ្យល់ ១ ធាតុអាកាស ១ ធាតុវិញ្ញាណ ១ ។

[១៩១] និស្សារណីយធាតុ ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា មេត្តាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា ព្យាបាទនៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះ ថា លោកកុំនិយាយយ៉ាងនេះឡើយ លោកមានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ

ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ ។ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ មេត្តាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស ព្យាបាទោ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ និស្សរណំ ហេតំ អាវុសោ ព្យាបាទស្ស យទិទំ មេត្តា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ ករុណា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ វិហេសា ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា[១] ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ

១ ឱ. ម. មាយស្មា ។

ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ មេត្តាចេតោវិមុត្តិ ដែលភិក្ខុចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា ព្យាបាទនៅតែគ្របសង្កត់ចិត្តភិក្ខុនោះ ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះមេត្តាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញ នូវព្យាបាទ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា ករុណាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា សេចក្តីបៀតបៀននៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះ ថា លោកកុំនិយាយយ៉ាងនេះឡើយ លោកមានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ

សង្គីតិសុត្តេ សង្គីតិយច្ឆក្កំ

ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ ។ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ ករុណាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស វិហេសា ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ និស្សរណំ ហេតំ អាវុសោ វិហេសាយ យទិទំ ករុណា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ មុទិតា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ អរតិ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា[១] ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ

១ ឱ. ម. មាយស្មា ។

ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ករុណាចេតោវិមុត្តិដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា សេចក្តីបៀតបៀននៅតែគ្រប់សង្កត់ចិត្តភិក្ខុនោះបាន ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះករុណាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវសេចក្តីបៀតបៀន ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា មុទិតាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា សេចក្តីមិនត្រេកអរនៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះ ថា លោកកុំនិយាយយ៉ាងនេះឡើយ លោកមានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះ

ន ហិ ភគវា ឯវំ វទេយ្យ ។ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ មុទិតាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស អរតិ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ និស្សរណំ ហេតំ អាវុសោ អរតិយា យទិទំ មុទិតា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ ឧបេក្ខា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ រាគោ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ ។

មានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការណ៍នេះមិនមែនជាហេតុមិនមែនជាបច្ច័យទេ មុទិតាចេតោវិមុត្តិដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថាសេចក្តីមិនត្រេកអរនៅតែគ្របសង្កត់ចិត្តភិក្ខុនោះបាន ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះមុទិតាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវសេចក្តីមិនត្រេកអរ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា ឧបេក្ខាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា រាគៈនៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកមានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគ មិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។

សង្គីតិសុត្តេ សង្គីតិយច្ឆក្កំ

អដ្ឋានមេតំ អាវុសោ អនវកាសោ យំ ឧបេក្ខាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស រាគោ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ និស្សរណំ ហេតំ អាវុសោ រាគស្ស យទិទំ ឧបេក្ខា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ អនិមិត្តា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ[១] និមិត្តានុសារិ វិញ្ញាណំ ហោតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ ។ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ អនិមិត្តាយ ចេតោវិមុត្តិយា ភាវិតាយ

---

១ ឱ. មេ ។

ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ឧបេក្ខាចេតោវិមុត្តិ ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា រាគៈនៅតែគ្របសង្កត់ចិត្តភិក្ខុនោះបាន ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះឧបេក្ខាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវរាគៈ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា អនិមិត្តាចេតោវិមុត្តិ (អរហត្តផលសមាបត្តិ) ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា ខ្ញុំនៅតែមានវិញ្ញាណដែលរលឹកតាមនូវនិមិត្ត ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកមានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ អនិមិត្តាចេតោវិមុត្តិ

ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិ-
តាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស
និមិត្តានុសារិ វិញ្ញាណំ ភវិស្សតីតិ នេតំ ឋានំ វិជ្ជ-
តិ ។ និស្សរណំ ហេតំ អាវុសោ សព្វនិមិត្តានំ យទិទំ
អនិមិត្តា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ
វទេយ្យ អស្មីតិ ខោ មេ វិគតេ[១] អយមហមស្មីតិ
ន សមនុបស្សាមិ ។ អថ ច បន មេ វិចិកិច្ឆា-
កថង្កថាសល្លំ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ
មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច
មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ
អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ ។ អដ្ឋានៈ-
មេតំ អាវុសោ អនវកាសោ យំ អស្មីតិ វិគតេ

១ ឱ. វិឃាតំ ។ ម. វិគតំ ។

ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថាភិក្ខុនោះនឹងមានវិញ្ញាណរលឹកតាមនូវនិមិត្ត ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះអនិមិត្តាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវនិមិត្តទាំងអស់ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា កាលបើសេចក្តីប្រកាន់របស់ខ្ញុំថា អាត្មាអញមានដូច្នេះ អស់រលីងទៅហើយ ខ្ញុំក៏ពិចារណាមិនឃើញថា របស់ឈ្មោះនេះ គឺអាត្មាអញនៅមានដូច្នេះដែរ តែថា ព្រួញគឺសេចក្តីសង្ស័យងឿងឆ្ងល់ នៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកមានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ កាលបើសេចក្តីប្រកាន់របស់ភិក្ខុនោះថា អាត្មាអញមានដូច្នេះ អស់រលីងទៅហើយ

២០៧

សង្គីតិសុត្តេ សង្គីតិយច្ឆក្កំ

អយមហមស្មីតិ ច[១] អសមនុបស្សតោ អថ ច បនស្ស វិចិកិច្ឆាកថង្កថាសល្លំ ចិត្តំ បរិយាទាយ បស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ និស្សរណំ ហេតំ អាវុសោ វិចិកិច្ឆាកថង្កថាសល្លស្ស យទិទំ អស្មីតិ មានសមុគ្ឃាតោ ។

[១៩២] ឆ អនុត្តរិយានិ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ សិក្ខានុត្តរិយំ ចារិចរិយានុត្តរិយំ អនុស្សតានុត្តរិយំ ។

[១៩៣] ឆ អនុស្សតិដ្ឋានានិ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ។

[១៩៤] ឆ សតតវិហារា ឥធាវុសោ ភិក្ខុ

១ ឱ. ម. ចកាពោ ន ទិស្សតិ ។

ភិក្ខុនោះក៏ពិចារណាមិនឃើញថា របស់ឈ្មោះនេះ គឺអាត្មាអញនៅមានដូច្នេះដែរ តែថាព្រួញគឺសេចក្ដីសង្ស័យងឿងឆ្ងល់ នៅតែគ្របសង្កត់ចិត្តភិក្ខុនោះ ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះការគាស់រំលើងសេចក្ដីប្រកាន់ថា អាត្មានៅមានដូច្នេះនុ៎ះចេញបាន ជាគ្រឿងរលាស់ចេញនូវព្រួញគឺសេចក្ដីសង្ស័យងឿងឆ្ងល់បាន ១ ។

[១៩២] អនុត្តរិយៈ (ធម្មជាតប្រសើរបំផុត) មាន ៦ យ៉ាង គឺ ទស្សនានុត្តរិយៈ (ប្រសើរបំផុតដោយការឃើញ) ១ សវនានុត្តរិយៈ (ប្រសើរបំផុតដោយការស្ដាប់) ១ លាភានុត្តរិយៈ (ប្រសើរបំផុតដោយការបាន) ១ សិក្ខានុត្តរិយៈ (ប្រសើរបំផុតដោយការសិក្សា) ១ បារិចរិយានុត្តរិយៈ (ប្រសើរបំផុតខាងការបម្រើ) ១ អនុស្សតានុត្តរិយៈ (ប្រសើរបំផុតដោយការរលឹករឿយ ៗ) ១ ។

[១៩៣] ទីតាំងនៃអនុស្សតិមាន ៦ យ៉ាង គឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ។

[១៩៤] ធម៌ជាគ្រឿងនៅដ៏ទៀងទាត់ (របស់ព្រះខីណាស្រព) មាន ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។

[១៩៥] ឆឡាភិជាតិយោ ឥធាវុសោ ឯកច្ចោ កណ្ហាភិជាតិកោ សមានោ កណ្ហំ ធម្មំ អភិជា-យតិ ។ ឥធាវុសោ ឯកច្ចោ កណ្ហាភិជាតិកោ សមានោ សុក្កំ ធម្មំ អភិជាយតិ ។ ឥធាវុសោ ឯកច្ចោ កណ្ហាភិជាតិកោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ ឥធាវុសោ ឯកច្ចោ សុក្កាភិជាតិកោ សមានោ សុក្កំ ធម្មំ អភិជា-យតិ ។ ឥធាវុសោ ឯកច្ចោ សុក្កាភិជាតិកោ សមានោ កណ្ហំ ធម្មំ អភិជាយតិ ។ ឥធាវុសោ

ឃើញរូប ដោយចក្ខុក៏មិនត្រេកអរ មិនអន់ចិត្ត គឺជាបុគ្គលនៅព្រងើយ តែមានសតិនិងសម្បជញ្ញៈ ១ ។ ឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ ទទួលរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនត្រេកអរ មិនអន់ចិត្ត គឺជាបុគ្គលនៅព្រងើយ ។ តែមានសតិនិង សម្បជញ្ញៈ ១ ។

[១៩៤] អភិជាតិ (កំណើត) មាន ៦ យ៉ាង ម្នាលអាវុសោទាំង-ឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្មៅ (ថោកទាប) ហើយប្រព្រឹត្តធម៌ខ្មៅ (ទុច្ចរិត) ទៀត ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្មៅ ហើយប្រព្រឹត្តធម៌ស (សុចរិត) ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្មៅ ហើយប្រព្រឹត្តធម៌មិនខ្មៅមិនសគឺព្រះនិព្វាន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូល-ស (ត្រកូលខ្ពស់) ហើយប្រព្រឹត្តធម៌ស ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូល-ស ហើយប្រព្រឹត្តធម៌ខ្មៅ ១ ។ ម្នាលអាវុសោទាំងឡាយ

២០៩

សង្គីតិសុត្តេ សង្គីតិយសត្តកំ

ឯកច្ចោ សុក្កាភិជាតិកោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។

[១៩៦] ឆ និព្វេធភាគិយសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មា-សម្ពុទ្ធេន ឆ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

សង្គីតិយច្ឆក្កំ និដ្ឋិតំ[១] ។

[១៩៧] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សត្ត ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ

១ ឱ. សង្គីតិយច្ឆក្កំ និដ្ឋិតន្តិ ន ទិស្សតិ ។

បុគ្គលពួកខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូល-ស ហើយប្រព្រឹត្តធម៌មិនខ្មៅមិនស គឺព្រះនិព្វាន ១ ។

[១៩៦] និព្វេធភាគិយសញ្ញា (សេចក្តីសំគាល់នូវធម៌ដែលទៅជិតព្រះនិព្វាន) មាន ៦ យ៉ាង គឺ សេចក្តីសំគាល់ថាមិនទៀង ១ សេចក្តីសំគាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសំគាល់ក្នុងរបស់ជាទុក្ខថាមិនមែនជារបស់ខ្លួន ១ សេចក្តីសំគាល់ក្នុងរបស់គួរលះបង់ ១ សេចក្តីសំគាល់ក្នុងរបស់គួរនឿយណាយ ១ សេចក្តីសំគាល់ក្នុងធម៌ជាគ្រឿងរំលត់ទុក្ខ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងធម៌ពួកប្រាំមួយ ៗ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកល្អហើយ យើងទាំងអស់គ្នាត្រូវសង្គាយនាធម៌ពួកប្រាំមួយ ៗ នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌ប្រាំមួយ ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[១៩៧] ម្នាលអាវុសោទាំងឡាយ មានធម៌ពួកប្រាំពីរ ៗ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សំដែងទុកល្អហើយ យើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួក

។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ សត្ត ។ សត្ត អរិយធនានិ[១] សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ ។

[១៩៨] សត្ត ពោជ្ឈង្គា[២] សតិសម្ពោជ្ឈង្គោ[៣] ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។

[១៩៩] សត្ត សមាធិបរិក្ខារា សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ ។

[២០០] សត្ត អសទ្ធម្មា ឥធាវុសោ ភិក្ខុ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ ហោតិ ។

---

១ ឱ. សត្ត ធនានិ ។ ២ ឱ. សត្ត សម្ពោជ្ឈង្គា ។ ៣ ម. សតិសម្ពោជ្ឈង្គោ ។

ប្រាំពីរ ៗ នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ពួក ៧ ដូចម្តេចខ្លះ ។ អរិយទ្រព្យមាន ៧ យ៉ាង គឺ ទ្រព្យគឺសទ្ធា ១ ទ្រព្យគឺសីល ១ ទ្រព្យគឺហិរិ ១ ទ្រព្យគឺឱត្តប្បៈ ១ ទ្រព្យគឺសុតៈ ១ ទ្រព្យគឺចាគៈ ១ ទ្រព្យគឺបញ្ញា ១ ។

[១៩៨] ពោជ្ឈង្គមាន ៧ យ៉ាង គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

[១៩៩] សមាធិបរិក្ខារ (ធម៌ជាបរិវារសមាធិ) មាន ៧ យ៉ាង គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ ។

[២០០] អសទ្ធម្ម (ធម៌របស់អសប្បុរស) មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនជឿ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ មានការចេះដឹងតិច ១ ខ្ជិលច្រអូស ១ ប្រហែស ១ អប្បឥតប្រាជ្ញា ១ ។

សង្គីតិសុត្តេ សង្គីតិយសត្តកំ

[២០១] សត្ត សទ្ធម្មា ឥធាវុសោ ភិក្ខុ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ ឧបដ្ឋិតស្សតិ ហោតិ បញ្ញវា ហោតិ ។

[២០២] សត្ត សប្បុរិសធម្មា ឥធាវុសោ ភិក្ខុ ធម្មញ្ញូ ច ហោតិ អត្ថញ្ញូ ច អត្តញ្ញូ ច មត្តញ្ញូ ច កាលញ្ញូ ច បរិសញ្ញូ ច បុគ្គលញ្ញូ ច ។

[២០៣] សត្ត និទ្ទសវត្ថូនិ[១] ឥធាវុសោ ភិក្ខុ សិក្ខាសមាទានេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច សិក្ខាសមាទានេ អវិគតប្បេមោ ធម្មនិសន្តិយា តិព្វ-ច្ឆន្ទោ ហោតិ អាយតិញ្ច ធម្មនិសន្តិយា អវិគតប្បេមោ

១ ឱ. និទ្ទេសវត្ថូនិ ។

សង្គីតិសូត្រ ពួកធម៌ប្រាំពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[២០១] *សទ្ធម្ម* (*ធម៌របស់សប្បុរស*) មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកជឿ ១ ខ្មាសបាប ១ ខ្លាចបាប ១ មានការចេះដឹងច្រើន ១ ផ្តើមសេចក្តីព្យាយាម ១ ប្រុងស្មារតី ១ មានប្រាជ្ញា ១ ។

[២០២] *សប្បុរសធម៌* មាន ៧ យ៉ាង (*ទៀត*) ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្គាល់នូវហេតុ ១ ជាអ្នកស្គាល់នូវផល (*របស់ហេតុ*) ១ ជាអ្នកស្គាល់ខ្លួន ១ ជាអ្នកស្គាល់ប្រមាណ (*ក្នុងភោជន*) ១ ជាអ្នកស្គាល់កាលគួរ ១ ជាអ្នកស្គាល់បរិស័ទ ១ ជាអ្នកស្គាល់បុគ្គល (*គួរគប់និងមិនគួរគប់*) ១ ។

[២០៣] *និទ្ទសវត្ថុ*[១] មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានបំណងដ៏ក្លៀវក្លា ក្នុងការសមាទានសិក្ខា មិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការសមាទានសិក្ខាតទៅ ១ មានបំណងដ៏ក្លៀវក្លា ក្នុងការពិចារណាធម៌ មិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការ

១ ប្រែថា ហេតុនៃភិក្ខុមានអាយុ ១០ ឆ្នាំ ។ តែពាក្យនេះ លោកសំដៅយកព្រះខីណាស្រព ព្រោះលោកសូម្បីបរិនិព្វានពីអាយុ ១០ ឆ្នាំ ក៏លោកលែងមានអាយុ ១ ឆ្នាំតទៅខាងមុខទៀត ។ មិនត្រឹមតែ ១០ ឆ្នាំ ប៉ុណ្ណោះឡើយ សូម្បី ៩ ឆ្នាំ (រហូតដល់) ១ ថ្ងៃ ឬ ១ យាម ក៏លែងមាន ព្រោះលោកលែងមានបដិសន្ធិទៀត (អដ្ឋកថា) ។

ឥច្ឆាវិនយេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ឥច្ឆាវិនយេ អវិគតប្បេមោ បដិសល្លានេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច បដិសល្លានេ អវិគតប្បេមោ វីរិយារម្ភេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច វីរិយារម្ភេ អវិគតប្បេមោ សតិនេបក្កេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច សតិនេបក្កេ អវិគតប្បេមោ ទិដ្ឋិប្បដិវេធេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ទិដ្ឋិប្បដិវេធេ អវិគតប្បេមោ ។

[២០៤] សត្ត សញ្ញា អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។

[២០៥] សត្ត ពលានិ សទ្ធាពលំ វីរិយពលំ ហិរិពលំ ឱត្តប្បពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។

ពិចារណាធម៌តទៅ ១ មានបំណងដ៏ក្លៀវក្លា ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា មិនប្រាសចាកសេចក្ដីស្រឡាញ់ ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហាតទៅ ១ មានបំណងដ៏ក្លៀវក្លា ក្នុងការស្ងប់ស្ងាត់ មិនប្រាសចាក សេចក្ដីស្រឡាញ់ក្នុងការស្ងប់ស្ងាត់តទៅ ១ មានបំណងដ៏ក្លៀវក្លា ក្នុងការ ប្រារព្ធព្យាយាម មិនប្រាសចាកសេចក្ដីស្រឡាញ់ ក្នុងការប្រារព្ធព្យា-យាមតទៅ ១ មានបំណងដ៏ក្លៀវក្លា ក្នុងការរលឹកនិងការៈនៃខ្លួនមានប្រាជ្ញា ចាស់ មិនប្រាសចាកសេចក្ដីស្រឡាញ់ ក្នុងការរលឹកនិងការៈនៃខ្លួនមាន ប្រាជ្ញាចាស់តទៅ ១ មានបំណងក្នុងការត្រាស់ដោយទិដ្ឋិ គឺឃើញនូវ មគ្គ មិនប្រាសចាកសេចក្ដីស្រឡាញ់ ក្នុងការត្រាស់ដឹងដោយទិដ្ឋិតទៅ ១ ។

[២០៤] សញ្ញាមាន ៧ យ៉ាង គឺ អនិច្ចសញ្ញា ១ អនត្ត-សញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគ-សញ្ញា ១ និរោធសញ្ញា ១ ។

[២០៥] កម្លាំងមាន ៧ យ៉ាង គឺ កម្លាំងសទ្ធា ១ កម្លាំងព្យា-យាម ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងសតិ ១ កម្លាំង សមាធិ ១ កម្លាំងបញ្ញា ១ ។

## សង្គីតិសុត្តេ សង្គីតិយសត្តកំ

[២០៦] សត្ត វិញ្ញាណដ្ឋិតិយោ សន្តាវុសោ សត្តា នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា នានត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា អយំ ទុតិយា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា ឯកត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហា អយំ ចតុត្ថា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនូបគា អយំ បញ្ចមី វិញ្ញាណដ្ឋិតិ ។

សង្គីតិសូត្រ ពួកធម៌ប្រាំពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[២០៦] វិញ្ញាណដ្ឋិតិ (ទីតាំងនៃវិញ្ញាណ) មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស ទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិ ទី ១ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាក្នុងពួកព្រហ្មដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជា វិញ្ញាណដ្ឋិតិ ទី ២ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជា វិញ្ញាណដ្ឋិតិ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជា វិញ្ញាណដ្ឋិតិ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វ ចូលកាន់អាកាសានញ្ចាយតនជ្ឈានដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសទៅនៃពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្ត នូវពួកនា-នត្តសញ្ញា ដោយប្រការទាំងពួង នេះជា វិញ្ញាណដ្ឋិតិ ទី ៥ ។

សព្ពសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា

សព្ពសោ អាកាសានញ្ចា- យតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយ- តនូបគា អយំ ឆដ្ឋី[១] វិញ្ញាណដ្ឋិតិ ។ សព្ពសោ សត្តា សព្ពសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា អយំ សត្តមី វិញ្ញា- ណដ្ឋិតិ ។

[២០៧] សត្ត បុគ្គលា ទក្ខិណេយ្យា ឧភតោ- ភាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី ។

[២០៨] សត្ត អនុសយា កាមរាគានុសយោ ប- ដិឃានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ មា- នានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ។

[២០៩] សត្ត សញ្ញោជនានិ[២] កាមសញ្ញោជនំ[៣] បដិឃសញ្ញោជនំ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ មានសញ្ញោជនំ ភវរាគសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ។

---

១ ម. ឆដ្ឋា ។ ២ ឱ. សត្ត សំយោជនានិ ។ ៣ ឱ. ម. អនុនយសំយោជនំ ។

ម្នាលអាវុសោទាំងឡាយ មានពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនៈ- ដ្ឋាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនដ្ឋាន ដោយគិតថា វិញ្ញាណមិនមានទីបំផុត នេះជាវិញ្ញាណដ្ឋិតិទី ៦ ។ ម្នាល អាវុសោទាំងឡាយ មានពួកសត្វ កន្លងបង់នូវវិញ្ញាណញ្ចាយតនដ្ឋាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនដ្ឋាន ដោយ គិតថា វត្ថុតិចតួចមិនមាន នេះជាវិញ្ញាណដ្ឋិតិ ទី ៧ ។

[២០៧] បុគ្គលគួរទទួលនូវទក្ខិណាទាន មាន ៧ ពួក គឺ លោក ជាឧភតោភាគវិមុត្ត ១ បញ្ញាវិមុត្ត ១ កាយសក្ខី ១ ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្ត ១ ធម្មានុសារី ១ សទ្ធានុសារី[១] ១ ។

[២០៨] អនុសយកិលេស មាន ៧ យ៉ាង គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ មានានុស័យ ១ ភវ- រាគានុស័យ ១ អវិជ្ជានុស័យ ១ ។

[២០៩] សញ្ញោជនៈ[២] មាន ៧ យ៉ាង គឺ កាមសញ្ញោជនៈ ១ បដិ- ឃសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មានសញ្ញោ- ជនៈ ១ ភវរាគៈសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ ។

---

១ ចូលមើលសេចក្តីពន្យល់ក្នុងសម្បសាទនីយសូត្រ ទីឃនិកាយ បាដិកវគ្គ ។ ២ ហៅថា សំយោជនៈក៏បាន ។

[២១០] សត្ត អធិករណសមថា ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ សម្មុខាវិនយោ ទាតព្វោ សតិវិនយោ ទាតព្វោ អមូឡ្ហវិនយោ ទាតព្វោ បដិញ្ញាយ ការេតព្វំ យេភុយ្យសិកា តស្ស ចាបិយសិកា តិណវត្ថារកោ ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សត្ត ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

សង្គីតិយសត្តកំ និដ្ឋិតំ[១] ។

[២១១] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អដ្ឋ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

---

១ ឱ. ទុតិយកភាណវារំ និដ្ឋិតំ ។ ម. សង្គីតិយសត្តកំ និដ្ឋិតន្តិ ន ទិស្សតិ ។

សង្គីតិសូត្រ ពួកធម៌ប្រាំបី ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[២១០] អធិករណសមថៈ មាន ៧ យ៉ាង គឺ ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ដែលកើតឡើងហើយ ៗ សង្ឃត្រូវឲ្យសម្មុខាវិន័យ ១ ត្រូវឲ្យសតិវិន័យ ១ ត្រូវឲ្យអមូឡ្ហវិន័យ ១ ត្រូវធ្វើតាមសេចក្តីប្តេជ្ញា ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ[១] ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងជាពួកធម៌ប្រាំពីរ ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដែងទុកដោយប្រពៃហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួក ៧ នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌ប្រាំពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[២១១] ម្នាលអាវុសោទាំងឡាយ មានធម៌ពួកប្រាំបី ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំបីនោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

---

១ ចូរមើលក្នុងសមថក្ខន្ធកៈប៉ែកវិន័យសៀវភៅទី ១០ ។

កតមេ អដ្ឋ ។ អដ្ឋ មិច្ឆត្តា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ ។

[២១២] អដ្ឋ សម្មត្តា សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

[២១៣] អដ្ឋ បុគ្គលា ទក្ខិណេយ្យា សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តសច្ឆិកិរិយាយ[១] បដិបន្នោ ។

[២១៤] អដ្ឋ កុសីតវត្ថូនិ ឥធាវុសោ ភិក្ខុនា កម្មំ កាតព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ កាតព្វំ ភវិស្សតិ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ ។

---

១ ឱ. អរហត្តាយ ។

ពួកធម៌ប្រាំបី តើដូចម្តេច ។ មិច្ឆត្តៈ (ភាវៈដែលខុស) មាន ៨ យ៉ាង គឺ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បៈ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១ មិច្ឆាអាជីវៈ ១ មិច្ឆាវាយាមៈ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។

[២១២] សម្មត្តៈ (ភាវៈដែលត្រូវ) មាន ៨ យ៉ាង គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

[២១៣] បុគ្គលទទួលនូវទក្ខិណាទាន មាន ៨ ពួក គឺ លោកអ្នកដល់នូវសោតៈហើយ ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ ជាសកទាគាមី ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ ជាអនាគាមី ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ ជាអរហន្ត ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអរហន្ត ១ ។

[២១៤] កុសីតវត្ថុ (ហេតុរបស់បុគ្គលខ្ជិល) មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវធ្វើការងារ ភិក្ខុនោះមានគំនិតយ៉ាងនេះថា ការងារហ្នឹងឯង អាត្មាអញនឹងត្រូវធ្វើ តែថាបើអាត្មាអញធ្វើការងារទៅហើយ កាយនឹងលំបាក ណ្ហើយចុះ អាត្មាអញដេកសិន ។

២១៧



សោ និបជ្ជតិ ន វិរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ បឋមំ កុសីតវត្ថុ[១] ។ បុន ចបរំ អាវុសោ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលន្តោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វិរិយំ អារភតិ... ឥទំ ទុតិយំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ ខោ បន មេ គច្ឆន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វិរិយំ អារភតិ... ឥទំ តតិយំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ មគ្គំ អគមាសឹ មគ្គំ ខោ បន

១ ឱ. កុសីតវត្ថុំ ។ ម. កុសិតវត្ថុ ។

ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុ ទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានធ្វើការងារហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានធ្វើការងាររួចហើយ តែថាកាលដែលអាត្មាអញកំពុងធ្វើការងារ កាយក៏លំបាកទៅហើយ ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកមិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុ ទី ២ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុត្រូវដើរផ្លូវ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវដើរផ្លូវ តែថាបើអាត្មាអញដើរផ្លូវ កាយនឹងលំបាក ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរផ្លូវរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរផ្លូវរួចហើយ

មេ គច្ឆន្តស្ស កាយោ កិលន្តោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ... ឥទំ ចតុត្ថំ កុ-សីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ន លភតិ លូខស្ស វា ប-ណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌា-យ ចរន្តោ នាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស មេ កា-យោ កិលន្តោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ... ឥទំ បញ្ចមំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ

តែថាកាលដែលអាត្មាអញកំពុងដើរផ្លូវ កាយក៏លំបាកទៅហើយ ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត តែមិនបានភោជនសៅហ្មង ឬថ្លៃថ្លាឲ្យបរិបូណ៌ដរាបដល់ឆ្អែតទេ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដែលដើរទៅកាន់ស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លាឲ្យបរិបូណ៌ដរាបដល់ឆ្អែតសោះ កាយរបស់អាត្មាអញនេះ ក៏លំបាកទៅហើយ ធ្វើការងារមិនកើត ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាតបានភោជនសៅហ្មង ឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដែលដើរទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត

២១៩

## សង្គីតិសុត្តេ សង្គីតិយអដ្ឋកំ

អលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស មេ កាយោ គរុកោ អកម្មញ្ញោ មាសាចិតំ មញ្ញេ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ... ឥទំ ឆដ្ឋំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ មេ អយំ[1] អប្បមត្តកោ អាពាធោ អត្ថិ កប្បោ និបជ្ជិតុំ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ... ឥទំ សត្តមំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា តស្ស ឯវំ ហោតិ អយំ ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា តស្ស មេ កាយោ ទុព្វលោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ អដ្ឋមំ កុសីតវត្ថុ ។

---

១ ឱ. អយន្តិ ន ទិស្សតិ ។

បានភោជនសៅហ្មង ឬថ្ងៃថ្វាបរិបូណ៌ដរាបដល់ឆ្អែតដែរហើយ តែកាយរបស់អាត្មាអញក៏ធ្ងន់ ធ្វើការងារមិនកើត ទំនងដូចជាសណ្ដែកដែលត្រូវទឹក ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុ ទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកើតអាពាធតិចតួច ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានកើតអាពាធតិចតួចនេះហើយ មានទំនងនឹងដេកបាន បើដូច្នោះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុ ទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសះស្បើយអំពីជំងឺហើយ ទើបនឹងសះស្បើយអំពីជំងឺមិនយូរប៉ុន្មាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញសះស្បើយអំពីជំងឺហើយ តែសះស្បើយអំពីជំងឺមិនយូរប៉ុន្មាន កាយរបស់អាត្មាអញនៅមិនទាន់មានកម្លាំង ធ្វើការងារមិនកើត ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុ ទី ៨ ។

[២១៤] អដ្ឋ អារព្ភវត្ថូនិ ឥធាវុសោ ភិក្ខុនា កម្មំ កាតព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ កាតព្វំ ភវិស្សតិ កម្មំ ខោ បន[១] ករោន្តេន ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ បឋមំ អារព្ភវត្ថុ[២] ។ បុន ចបរំ អាវុសោ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បនាហំ ករោន្តោ នាសក្ខឹ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ សោ វីរិយំ អារភតិ...

---

១ ឱ. ម. ខោ បន មេ ។ ២ ឱ. អារព្ភវត្ថុំ ។

[២១៥] *អារព្ភវត្ថុ* (*ហេតុរបស់បុគ្គលប្រុងប្រៀបព្យាយាម*) មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវធ្វើការងារ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវធ្វើការងារ តែថាបើអាត្មាអញធ្វើការងារទៅ នឹងធ្វើទុកក្នុងចិត្ត នូវសាសនារបស់ព្រះពុទ្ធទាំងឡាយ មិនបានស្រួលឡើយ ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ដើម្បីដល់ នូវគុណវិសេសដែលមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេស ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុ ទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានធ្វើការងាររួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានធ្វើការងាររួចហើយ កាលដែលអាត្មាអញធ្វើការងារ ក៏មិនអាចធ្វើទុកក្នុងចិត្តនូវសាសនារបស់ព្រះពុទ្ធទាំងឡាយបាន ណ្ហើយចុះ គួរអាត្មាអញប្រុងប្រៀបព្យាយាម ។ បេ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម...

២២១

## សង្គីតិសុត្តេ សង្គីតិយអដ្ឋកំ

ឥទំ ទុតិយំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ ខោ បន[១] គច្ឆន្តេន ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ សោ វីរិយំ អារភតិ... ឥទំ តតិយំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ មគ្គំ អគមាសឹ មគ្គំ ខោ បនាហំ គច្ឆន្តោ នាសក្ខឹ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារ-ភាមិ ។ បេ ។ សោ វីរិយំ អារភតិ... ឥទំ ចតុត្ថំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ន លភតិ លូ-ខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ នាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ

១ ឱ. ម. ខោ បន មេ ។

នេះជា អារព្ភវត្ថុ ទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវដើរផ្លូវ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវដើរផ្លូវ កាលបើអាត្មាអញនឹងដើរផ្លូវមិនងាយធ្វើទុកក្នុងចិត្ត នូវសាសនារបស់ព្រះពុទ្ធទាំងឡាយបាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។ បេ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម... នេះជា អារព្ភវត្ថុ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរផ្លូវរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរផ្លូវរួចហើយ កាលដែលអាត្មាអញកំពុងដើរផ្លូវ មិនអាចធ្វើទុកក្នុងចិត្ត នូវសាសនារបស់ព្រះពុទ្ធទាំងឡាយ ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។ បេ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម... នេះជា អារព្ភវត្ថុ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត មិនបានភោជនសៅហ្មងឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញដើរទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត មិនបានភោជនសៅហ្មង ឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត

តស្ស មេ កាយោ លហុកោ កម្មញ្ញោ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ សោ វីរិយំ អារភតិ... ឥទំ បញ្ចមំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ អលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស មេ កាយោ ពលវា កម្មញ្ញោ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ សោ វីរិយំ អារភតិ... ឥទំ ឆដ្ឋំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ មេ អយំ អប្ប-មត្តកោ អាពាធោ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អាពាធោ បវឌ្ឍេយ្យ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ សោ វីរិយំ អារភតិ... ឥទំ សត្តមំ អា-រព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា តស្ស ឯវំ ហោតិ

កាយរបស់អាត្មាអញក៏ស្រាល គួរធ្វើការងារបាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។ បេ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម... នេះជាអារព្ភវត្ថុ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនសៅហ្មង ឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរទៅកាន់ស្រុកឬនិគមដើម្បីបិណ្ឌបាត បានភោជនសៅហ្មងឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត កាយរបស់អាត្មាអញ មានកម្លាំងល្មមធ្វើការងារបាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។ បេ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម... នេះជាអារព្ភវត្ថុ ទី ៦ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុកើតអាពាធតិចតួច ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកើតអាពាធតិចតួចនេះហើយ អាពាធរបស់អាត្មាអញគង់មានទំនងចម្រើនឡើងមិនខាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។ បេ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម... នេះជាអារព្ភវត្ថុ ទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានសះស្បើយអំពីជំងឺហើយ លុះស្បើយអំពីជំងឺ មិនទាន់យូរប៉ុន្មាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា

អហំ ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា ហនំ ខោ បនេតំ វិជ្ជតិ យំ មេ អាពាធោ បច្ចុទាវត្តេយ្យ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិ-គតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយា-យាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិ-យាយ ឥទំ អដ្ឋមំ អារព្ភវត្ថុ ។

[២១៦] អដ្ឋ ទានវត្ថូនិ អាសជ្ជ ទានំ ទេតិ ភយា ទានំ ទេតិ អទាសិ មេតិ ទានំ ទេតិ ទស្សតិ មេតិ ទានំ ទេតិ សាធុ[១] ទានន្តិ ទានំ ទេតិ អហំ បចាមិ ឥមេ ន បចន្តិ នារហាមិ បចន្តោ អបចន្តានំ ទានំ ន ទាតុន្តិ ទានំ ទេតិ ឥទំ មេ ទានំ ទទតោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតីតិ ទានំ ទេតិ ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ ។

---

១ សាហុតិបិ ។ អដ្ឋកថាយម្បិ ឯវមេវ ។

អាត្មាអញបានសះស្បើយអំពីជំងឺហើយ តែសះស្បើយអំពីជំងឺមិនទាន់យូរប៉ុន្មាន អាពាធរបស់អាត្មាអញគង់មានទំនងរើឡើងវិញ ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលមិនទាន់ដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏ប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលមិនទាន់ដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ៨ ។

[២១៦] ទានវត្ថុ មាន ៨ យ៉ាង គឺ បុគ្គលឲ្យទានព្រោះបុគ្គលស្រាប់តែមកដល់ ១ ឲ្យទានព្រោះខ្លាច (គេតិះដៀល ឬខ្លាចអបាយភូមិ) ១ ឲ្យទានដោយគិតថា គេធ្លាប់ឲ្យដល់អាត្មាអញហើយ ១ ឲ្យទានដោយគិតថា គេនឹងឲ្យដល់អាត្មាអញវិញ ១ ឲ្យទានដោយគិតថា ទានជាការឲ្យសម្រេចប្រយោជន៍ ១ ឲ្យទានដោយគិតថា អាត្មាអញបានចម្អិន ជនទាំងនេះមិនបានចម្អិន កាលបើអាត្មាអញបានចម្អិន មិនគួរនឹងមិនឲ្យទានដល់ពួកជនដែលមិនបានចម្អិនទេ ១ ឲ្យទានដោយគិតថា កាលបើអាត្មាអញឲ្យទាននេះទៅហើយ កិត្តិសព្ទដ៏ល្អរមែងខ្ចរខ្ចាយទៅ ១ ឲ្យទានដើម្បីជាគ្រឿងប្រដាប់ចិត្ត ទាំងជាបរិវាររបស់ចិត្ត ១ ។

[២១៧] អដ្ឋ ទានុបបត្តិយោ[(១)] ឥធាវុសោ ឯ-កច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវស-ថប្បទីបេយ្យំ សោ យំ ទេតិ តំ បច្ចាសីសតិ សោ បស្សតិ ខត្តិយមហាសាលំ វា ព្រាហ្មណមហាសាលំ វា គហបតិមហាសាលំ វា បញ្ចហិ កាមគុណេហិ សមប្បិតំ សមង្គីភូតំ បរិចារយមានំ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា ខត្តិយ-មហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហ-បតិមហាសាលានំ វា សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ ។ តស្ស តំ ចិត្តំ ហីនេ វិមុត្តំ ឧត្តរិអភាវិតំ តត្រុបបត្តិ-យា[(២)] សំវត្តតិ ។ តញ្ច ខោ សីលវតោ វទាមិ នោ

១ ឱ. ទានុប្បត្តិយោ ។ ២ ឱ. ឧត្តរឹ អភាវិតំ តត្រុប្បត្តិយា ។

[២១៧] ទានុបបត្តិ (ការកើតឡើង ព្រោះទាន) មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងវត្ថុសម្រាប់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យវត្ថុណា ប្រាថ្នាយកវត្ថុនោះវិញ (ព្រោះ) បុគ្គលនោះឃើញខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិមហាសាលក្តី ដែលឆ្អែតស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណ ៥ បុគ្គលនោះ មានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះមានរាងកាយបែកធ្លាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ សូមឲ្យទៅកើតរួមជាមួយ នឹងខត្តិយមហាសាល ឬព្រាហ្មណមហាសាល ឬក៏គហបតិមហាសាល ។ បុគ្គលនោះក៏តម្កល់ចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ។ ចិត្តរបស់បុគ្គលនោះ ផុតស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើង[១]តទៅ តែងប្រព្រឹត្តទៅ ដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមានសីល មិនពោលចំពោះ

---

១ សំដៅយកចិត្តដែលមិនបានចម្រើន ដើម្បីប្រយោជន៍ដល់មគ្គនិងផល ដែលលើសលុបជាងសម្បត្តិខត្តិយមហាសាលជាដើមនោះ (អដ្ឋកថា) ។

ទុស្សីលស្ស ។ ឥធាវុសោ សីលវតោ ចេតោបណិធិ វិសុទ្ធត្តា ។ បុន ចបរំ អាវុសោ ឥធេកច្ចោ ទានំ ទេ-តិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ សោ យំ ទេតិ តំ បច្ចាសីសតិ តស្ស សុតំ ហោតិ ចាតុម្ម-ហារាជិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា-តិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេ-ទា បរំ មរណា ចាតុម្មហារាជិកានំ ទេវានំ សហាព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អ-ធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេ វិមុត្តំ ឧត្តរិអភាវិតំ តត្រុបបត្តិយា សំវត្តតិ ។ តញ្ច ខោ សីល-វតោ វទាមិ នោ ទុស្សីលស្ស ។ ឥធាវុសោ សីល-វតោ ចេតោបណិធិ វិសុទ្ធត្តា ។ បុន ចបរំ អាវុសោ

បុគ្គលទ្រុស្តសីលឡើយ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីតាំងចិត្ត របស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្តីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលពួក ខ្លះ ក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿង ក្រអូប គ្រឿងលាប ទីដេក ទីនៅ និងប្រដាប់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ប្រាថ្នាយកវត្ថុនោះវិញ បុគ្គល នោះបានឮថា ពួកទេវតាក្នុងឋានចាតុម្មហារាជិកៈ មានអាយុវែង មាន សម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះមានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះមានរាងកាយបែកធ្លាយ ខាងមុខបន្ទាប់អំពីសេចក្តី ស្លាប់ទៅ សូមឲ្យទៅកើតរួមជាមួយ នឹងពួកទេវតាក្នុងឋានចាតុម្មហា-រាជិកៈ ។ បុគ្គលនោះក៏តាំងចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំ-ចិត្តនោះទុក ចិត្តរបស់បុគ្គលនោះ ផុតស្រឡះចាកកាមគុណ ដ៏ថោក ទាប តែមិនចម្រើនឡើងតទៅ តែងប្រព្រឹត្តទៅ ដើម្បីកើតក្នុងទីដែល ខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមាន សីល មិនពោលចំពោះបុគ្គលទ្រុស្តសីលឡើយ ។ ម្នាលអាវុសោ ទាំងឡាយ សេចក្តីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្តីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ១ ។ ម្នាលអាវុសោ

ឥធេកច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្ម-ណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ សោ យំ ទេតិ តំ បច្ចា-សីសតិ តស្ស សុតំ ហោតិ តាវត្តឹសា ទេវា ។ បេ ។ យាមា ទេវា ។ បេ ។ តុសិតា ទេវា ។ បេ ។ និម្មានរតី ទេវា ។ បេ ។ បរនិម្មិតវសវត្តី ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេ វិមុត្តំ ឧត្តរិអភាវិតំ តត្រុបបត្តិយា សំវត្តតិ ។ តញ្ច ខោ សីលវតោ វទាមិ នោ ទុស្សីលស្ស ។

ទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និង ប្រដាប់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យរបស់ណា ប្រាថ្នាយករបស់នោះវិញ បុគ្គលនោះបានឮថា ពួកទេវតាក្នុងឋាន តាវត្តិង្ស ។ បេ ។ ពួកទេវតាក្នុងឋានយាមៈ ។ បេ ។ ពួកទេវតាក្នុង ឋានតុសតិ ។ បេ ។ ពួកទេវតាក្នុងឋាននិម្មានរតី ។ បេ ។ ពួកទេវតា ក្នុងឋានបរនិម្មិតវសវត្តី មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខ ច្រើន ។ បុគ្គលនោះមានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះមានរាង កាយបែកធ្លាយខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ទៅ សូមឲ្យទៅកើតរួមជា មួយនឹងពួកទេវតាក្នុងឋានបរនិម្មិតវសវត្តី ។ បុគ្គលនោះ ក៏តាំងចិត្តនោះ ទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ចិត្តរបស់បុគ្គលនោះរួច ស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើងតទៅ តែងប្រព្រឹត្ត ទៅ ដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមានសីល មិនពោលចំពោះបុគ្គលទ្រុស្តសីលឡើយ ។

២២៧

សង្គីតិសុត្តេ សង្គីតិយអដ្ឋកំ

ឥជ្ឈតាវុសោ សីលវតោ ចេតោបណិធិ វិសុទ្ធត្តា ។ បុនចបរំ អាវុសោ ឥធេកច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថបទីបេយ្យំ សោ យំ ទេតិ តំ បច្ចាសីសតិ តស្ស សុតំ ហោតិ ព្រហ្មកាយិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរំ មរណា ព្រហ្មកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ។ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេ វិមុត្តំ ឧត្តរិអភាវិតំ តត្រុបបត្តិយា សំវត្តតិ ។ តញ្ច ខោ សីលវតោ វទាមិ នោ ទុស្សីលស្ស វីតរាគស្ស នោ សរាគស្ស ។ ឥជ្ឈតាវុសោ សីលវតោ ចេតោបណិធិ វីតរាគត្តា ។

សង្គីតិសូត្រ ពួកធម៌ប្រាំបី ៗ ដែលរាប់ចូលក្នុងការសង្គាយនា

ម្នាលអាវុសោទាំងឡាយ សេចក្ដីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្ដីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងប្រដាប់ប្រទីប ដល់សមណៈឬព្រាហ្មណ៍ បុគ្គលនោះឲ្យរបស់ណា ប្រាថ្នាយករបស់នោះវិញ បុគ្គលនោះបានឮថា ពួកទេវតាក្នុងព្រហ្មលោក មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន ។ បុគ្គលនោះមានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះមានរាងកាយបែកធ្លាយខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ សូមឲ្យទៅកើតរួមជាមួយ នឹងពួកទេវតាក្នុងព្រហ្មលោក ។ បុគ្គលនោះ ក៏តាំងចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ចិត្តរបស់បុគ្គលនោះ រួចស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើងទៅ តែងប្រព្រឹត្តទៅ ដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមានសីល មិនពោលចំពោះបុគ្គលទ្រុស្តសីលឡើយ ពោលចំពោះតែបុគ្គលប្រាសចាករាគៈ មិនពោលចំពោះបុគ្គលប្រកបដោយរាគៈឡើយ ។ ម្នាលអាវុសោទាំងឡាយ សេចក្ដីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្ដីតាំងចិត្តនោះជារបស់ប្រាសចាករាគៈ ១ ។

[២១៨] អដ្ឋ លោកធម្មា លាភោ ច អលាភោ ច យសោ ច អយសោ ច និន្ទា ច បសំសា ច សុខញ្ច ទុក្ខញ្ច ។

[២១៩] អដ្ឋ បរិសា ខត្តិយបរិសា ព្រាហ្មណបរិសា គហបតិបរិសា សមណបរិសា ចាតុម្មហារាជិកបរិសា តាវត្តឹសបរិសា និម្មានរតិបរិសា ព្រហ្មបរិសា ។

[២២០] អដ្ឋ អភិភាយតនានិ អជ្ឈត្តំរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បឋមំ អភិភាយតនំ ។ អជ្ឈត្តំរូបសញ្ញី ឯកោ ព-ហិទ្ធារូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ

[២១៨] លោកធម៌ មាន ៨ យ៉ាង គឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ សរសើរ ១ សុខ ១ ទុក្ខ ១ ។

[២១៩] បរិស័ទ មាន ៨ ពួក គឺ ខត្តិយបរិស័ទ ១ ព្រាហ្មណ-បរិស័ទ ១ គហបតិបរិស័ទ ១ សមណបរិស័ទ ១ ចាតុម្មហារាជិក-បរិស័ទ ១ តាវត្តឹសបរិស័ទ ១ និម្មានរតិបរិស័ទ ១ ព្រហ្មបរិស័ទ ១ ។

[២២០] អភិភាយតនៈ មាន ៨ យ៉ាង គឺ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ មានប្រមាណតិច ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជា អភិភាយតនៈ ទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ រកប្រមាណមិនបាន ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជា អភិភាយតនៈ ទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ មានប្រមាណតិច ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ

ឥទំ តតិយំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ សេយ្យថាបិ នាម ឧម្មារបុប្ផំ[១] នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ សេយ្យថាបិ វា បន[២] តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បញ្ចមំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ

---

១ ឱ. ម. ឧម្មាបុប្ផំ ។ ២ ឱ. សេយ្យថា វា បន ។

នេះជា អភិភាយតនៈ ទី ៣ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ រកប្រមាណមិនបាន ហើយមានសេចក្តីសំគាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជា អភិភាយតនៈ ទី ៤ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ដ៏ធ្ងុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ ប្រៀបដូចផ្កាត្រកៀតខៀវ មានសម្បុរខៀវ ដ៏ធ្ងុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ ពុំនោះសោត ប្រៀបដូចសំពត់ខៀវ កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌ខៀវ ដ៏ធ្ងុះចេញនូវពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ដ៏ធ្ងុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះយ៉ាងនេះឯង នេះជា អភិ-ភាយតនៈ ទី ៥ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង

ពហិទ្ធារូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ សេយ្យថាបិ នាម កណ្ណិការបុប្ផំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ សេយ្យថាបិ វា បន[1] តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ សេយ្យថាបិ នាម ពន្ធុជីវកបុប្ផំ លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតកនិភាសំ សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ

១ ឱ. សេយ្យថា វា បន ។

ឃើញនូវពួករូបខាងក្រៅ ដែលជារូបលឿង មានពណ៌លឿង ដ៏ផ្ទុះចេញនូវពណ៌លឿង មានពន្លឺលឿង ប្រៀបដូចផ្កាកណ្ណិការលឿង មានពណ៌លឿង ដ៏ផ្ទុះចេញនូវពណ៌លឿង មានពន្លឺលឿង ពុំនោះសោត ប្រៀបដូចសំពត់លឿង កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌លឿង ដ៏ផ្ទុះចេញនូវពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបលឿង មានសម្បុរលឿង ដ៏ផ្ទុះចេញនូវសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះយ៉ាងនេះឯង នេះជា អភិភាយតនៈ ទី ៦ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ដ៏ផ្ទុះចេញនូវសម្បុរក្រហម មានពន្លឺក្រហម ប្រៀបដូចផ្កាចព្ញារក្រហម មានពណ៌ក្រហម ដ៏ផ្ទុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត ប្រៀបដូចសំពត់ក្រហម កើតក្នុងក្រុង

២៣១

សង្គីតិសុត្តេ  សង្គីតិយអដ្ឋកំ

ឧភតោភាគវិមុត្តោ លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតកនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ សត្តមំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ សេយ្យថាបិ នាម ឱសធិតារកា ឱទាតា ឱទាតវណ្ណា ឱទាតនិទស្សនា ឱទាតនិភាសា សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ ឱទាតំ ឱទាតវណ្ណំ ឱទាតនិទស្សនំ ឱទាតនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយតនំ ។

ពារាណសីនោះ រលើងទាំងពីរខាង មានពណ៌ក្រហម ដ៏ច្ចុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ដ៏ច្ចុះចេញនូវសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះយ៉ាងនេះឯង នេះជាអភិភាយតនៈ ទី ៧ ។ បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូប-ស មានសម្បុរ-ស ដ៏ច្ចុះចេញនូវសម្បុរ-ស មានពន្លឺ-ស ប្រៀបដូចផ្កាយព្រឹក-ស មានពណ៌-ស ដ៏ច្ចុះចេញនូវពណ៌-ស មានពន្លឺ-ស ពុំនោះសោតប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសីនោះ រលើងទាំងពីរខាង មានពណ៌-ស ដ៏ច្ចុះចេញនូវពណ៌-ស មានពន្លឺ-ស យ៉ាងណាមិញ បុគ្គលពួកមួយមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូប-ស មានសម្បុរ-ស ដ៏ច្ចុះចេញនូវសម្បុរ-ស មានពន្លឺ-ស គ្រប-សង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះយ៉ាងនេះឯង នេះជាអភិភាយតនៈទី ៨ ។

[២២១] អដ្ឋ វិមោក្ខា រូបីរូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេវ អធិមោក្ខោ ហោតិ អយំ តតិយោ វិមោក្ខោ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ

[២២១] វិមោក្ខមាន ៨ យ៉ាង គឺ បុគ្គលរមែងឃើញនូវរូបទាំង-ឡាយបាន នេះជា វិមោក្ខ ទី ១ ។ បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ នេះជា វិមោក្ខ ទី ២ ។ សេចក្ដីជឿស៊ប់ចំពោះកសិណដ៏ល្អ នេះជា វិមោក្ខ ទី ៣ ។ ព្រោះការកន្លងនូវពួករូបសញ្ញា វិនាសទៅនៃពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង បុគ្គល រមែងចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ នេះជា វិមោក្ខ ទី ៤ ។ បុគ្គលកន្លងនូវអាកាសានញ្ចាយតនជ្ឈាយ ដោយប្រការទាំងពួង រមែងចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជា វិមោក្ខទី ៥ ។ បុគ្គលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង រមែងចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមានដូច្នេះ នេះជា វិមោក្ខ ទី ៦ ។ បុគ្គលកន្លងនូវអាកិញ្ចញ្ញាយ-តនជ្ឈាន ដោយប្រការទាំងពួង រមែងចូលកាន់នេវសញ្ញានាសញ្ញាយ-តនជ្ឈាន នេះជា វិមោក្ខ ទី ៧ ។ បុគ្គលកន្លងនូវនេវសញ្ញានាសញ្ញាយ-តនជ្ឈាន ដោយប្រការទាំងពួង រមែងចូលកាន់សញ្ញាវេទយិតនិរោធ

២៣៣

សង្គីតិសុត្តេ សង្គីតិយនវកំ

អយំ អដ្ឋមោ វិមោក្ខោ ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អដ្ឋ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

សង្គីតិយអដ្ឋកំ និដ្ឋិតំ[១] ។

[២២២] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន នវ ធម្មា សម្ម-ទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ នវ ។ នវ អាឃាតវត្ថូនិ អនត្ថំ មេ[២] អចរីតិ អាឃាតំ ពន្ធតិ ។

---

១ ឱ. ម. សង្គីតិយអដ្ឋកំ និដ្ឋិតន្តិ ន ទិស្សតិ ។ ២ ឱ. អនត្ថម្មេ ។

នេះជា វិមោក្ខ ទី ៨ ។ ម្នាលអាវុសោទាំងឡាយ ធម៌ពួកប្រាំបីនេះឯង ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សំដែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំបីនោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌ប្រាំបី ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[២២២] ម្នាលអាវុសោទាំងឡាយ ធម៌ពួកប្រាំបួន ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកល្អហើយ រមែងមានប្រាកដ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំបួននោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំង-ឡាយ ។ ធម៌ពួកប្រាំបួន ដូចម្តេចខ្លះ ។ អាឃាតវត្ថុ (ហេតុនៃសេចក្តីគុំគួន) មាន ៩ យ៉ាង គឺ បុគ្គលចងអាឃាត ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ ដល់អញ ។

អនត្ថំ មេ[១] ចរតីតិ អាឃាតំ ពន្ធតិ ។ អនត្ថំ មេ ចរិស្សតីតិ អាឃាតំ ពន្ធតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ ។ អនត្ថំ ចរតិ ។ អនត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ ។ អត្ថំ ចរតិ ។ អត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ ។

[២២៣] នវ អាឃាតប្បដិវិនយា អនត្ថំ មេ អចរីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ អនត្ថំ មេ ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។

១ ឱ. អនត្ថម្មេ ។

ចងអាឃាត ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ ។ កំពុងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ ។ នឹងប្រព្រឹត្ត នូវអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើជាប្រយោជន៍ ។ កំពុងប្រព្រឹត្ត នូវអំពើជាប្រយោជន៍ ។ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ ។

[២២៣] អាឃាតប្បដិវិន័យ (ការកំចាត់បង់អាឃាត) មាន ៩ យ៉ាងគឺ បុគ្គលកំចាត់បង់នូវអាឃាត ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះ អំពីណា ។ បុគ្គលកំចាត់បង់នូវអាឃាត ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះ អំពីណា ។

អនត្ថំ មេ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ ។ អនត្ថំ ចរតិ ។ អនត្ថំ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ ។ អត្ថំ ចរតិ ។ អត្ថំ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។

[២២៤] នវ សត្តាវាសា សត្តាវុសោ សត្តា នានត្ត-កាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមោ សត្តា-វាសោ ។ សន្តាវុសោ សត្តា នានត្តកាយា ឯកត្តសញ្ញិ-នោ សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា

បុគ្គលកំចាត់បង់នូវអាឃាត ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះ អំពីណា ។ បុគ្គលកំចាត់បង់នូវអាឃាតដោយគិតថា ជនឯណោះបានប្រព្រឹត្តហើយនូវអំពើមិនជាប្រយោជន៍ ។ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ។ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះ អំពីណា ។ បុគ្គលកំចាត់បង់នូវអាឃាតដោយគិតថា ជនឯណោះបានប្រព្រឹត្តប្រយោជន៍ ។ កំពុងប្រព្រឹត្តប្រយោជន៍ ។ នឹងប្រព្រឹត្តប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តនោះអាត្មាអញ គប្បីបានក្នុងបុគ្គលនុ៎ះ អំពីណា ។

[២២៤] សត្តាវាសៈ (ប្រទេសជាទីនៅរបស់សត្វ) មាន ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស ទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជា សត្តាវាស ទី ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតា ក្នុងជាន់ព្រហ្មលោក ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ

អយំ ទុតិយោ សត្តាវាសោ ។ សន្តាវុសោ សត្តា ឯកត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយោ សត្តាវាសោ ។ សន្តាវុសោ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហា អយំ ចតុត្ថោ សត្តាវាសោ ។ សន្តា-វុសោ សត្តា អសញ្ញិនោ អប្បដិសំវេទិនោ សេយ្យ-ថាបិ ទេវា អសញ្ញិសត្តា អយំ បញ្ចមោ សត្តា-វាសោ ។ សន្តាវុសោ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្ត-សញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អា-កាសានញ្ចាយតនូបគា អយំ ឆដ្ឋោ សត្តាវាសោ ។ សន្តាវុសោ សត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយត-នូបគា អយំ សត្តមោ សត្តាវាសោ ។ សន្តាវុសោ

នេះជា សត្តាវាស ទី ២ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជា សត្តាវាស ទី ៣ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជា សត្តាវាស ទី ៤ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វឥតសញ្ញា មិនដឹងច្បាស់ (នូវអារម្មណ៍) ដូចពួកទេវតាជាអសញ្ញិសត្វ នេះជា សត្តាវាស ទី ៥ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសទៅនៃពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្ត-សញ្ញាដោយប្រការទាំងពួង នេះជា សត្តាវាស ទី ៦ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រ-ការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជា សត្តាវាស ទី ៧ ។ ម្នាលអាវុសោ

សត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា អយំ អដ្ឋមោ សត្តាវាសោ ។ សន្តាវុសោ សត្តា សព្វសោ អា-កិញ្ចញ្ញាយតនំ សមតិក្កម្ម សន្តមេតំ បណីតមេ-តន្តិ[១] នេវសញ្ញានាសញ្ញាយតនូបគា អយំ នវមោ សត្តាវាសោ ។

[២២៤] នវ អក្ខណា អសមយា ព្រហ្មចរិយ-វាសាយ ឥធាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ទេសិយតិ ឱបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគ-តប្បវេទិតោ ។ អយញ្ច បុគ្គលោ និរយំ ឧបបន្នោ ហោតិ អយំ បឋមោ អក្ខណោ អសមយោ ព្រហ្ម-ចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ

១ ឱ. ម. សន្តមេតំ បណីតមេតន្តិ ន ទិស្សតិ ។

ទាំងឡាយ ពួកសត្វកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមានដូច្នេះ នេះជា សត្តាវាស ទី ៨ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងឡាយ ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុនេះស្ងប់រម្ងាប់ វត្ថុនេះប្រសើរ ដូច្នេះ នេះជា សត្តាវាស ទី ៩ ។

[២២៥] អក្ខណអសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យ មាន ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោកនេះផង ធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតប្រកាសទុក ព្រះអង្គក៏បានសំដែងហើយផង ។ តែបុគ្គលនេះទៅកើតក្នុងនរក នេះជា អក្ខណអសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ កើត

ជម្មោ ច នេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគតប្បវេទិតោ ។ អយញ្ច បុគ្គលោ តិរច្ឆានយោនឹ ឧបបន្នោ ហោតិ ។ បេ ។ បិត្តិវិសយំ ឧបបន្នោ ហោតិ ។ បេ ។ អសុរកាយំ ឧបបន្នោ ហោតិ ។ បេ ។ អញ្ញតរំ ទីឃាយុកំ ទេវនិកាយំ ឧបបន្នោ ហោតិ ។ បេ ។ បច្ចន្តិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ មិលក្ខកេសុ[១] អវិញ្ញាតារេសុ យត្ថ នត្ថិ គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ[២] ។ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ[៣] នត្ថិ មាតា នត្ថិ បិតា

១ ឱ. ម. មិលក្ខូសុ ។ ២ ឱ. ឯត្តន្តរេ អយំ ឆដ្ឋោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ.... អយញ្ច បុគ្គលោតិ ទិស្សន្តិ ។ ៣ ឱ. បរលោកោ ។

ឡើងហើយក្នុងលោកផង ធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតប្រកាសទុក ព្រះអង្គក៏បានសំដែងហើយផង ។ តែបុគ្គលនោះទៅកើតក្នុងកំណើតតិរច្ឆាន ។ បេ ។ ទៅកើតក្នុងបិត្តិវិស័យ ។ បេ ។ ទៅកើតក្នុងអសុរកាយ ។ បេ ។ ទៅកើតក្នុងពួកទេវតាមានអាយុវែងណាមួយ ។ បេ ។ ទៅកើតក្នុងពួកមិលក្ខជន ជាអ្នកមិនដឹងការខុសត្រូវច្បាស់លាស់ ក្នុងពួកបច្ចន្តិមជនបទ ដែលជាប្រទេសគ្មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទៅដល់ ។ បានកើតក្នុងមជ្ឈិមជនបទហើយ តែអ្នកនោះជាមិច្ឆាទិដ្ឋិ មានសេចក្តីឃើញវិបរិតថា ទានដែលបុគ្គលឲ្យហើយគ្មានផល របស់ដែលគេបូជាហើយគ្មានផល ការបូជាធំគ្មានផល ការបូជាតូចគ្មានផស ផលនិងវិបាករបស់កម្ម ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន លោកនេះមិនមាន លោកដទៃមិនមាន មាតាមិនមាន បិតាមិនមាន

២៣៩



នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា[១] សម្មាបដិបន្នា ឥមញ្ច[២] លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ[៣] ។ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ ទុប្បញ្ញោ[៤] ជឡោ ឯលមូគោ នប្បដិពលោ សុភាសិតទុព្ភាសិតានំ អត្ថមញ្ញាតុំ អយំ អដ្ឋមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ន ឧប្បន្នោ[៥] ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ន ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគតប្បវេទិតោ ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ បញ្ញវា[៦] អជឡោ អនេលមូគោ បដិពលោ

---

១ ឱ. សម្មគ្គាតា ។ ២ យេ ឥមញ្ច ។ ៣ ឱ. ឯត្ថន្តរេ អយំ សត្តមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ...... អយញ្ច បុគ្គលោតិ ទិស្សតិ ។ ៤ ឱ. ហោតិ សោ ច ហោតិ ទុប្បញ្ញោ ។ ៥ ឱ. អនុប្បន្នោ ។ ៦ ឱ. ហោតិ សោ ច ហោតិ បញ្ញវា ។

ពួកសត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ ក្នុងលោកជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិដោយល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ព្រោះដឹងច្បាស់ដោយខ្លួនឯង ហើយឲ្យអ្នកដទៃបានត្រាស់ដឹងផង មិនមាន ។ បានកើតក្នុងពួកមជ្ឈិមជនបទហើយ តែជាបុគ្គលអប្បឥតប្រាជ្ញាល្ងង់ខ្លៅ ជាមនុស្សគ មិនអង់អាចដើម្បីដឹងសេចក្តីនៃសុភាសិតនិងទុព្ភាសិតបាន នេះជា អក្ខណអសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ៨ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធមិនកើតឡើងក្នុងលោកផង ធម៌ធ្វើនូវសេចក្តីស្ងប់រម្ងាប់កិលេសប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏មិនបានសំដែងផង ។ តែបុគ្គលនេះបានកើតក្នុងមជ្ឈិមជនបទ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ អង់អាច

សុភាសិតទុព្ភាសិតានមត្ថមញ្ញាតុំ អយំ នវមោ អក្ខ-ណោ អសមយោ ព្រហ្មចរិយវាសាយ ។

[២២៦] នវ អនុបុព្វវិហារា ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិ-យជ្ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេ វ សោមនស្សទោម-នស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ

ដើម្បីដឹងសេចក្តីនៃសុភាសិតនិងទុព្ភាសិតបាន ។ នេះជា អក្ខណអសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៩ ។

[២២៦] អនុបុព្វវិហារៈ (ធម៌ជាគ្រឿងនៅដែលបុគ្គលត្រូវចូលតាមលំដាប់ឈាន) មាន ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ស្រឡះចាកកាមទាំងឡាយ ស្ងាត់ស្រឡះចាកអកុសលធម៌ទាំង-ឡាយ ហើយចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ១ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈទាំង-ឡាយ រមែងចូលទុតិយជ្ឈាន ជាឈានកើតក្នុងសន្តាននៃខ្លួន ជាទីជ្រះ-ថ្លាគឺសទ្ធាមានភាវៈជាចិត្តប្រសើរឯក គ្មានវិតក្កៈ គ្មានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ១ ព្រោះអស់ទៅនៃបីតិ ប្រកបដោយឧបេក្ខាផង មានសតិសម្បជញ្ញៈផង ទទួលនូវសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលចូលតតិយជ្ឈាននោះថា បុគ្គលនោះ ប្រកបដោយឧបេក្ខាមានសតិនៅជាសុខ ដោយអំណាចតតិយជ្ឈានណា បានចូលតតិយជ្ឈាន (នោះ) ១ ព្រោះលះសុខផង លះទុក្ខផង អស់សោមនស្សនិងទោមនស្ស ក្នុងកាលមុន ចូលចតុត្ថជ្ឈានមិនទុក្ខមិនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ១ ព្រោះកន្លងបង់នូវពួករូបសញ្ញា អស់ពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា

អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចា-
យតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកាសានញ្ចា-
យតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចា-
យតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចា-
យតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ
ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ
សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ
វិហរតិ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សម-
តិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។

[២២៧] នវ អនុបុព្វនិរោធា បឋមជ្ឈានំ សមា-
បន្នស្ស កាមសញ្ញា និរុទ្ធា ហោតិ ទុតិយជ្ឈានំ
សមាបន្នស្ស វិតក្កវិចារា និរុទ្ធា ហោន្តិ តតិយជ្ឈានំ
សមាបន្នស្ស បីតិ និរុទ្ធា ហោតិ ចតុត្ថជ្ឈានំ ស-
មាបន្នស្ស អស្សាសបស្សាសា និរុទ្ធា ហោន្តិ អាកា-
សានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញា និរុទ្ធា

ដោយប្រការទាំងពួង ចូលអាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុតដូច្នេះ ១ កន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលវិញ្ញាណញ្ចាយតនជ្ឈានដោយគិតថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ១ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលអាកិញ្ចញ្ញាយតនជ្ឈានដោយគិតថា វត្ថុអ្វីតិចតួចមិនមានដូច្នេះ ១ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ១ កន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលសញ្ញាវេទយិតនិរោធ ១ ។

[២២៧] អនុបុព្វនិរោធ (ធម៌ជាគ្រឿងរលត់ដោយលំដាប់ឈាន) មាន ៩ យ៉ាង គឺ កាលបុគ្គលចូលបឋមជ្ឈាន កាមសញ្ញារលត់ ១ កាលដែលចូលទុតិយជ្ឈាន វិតក្កវិចារៈរលត់ ១ កាលដែលចូលតតិយជ្ឈាន បីតិរលត់ ១ កាលដែលចូលចតុត្ថជ្ឈាន អស្សាសៈនិងបស្សាសៈរលត់ ១ កាលដែលចូលអាកាសានញ្ចាយតនជ្ឈាន រូបសញ្ញារលត់ ១ កាល

ហោតិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសា-នញ្ចាយតនសញ្ញា និរុទ្ធា ហោតិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញា និរុទ្ធា ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញា-យតនសញ្ញា និរុទ្ធា ហោតិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច និរុទ្ធា ហោន្តិ ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន នវ ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ នវកានំ បេយ្យាលោ ច[១] ។

សង្គីតិយនវកំ និដ្ឋិតំ[២] ។

[២២៨] អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទស ធម្មា សម្ម-ទក្ខាតា តត្ថ សព្វេហេវ សង្គាយិតព្វំ ។ បេ ។ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ ទស ។

---

១ ឱ. ម. នវកានំ បេយ្យាលោ ចាតិ ន ទិស្សតិ ។ ២ ឱ. ម. សង្គីតិយនវកំ និដ្ឋិតន្តិ ន ទិស្សតិ ។

ដែលចូលវិញ្ញាណញ្ចាយតនជ្ឈាន អាកាសានញ្ចាយតនសញ្ញារលត់ ១ កាលដែលចូលអាកិញ្ចញ្ញាយតនជ្ឈាន វិញ្ញាណញ្ចាយតនសញ្ញារលត់ ១ កាលដែលចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន អាកិញ្ចញ្ញាយតនសញ្ញារលត់ ១ កាលដែលចូលសញ្ញាវេទយិតនិរោធ សញ្ញានិងវេទនារលត់ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងជាធម៌ពួក ៩ ដែលព្រះមានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សំដែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនា ក្នុងធម៌ពួក ៩ នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ សេចក្តីបំប្រួញធម៌ពួក ៩ ។

ចប់ ពួកធម៌ប្រាំបួន ។ ដែលរាប់ចូលក្នុងការសង្គាយនា ។

[២២៨] ម្នាលអាវុសោទាំងឡាយ មានធម៌ពួក ១០ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ត្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សំដែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួក ១០ នោះ ។ បេ ។ ដើម្បីសេចក្តីចម្រើនដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ពួក ១០ ដូចម្តេចខ្លះ ។

ទស នាថករណា ធម្មា ឥធាវុសោ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ យំបាវុសោ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អយំ[១] ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ ។ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា[២] វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ យំបាវុសោ ភិក្ខុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ កល្យាណមិត្តោ

១ ឱ. អយម្បិ ។ ២ ឱ. ម. ធាតា ។

នាថករណធម៌ (ធម៌ជាគ្រឿងធ្វើនូវទីពឹង) មាន ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរ ឃើញភ័យចំពោះទោសទាំងឡាយ សូម្បីមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរ ឃើញភ័យចំពោះទោសទាំងឡាយ សូម្បីមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុ ជាពហុស្សូតចាំពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ។ ពួកធម៌ណា មានពីរោះខាងដើម មានពីរោះក្នុងកណ្តាល មានពីរោះក្នុងទីបំផុត ប្រកាសនូវព្រហ្មចារ្យ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌សព្វគ្រប់ ភិក្ខុនោះ បានស្តាប់ច្រើន បានចាំរត់មាត់ រំពឹងដោយចិត្តចាក់ធ្លុះដោយសេចក្តីយល់នូវធម៌មានសភាពដូច្នោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាពហុស្សូត ។ បេ ។ ចាក់ធ្លុះដោយសេចក្តីយល់ណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានមិត្រល្អ

ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ យំចាវុសោ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ អយំបិ ធម្មោ នាថការណោ ។ បុន ចបរំ អាវុសោ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនឹ ។ យំចាវុសោ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ បទក្ខិណគ្គាហី អនុសាសនឹ អយំបិ ធម្មោ នាថការណោ ។ បុន ចបរំ អាវុសោ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ ។ យំចាវុសោ ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ។ បេ ។ អលំ សំវិធាតុំ អយំបិ ធម្មោ នាថការណោ ។

មានសំឡាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានមិត្រល្អ មានសំឡាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយពួកធម៌ ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ[១] ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយពួកធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិច្ចអ្វីដែលបុគ្គលត្រូវធ្វើ ទោះបីធំឬតូច របស់ពួកសព្រហ្មចារីណា ភិក្ខុជាអ្នកឈ្លាស មិនខ្ជិលច្រអូសក្នុងកិច្ចទាំងនោះ ប្រកបដោយការពិចារណាជាឧបាយក្នុងកិច្ចនោះ អាចធ្វើបាន អាចចាត់ចែងបាន ។ ម្នាលអាវុសោទាំងឡាយ កិច្ចអ្វី ៗ ដែលបុគ្គលត្រូវធ្វើរបស់ពួកសព្រហ្មចារីណា ភិក្ខុ ។ បេ ។ អាចចាត់ចែងបានណា នេះជា នាថករណធម៌ ១ ។

---

១ ស្តាំជាប៉ែកខាងល្អ ឆ្វេងជាប៉ែកខាងអាក្រក់ អ្នកប្រព្រឹត្តល្អហៅថា ប្រព្រឹត្តខាងស្តាំ អ្នកប្រព្រឹត្តខុសហៅថា ប្រព្រឹត្តឆ្វេង ។

សង្គីតិសុត្តេ សង្គីតិយទសកំ

បុន ចបរំ អាវុសោ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុ-
ទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមោជ្ជោ[1] ។
យំបាវុសោ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទា-
ហារោ អភិធម្មេ អភិវិនយេ ឧឡារបាមោជ្ជោ[2] អយំបិ
ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ
សន្តុដ្ឋោ ហោតិ ឥតរីតរេហិ ចីវរបិណ្ឌបាតសេនាសន-
គិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។ យំបាវុសោ ភិក្ខុ
សន្តុដ្ឋោ ហោតិ ឥតរីតរេហិ ចីវរបិណ្ឌបាតសេនាសន-
គិលានប្បច្ចយភេសជ្ជបរិក្ខារេហិ អយំបិ ធម្មោ នា-
ថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អារទ្ធវីរិយោ
វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ
ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អ-
និក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ យំបាវុសោ ភិក្ខុ

---

១-២ ឱ. ឧឡារបាមុជ្ជោ ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកមានសំដីគួរស្រឡាញ់ មានសេចក្តីរីករាយដ៏លើសលប់ ក្នុងអភិធម្ម ក្នុងអភិវិន័យ[១] ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកមានសំដីគួរស្រឡាញ់ មានសេចក្តីត្រេកអរដ៏លើសលប់ ក្នុងអភិធម្ម ក្នុងអភិវិន័យណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបានណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានព្យាយាមប្រារព្ធហើយ ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីចម្រើនពួកកុសលធម៌ ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីសង្វាតមាំមួន មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានព្យាយាម

---

១ ក្នុងធម៌ គឺសុត្តន្តបិដក អភិធម្ម គឺសត្តបករណ វិន័យ គឺឧភតោវិភង្គ អភិវិន័យ គឺខន្ធកបរិវារ ឬថា ធម៌គឺសុត្តន្តបិដក អភិធម្ម គឺមគ្គផល វិន័យ គឺវិនយបិដកទាំងអស់ អភិវិន័យ គឺការរម្ងាប់កិលេស (អដ្ឋកថា) ។

អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា ។ យំបាវុសោ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ យំបាវុសោ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា អយំបិ ធម្មោ នាថករណោ ។

ប្រារព្ធហើយ ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីចម្រើនពួកកុសលធម៌ ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីសង្វាតមាំមួន មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសតិ ប្រកបដោយសតិ និងភាវៈជាបុគ្គលមានប្រាជ្ញាចាស់ក្លាក្រៃលែង ជាអ្នករលឹកបាន រលឹកបានរឿយ ៗ នូវការងារដែលបានធ្វើយូរហើយក្តី និយាយយូរហើយក្តី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសតិ ប្រកបដោយសតិ និងភាវៈជាបុគ្គលមានប្រាជ្ញាចាស់ក្លាក្រៃលែង ជាអ្នករលឹកបាន រលឹកបានរឿយ ៗ នូវការងារដែលបានធ្វើយូរហើយក្តី និយាយយូរហើយក្តីណា នេះជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងធ្លុះយល់នូវសេចក្តីចម្រើននិងសេចក្តីវិនាស ជាប្រាជ្ញាចាក់ធ្លុះដ៏ប្រសើរ ដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងធ្លុះយល់នូវសេចក្តីចម្រើននិងសេចក្តីវិនាស ជាប្រាជ្ញាចាក់ធ្លុះដ៏ប្រសើរ ដល់នូវសេចក្តីអស់ទៅ នៃទុក្ខដោយប្រពៃណា នេះជា នាថករណធម៌ ១ ។

សង្គីតិសុត្តេ សង្គីតិយទសកំ

[២២៩] ទស កសិណាយតនានិ បឋវីកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ អទ្វយំ[១] អប្បមាណំ ។ អាបោកសិណមេកោ សញ្ជានាតិ ។ បេ ។ តេជោកសិណមេកោ សញ្ជានាតិ ។ បេ ។ វាយោកសិណមេកោ សញ្ជានាតិ ។ បេ ។ នីលកសិណមេកោ សញ្ជានាតិ ។ បេ ។ បីតកសិណមេកោ សញ្ជានាតិ ។ បេ ។ លោហិតកសិណមេកោ សញ្ជានាតិ ។ បេ ។ ឱទាតកសិណមេកោ សញ្ជានាតិ ។ បេ ។ វិញ្ញាណកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ អទ្វយំ អប្បមាណំ ។

[២៣០] ទស អកុសលកម្មបថា បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ អភិជ្ឈា ព្យាបាទោ មិច្ឆាទិដ្ឋិ ។

១ ឱ. ម. អទុយំ ។

សង្គីតិសូត្រ ពួកធម៌ដប់ ៗ ដែលរាប់ចូលក្នុងការសង្គាយនា

[២២៩] កសិណាយតនៈមាន ១០ យ៉ាង គឺ បុគ្គលម្នាក់ ចាំបាននូវបឋវីកសិណ ទាំងទិសខាងលើខាងក្រោម និងទិសទទឹងតាមលំដាប់ រកប្រមាណមិនបាន ។ បុគ្គលម្នាក់ ចាំបាននូវអាបោកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវតេជោកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវវាយោកិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវនីលកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវបីតកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវលោហិតកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវឱទាតកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវអាកាសកសិណ ។ បេ ។ បុគ្គលម្នាក់ ចាំបាននូវវិញ្ញាណកសិណ ទាំងទិសខាងលើខាងក្រោម និងទិសទទឹងតាមលំដាប់ រកប្រមាណមិនបាន ។

[២៣០] អកុសលកម្មបថមាន ១០ យ៉ាង គឺ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារៈ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

[២៣១] ទស កុសលកម្មបថា ចាណាតិចាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អនភិជ្ឈា អព្យាបាទោ សម្មាទិដ្ឋិ ។

[២៣២] ទស អរិយវាសា ឥធាវុសោ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេនោ បនុណ្ណបច្ចេកសច្ចោ[១] សមវយសដ្ឋេសនោ អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តប្បញ្ញោ ។ កថញ្ចាវុសោ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ កាមច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ ថីនមិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ

១ ឱ. បនុន្នប្បច្ចេកសច្ចោ ។

[២៣១] កុសលកម្មបថមាន ១០ យ៉ាង គឺ ចេតនាវៀរចាកបាណាតិបាត ១ ចេតនាវៀរចាកអទិន្នាទាន ១ ចេតនាវៀរចាកកាមេសុមិច្ឆាចារ ១ ចេតនាវៀរចាកមុសាវាទ ១ ចេតនាវៀរចាកបិសុណាវាចា ១ ចេតនាវៀរចាកផរុសវាចា ១ ចេតនាវៀរចាកសម្ផប្បលាបៈ ១ មិនមានអភិជ្ឈា ១ មិនមានព្យាបាទ ១ សម្មាទិដ្ឋិ ១ ។

[២៣២] អរិយវាសៈ (ធម៌ជាគ្រឿងនៅរបស់ព្រះអរិយៈ) មាន ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានអង្គ ៥ លះបង់ហើយ ១ ប្រកបដោយឆឡង្គុបេក្ខា ១ មានកិរិយារក្សាធម៌តែមួយ ១ មានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង ១ លះបង់សច្ចៈដែលបុគ្គលប្រកាន់ផ្សេង ៗ គ្នា ១ មានការស្វែងរកនូវវត្ថុទាំងពួង លះបង់ហើយដោយប្រពៃ ១ មានសេចក្តីត្រិះរិះមិនសៅហ្មង ១ មានកាយសង្ខារស្ងប់រម្ងាប់ហើយ ១ មានចិត្តរួចស្រឡះហើយដោយល្អ ១ មានប្រាជ្ញារួចស្រឡះហើយ ដោយល្អ ១ ។ ម្នាលអាវុសោទាំងឡាយ ឯភិក្ខុមានអង្គ ៥ លះបង់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់កាមច្ឆន្ទៈ ១ លះបង់ព្យាបាទ ១ លះបង់ថីនមិទ្ធៈ ១ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ១

វិចិកិច្ឆា បហីនា ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ ។ ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។ ឯវំ ខោ អាវុសោ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ ឯការក្ខោ ហោតិ ។ ឥធាវុសោ ភិក្ខុ សតារក្ខេន ចេតសា សមន្នាគតោ ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ ឯការក្ខោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ ចតុរាបស្សេនោ ហោតិ ។

លះបង់វិចិកិច្ឆា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានអង្គ ៥ លះបង់ហើយដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ក៏មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលព្រងើយកន្ដើយ មានសតិនិងសម្បជញ្ញៈ ។ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ទទួលរសដោយអណ្ដាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ក៏មិនមានសោមនស្ស មិនមានទោមនស្ស ជាបុគ្គលព្រងើយកន្ដើយ មានសតិនិងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកិរិយារក្សាធម៌តែមួយ តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត មានសតិជាគ្រឿងរក្សាទុក្ខ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកិរិយារក្សាធម៌តែមួយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង តើដូចម្ដេច ។

ឥធាវុសោ ភិក្ខុ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោ-ទេតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ ចតុរាបស្សេនោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ បនុណ្ណបច្ចេកសច្ចោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ យានិ តានិ បុថុស-មណព្រាហ្មណានំ បុថុបច្ចេកសច្ចានិ សព្វានិ តា-និ[១] នុណ្ណានិ ហោន្តិ បនុណ្ណានិ ចត្តានិ វន្តានិ មុត្តានិ បហីនានិ បដិនិស្សដ្ឋានិ ។ ឯវំ ខោ អា-វុសោ ភិក្ខុ បនុណ្ណបច្ចេកសច្ចោ ហោតិ ។ កថញ្ចា-វុសោ ភិក្ខុ សមវយសដ្ឋេសនោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ កាមេសនា បហីនា ហោតិ ភវេសនា បហីនា ហោតិ ព្រហ្មចរិយេសនា បដិនិស្សដ្ឋា[២] ។

---

១ ឱ. សព្វានិស្សតានិ ។ ២ ឱ. ម. បដិប្បស្សទ្ធា ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយទើបសេពវត្ថុដែលគួរសេព ១ ពិចារណាហើយទើបអត់សង្កត់វត្ថុដែលគួរអត់សង្កត់ ១ ពិចារណាហើយទើបវៀរវត្ថុដែលគួរវៀរ ១ ពិចារណាហើយទើបបន្ទោបង់វត្ថុដែលគួរបន្ទាបង់ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុលះបង់សច្ចៈដែលបុគ្គលប្រកាន់ផ្សេង ៗ គ្នា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បាននាំចេញ បន្ទោបង់ លះចោល ខ្ជាក់ចេញ ផ្តាច់ចេញ លះបង់រលាស់ចោល នូវសច្ចធម៌ដែលបុគ្គលប្រកាន់ផ្សេងគ្នាច្រើនយ៉ាង របស់ពួកសមណព្រាហ្មណ៍ជាច្រើននោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុលះបង់សច្ចៈដែលបុគ្គលប្រកាន់ផ្សេង ៗ គ្នា ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានការស្វែងរកលះបង់ហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ លះបង់ការស្វែងរកកាម លះបង់ការស្វែងរកភព លះបង់ការស្វែងរកព្រហ្មចារ្យ[១] ។

---

១ សំដៅយកការលះអន្តគ្គាហិកទិដ្ឋិ (អដ្ឋកថា) ។

សង្គីតិសុត្តេ សង្គីតិយទសកំ

ឯវំ ខោ អាវុសោ ភិក្ខុ សមវយសដ្ឋេសនោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ អនាវិលសង្កប្បោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ កាមសង្កប្បោ បហីនោ ហោតិ ព្យាបាទសង្កប្បោ បហីនោ ហោតិ វិហឹសាសង្កប្បោ បហីនោ ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ អនាវិលសង្កប្បោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ បស្សទ្ធកាយសង្ខារោ ហោតិ ។ ឥធាវុសោ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ បស្សទ្ធកាយសង្ខារោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ សុវិមុត្តចិត្តោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ ហោតិ ទោសា ចិត្តំ វិមុត្តំ ហោតិ មោហា ចិត្តំ វិមុត្តំ ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ សុវិមុត្តចិត្តោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានការស្វែងរកលះបង់ហើយ ដោយល្អ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះមិនសៅហ្មង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ លះបង់សេចក្តីត្រិះរិះក្នុងកាម លះបង់សេចក្តីត្រិះរិះក្នុងព្យាបាទ លះបង់សេចក្តីត្រិះរិះក្នុងការបៀតបៀន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះមិនសៅហ្មង ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលកាន់ចតុត្ថជ្ឈាន មិនទុក្ខមិនសុខ មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះអស់សោមនស្ស និងទោមនស្សក្នុងកាលមុន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ហើយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តរួចស្រឡះហើយចាករាគៈ មានចិត្តរួចស្រឡះហើយចាកទោសៈ មានចិត្តរួចស្រឡះហើយចាកមោហៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុ

សុវិមុត្តប្បញ្ញោ ហោតិ ។ ឥធាវុសោ ភិក្ខុ រាគោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ ទោសោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ មោហោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ សុវិមុត្តប្បញ្ញោ ហោតិ ។

[២៣៣] ទស អសេក្ខា ធម្មា អសេក្ខា សម្មា-ទិដ្ឋិ អសេក្ខោ សម្មាសង្កប្បោ អសេក្ខា សម្មា-វាចា អសេក្ខោ សម្មាកម្មន្តោ អសេក្ខោ សម្មា-អាជីវោ អសេក្ខោ សម្មាវាយាមោ អសេក្ខា សម្មា-សតិ អសេក្ខោ សម្មាសមាធិ អសេក្ខំ សម្មាញាណំ

មានប្រាជ្ញារួចស្រឡះហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់ថា រាគៈអាត្មាអញលះបង់បានហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀត ដូចដើមត្នោត (កំបុត-ក) ហើយ ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅជាធម្មតា ដឹងច្បាស់ថា ទោសៈ អាត្មាអញលះបង់បានហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀត ដូចដើមត្នោត (កំបុត-ក) ហើយ ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅជាធម្មតា ដឹងច្បាស់ថា មោហៈអាត្មាអញលះបង់បានហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀត ដូចដើមត្នោត (កំបុត-ក) ហើយ ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅជាធម្មតា ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានប្រាជ្ញារួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។

[២៣៣] អសេក្ខធម៌ (ធម៌របស់អសេក្ខបុគ្គល) មាន ១០ យ៉ាងគឺ សម្មាទិដ្ឋិ ជាអសេក្ខធម៌ ១ សម្មាសង្កប្បៈ ជាអសេក្ខធម៌ ១ សម្មាវាចា ជាអសេក្ខធម៌ ១ សម្មាកម្មន្តៈ ជាអសេក្ខធម៌ ១ សម្មាអាជីវៈ ជាអសេក្ខធម៌ ១ សម្មាវាយាមៈ ជាអសេក្ខធម៌ ១ សម្មាសតិ ជាអសេក្ខធម៌ ១ សម្មាសមាធិ ជាអសេក្ខធម៌ ១ សម្មាញាណៈ ជាអសេក្ខធម៌ ១

អសេក្ខា សម្មាវិមុត្តិ ។ ឥមេ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទស ធម្មា សម្មទក្ខាតា តត្ថ សព្វេហេវ សង្គា-យិតព្វំ ន វិវទិតព្វំ យថយិទំ ព្រហ្មចរិយំ អទ្ធ-និយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

សង្គីតិយទសកំ និដ្ឋិតំ[១] ។

[២៣៤] អថខោ ភគវា ឧដ្ឋហិត្វា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ សាធុ សាធុ សារីបុត្ត សាធុ ខោ ត្វំ សារីបុត្ត ភិក្ខូនំ សង្គីតិបរិយាយំ អភាសីតិ ។ ឥទមវោច អាយស្មា សារីបុត្តោ ។ សមនុញ្ញោ សត្ថា អហោសិ ។ អត្តមនា ច តេ ភិក្ខូ អាយ-ស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

សង្គីតិសុត្តំ ទសមំ[២] និដ្ឋិតំ ។

---

១ ឱ. ម. សង្គីតិយទសកំ និដ្ឋិតន្តិ ន ទិស្សតិ ។ ២ ឱ. សង្គីតិសុត្តន្តំ សមត្តំ ។ ម. សង្គីតិបរិយាយំ នាម សុត្តន្តំ ទសមំ ។

សម្មាវិមុត្តិ ជាអសេក្ខធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងធម៌ពួក ១០ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សំដែងទុកស្រេចហើយ ពួកយើងទាំងអស់គ្នាត្រូវសង្គាយនា មិនត្រូវទាស់ទែងគ្នាក្នុងធម៌ទាំងនោះ ព្រហ្មចរិយធម៌នេះ ដែលនឹងតាំងនៅមាំ ឋិតនៅអស់កាលយូរ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ចប់ ពួកធម៌ដប់ ៗ ដែលរាប់ចូលក្នុងការសង្គាយនា ។

[២៣៤] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ក្រោកឡើងត្រាស់នឹងព្រះសារីបុត្តមានអាយុថា ម្នាលសារីបុត្ត ល្អហើយល្អហើយ ម្នាលសារីបុត្ត អ្នកបានសំដែងសង្គីតិបរិយាយ ដល់ភិក្ខុទាំងឡាយជាការប្រពៃពេកណាស់ ។ លុះព្រះសារីបុត្តបានសំដែងសូត្រនេះចប់ ។ ព្រះសាស្តាក៏បានពេញព្រះហឫទ័យហើយ ។ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរនឹងភាសិត របស់ព្រះសារីបុត្តមានអាយុ ។

ចប់ សង្គីតិសូត្រទី ១០ ។

# ទសុត្តរសុត្តំ ឯកាទសមំ

[២៣៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ចម្បាយំ វិហរតិ កគ្គរាយ ចោក្ខរណិយា តីរេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច

[២៣៦] ឧសុត្តរំ បវក្ខាមិ ជម្មំ និព្វានប្បត្តិយា

ទុក្ខស្សន្តកិរិយាយ សព្វគន្ថប្បមោចនន្តិ ។

[២៣៧] ឯកោ អាវុសោ ជម្មោ ពហុការោ ឯកោ ជម្មោ ភាវេតព្វោ ឯកោ ជម្មោ បរិញ្ញេយ្យោ ឯកោ ជម្មោ បហាតព្វោ ឯកោ ជម្មោ ហានភាគិយោ ឯកោ ជម្មោ វិសេសភាគិយោ ឯកោ ជម្មោ

# ទសុត្តរសូត្រ ទី ១១

[២៣៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរស្រះបោក្ខរណីឈ្មោះគគ្គរា ជិតក្រុងចម្បា ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប ។ ព្រះសារីបុត្តមានអាយុ បានហៅភិក្ខុទាំងឡាយ (ដែលនៅ) ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយដ៏មានអាយុ ។ ភិក្ខុទាំងនោះ ឆ្លើយតបពាក្យព្រះសារីបុត្តមានអាយុថា ម្នាលអាវុសោ ។ ព្រះសារីបុត្តមានអាយុ បានពោលយ៉ាងនេះថា

[២៣៦] ខ្ញុំនឹងសំដែងទសុត្តរធម៌[១] ជាធម៌សម្រាប់ដោះស្រាយនូវគ្រឿងចាក់ស្រែះ គឺកិលេសទាំងអស់ (មានអភិជ្ឈាជាដើម) ដើម្បីបានដល់ព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃវដ្តទុក្ខ ។

[២៣៧] ម្នាលអាវុសោទាំងឡាយ ធម៌មួយមានឧបការៈច្រើន ធម៌មួយគួរចម្រើន ធម៌មួយគួរកំណត់ដឹង ធម៌មួយគួរលះបង់ ធម៌មួយជាចំណែកនៃសេចក្តីវិនាស ធម៌មួយជាចំណែកវិសេស ធម៌មួយត្រាស់

១ ធម៌ដែលលោកចែកជាមាតិកាដប់ ៗ មួយទៀត ធម៌តាំងពីមួយ ១០ ដងឡើងទៅដល់ដប់ ១០ ដង ។ ឬក្នុងមួយសង្កាត់ ៗ មានប្រស្នាដប់ ៗ ក្នុងខមួយ ៗ ហៅថា ទសុត្តរធម៌ (អដ្ឋកថា) ។

ឧប្បជ្ជិតព្វោ ឯកោ ធម្មោ ឧប្បាទេតព្វោ ឯកោ ធម្មោ អភិញ្ញេយ្យោ ឯកោ ធម្មោ សច្ឆិកាតព្វោ ។

[២៣៨] កតមោ ឯកោ ធម្មោ ពហុការោ ។ អប្បមាទោ កុសលេសុ ធម្មេសុ ។ អយំ ឯកោ ធម្មោ ពហុការោ ។

[២៣៩] កតមោ ឯកោ ធម្មោ ភាវេតព្វោ ។ កាយគតាសតិ សាតសហគតា ។ អយំ ឯកោ ធម្មោ ភាវេតព្វោ ។

[២៤០] កតមោ ឯកោ ធម្មោ បរិញ្ញេយ្យោ ។ ផស្សោ សាសវោ ឧបាទានិយោ ។ អយំ ឯកោ ធម្មោ បរិញ្ញេយ្យោ ។

[២៤១] កតមោ ឯកោ ធម្មោ បហាតព្វោ ។ អស្មិមានោ ។ អយំ ឯកោ ធម្មោ បហាតព្វោ ។

[២៤២] កតមោ ឯកោ ធម្មោ ហានភាគិយោ ។ អយោនិសោមនសិការោ ។ អយំ ឯកោ ធម្មោ ហានភាគិយោ ។

ដឹងបានដោយក្រ ធម៌មួយគួរឲ្យកើតឡើង ធម៌មួយគួរដឹងច្បាស់ ធម៌មួយគួរធ្វើឲ្យជាក់ច្បាស់ ។

[២៣៨] ធម៌មួយមានឧបការៈច្រើន តើដូចម្តេច ។ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយជាកុសល ។ នេះជាធម៌មួយ ដែលមានឧបការៈច្រើន ។

[២៣៩] ធម៌មួយដែលគួរចម្រើន តើដូចម្តេច ។ កាយគតាសតិដែលប្រកបដោយសេចក្តីត្រេកអរ (សេចក្តីសុខ) ។ នេះជាធម៌មួយដែលគួរចម្រើន ។

[២៤០] ធម៌មួយដែលគួរកំណត់ដឹង តើដូចម្តេច ។ ផស្សៈដែលប្រកបដោយអាសវៈជាទីតាំងនៃឧបាទាន ។ នេះជាធម៌មួយ ដែលគួរកំណត់ដឹង ។

[២៤១] ធម៌មួយដែលគួរលះបង់ តើដូចម្តេច ។ អស្មិមានៈ គឺសេចក្តីប្រកាន់ខ្លួន ។ នេះជាធម៌មួយដែលគួរលះបង់ ។

[២៤២] ធម៌មួយដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេច ។ អយោនិសោមនសិការៈ គឺការធ្វើទុកក្នុងចិត្ត ដោយមិនជាឧបាយនៃប្រាជ្ញា[១] ។ នេះជាធម៌មួយដែលជាចំណែកនៃសេចក្តីវិនាស ។

១ បានដល់ការកំណត់ទុកក្នុងចិត្តខុសគន្លង ដូចកំណត់ក្នុងលក្ខណៈ ដែលមិនទៀងថាទៀងវិញជាដើម ។

[២៤៣] កតមោ ឯកោ ធម្មោ វិសេសភាគិយោ យោនិសោមនសិការោ ។ អយំ ឯកោ ធម្មោ វិសេសភាគិយោ ។

[២៤៤] កតមោ ឯកោ ធម្មោ ទុប្បដិវិជ្ឈោ ។ អនន្តរិកោ[១] ចេតោសមាធិ ។ អយំ ឯកោ ធម្មោ ទុប្បដិវិជ្ឈោ ។

[២៤៥] កតមោ ឯកោ ធម្មោ ឧប្បាទេតព្វោ ។ អកុប្បំ ញាណំ ។ អយំ ឯកោ ធម្មោ ឧប្បា-ទេតព្វោ ។

[២៤៦] កតមោ ឯកោ ធម្មោ អភិញ្ញេយ្យោ ។ សព្វេ សត្តា អាហារដ្ឋិតិកា ។ អយំ ឯកោ ធម្មោ អភិញ្ញេយ្យោ ។

[២៤៧] កតមោ ឯកោ ធម្មោ សច្ឆិកាតព្វោ ។ អកុប្បា ចេតោវិមុត្តិ ។ អយំ ឯកោ ធម្មោ សច្ឆិ-កាតព្វោ ។ ឥតិ ឥមេ[២] ទស ធម្មា ភូតា

១ ម. អានន្តរិកោ ។ អដ្ឋកថាយម្បិ ឯវមេវ ទិស្សតិ ។ ២ ឱ. ឥតិ មេ ។

[២៤៣] ធម៌មួយដែលជាចំណែកវិសេស តើដូចម្តេច ។ យោនិសោមនសិការៈ គឺការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។ នេះជាធម៌មួយដែលជាចំណែកវិសេស ។

[២៤៤] ធម៌មួយដែលត្រាស់ដឹង បានដោយក្រ តើដូចម្តេច ។ អនន្តរិកចេតោសមាធិ[១] ។ នេះជាធម៌មួយដែលត្រាស់ដឹងបានដោយក្រ ។

[២៤៥] ធម៌មួយដែលគួរឲ្យកើតឡើង តើដូចម្តេច ។ ញាណដែលមិនកម្រើក គឺបច្ចវេក្ខណបញ្ញា ។ នេះជាធម៌មួយដែលគួរឲ្យកើតឡើង ។

[២៤៦] ធម៌មួយដែលគួរដឹងច្បាស់ តើដូចម្តេច ។ បានដល់ពួកសត្វទាំងពួងតាំងនៅបានព្រោះអាហារ ។ នេះជាធម៌មួយដែលគួរដឹងច្បាស់ ។

[២៤៧] ធម៌មួយ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ។ អកុប្បាចេតោវិមុត្តិ ការរួចផុតនៃចិត្តមិនកម្រើក គឺអរហត្តផល ។ នេះជាធម៌មួយដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំងឡាយ ១០ នេះជាធម៌ពិត

១ ក្នុងទីដទៃលោកសំដៅយកផលជាលំដាប់នៃមគ្គ ហៅថា អនន្តរិកចេតោសមាធិ តែក្នុងទីនេះ លោកសំដៅយកមគ្គជាលំដាប់នៃវិបស្សនាវិញ ព្រោះសមាធិនោះជាលំដាប់នៃវិបស្សនាផង ឲ្យនូវផលជាលំដាប់នៃខ្លួនផង (អដ្ឋកថា) ។

តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

[២៤៨] ទ្វេ ធម្មា ពហុការា ទ្វេ ធម្មា ភាវេតព្វា ទ្វេ ធម្មា បរិញ្ញេយ្យា ទ្វេ ធម្មា បហាតព្វា ទ្វេ ធម្មា ហានភាគិយា ទ្វេ ធម្មា វិសេសភាគិយា ទ្វេ ធម្មា ទុប្បដិវិជ្ឈា ទ្វេ ធម្មា ឧប្បាទេតព្វា ទ្វេ ធម្មា អភិញ្ញេយ្យា ទ្វេ ធម្មា សច្ឆិកាតព្វា ។

[២៤៩] កតមេ ទ្វេ ធម្មា ពហុការា ។ សតិ ច សម្បជញ្ញញ្ច ។ ឥមេ ទ្វេ ធម្មា ពហុការា ។

[២៥០] កតមេ ទ្វេ ធម្មា ភាវេតព្វា ។ សមថោ ច វិបស្សនា ច ។ ឥមេ ទ្វេ ធម្មា ភាវេតព្វា ។

[២៥១] កតមេ ទ្វេ ធម្មា បរិញ្ញេយ្យា ។ នាមញ្ច រូបញ្ច ។ ឥមេ ទ្វេ ធម្មា បរិញ្ញេយ្យា ។

ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ គឺព្រះតថាគតត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

[២៤៨] ធម៌ពីរមានឧបការៈច្រើន ធម៌ពីរគួរចម្រើន ធម៌ពីរគួរកំណត់ដឹង ធម៌ពីរគួរលះបង់ ធម៌ពីរជាចំណែកនៃសេចក្ដីវិនាស ធម៌ពីរជាចំណែកវិសេស ធម៌ពីរត្រាស់ដឹងបានដោយក្រ ធម៌ពីរគួរឲ្យកើតឡើង ធម៌ពីរគួរដឹងច្បាស់ ធម៌ពីរគួរធ្វើឲ្យជាក់ច្បាស់ ។

[២៤៩] ធម៌ពីរដែលមានឧបការៈច្រើន តើដូចម្ដេចខ្លះ ។ សតិ (សេចក្ដីរលឹក) ១ សម្បជញ្ញៈ (សេចក្ដីដឹងខ្លួន) ១ ។ ធម៌ទាំងពីរនេះមានឧបការៈច្រើន ។

[២៥០] ធម៌ពីរដែលគួរចម្រើន តើដូចម្ដេចខ្លះ ។ សមថៈ ១ វិបស្សនា ១ ។ ធម៌ទាំងពីរនេះ គួរចម្រើន ។

[២៥១] ធម៌ពីរដែលគួរកំណត់ដឹង តើដូចម្ដេចខ្លះ ។ នាម ១ រូប ១ ។ ធម៌ទាំងពីរនេះ គួរកំណត់ដឹង ។

[២៤២] កតមេ ទ្វេ ធម្មា បហាតព្វា ។ អ-
វិជ្ជា ច ភវតណ្ហា ច ។ ឥមេ ទ្វេ ធម្មា បហាតព្វា ។

[២៤៣] កតមេ ទ្វេ ធម្មា ហានភាគិយា ។
ទោវចស្សតា ច បាបមិត្តតា ច ។ ឥមេ ទ្វេ ធម្មា
ហានភាគិយា ។

[២៤៤] កតមេ ទ្វេ ធម្មា វិសេសភាគិយា ។
សោវចស្សតា ច កល្យាណមិត្តតា ច ។ ឥមេ
ទ្វេ ធម្មា វិសេសភាគិយា ។

[២៤៥] កតមេ ទ្វេ ធម្មា ទុប្បដិវិជ្ឈា ។ យោ
ច ហេតុ យោ ច បច្ចយោ សត្តានំ សង្កិលេសា-
យ យោ ច ហេតុ យោ ច បច្ចយោ សត្តានំ
វិសុទ្ធិយា ។ ឥមេ ទ្វេ ធម្មា ទុប្បដិវិជ្ឈា ។

[២៤៦] កតមេ ទ្វេ ធម្មា ឧប្បាទេតព្វា ។ ទ្វេ
ញាណានិ[១] ខយេ ញាណំ អនុប្បាទេ ញាណំ ។
ឥមេ ទ្វេ ធម្មា ឧប្បាទេតព្វា ។

---

១ ឱ. ទ្វេ ញាណានីតិ ន ទិស្សតិ ។

[២៥២] ធម៌ពីរដែលគួរលះបង់ តើដូចម្តេចខ្លះ ។ អវិជ្ជា (សេចក្តីល្ងង់) ១ ភវតណ្ហា (ចំណង់ក្នុងភព) ១ ។ ធម៌ទាំងពីរនេះ គួរលះបង់ ។

[២៥៣] ធម៌ពីរដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ ភាវៈជាអ្នកដែលគេស្តីប្រដៅបានដោយក្រ ១ ភាវៈជាអ្នកគប់មិត្តអាក្រក់ ១ ។ ធម៌ទាំងពីរនេះ ជាចំណែកនៃសេចក្តីវិនាស ។

[២៥៤] ធម៌ពីរដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ ភាវៈជាអ្នកដែលគេស្តីប្រដៅងាយ ១ ភាវៈជាអ្នកគប់មិត្តល្អ ១ ។ ធម៌ទាំងពីរនេះ ជាចំណែកវិសេស ។

[២៥៥] ធម៌ពីរដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ ហេតុនិងបច្ច័យ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីសៅហ្មង របស់សត្វទាំង-ឡាយ ១ ហេតុនិងបច្ច័យដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធ របស់សត្វទាំងឡាយ ១ ។ ធម៌ទាំងពីរនេះ ត្រាស់ដឹងបានដោយក្រ ។

[២៥៦] ធម៌ពីរដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ញាណ (ការដឹង) ពីរយ៉ាង ការដឹងក្នុងរបស់អស់ទៅ ១ ការដឹងក្នុងរបស់មិនទាន់កើតឡើង ១ ។ ធម៌ទាំងពីរនេះ គួរឲ្យកើតឡើង ។

ទសុត្តរសុត្តេ ធម្មប្បភេទត្តិកំ

[២៤៧] កតមេ ទ្វេ ធម្មា អភិញ្ញេយ្យា ។ ទ្វេ ធាតុយោ សង្ខតា ច ធាតុ អសង្ខតា ច ធាតុ ។ ឥមេ ទ្វេ ធម្មា អភិញ្ញេយ្យា ។

[២៤៨] កតមេ ទ្វេ ធម្មា សច្ឆិកាតព្វា ។ វិជ្ជា ច វិមុត្តិ ច ។ ឥមេ ទ្វេ ធម្មា សច្ឆិកា-តព្វា ។ ឥតិ ឥមេ វីសតិ ធម្មា ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិ-សម្ពុទ្ធា ។

[២៤៩] តយោ ធម្មា ពហុការា តយោ ធម្មា ភាវេតព្វា តយោ ធម្មា បរិញ្ញេយ្យា តយោ ធម្មា បហាតព្វា តយោ ធម្មា ហានភាគិយា តយោ ធម្មា វិសេសភាគិយា តយោ ធម្មា ទុប្បដិវិជ្ឈា តយោ ធម្មា ឧប្បាទេតព្វា តយោ ធម្មា អភិញ្ញេយ្យា តយោ ធម្មា សច្ឆិកាតព្វា ។

[២៥០] កតមេ តយោ ធម្មា ពហុការា ។ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ ធម្មានុធម្មប្បដិបត្តិ ។ ឥមេ តយោ ធម្មា ពហុការា ។

ទសុត្តរសូត្រ ប្រភេទនៃធម៌បី ៗ

[២៥៧] ធម៌ពីរដែលគួរដឹងច្បាស់ តើដូចម្ដេចខ្លះ ។ ធាតុពីរយ៉ាង ធាតុដែលមានបច្ច័យតាក់តែង[១] ១ ធាតុដែលគ្មានបច្ច័យតាក់តែង[២] ១ ។ ធម៌ទាំងពីរនេះ គួរដឹងច្បាស់ ។

[២៥៨] ធម៌ពីរដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្ដេចខ្លះ ។ វិជ្ជា សេចក្ដីដឹង ១ វិមុត្តិ សេចក្ដីរួចផុតស្រឡះចាកកិលេស ១ ។ ធម៌ទាំងពីរនេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ២០ នេះជាធម៌ពិត ធម៌មែន ធម៌ទៀតទាត់ មិនប្រែប្រួលជាយ៉ាងដទៃ ដែលព្រះតថាគតត្រាស់ដឹងដោយប្រពៃហើយ ដោយប្រការដូច្នេះ ។

[២៥៩] ធម៌បីមានឧបការៈច្រើន ធម៌បីគួរចម្រើន ធម៌បីគួរកំណត់ដឹង ធម៌បីគួរលះបង់ ធម៌បីជាចំណែកនៃសេចក្ដីវិនាស ធម៌បីជាចំណែកវិសេស ធម៌បីត្រាស់ដឹងបានដោយក្រ ធម៌បីគួរឲ្យកើតឡើង ធម៌បីគួរឲ្យដឹងច្បាស់ ធម៌បីគួរធ្វើឲ្យជាក់ច្បាស់ ។

[២៦០] ធម៌បីមានឧបការៈច្រើន តើដូចម្ដេចខ្លះ ។ ការសេពគប់នឹងសប្បុរស ១ ការស្ដាប់ធម៌របស់សប្បុរស ១ សេចក្ដីប្រតិបត្តិធម៌សមគួរដល់ធម៌ ១ ។ ធម៌ទាំង ៣ នេះ មានឧបការៈច្រើន ។

---

១ បានដល់ ខន្ធ ៥ ។ ២ បានដល់ ព្រះនិព្វាន ។

[២៦១] កតមេ តយោ ធម្មា ភាវេតព្វា ។ តយោ សមាធី សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធិ ។ ឥមេ តយោ ធម្មា ភាវេតព្វា ។

[២៦២] កតមេ តយោ ធម្មា បរិញ្ញេយ្យា ។ តិស្សោ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមេ តយោ ធម្មា បរិញ្ញេយ្យា ។

[២៦៣] កតមេ តយោ ធម្មា បហាតព្វា ។ តិស្សោ តណ្ហា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥមេ តយោ ធម្មា បហាតព្វា ។

[២៦៤] កតមេ តយោ ធម្មា ហានភាគិយា ។ តីណិ អកុសលមូលានិ លោភោ អកុសលមូលំ ទោសោ អកុសលមូលំ មោហោ អកុសលមូលំ ។ ឥមេ តយោ ធម្មា ហានភាគិយា ។

[២៦១] ធម៌បីដែលគួរចម្រើន តើដូចម្ដេចខ្លះ ។ សមាធិបីយ៉ាង សមាធិដែលមានវិតក្កៈ ទាំងវិចារៈ ១ សមាធិដែលគ្មានវិតក្កៈ មានតែវិចារៈ ១ សមាធិដែលគ្មានវិតក្កៈ គ្មានទាំងវិចារៈ ១ ។ ធម៌ទាំង ៣ នេះ គួរចម្រើន ។

[២៦២] ធម៌បីដែលគួរកំណត់ដឹង តើដូចម្ដេចខ្លះ ។ វេទនាបីប្រការ វេទនាដែលជាសុខ ១ វេទនាដែលជាទុក្ខ ១ វេទនាដែលមិនជាទុក្ខ មិនជាសុខ ១ ។ ធម៌ទាំងបីនេះ គួរកំណត់ដឹង ។

[២៦៣] ធម៌បីដែលគួរលះបង់ តើដូចម្ដេចខ្លះ ។ តណ្ហាបីប្រការ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ធម៌ទាំងបីនេះ គួរលះបង់ ។

[២៦៤] ធម៌បីដែលជាចំណែក នៃសេចក្ដីវិនាស តើដូចម្ដេចខ្លះ ។ អកុសលមូល (ឫសអកុសល) បីយ៉ាង គឺ លោភៈជាឫសអកុសល ១ ទោសៈជាឫសអកុសល ១ មោហៈជាឫសអកុសល ១ ។ ធម៌ទាំងបីនេះ ជាចំណែកនៃសេចក្ដីវិនាស ។

ទសុត្តរសុត្តេ ធម្មប្បភេទត្តិកំ

[២៦៥] កតមេ តយោ ធម្មា វិសេសភាគិយា ។ តីណិ កុសលមូលានិ អលោភោ កុសលមូលំ អ-ទោសោ កុសលមូលំ អមោហោ កុសលមូលំ ។ ឥមេ តយោ ធម្មា វិសេសភាគិយា ។

[២៦៦] កតមេ តយោ ធម្មា ទុប្បដិវិជ្ឈា ។ តិស្សោ និស្សារណីយា ធាតុយោ កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ រូបានមេតំ និស្សរណំ យទិទំ អរូបំ យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ បដិច្ចសមុប្បន្នំ និរោធោ តស្ស និស្សរណំ ។ ឥមេ តយោ ធម្មា ទុប្បដិវិជ្ឈា ។

[២៦៧] កតមេ តយោ ធម្មា ឧប្បាទេតព្វា ។ តីណិ ញាណានិ អតីតំសញ្ញាណំ អនាគតំសញ្ញាណំ បច្ចុប្បន្នំ-សញ្ញាណំ[១] ។ ឥមេ តយោ ធម្មា ឧប្បាទេតព្វា ។

១ ឱ. ម. អតីតំសេ ញាណំ អនាគតំសេ ញាណំ បច្ចុប្បន្នំសេ ញាណំ ។

ទសុត្តរសូត្រ ប្រភេទនៃធម៌បី ៗ

[២៦៥] ធម៌បីដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ កុសលមូល (ឬកុសល) បីប្រការ គឺ អលោភៈជាឫសកុសល ១ អទោសៈជាឫសកុសល ១ អមោហៈជាឫសកុសល ១ ។ ធម៌ទាំងបីនេះ ជាចំណែកវិសេស ។

[២៦៦] ធម៌បីដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ និស្សារណីយធាតុ (ធាតុដែលត្រូវរលាស់ចេញ) ៣ ប្រការ គឺ នេក្ខម្មៈ[១] ដែលជាធម្មជាតរលាស់ចេញនូវកាមទាំងឡាយ ១ អរូបជ្ឈាន[២] ដែលជាធម្មជាតរលាស់ចេញនូវរូបទាំងឡាយ ១ និរោធ[៣] ដែលជាធម៌រលាស់ចេញនូវអ្វីមួយដែលកើតឡើង ព្រោះអាស្រ័យនឹងបច្ច័យដែលតាក់តែង ១ ។ ធម៌ទាំង ៣ នេះ ត្រាស់ដឹងបានដោយក្រ ។

[២៦៧] ធម៌បីដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ញាណ ៣ យ៉ាង គឺ ញាណដែលជាចំណែកអតីតៈ ១ ញាណដែលជាចំណែកអនាគត ១ ញាណដែលជាចំណែកបច្ចុប្បន្ន ១ ។ ធម៌ទាំងបីនេះ គួរឲ្យកើតឡើង ។

---

១ នេក្ខម្មៈក្នុងទីនេះ លោកសំដៅយកអនាគាមិមគ្គ ព្រោះជាធម៌រលាស់ចេញនូវកាមគ្រប់យ៉ាង ។ ២ បានដល់អរហត្តមគ្គ ព្រោះជាធម៌រលាស់ចេញនូវរូបទាំងពួងឃាត់មិនឲ្យកើតឡើងទៀត ។ ៣ និរោធក្នុងទីនេះបានដល់អរហត្តផល ព្រោះអរិយបុគ្គលដែលបានឃើញនូវព្រះនិព្វានដោយអរហត្តផលហើយ សង្ខារទាំងពួងលែងមានតទៅទៀត ។

[២៦៨] កតមេ តយោ ធម្មា អភិញ្ញេយ្យា ។ តិស្សោ ធាតុយោ កាមធាតុ រូបធាតុ អរូបធាតុ ។ ឥមេ តយោ ធម្មា អភិញ្ញេយ្យា ។

[២៦៩] កតមេ តយោ ធម្មា សច្ឆិកាតព្វា ។ តិស្សោ វិជ្ជា បុព្វេនិវាសានុស្សតិញ្ញាណំ វិជ្ជា សត្តានំ ចុតូបបាតេ ញាណំ វិជ្ជា អាសវានំ ខយេ ញាណំ វិជ្ជា ។ ឥមេ តយោ ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ[១] តឹស ធម្មា ភូតា តច្ឆា តថា អវិ-តថា អនញ្ញថា សម្មា ភូតា តច្ឆា តថា អវិ-តថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

[២៧០] ចត្តារោ ធម្មា ពហុការា ចត្តារោ ធម្មា ភាវេតព្វា ចត្តារោ ធម្មា បរិញ្ញេយ្យា ចត្តារោ ធម្មា បហាតព្វា ចត្តារោ ធម្មា ហានភាគិយា ចត្តារោ ធម្មា វិសេសភាគិយា ចត្តារោ ធម្មា ទុប្បដិវិជ្ឈា ចត្តារោ ធម្មា ឧប្បាទេតព្វា ចត្តារោ ធម្មា អភិញ្ញេយ្យា ចត្តារោ ធម្មា សច្ឆិកាតព្វា ។

---
១ ឱ. ឥតិ មេ ។

[២៦៨] ធម៌បីដែលគួរឲ្យដឹងច្បាស់ តើដូចម្តេចខ្លះ ។ ធាតុបីយ៉ាង គឺ កាមធាតុ ១ រូបធាតុ ១ អរូបធាតុ ១ ។ ធម៌ទាំង ៣ នេះ គួរដឹងច្បាស់ ។

[២៦៩] ធម៌បីគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ វិជ្ជា ៣ ប្រការ គឺញាណជាគ្រឿងរលឹកបាននូវខន្ធ ដែលអាស្រ័យនៅក្នុងកាលមុនជាវិជ្ជា ១ ធម្មជាតជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយជាវិជ្ជា ១ ធម្មជាតជាគ្រឿងដឹងក្នុងកិរិយាអស់ទៅនៃអាសវៈទាំងឡាយជាវិជ្ជា ១ ។ ធម៌ទាំង ៣ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៣០ នេះ ជាធម៌ពិត ធម៌មែន ជាធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងដោយប្រពៃ ដោយប្រការដូច្នេះ ។

[២៧០] ធម៌ ៤ មានឧបការៈច្រើន ធម៌ ៤ គួរចម្រើន ធម៌ ៤ គួរកំណត់ដឹង ធម៌ ៤ គួរលះបង់ ធម៌ ៤ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៤ ជាចំណែកវិសេស ធម៌ ៤ ត្រាស់ដឹងបានដោយក្រ ធម៌ ៤ គួរឲ្យកើតឡើង ធម៌ ៤ គួរឲ្យដឹងច្បាស់ ធម៌ ៤ គួរធ្វើឲ្យជាក់ច្បាស់ ។

ទសុត្តរសុត្តេ ធម្មប្បភេទចតុក្កំ

[២៧១] កតមេ ចត្តារោ ធម្មា ពហុការា ។ ចត្តារិ ចក្កានិ បដិរូបទេសវាសោ សប្បុរិសូបស្ស-យោ[១] អត្តសម្មាបណិធិ បុព្វេ ច កតបុញ្ញតា ។ ឥមេ ចត្តារោ ធម្មា ពហុការា ។

[២៧២] កតមេ ចត្តារោ ធម្មា ភាវេតព្វា ។ ចត្តារោ សតិប្បដ្ឋានា ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនា-សុ ។ បេ ។ ចិត្តេ ។ បេ ។ ធម្មេសុ ធម្មានុ-បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ ចត្តារោ ធម្មា ភាវេតព្វា ។

---

១ ម. សប្បុរិសុបនិស្សយោ ។

ទសុត្តរសូត្រ ប្រភេទនៃធម៌បួន ៗ

[២៧១] ធម៌ ៤ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ ចក្កធម៌[១] ៤ យ៉ាង គឺ ការនៅក្នុងប្រទេសដ៏សមគួរ ១ ការសេពគប់សប្បុរស ១ ការតាំងខ្លួនទុកប្រពៃ ១ ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ១ ។ ធម៌ទាំង ៤ នេះ មានឧបការៈច្រើន ។

[២៧២] ធម៌ ៤ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ សតិប្បដ្ឋាន ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញកាយក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានប្រាជ្ញាស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ ក្នុងវេទនាទាំងឡាយ ។ បេ ។ ក្នុងចិត្ត ។ បេ ។ ជាអ្នកពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានប្រាជ្ញាស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ ធម៌ទាំង ៤ នេះ គួរចម្រើន ។

---

១ ធម្មជាតជាគ្រឿងវិលទៅ ហៅថា ចក្កៈ (កង់) មាន ៥ យ៉ាងគឺ ទារុចក្កៈ (កង់ឈើ) ១ រតនចក្កៈ (កង់កែវ) ១ ធម្មចក្កៈ (កង់គឺធម៌) ១ ឥរិយាបថចក្កៈ (កង់គឺឥរិយាបថ) ១ សម្បត្តិ-ចក្កៈ (កង់គឺសម្បត្តិ) ១ ក្នុងទីនេះសំដៅយក សម្បត្តិចក្កៈ តែម្យ៉ាង ។

[២៧៣] កតមេ ចត្តារោ ធម្មា បរិញ្ញេយ្យា ។ ចត្តារោ អាហារា កពឡីការោ[១] អាហារោ ឱឡារិកោ វា សុខុមោ វា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។ ឥមេ ចត្តារោ ធម្មា បរិញ្ញេយ្យា ។

[២៧៤] កតមេ ចត្តារោ ធម្មា បហាតព្វា ។ ចត្តារោ ឱឃា កាមោឃោ ភវោឃោ ទិដ្ឋោឃោ អវិជ្ជោឃោ ។ ឥមេ ចត្តារោ ធម្មា បហាតព្វា ។

[២៧៥] កតមេ ចត្តារោ ធម្មា ហានភាគិយា ។ ចត្តារោ យោគា កាមយោគោ ភវយោគោ ទិដ្ឋិយោគោ អវិជ្ជាយោគោ ។ ឥមេ ចត្តារោ ធម្មា ហានភាគិយា ។

[២៧៦] កតមេ ចត្តារោ ធម្មា វិសេសភាគិយា ។ ចត្តារោ វិសំយោគា កាមយោគវិសំយោគោ ភវយោគវិសំយោគោ ទិដ្ឋិយោគវិសំយោគោ អវិជ្ជាយោគវិសំយោគោ ។ ឥមេ ចត្តារោ ធម្មា វិសេសភាគិយា ។

---

១ ឱ. កពលិង្ការោ ។ ម. កពឡីការោ ។

[២៧៣] ធម៌ ៤ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ អាហារ ៤ គឺ អាហារដែលពូតជាពំនូត ទោះគ្រោតគ្រាតក្តី ល្អិតក្តី (ជាទី ១) ផស្សាហារ ជាទី ២ មនោសញ្ចេតនាហារ ជាទី ៣ វិញ្ញាណាហារ ជាទី ៤ ។ ធម៌ទាំង ៤ នេះ គួរកំណត់ដឹង ។

[២៧៤] ធម៌ ៤ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ អន្ទង់ ៤ អន្ទង់គឺកាម ១ អន្ទង់គឺភព ១ អន្ទង់គឺទិដ្ឋិ ១ អន្ទង់គឺអវិជ្ជា ១ ។ ធម៌ទាំង ៤ នេះ គួរលះបង់ ។

[២៧៥] ធម៌ ៤ ដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ យោគៈ (គ្រឿងប្រកប) ៤ គឺកាមយោគៈ (គ្រឿងប្រកបគឺកាម) ១ ភវយោគៈ (គ្រឿងប្រកបគឺភព) ១ ទិដ្ឋិយោគៈ (គ្រឿងប្រកបគឺទិដ្ឋិ) ១ អវិជ្ជាយោគៈ (គ្រឿងប្រកបគឺអវិជ្ជា) ១ ។ ធម៌ទាំង ៤ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[២៧៦] ធម៌ ៤ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ ការប្រាសចាកគ្រឿងប្រកប ៤ គឺ ការប្រាសចាកគ្រឿងប្រកបគឺកាម ១ ការប្រាសចាកគ្រឿងប្រកបគឺភព ១ ការប្រាសចាកគ្រឿងប្រកបគឺទិដ្ឋិ ១ ការប្រាសចាកគ្រឿងប្រកបគឺអវិជ្ជា ១ ។ ធម៌ទាំង ៤ នេះ ជាចំណែកវិសេស ។

[២៧៧] កតមេ ចត្តារោ ធម្មា ទុប្បដិវិជ្ឈា ។ ចត្តារោ សមាធី ហានភាគិយោ សមាធិ ឋិតិភាគិយោ សមាធិ វិសេសភាគិយោ សមាធិ និព្វេធភាគិយោ សមាធិ ។ ឥមេ ចត្តារោ ធម្មា ទុប្បដិវិជ្ឈា ។

[២៧៨] កតមេ ចត្តារោ ធម្មា ឧប្បាទេតព្វា ។ ចត្តារិ ញាណានិ ធម្មេ ញាណំ អន្វយេ ញាណំ បរិច្ចេ[១] ញាណំ សម្មតិយា[២] ញាណំ ។ ឥមេ ចត្តារោ ធម្មា ឧប្បាទេតព្វា ។

[២៧៩] កតមេ ចត្តារោ ធម្មា អភិញ្ញេយ្យា ។ ចត្តារិ អរិយសច្ចានិ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ ឥមេ ចត្តារោ ធម្មា អភិញ្ញេយ្យា ។

[២៨០] កតមេ ចត្តារោ ធម្មា សច្ឆិកាតព្វា ។ ចត្តារិ សាមញ្ញផលានិ សោតាបត្តិផលំ សកទាគាមិផលំ អនាគាមិផលំ អរហត្តផលំ ។ ឥមេ ចត្តារោ ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ ចត្តាឡីស[៣] ធម្មា

---

១ ម. បរិច្ឆេទេ ។ ២ ឱ. សម្មុតិ ។ ម. សម្មុតិយា ។ ៣ ឱ. ឥតិ មេ ចត្តារីសំ ។

ទសុត្តរសូត្រ ប្រភេទនៃធម៌បួន ៗ

[២៧៧] ធម៌ ៤ ដែលត្រាស់ដឹងបានដោយក្រ តើដូចម្ដេចខ្លះ ។ សមាធិ ៤ គឺ សមាធិដែលជាចំណែកនៃសេចក្ដីវិនាស ១ សមាធិដែលជាចំណែកនៃការឋិតថេរ ១ សមាធិដែលជាចំណែកវិសេស ១ សមាធិដែលជាចំណែកនៃកិរិយាទម្លាយនូវកិលេស ១ ។ ធម៌ទាំង ៤ នេះ ត្រាស់ដឹងបានដោយក្រ ។

[២៧៨] ធម៌ ៤ ដែលគួរឲ្យកើតឡើង តើដូចម្ដេចខ្លះ ។ ញាណ ៤ គឺ ធម្មជាតជាគ្រឿងដឹងក្នុងធម៌ ១ ធម្មជាតជាគ្រឿងដឹងក្នុងការយល់ ១ ធម្មជាតជាគ្រឿងដឹងក្នុងការកំណត់ ១ ធម្មជាតជាគ្រឿងដឹងក្នុងការសម្មត ១ ។ ធម៌ទាំង ៤ នេះ គួរឲ្យកើតឡើង ។

[២៧៩] ធម៌ ៤ ដែលគួរដឹងច្បាស់ តើដូចម្ដេចខ្លះ ។ អរិយសច្ច ៤ គឺ ទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ធម៌ទាំង ៤ នេះ គួរដឹងច្បាស់ ។

[២៨០] ធម៌ ៤ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្ដេចខ្លះ ។ សាមញ្ញផល ៤ គឺសោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។ ធម៌ទាំង ៤ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៤០ នេះ

ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថា-
គតេន អភិសម្ពុទ្ធា ។

[២៨១] បញ្ច ធម្មា ពហុការា បញ្ច ធម្មា
ភាវេតព្វា បញ្ច ធម្មា បរិញ្ញេយ្យា បញ្ច ធម្មា បហា-
តព្វា បញ្ច ធម្មា ហានភាគិយា បញ្ច ធម្មា វិសេ-
សភាគិយា បញ្ច ធម្មា ទុប្បដិវិជ្ឈា បញ្ច ធម្មា
ឧប្បាទេតព្វា បញ្ច ធម្មា អភិញ្ញេយ្យា បញ្ច ធម្មា
សច្ឆិកាតព្វា ។

[២៨២] កតមេ បញ្ច ធម្មា ពហុការា ។ បញ្ច
បធានិយង្គានិ ឥធាវុសោ ភិក្ខុ សទ្ធោ ហោតិ
សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា
អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ
លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវម-
នុស្សានំ ពុទ្ធោ ភគវាតិ អប្បាពាធោ ហោតិ

ជាធម៌ពិត ធម៌មែន ជាធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

[២៨១] ធម៌ ៥ មានឧបការៈច្រើន ធម៌ ៥ គួរចម្រើន ធម៌ ៥ គួរកំណត់ដឹង ធម៌ ៥ គួរលះបង់ ធម៌ ៥ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៥ ជាចំណែកវិសេស ធម៌ ៥ ត្រាស់ដឹងបានដោយក្រ ធម៌ ៥ គួរឲ្យកើតឡើង ធម៌ ៥ គួរដឹងច្បាស់ ធម៌ ៥ គួរធ្វើឲ្យជាក់ច្បាស់ ។

[២៨២] ធម៌ ៥ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ អង្គដែលជាទីតាំងនៃសេចក្តីព្យាយាម ៥ ប្រការ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគត ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនិងក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតដូច្នេះ ជាអ្នកមិនមានអាពាធ

អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគ-
តោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខ-
មាយ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ
អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ
អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានា-
យ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា
ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ
បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នា-
គតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគា-
មិនិយា ។ ឥមេ បញ្ច ធម្មា ពហុការា ។

[២៨៣] កតមេ បញ្ច ធម្មា ភាវេតព្វា ។ បញ្ចង្គិ-
កោ សម្មាសមាធិ បីតិផរណតា សុខផរណតា ចេ-
តោផរណតា អាលោកផរណតា បច្ចវេក្ខណានិមិត្តំ[១] ។
ឥមេ បញ្ច ធម្មា ភាវេតព្វា ។

---

១ ឱ. ម. បច្ចវេក្ខណនិមិត្តំ ។

មិនមានទុក្ខ ប្រកបដោយតេជោធាតុដែលកើតអំពីកម្ម មានផលស្មើគ្នា មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម ១ ជាអ្នកមិនអួតអាង មិនមានមាយា សំដែងខ្លួនតាមពិតចំពោះគ្រូ ឬសព្រហ្មចារីបុគ្គលដែលជាអ្នកចេះដឹងទាំងឡាយ ១ ជាអ្នកមានព្យាយាមប្រារព្ធហើយ ដើម្បីលះបង់ធម៌ទាំងឡាយ ដែលជាអកុសល ដើម្បីញុំាងធម៌ទាំងឡាយដែលជាកុសលឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែង មិនដាក់ធុរៈចុះក្នុងធម៌ទាំងឡាយដែលជាកុសល ១ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលជាគ្រឿងធ្វើដំណើរទៅកាន់សេចក្តីចម្រើន និងសេចក្តីវិនាស ជាគ្រឿងត្រាស់ដឹងរបស់ព្រះអរិយៈជាគ្រឿងធ្វើដំណើរទៅកាន់ការអស់ទៅនៃទុក្ខដោយប្រពៃ ១ ។ ធម៌ទាំង ៥ នេះ មានឧបការៈច្រើន ។

[២៨៣] ធម៌ ៥ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ ការតាំងចិត្តប្រពៃប្រកបដោយអង្គ ៥ គឺ ការផ្សាយទៅនៃបីតិ ១ ការផ្សាយទៅនៃសេចក្តីសុខ ១ ការផ្សាយទៅនៃចិត្ត ១ ការផ្សាយទៅនៃពន្លឺ ១ និមិត្តនៃការពិចារណា ១ ។ ធម៌ទាំង ៥ នេះ គួរចម្រើន ។

[២៨៤] កតមេ បញ្ច ធម្មា បរិញ្ញេយ្យា ។ បញ្ចុបាទានក្ខន្ធា សេយ្យថីទំ[១] រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ។ ឥមេ បញ្ច ធម្មា បរិញ្ញេយ្យា ។

[២៨៥] កតមេ បញ្ច ធម្មា បហាតព្វា ។ បញ្ច នីវរណានិ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ។ ឥមេ បញ្ច ធម្មា បហាតព្វា ។

[២៨៦] កតមេ បញ្ច ធម្មា ហានភាគិយា ។ បញ្ច ចេតោខីលា ឥធាវុសោ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ យោ សោ អាវុសោ ភិក្ខុ សត្ថរិ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ តស្ស ចិត្តំ ន នមតិ អាតប្បាយ

---

១ ម. សេយ្យថីទន្តិ ន ទិស្សតិ ។

[២៨៤] ធម៌ ៥ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ ឧបាទានក្ខន្ធ (គំនរនៃសេចក្តីប្រកាន់) ៥ គឺ រូបជាឧបាទានក្ខន្ធ ១ វេទនាជាឧបាទានក្ខន្ធ ១ សញ្ញាជាឧបាទានក្ខន្ធ ១ សង្ខារជាឧបាទានក្ខន្ធ ១ វិញ្ញាណជាឧបាទានក្ខន្ធ ១ ។ ធម៌ទាំង ៥ នេះ គួរកំណត់ដឹង ។

[២៨៥] ធម៌ ៥ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ នីវរណៈ (ធម៌ជាគ្រឿងរារាំង) ៥ គឺ កាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ធម៌ទាំង ៥ នេះ គួរលះបង់ ។

[២៨៦] ធម៌ ៥ ដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ សេចក្តីរឹងត្អឹងនៃចិត្ត ៥ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក ម្នាលអាវុសោទាំងឡាយ ភិក្ខុណា សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះ មិនបានបង្អោនទៅ ដើម្បីសេចក្តីព្យាយាមជា

អនុយោគាយ សាតច្ចាយ បធានាយ យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បឋមោ ចេតោខីលោ ។ បុន ចបរំ អាវុសោ ភិក្ខុ ធម្មេ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ ។ បេ ។ សង្ឃេ កង្ខតិ ។ បេ ។ សិក្ខា-ស កង្ខតិ ។ បេ ។ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ យោ សោ អាវុ-សោ ភិក្ខុ សព្រហ្មចារីសុ កុបិតោ ហោតិ អនត្តមនោ អាហតចិត្តោ ខីលជាតោ តស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ

គ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យា-យាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក នេះជាសេចក្តីរឹងត្អឹងនៃចិត្ត ទី ១ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត ភិក្ខុ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងធម៌ ។ បេ ។ សង្ស័យក្នុងព្រះសង្ឃ ។ បេ ។ សង្ស័យក្នុងសិក្ខា ។ បេ ។ ជាអ្នកខឹងអាក់អន់ចិត្ត មានចិត្តបង់គំនុំ មានចិត្តរឹងត្អឹងចំពោះសព្រហ្មចារី-បុគ្គលទាំងឡាយ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា ជាអ្នកខឹងអាក់អន់ចិត្ត មានចិត្តបង់គំនុំ មានចិត្តរឹងត្អឹង ចំពោះសព្រហ្មចារីបុគ្គលទាំង-ឡាយ ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងតាំងទុក

យស្ស ចិត្តំ ន នមតិ អាតប្បាយ អនុយោគាយ សាតច្ចាយ បធានាយ អយំ បញ្ចមោ ចេតោខីលោ ។ ឥមេ បញ្ច ធម្មា ហានភាគិយា ។

[២៨៧] កតមេ បញ្ច ធម្មា វិសេសភាគិយា ។ បញ្ចិន្ទ្រិយានិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ ឥមេ បញ្ច ធម្មា វិសេ-សភាគិយា ។

[២៨៨] កតមេ បញ្ច ធម្មា ទុប្បដិវិជ្ឈា ។ បញ្ច និស្សារណិយា ធាតុយោ ឥធាវុសោ ភិក្ខុនោ កាមេ មនសិករោតោ កាមេសុ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ នេក្ខម្មំ ខោ បនស្ស មនសិករោតោ នេក្ខម្មេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស ចិត្តំ

ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក នេះជាសេចក្តីរឹងត្អឹងនៃចិត្ត ទី ៥ ។ ធម៌ ៥ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[២៨៧] ធម៌ ៥ ដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ ឥន្ទ្រិយ (ធម្មជាតដែលជាធំ) ៥ គឺ ឥន្ទ្រិយគឺសទ្ធា ១ ឥន្ទ្រិយគឺវិរិយៈ ១ ឥន្ទ្រិយគឺសតិ ១ ឥន្ទ្រិយគឺសមាធិ ១ ឥន្ទ្រិយគឺបញ្ញា ១ ។ ធម៌ទាំង ៥ នេះ ជាចំណែកវិសេស ។

[២៨៨] ធម៌ ៥ ដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ និស្សារណីយធាតុ (ធាតុជាគ្រឿងរលាស់ចេញ) ៥ ម្នាលអាវុសោទាំង-ឡាយ កាលភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងកាមទាំងឡាយ តែកាលបើភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវនេក្ខម្មៈគឺបឋមជ្ឈាន ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅ ជ្រប់នៅក្នុងនេក្ខម្មៈ អសុកជ្ឈានចិត្តរបស់ភិក្ខុនោះ

២៧១

ទសុត្តរសុត្តេ ធម្មប្បភេទបញ្ចកំ

សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ កាមេហិ យេ ច កាមប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទំ អក្ខាតំ កាមានំ និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ព្យាបាទំ មនសិករោតោ ព្យាបាទេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អព្យាបាទំ ខោ បនស្ស មនសិករោតោ អព្យាបាទេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ ព្យាបាទេន យេ ច ព្យាបាទប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ ព្យាបាទស្ស និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ វិហេសំ មនសិករោតោ វិហេសាយ ចិត្តំ ន បក្ខន្ទតិ

ឈ្មោះថា មានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាស ចាកកាមទាំងឡាយ ភិក្ខុនោះឈ្មោះថា ផុតហើយចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះកាម ជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ អសុភជ្ឈាននេះ ព្រះ មានព្រះភាគត្រាស់ថា ជាគ្រឿងធ្វើសត្វឲ្យចេញចាកកាមទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវព្យាបាទ ហើយ ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅ ក្នុងព្យាបាទ តែថាកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវការមិនព្យាបាទ ចិត្ត ក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងការមិនព្យាបាទ មេត្តាឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថា មានដំណើរល្អ អប់រំល្អ តាំង ឡើងល្អ ផុតស្រឡះ ប្រាសចាកការព្យាបាទហើយ ភិក្ខុនោះឈ្មោះ ថា ផុតចាកអាសវៈទាំងឡាយជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះការព្យាបាទជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេ-ទនានោះទេ មេត្តាឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿង ធ្វើសត្វឲ្យចេញចាកការព្យាបាទ ១ ។ ម្នាលអាវុសោទាំងឡាយ មួយ ទៀត កាលភិក្ខុធ្វើទុកក្នុងចិត្ត នូវសេចក្តីបៀតបៀន ចិត្តក៏មិនលឿនទៅ

ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អវិហេសំ ខោ បនស្ស មនសិករោតោ អវិហេសាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ វិហេសាយ យេ ច វិហេសប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតប-រិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ វិហេសាយ និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ រូបេ មនសិករោតោ រូបេសុ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ អរូបំ ខោ បនស្ស មនសិករោតោ អរូបេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស តំ ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ រូបេហិ

មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនជ្រប់នៅក្នុងសេចក្តីបៀតបៀន តែថា កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនបៀតបៀន ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅ ក្នុងសេចក្តីមិនបៀតបៀន ករុណាឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថា មានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាសចាកសេចក្តីបៀតបៀនហើយ ភិក្ខុនោះ ឈ្មោះថា ផុតចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះសេចក្តីបៀតបៀនជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ ករុណាឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងធ្វើសត្វឲ្យចេញចាកការបៀតបៀន ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវរូបទាំងឡាយហើយ ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនជ្រប់នៅក្នុងរូបទាំងឡាយ តែកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្ត នូវរបស់គ្មានរូប ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងរបស់ដែលគ្មានរូប អរូបជ្ឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថា មានដំណើរល្អ អប់-រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាសចាករូបទាំងឡាយហើយ

២៧៣

ទសុត្តរសុត្តេ ធម្មប្បភេទបញ្ចកំ

យេ ច រូបប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ រូបានំ និស្សរណំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ សក្កាយំ មនសិករោតោ សក្កាយេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ សក្កាយនិរោធំ ខោ បនស្ស មនសិករោតោ សក្កាយនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ តស្ស ចិត្តំ សុគតំ សុភាវិតំ សុវុដ្ឋិតំ សុវិមុត្តំ វិសំយុត្តំ សក្កាយេន យេ ច សក្កាយប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មុត្តោ សោ តេហិ ន សោ តំ វេទនំ វេទេតិ ឥទមក្ខាតំ សក្កាយស្ស និស្សរណំ ។ ឥមេ បញ្ច ធម្មា ទុប្បដិវិជ្ឈា ។

ភិក្ខុនោះ ឈ្មោះថា ផុតចាកអាសវៈទាំងឡាយជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះរូបជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ អរូបជ្ឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងញុំាងសត្វឲ្យចេញចាករូបទាំងឡាយ ១ ។ ម្នាលអាវុសោទាំងឡាយមួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវកាយរបស់ខ្លួន ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនជ្រប់នៅក្នុងកាយរបស់ខ្លួន តែកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវការរំលត់នៃកាយរបស់ខ្លួន ចិត្តក៏លឿនទៅ ជ្រះ-ថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងសេចក្តីរំលត់នៃកាយរបស់ខ្លួន អរហត្តផលសមាបត្តិចិត្តរបស់ភិក្ខុនោះឈ្មោះថា មានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាសចាកកាយរបស់ខ្លួនហើយ ភិក្ខុនោះឈ្មោះថា ផុតចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះកាយរបស់ខ្លួនជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ អរហត្តផលសមាបត្តិចិត្តនេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងញុំាងសត្វឲ្យចេញចាកកាយជារបស់ខ្លួន ១ ។ ធម៌ទាំង ៥ នេះ ត្រាស់ដឹងបានដោយក្រ ។

[២៨៩] កតមេ បញ្ច ធម្មា ឧប្បាទេតព្វា ។ បញ្ចញាណិកោ សម្មាសមាធិ អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ អាយតឹ ច សុខវិបាកោតិ បច្ចត្តំយេវ ញាណំ ឧប្បជ្ជតិ ។ អយំ សមាធិ អរិយោ និរាមិសោតិ បច្ចត្តំយេវ ញាណំ ឧប្បជ្ជតិ ។ អយំ សមាធិ អកាបុរិសសេវិតោតិ បច្ចត្តំយេវ ញាណំ ឧប្បជ្ជតិ ។ អយំ សមាធិ សន្តោ បណីតោ បដិប្បស្សទ្ធិលទ្ធោ ឯកោទិភាវាធិគតោ ន ច សសង្ខារំ និគ្គយ្ហ វារិតវតោតិ បច្ចត្តំយេវ ញាណំ ឧប្បជ្ជតិ ។ សោ ខោ បនាហំ ឥមំ សមាធឹ សតោ ច សមាបជ្ជាមិ សតោ ឧដ្ឋហាមីតិ បច្ចត្តំយេវ ញាណំ ឧប្បជ្ជតិ ។ ឥមេ បញ្ច ធម្មា ឧប្បាទេតព្វា ។

[២៩០] កតមេ បញ្ច ធម្មា អភិញ្ញេយ្យា ។ បញ្ច វិមុត្តាយតនានិ ឥធាវុសោ ភិក្ខុនោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ[១] សព្រហ្មចារី

១ ឱ. ម. គរុដ្ឋានិកោ ។

[២៨៩] ធម៌ ៥ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ការតាំងចិត្តត្រូវប្រកបដោយប្រាជ្ញា ៥ គឺ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះ ជាសុខក្នុងបច្ចុប្បន្ន និងឲ្យផលជាសុខ តទៅមុខ ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះជាធម៌ប្រសើរ ឥតមានអាមិសៈឡើយ ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះមានតែបុរសល្អ[១] ទើបសេពគប់បាន ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះរម្ងាប់ដ៏ឧត្តម បាននូវសេចក្តីស្ងប់ស្ងាត់ ដល់នូវភាពជាធម៌មានអារម្មណ៍តែមួយ ទាំងជាគុណហាមឃាត់ សង្កត់សង្កិនធម៌ដែលប្រកបដោយសង្ខារ ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា អាត្មាអញនោះឯង ជាអ្នកមានស្មារតីចូលកាន់សមាធិនេះ ទាំងជាអ្នកមានស្មារតីចេញចាកសមាធិនេះ ១ ។ ធម៌ ៥ នេះ គួរឲ្យកើតឡើង ។

[២៩០] ធម៌ ៥ គួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ វិមុត្តាយតនៈ (ហេតុជាគ្រឿងរួចស្រឡះ) ៥ ម្នាលអាវុសោទាំងឡាយ គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយក្នុងសាសនានេះ គួរជាទីគោរព តែងសំដែងធម៌ដល់ភិក្ខុ

---

១ សំដៅយកមហាបុរសមានព្រះពុទ្ធជាដើម អដ្ឋកថា ។

យថា យថា អាវុសោ ភិក្ខុនោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ[១] សព្រហ្មចារី តថា តថា ភិក្ខុ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ បឋមំ វិមុត្តាយតនំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ន ហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ យថា យថា អាវុសោ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំវេទិនោ

១ ឱ. ម. គរុដ្ឋានិកោ ។

## ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំ ៗ

ម្នាលអាវុសោទាំងឡាយ គ្រូឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព បានសំដែងធម៌ដល់ភិក្ខុយ៉ាងណា ៗ ភិក្ខុ (នោះ) ជាអ្នកបានដឹងច្បាស់នូវអត្ថផង បានដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះ ៗ កាលបើភិក្ខុនោះដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ បាមោជ្ជៈ គឺសេចក្ដីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្ដីត្រេកអរទន់ កើតឡើងហើយ បីតិ គឺសេចក្ដីឆ្អែតចិត្ត ក៏កើតឡើង កាលលោកមានសេចក្ដីឆ្អែតចិត្តកើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាម-កាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្ដីសុខ កាលលោកមានសេចក្ដីសុខហើយ ចិត្តក៏តម្កល់នៅនឹង នេះជា វិមុត្តាយតនៈ ទី ១ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត គ្រូឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព មិនបានសំដែងធម៌ដល់ភិក្ខុសោះទេ តែលោកបានសំដែងធម៌ ដល់ជនទាំងឡាយដទៃដោយពិស្ដារ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ម្នាលអាវុសោទាំងឡាយ ភិក្ខុសំដែងធម៌ដល់ជនទាំងឡាយដទៃដោយពិស្ដារ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក យ៉ាងណា ៗ ភិក្ខុនោះ ជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះ ៗ កាលលោកបានដឹងច្បាស់នូវអត្ថ

ធម្មប្បដិសំវេទិនោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ ទុតិយំ វិមុត្តាយតនំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ន ហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី ន ហេវ ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ យថា យថា អាវុសោ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ

ដឹងច្បាស់នូវធម៌ហើយ សេចក្តីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់កើតហើយ សេចក្តីឆ្អែតចិត្តក៏ស្ងប់រម្ងាប់ កាលលោកមានសេចក្តីឆ្អែតចិត្តកើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្តីសុខ លុះលោកមានសេចក្តី-សុខហើយ ចិត្តក៏តម្កល់នៅនឹង នេះជាវិមុត្តាយតនៈ ទី ២ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត គ្រូឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព មិនបានសំដែងធម៌ដល់ភិក្ខុ ទាំងមិនបានសំដែងធម៌ដល់ជនទាំង-ឡាយដទៃដោយពិស្តារ តាមដែលស្តាប់មក តាមដែលបានរៀនមក លោកគ្រាន់តែសូត្រធម៌ដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ម្នាលអាវុសោទាំងឡាយ ភិក្ខុបានសូត្រធម៌ដោយពិស្តារតាមដែលបានស្តាប់មក ដែលបានរៀនមកយ៉ាងណា ៗ ភិក្ខុនោះជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះយ៉ាងនោះ ៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ សេចក្តីត្រេកអរទន់កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់ កើតឡើងហើយ សេចក្តីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្តីឆ្អែតចិត្ត កើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្តីសុខ លុះលោកមានសេចក្តីសុខហើយ ចិត្តក៏តម្កល់

សមាធិយតិ ឥទំ តតិយំ វិមុត្តាយតនំ ។ បុន ច-
បរំ អាវុសោ ភិក្ខុនោ ន ហេវ ខោ សត្ថា ធម្មំ
ទេសេតិ អញ្ញតរោ វា គរុដ្ឋានិយោ សព្រហ្មចារី
នាបិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ
ទេសេតិ នាបិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថា-
រេន សជ្ឈាយំ ករោតិ អបិច ខោ យថាសុតំ
យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ
មនសានុបេក្ខតិ យថា យថា អាវុសោ ភិក្ខុ យ-
ថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ
អនុវិចារេតិ មនសានុបេក្ខតិ តថា តថា សោ តស្មឹ
ធម្មេ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី
ច តស្ស អត្ថប្បដិសំវេទិនោ ធម្មប្បដិសំវេទិនោ បា-
មោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិម-
នស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ

ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំ ៗ

នៅនឹង នេះ ជាវិមុត្តាយតនៈ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព មិនបានសំដែងធម៌ដល់ភិក្ខុ មិនបានសំដែងធម៌ដល់ជនទាំងឡាយដទៃដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ទាំងមិនបានសូត្រធម៌ដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមកឡើយ លោកគ្រាន់តែត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ពិនិត្យរឿយ ៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ពិនិត្យរឿយ ៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក យ៉ាងណា ៗ ភិក្ខុនោះ ជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផងក្នុងធម៌នោះ យ៉ាងនោះ ៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ សេចក្តីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់កើតឡើងហើយ សេចក្តីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្តីឆ្អែតចិត្ត កើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយ ស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្តីសុខ

សុខិនោ ចិត្តំ សមាធិយតិ ឥទំ ចតុត្ថំ វិមុត្តា-
យតនំ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ន
ហេវ ខោ សត្ថា ធម្មំ ទេសេតិ អញ្ញតរោ វា គ-
រុដ្ឋានិយោ សព្រហ្មចារី នាបិ យថាសុតំ យថាបរិ-
យត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ នាបិ យ-
ថាសុតំ យថាបរិយត្តំ វិត្ថារេន សជ្ឈាយំ ករោតិ
នាបិ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អ-
នុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ អបិច ខ្វស្ស
អញ្ញតរំ សមាធិនិមិត្តំ សុគ្គហិតំ ហោតិ សុមនសិ-
កតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញាយ យថា យថា
អាវុសោ ភិក្ខុនោ អញ្ញតរំ សមាធិនិមិត្តំ សុគ្គហិតំ
ហោតិ សុមនសិកតំ សូបធារិតំ សុប្បដិវិទ្ធំ បញ្ញា-
យ តថា តថា សោ តស្មឹ ធម្មេ អត្ថប្បដិសំវេទី
ច ហោតិ ធម្មប្បដិសំវេទី ច តស្ស អត្ថប្បដិសំ-
វេទិនោ ធម្មប្បដិសំវេទិនោ បាមោជ្ជំ ជាយតិ បមុទិតស្ស

លុះលោកមានសេចក្តីសុខហើយ ចិត្តក៏តម្កល់នៅនឹង នេះជាវិមុត្តាយតនៈទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយគួរជាទីគោរព មិនបានសំដែងធម៌ដល់ភិក្ខុផង មិនបានសំដែងធម៌ដល់ជនទាំងឡាយដទៃផង ដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមក មិនសូត្រធម៌ដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមកផង ទាំងមិនបានត្រិះរិះរឿយ ៗ មិនពិចារណារឿយ ៗ មិនពិនិត្យរឿយ ៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមកផង តែលោកបានរៀនសមាធិនិមិត្តណាមួយដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចេះចាំដោយល្អ ត្រាស់ដឹងដោយល្អ ដោយប្រាជ្ញា ម្នាលអាវុសោទាំងឡាយ សមាធិនិមិត្តណាមួយ ដែលភិក្ខុរៀនដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចេះចាំដោយល្អ ត្រាស់ដឹងដោយល្អ ដោយប្រាជ្ញា យ៉ាងណា ៗ ភិក្ខុនោះ ជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះ ៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ សេចក្តីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់ កើតឡើងហើយ

២៧៩



បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ឥទំ បញ្ចមំ វិមុត្តាយតនំ ។ ឥមេ បញ្ច ធម្មា អភិញ្ញេយ្យា ។

[២៩១] កតមេ បញ្ច ធម្មា សច្ឆិកាតព្វា ។ បញ្ច ធម្មក្ខន្ធា សីលក្ខន្ធោ សមាធិក្ខន្ធោ បញ្ញាក្ខន្ធោ វិមុត្តិក្ខន្ធោ វិមុត្តិញាណទស្សនក្ខន្ធោ ។ ឥមេ បញ្ច ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ បញ្ញាស ធម្មា ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

[២៩២] ឆ ធម្មា ពហុការា ឆ ធម្មា ភាវេតព្វា ឆ ធម្មា បរិញ្ញេយ្យា ឆ ធម្មា បហាតព្វា ឆ ធម្មា ហានភាគិយា ឆ ធម្មា វិសេសភាគិយា ឆ ធម្មា ទុប្បដិវិជ្ឈា ឆ ធម្មា ឧប្បាទេតព្វា ឆ ធម្មា អភិញ្ញេយ្យា ឆ ធម្មា សច្ឆិកាតព្វា ។

សេចក្ដីឆ្អែតចិត្ត ក៏កើតឡើង កាលលោក មានសេចក្ដីឆ្អែតចិត្តកើតឡើងហើយ នាមកាយ ក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្ដីសុខ លុះលោកមានសេចក្ដីសុខហើយ ចិត្តក៏តាំងនៅមាំ នេះជា វិមុត្តាយតនៈ ទី ៥ ។ ធម៌ទាំង ៥ នេះ គួរដឹងច្បាស់ ។

[២៩១] ធម៌ ៥ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្ដេចខ្លះ ។ ធម្មក្ខន្ធ ៥ គឺ សីលក្ខន្ធ ១ សមាធិក្ខន្ធ ១ បញ្ញាខន្ធ ១ វិមុត្តិក្ខន្ធ ១ វិមុត្តិញ្ញាណ-ទស្សនក្ខន្ធ ១ ។ ធម៌ទាំង ៥ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៥០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀង មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងដោយប្រពៃហើយ ដោយប្រការដូច្នេះ ។

[២៩២] ធម៌ ៦ មានឧបការៈច្រើន ធម៌ ៦ គួរចម្រើន ធម៌ ៦ គួរកំណត់ដឹង ធម៌ ៦ គួរលះបង់ ធម៌ ៦ ជាចំណែកនៃសេចក្ដីវិនាស ធម៌ ៦ ជាចំណែកវិសេស ធម៌ ៦ ត្រាស់ដឹងបានដោយក្រ ធម៌ ៦ គួរឲ្យកើតឡើង ធម៌ ៦ គួរធ្វើឲ្យជាក់ច្បាស់ ។

[២៩៣] កតមេ ឆ ធម្មា ពហុការា ។ ឆ សារាណីយា ធម្មា ឥធាវុសោ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយំ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុនោ មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយំបិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុនោ មេត្តំ មនោកម្មំ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិយាបន្នមត្តំបិ

[២៩៣] ធម៌ ៦ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ សារាណីយ-ធម៌ (ធម៌គួររលឹក) ៦ ប្រការ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ តែងតម្កល់ចំពោះនូវកាយកម្ម (អំពើដែលធ្វើដោយកាយ) ប្រកបដោយមេត្តា ក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងចំពោះមុខ ទាំងកំបាំងមុខ នេះឯងជាធម៌គួររលឹកគ្នា ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រម-ព្រៀង ដើម្បីឯកីភាព គឺមូលមិត្រគ្នា ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុតែងតម្កល់ចំពោះនូវវចីកម្ម (អំពើដែលត្រូវធ្វើដោយសំដី) ប្រកបដោយមេត្តា ក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងចំពោះមុខ ទាំងកំបាំងមុខ ធម៌នេះឯងជាធម៌គួររលឹករកគ្នា ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុតែងតម្កល់ចំពោះនូវមនោកម្ម (អំពើដែលត្រូវធ្វើដោយចិត្ត) ប្រកបដោយមេត្តា ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត លាភណាមួយ កើតឡើងដោយធម៌ បានមកដោយធម៌ ដោយហោចទៅសូម្បីតែអាហារក្នុងបាត្រ

២៨១

ទសុត្តរសុត្តេ ធម្មប្បភេទច្ឆក្កំ

តថារូបេហិ លាភេហិ អប្បដិវិភត្តភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី អយំបិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុបសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេសុ សីលេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយំបិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អាវុសោ

ភិក្ខុបរិភោគដោយមិនបានចែកមុខអាមិសៈ មុខបុគ្គល[១] ដោយលាភមានសភាពដូច្នោះ គឺជាអ្នកបរិភោគជាសាធារណៈ ដោយសព្រហ្មចារីបុគ្គលទាំងឡាយ ដែលជាអ្នកមានសីល នេះឯងជាធម៌គួររលឹករកគ្នា ជាធម៌ធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត សីលណាដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលអ្នកជា ពួកវិញ្ញូជនតែងសរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិមិនបានស្ទាបអង្អែល ប្រព្រឹត្តទៅដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលដ៏ស្មើដោយសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងសីលទាំងឡាយមានសភាពដូច្នោះ ក្នុងទីចំពោះមុខនិងទីកំបាំងមុខ នេះឯងជាធម៌គួររលឹកគ្នា ជាធម៌ធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្ដីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត

១ មើល នយលក្ខណៈ ក្នុងសង្គីតិសូត្រខាងដើម ។

ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយំបិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកី-ភាវាយ សំវត្តតិ ។ ឥមេ ឆ ធម្មា ពហុការា ។

[២៩៤] កតមេ ឆ ធម្មា ភាវេតព្វា ។ ឆ អនុស្សតិដ្ឋានានិ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃា-នុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ។ ឥមេ ឆ ធម្មា ភាវេតព្វា ។

ទិដ្ឋិណាដ៏ប្រសើរ គឺសម្មាទិដ្ឋិ ជាគ្រឿងនាំសត្វចេញចាកភព តែង ស្រោចស្រង់សត្វដែលប្រព្រឹត្តតាមទិដ្ឋិនោះ ដើម្បីឲ្យអស់ទៅនៃទុក្ខដោយ ប្រពៃ ភិក្ខុជាអ្នកមានទិដ្ឋិដ៏ស្មើដោយសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទិដ្ឋិ មានសភាពដូច្នោះ ទាំងក្នុងទីចំពោះមុខនិងទីកំបាំង នេះឯងជាធម៌គួររលឹក រកគ្នា ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បី សង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បី ឯកីភាព ១ ។ ធម៌ទាំង ៦ នេះ មានឧបការៈច្រើន ។

[២៩៤] ធម៌ ៦ គួរចម្រើន តើដូចម្តេចខ្លះ ។ អនុស្សតិដ្ឋានៈ (ហេតុ ជាទីតាំងនៃសេចក្តីរលឹករឿយ ៗ) ៦ យ៉ាង សេចក្តីរលឹកនូវព្រះពុទ្ធ ១ រលឹកនូវព្រះធម៌មួយ រលឹកនូវព្រះសង្ឃ ១ រលឹកនូវគុណនៃសីល ១ រលឹកនូវទានដែលបានបរិច្ចាគហើយ ១ រលឹកដល់ធម៌ទេវតា[១] ១ ។ ធម៌ទាំង ៦ នេះ គួរចម្រើន ។

---

១ គឺរលឹកចំពោះគុណធមិទាំង ៥ ដែលនាំបុគ្គលឲ្យសម្រេចនូវភាពជាទេវតា ។ ឯធមិទាំង ៥ នោះគឺ សទ្ធា ១ សីល ១ សុតៈ ១ ចាគៈ ១ បញ្ញា ១ ព្រោះទេព្តាដែលទៅកើតបានសួគ៌ ក៏ដោយអំណាចធមិទាំង ៥ នេះឯង ។ វិសុទ្ធិមគ្គ ត្រង់ឆអនុស្សតិនិទ្ទេស ។

ទសុត្តរសុត្តេ ធម្មប្បភេទច្ឆក្កំ

[២៩៥] កតមេ ឆ ធម្មា បរិញ្ញេយ្យា ។ ឆ អជ្ឈត្តិកានិ អាយតនានិ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ។ ឥមេ ឆ ធម្មា បរិញ្ញេយ្យា ។

[២៩៦] កតមេ ឆ ធម្មា បហាតព្វា ។ ឆ តណ្ហាកាយា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ឥមេ ឆ ធម្មា បហាតព្វា ។

[២៩៧] កតមេ ឆ ធម្មា ហានភាគិយា ។ ឆ អគារវា ឥធាវុសោ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយ អគារវោ វិហរតិ អប្បតិស្សោ អប្បមាទេ អគារវោ វិហរតិ អប្បតិស្សោ បដិសន្ថារេ អគារវោ វិហរតិ អប្បតិស្សោ ។ ឥមេ ឆ ធម្មា ហានភាគិយា ។

ទសុត្តរសូត្រ ប្រភេទនៃធមិប្រាំមួយ ៗ

[២៩៥] ធម៌ ៦ គួរកំណត់ដឹង តើដូចម្តេចខ្លះ ។ អាយតនៈខាង ក្នុង ៦ គឺភ្នែកជាអាយតនៈ ១ ត្រចៀកជាអាយតនៈ ១ ច្រមុះជាអាយតនៈ ១ អណ្តាតជាអាយតនៈ ១ កាយជាអាយតនៈ ១ ចិត្តជាអាយតនៈ ១ ។ ធម៌ ទាំង ៦ នេះ គួរកំណត់ដឹង ។

[២៩៦] ធម៌ ៦ គួរលះបង់ តើដូចម្តេចខ្លះ ។ ពួកតណ្ហា ៦ គឺ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វ-តណ្ហា ១ ធម្មតណ្ហា ១ ។ ធម៌ទាំង ៦ នេះ គួរលះបង់ ។

[២៩៧] ធម៌ ៦ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ សេចក្តីមិនគោរព ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនា នេះ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះព្រះសាស្តា ១ ជាអ្នកមិនគោ-រព មិនកោតក្រែងចំពោះព្រះធម៌ ១ ជាអ្នកមិនគោរព មិនកោតក្រែង ចំពោះព្រះសង្ឃ ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះសិក្ខា ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះអប្បមាទធម៌ ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះបដិសន្ថារៈ ១ ។ ធម៌ទាំង ៦ នេះ ជាចំណែក នៃសេចក្តីវិនាស ។

[២៩៨] កតមេ ឆ ធម្មា វិសេសភាគិយា ។ ឆ គារវា ឥធាវុសោ ភិក្ខុ សត្ថរិ សគារវោ វិហរតិ សប្បតិស្សោ ធម្មេ សគារវោ វិហរតិ សប្បតិស្សោ ។ សង្ឃេ ។ សិក្ខាយ ។ អប្បមាទេ ។ បដិសន្ថារេ សគារវោ វិហរតិ សប្បតិស្សោ ។ ឥមេ ឆ ធម្មា វិសេសភាគិយា ។

[២៩៩] កតមេ ឆ ធម្មា ទុប្បដិវិជ្ឈា ។ ឆ និស្សារណីយា ធាតុយោ ឥធាវុសោ ភិក្ខុ ឯវំ វទេយ្យ មេត្តា ហិ ខោ មេ[១] ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ ព្យាបាទោ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា

១ ម. មេ អាវុសោ ។

[២៩៨] ធម៌ ៦ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ សេចក្តីគោរព ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីគោរព កោតក្រែង ចំពោះព្រះសាស្តា ១ ជាអ្នកមានសេចក្តីគោរព កោតក្រែងចំពោះព្រះធម៌ ១ ។ ចំពោះព្រះសង្ឃ ១ ។ ចំពោះសិក្ខា ១ ។ ចំពោះអប្បមាទធម៌ ១ ។ មានសេចក្តីគោរពកោតក្រែងចំពោះបដិសន្ថារៈ ១ ។ ធម៌ទាំង ៦ នេះ ជាចំណែកវិសេស ។

[២៩៩] ធម៌ ៦ ត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ និស្សារណីយធាតុ ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមេត្តា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ ព្យាបាទក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ (អ្នកផង) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគ

ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ មេត្តាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស ព្យាចាទោ ចិត្តំ បរិយាទាយ បស្សតីតិ នេតំ ហានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ ព្យាចាទស្ស យទិទំ មេត្តា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ ករុណា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ វិហេសា ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ

មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយមេត្តា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ ព្យាបាទក៏គង់នៅគ្របសង្កត់ចិត្តរបស់គេបានដូច្នេះ នេះមិនមែនជាហេតុជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេ-តោវិមុត្តិដែលប្រកបដោយមេត្តាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយករុណា ខ្ញុំបានអប់រំបន្ទុំទុកឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ វិហេសា (សេចក្តីបៀតបៀន) ក៏គង់តែគ្របសង្កត់នូវចិត្តរបស់ខ្ញុំបាន ។ (អ្នកផង) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះ-ភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគ មិនល្អទេ តាមដែល

ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ ករុណាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិ-តាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស វិហេសា ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ វិហេសាយ យទិទំ ករុណា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ មុទិតា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ អរតិ ចិត្តំ បរិយា-ទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ

ពិតនោះ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិ ប្រកបដោយករុណា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ វិហេសា ក៏គង់តែគ្របសង្កត់ចិត្តរបស់គេបានដូច្នេះ នេះ មិនមែនជាហេតុជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេតោវិមុត្តិ ដែលប្រកបដោយករុណាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវវិហេសា ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមុទិតា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិ (សេចក្តីមិនត្រេកអរ) ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ (អ្នកផង) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ

ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ មុទិតាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស អរតិ ចិត្តំ បរិយា-ទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណាញ្ហេតំ អាវុសោ អរតិយា យទិទំ មុទិតា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ ឧបេក្ខា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យា-នីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ រាគោ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ

ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិ ប្រកបដោយមុទិតា ដែលគេបានអប់រំបន្តុំឲ្យច្រើនហើយ បានធ្វើឲ្យ ដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បាន ប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិក៏គង់តែគ្របសង្កត់ ចិត្តរបស់គេបានដូច្នេះ នេះ មិនមែនជាហេតុជាទីតាំងឡើយ ម្នាល អាវុសោ តាមដែលពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយមុទិតាហ្នឹង ឯង ជាធម៌សម្រាប់រលាស់ចោលនូវអរតិ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រ-កបដោយឧបេក្ខា ខ្ញុំបានអប់រំបន្តុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ រាគៈក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ (អ្នកផង) គួរនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ

ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ ឧបេក្ខាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស រាគោ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ រាគស្ស យទិទំ ឧបេក្ខា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ អនិមិត្តា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ និមិត្តានុសារិវិញ្ញាណំ ហោតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ

ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោ-វិមុត្តិប្រកបដោយឧបេក្ខា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ រាគៈក៏គង់គ្របសង្កត់ចិត្តរបស់គេបានដូច្នេះ នេះ មិនមែនជាហេតុជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនោះ គឺចេតោវិមុត្តិ ដែលប្រកបដោយឧបេក្ខាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវរាគៈ ។ ម្នាលអាវុសោទាំងឡាយមួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយអនិមិត្ត ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ និមិត្តានុសារិវិញ្ញាណ គឺវិញ្ញាណដែលរលឹកឃើញនូវនិមិត្តរបស់ខ្លួន នៅតែមាន ។ (អ្នកផង) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការ

២៨៩



ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ អនិមិត្តាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស និមិត្តានុសារិវិញ្ញាណំ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ សព្វនិមិត្តានំ យទិទំ អនិមិត្តា ចេតោវិមុត្តិ ។ ឥធ បនាវុសោ ភិក្ខុ ឯវំ វទេយ្យ អស្មីតិ ខោ មេ វិគតេ អយមហមស្មីតិ ន សមនុបស្សាមិ អថ ច បន មេ វិចិកិច្ឆាកថង្កថាសល្លំ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន

និយាយបង្កាច់ព្រះមានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយអនិមិត្ត ដែលគេបានអប់រំបន្ទុំឲ្យច្រើន ធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ បើទុកជាដូច្នោះក៏ដោយ និមិត្តានុសារិវិញ្ញាណរបស់គេ គង់តែនៅមានដូច្នេះនេះ មិនមែនជាហេតុជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ចេតោវិមុត្តិ ដែលប្រកបដោយអនិមិត្តហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវនិមិត្តទាំងអស់ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសា-សនានេះ ពោលយ៉ាងនេះថា អស្មិមានះរបស់ខ្ញុំនេះ ទៅប្រាសអស់ហើយ ខ្ញុំពិចារណាមិនឃើញថា អាត្មាអញមានអស្មិមានះដូច្នេះឡើយ តែបើទុកជាដូច្នោះ កូនសរគឺសេចក្តីសង្ស័យនិងសេចក្តីងឿងឆ្ងល់ ក៏គង់គ្រប សង្កត់ចិត្តរបស់ខ្ញុំបាន ។ (អ្នកផង) គប្បីនិយាយឃាត់ភិក្ខុនោះយ៉ាងនេះថា លោកកុំនិយាយយ៉ាងនេះ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះឡើយ លោកកុំនិយាយបង្កាច់នូវព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះ

ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ អស្មីតិ វិគតេ អយមហមស្មីតិ ន[1] សមនុបស្សតោ អថ ច បនស្ស វិចិកិច្ឆាកថង្កថាសល្លំ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ វិចិកិច្ឆាកថង្កថាសល្លស្ស យទិទំ អស្មិមានសមុគ្ឃាតោ ។ ឥមេ ឆ ធម្មា ទុប្បដិវិជ្ឈា ។

[៣០០] កតមេ ឆ ធម្មា ឧប្បាទេតព្វា ។ ឆ សតតវិហារា ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ

---

[1] ម. អ ។

មានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគ មិនបាន ត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ រឿងនេះ មិនមែនជាហេតុ មិនមែនជា បច្ច័យ ត្រង់ពាក្យដែលថា អស្មិមានៈរបស់គេនេះទៅប្រាសអស់ហើយ គេពិចារណាមិនឃើញថា អាត្មាអញ មានអស្មិមានៈដូច្នេះឡើយ តែបើ ទុកជាដូច្នោះ កូនសរគឺសេចក្តីសង្ស័យនិងសេចក្តីងឿងឆ្ងល់ ក៏គង់តែគ្រប សង្កត់ចិត្តរបស់គេបានដូច្នេះ នេះ មិនមែនជាហេតុ ជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ការដកឡើងនូវអស្មិមានៈបានហ្នឹង ឯង ជាធម៌សម្រាប់រលាស់ចេញ នូវកូនសរគឺសេចក្តីសង្ស័យនិងសេចក្តី ងឿងឆ្ងល់ ។ ធម៌ទាំង ៦ នេះ ត្រាស់ដឹងបានដោយក្រ ។

[៣០០] ធម៌ទាំង ៦ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សតតវិ- ហារធម៌ (ធម៌ជាគ្រឿងនៅមិនដាច់នៃព្រះខីណាស្រព) ៦ យ៉ាង ម្នាល អាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូប ដោយភ្នែក ហើយ ជាអ្នកមិនមានសោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយ កន្តើយផង មានស្មារតីនិងប្រាជ្ញាផង ។ បានស្តាប់សំឡេង ដោយ ត្រចៀក ។ បេ ។ បានហិតក្លិន ដោយច្រមុះ ។ បេ ។ បានទទួល រស ដោយអណ្តាត ។ បេ ។ បានពាល់ត្រូវ ផោដ្ឋព្វៈ ដោយកាយ ។ បេ ។ បានដឹងច្បាស់ នូវធម្មារម្មណ៍ ដោយចិត្ត ហើយជាអ្នកមិនមានសោមនស្ស

ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្ប-
ជានោ ។ ឥមេ ឆ ធម្មា ឧប្បាទេតព្វា ។

[៣០១] កតមេ ឆ ធម្មា អភិញ្ញេយ្យា ។ ឆ
អនុត្តរិយានិ ទស្សនានុត្តរិយំ សវណានុត្តរិយំ លាភា-
នុត្តរិយំ សិក្ខានុត្តរិយំ ចារិចរិយានុត្តរិយំ អនុស្សតា-
នុត្តរិយំ ។ ឥមេ ឆ ធម្មា អភិញ្ញេយ្យា ។

[៣០២] កតមេ ឆ ធម្មា សច្ឆិកាតព្វា ។ ឆ អភិញ្ញា
ឥធាវុសោ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ
ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ
ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោ-
បព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ
បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ
ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយា
អាកាសេបិ បល្លង្កេន ចង្កមតិ សេយ្យថាបិ បក្ខី
សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហា-
នុភាវេ បាណិនា បរាមសតិ បរិមជ្ជតិ យាវ ព្រហ្មលោ-

មិនមានទោមនស្ស ជាអ្នកព្រងើយកន្តើយផង មានស្មារតីនិងប្រាជ្ញាផង ។ ធម៌ទាំង ៦ នេះ គួរឲ្យកើតឡើង ។

[៣០១] ធម៌ ៦ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អនុត្តរិយៈ (ធម្មជាតប្រសើរ) ៦ គឺការឃើញប្រសើរ ១ ការស្តាប់ប្រសើរ ១ ការបានប្រសើរ ១ ការសិក្សាប្រសើរ ១ ការបម្រើប្រសើរ ១ ការរលឹកប្រសើរ ១ ។ ធម៌ទាំង ៦ នេះ គួរដឹងច្បាស់ ។

[៣០២] ធម៌ ៦ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ អភិញ្ញា ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សំដែងឫទ្ធិបានច្រើនប្រការ គឺមនុស្សតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ឬមនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សតែម្នាក់វិញក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងទីខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ធ្វើនូវការមុជងើបក្នុងផែនដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹកមិនបែកធ្លាយទឹក ដូចជាដើរទៅលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ដូចជាសត្វសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់ (មណ្ឌល) ព្រះចន្ទ្រនិងព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាង

កាបិ កាយេន វសំ វត្តេតិ ។ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច ជានាតិ[១] សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ

១ ឱ. ម. បជានាតិ ។

នេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោកក៏បាន ១ ។ ភិក្ខុមានត្រចៀកទិព្វដ៏បរិសុទ្ធកន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វនិងសំឡេងមនុស្សក្នុងទីឆ្ងាយក៏បាន ទីជិតក៏បាន ១ ។ ភិក្ខុអាចកំណត់ដឹងចិត្ត របស់សត្វដទៃបុគ្គលដទៃដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលរួញរាក្តី ក៏ស្គាល់ថា ចិត្តរួញរា ចិត្តដែលរាយមាយក្តី ក៏ស្គាល់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈគឺរូបាវចរនិងអរូបាវចរក្តី ក៏ស្គាល់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈក្តី ក៏ស្គាល់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈគឺលោកិយចិត្តក្តី ក៏ស្គាល់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈគឺលោកុត្តរចិត្តក្តី ក៏ស្គាល់ថាចិត្តជាអនុត្តរៈ

២៩៣

ទសុត្តរសុត្តេ ធម្មប្បភេទច្ឆក្កំ

សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ
អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ
វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ
អវិមុត្តំ ចិត្តន្តិ បជានាតិ ។ អនេកវិហិតំ បុព្វេនិវាសំ
អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ
តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ
ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ
ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ
សតំបិ ជាតិយោ សហស្សំបិ ជាតិយោ សតស-
ហស្សំបិ ជាតិយោ អនេកេបិ សំវដ្តកប្បេ អនេកេបិ
វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ
ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខ-
ទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ
អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោ-
ត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី

*ចិត្តដែលតាំងនៅល្អដោយសមាធិក្តី ក៏ស្គាល់ថា ចិត្តតាំងនៅល្អដោយសមាធិ ចិត្តដែលមិនតាំងនៅល្អដោយសមាធិក្តី ក៏ស្គាល់ថា ចិត្តមិនតាំងនៅល្អដោយសមាធិ ចិត្តដែលផុតស្រឡះចាកកិលេសាសវៈក្តី ក៏ស្គាល់ថា ចិត្តផុតស្រឡះចាកកិលេសាសវៈ ចិត្តដែលមិនបានផុតស្រឡះចាកកិលេសាសវៈក្តី ក៏ស្គាល់ថា ចិត្តមិនផុតស្រឡះចាកកិលេសាសវៈ ១ ។ ភិក្ខុរលឹកជាតិដែលបានអាស្រ័យនៅមកអំពីមុន ជាអនេកជាតិ គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រលឹកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ*

ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ

មានកំណត់អាយុប៉ុណ្ណោះ អាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបមកកើតក្នុងភពនេះ (ភិក្ខុ) រលឹកតាមនូវជាតិដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសយ៉ាងនេះ ១ ។ ភិក្ខុមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានរូបល្អ មានរូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ទាំងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម (របស់ខ្លួន) ថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងនោះ លុះដល់ទម្លាយរាងកាយទៅខាងមុខអំពីសេចក្តីស្លាប់ រមែងទៅកាន់កំណើតសត្វតិរច្ឆាន ប្រេត អសុរ-កាយ និងនរកពុំខាន អើហ្ន៎ ចំណែកពួកសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ សត្វទាំងនោះ លុះទម្លាយរាងកាយទៅខាង

មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេ ទស ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ សដ្ឋី ធម្មា ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

[៣០៣] សត្ត ធម្មា ពហុការា សត្ត ធម្មា ភាវេតព្វា សត្ត ធម្មា បរិញ្ញេយ្យា សត្ត ធម្មា បហាតព្វា សត្ត ធម្មា ហានភាគិយា សត្ត ធម្មា វិសេសភាគិយា សត្ត ធម្មា ទុប្បដិវិជ្ឈា សត្ត ធម្មា ឧប្បាទេតព្វា សត្ត ធម្មា អភិញ្ញេយ្យា សត្ត ធម្មា សច្ឆិកាតព្វា ។

មុខអំពីសេចក្ដីស្លាប់ ក៏រមែងទៅកាន់សុគតិ សួគ៌ទេវលោក ។ ភិក្ខុនោះ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ជាសត្វឧត្តម មានរូបល្អ មានរូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ទាំងបានឃើញច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម (របស់ខ្លួន) ដោយប្រការដូច្នេះ ១ ។ ភិក្ខុនោះ ព្រោះធ្វើឲ្យអស់អាសវៈ ក៏បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញារបស់ខ្លួនឯង ក្នុងបច្ចុប្បន្នហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថ ១ ។ ធម៌ទាំង ៦ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៦០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគត បានត្រាស់ដឹងដោយប្រពៃហើយ ដោយប្រការដូច្នេះ ។

[៣០៣] ធម៌ ៧ មានឧបការៈច្រើន ធម៌ ៧ គួរចម្រើន ធម៌ ៧ គួរកំណត់ដឹង ធម៌ ៧ គួរលះបង់ ធម៌ ៧ ជាចំណែកខាងសេចក្ដីវិនាស ធម៌ ៧ ជាចំណែកវិសេស ធម៌ ៧ ត្រាស់ដឹងបានដោយក្រ ធម៌ ៧ គួរឲ្យកើតឡើង ធម៌ ៧ គួរដឹងច្បាស់ ធម៌ ៧ គួរធ្វើឲ្យជាក់ច្បាស់ ។

[៣០៤] កតមេ សត្ត ធម្មា ពហុការា ។ សត្ត អរិយធនានិ[១] សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ ។ ឥមេ សត្ត ធម្មា ពហុការា ។

[៣០៥] កតមេ សត្ត ធម្មា ភាវេតព្វា ។ សត្ត សម្ពោជ្ឈង្គា[២] សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ សត្ត ធម្មា ភាវេតព្វា ។

[៣០៦] កតមេ សត្ត ធម្មា បរិញ្ញេយ្យា ។ សត្ត វិញ្ញាណដ្ឋិតិយោ សន្តាវុសោ សត្តា នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា នានត្តកាយា ឯកត្តសញ្ញិនោ

១ ឱ. សត្ត ធនានិ ។ ២ ឱ. ពោជ្ឈង្គា ។ ម. សំពោជ្ឈង្គា ។

[៣០៤] ធម៌ ៧ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ អរិយទ្រព្យ ៧ គឺ សទ្ធាជាទ្រព្យ ១ សីលជាទ្រព្យ ១ ហិរិជាទ្រព្យ ១ ឱត្តប្បៈជាទ្រព្យ ១ សុតៈជាទ្រព្យ ១ ចាគៈជាទ្រព្យ ១ បញ្ញាជាទ្រព្យ ១ ។ ធម៌ទាំង ៧ នេះ មានឧបការៈច្រើន ។

[៣០៥] ធម៌ ៧ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ សម្ពោជ្ឈង្គ (អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង) ៧ គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ[១] ១ ។ ធម៌ទាំង ៧ នេះ គួរចម្រើន ។

[៣០៦] ធម៌ ៧ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ វិញ្ញាណដ្ឋិតិ ៧ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចយ៉ាងពួកមនុស្សនិងពួកទេវតាខ្លះ និងអសុរកាយពួកខ្លះ នេះជា វិញ្ញាណដ្ឋិតិ ទី ១ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា

---

១ ចូរមើល នយលក្ខណៈក្នុងមហាសតិប្បដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គផងចុះ ។

២៩៧



សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា អយំ ទុតិយា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា ឯកត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហា អយំ ចតុត្ថា វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនូបគា អយំ បញ្ចមី វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនូបគា អយំ ឆដ្ឋី វិញ្ញាណដ្ឋិតិ ។ សន្តាវុសោ សត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា អយំ សត្តមី វិញ្ញាណដ្ឋិតិ ។ ឥមេ សត្ត ធម្មា បរិញ្ញេយ្យា ។

ដូចយ៉ាងពួកព្រហ្មកាយិកទេវតា ដែលកើតក្នុងបឋមជ្ឈានភូមិ នេះជា វិញ្ញាណដ្ឋិតិ ទី ២ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មាន កាយដូចគ្នា តែមានសញ្ញាខុសគ្នា ដូចយ៉ាងពួកអាភស្សរទេវតា នេះ ជា វិញ្ញាណដ្ឋិតិ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយមាន កាយដូចគ្នា មានសញ្ញាដូចគ្នា ដូចយ៉ាងពួកសុភកិណ្ហទេវតា នេះជា វិញ្ញាណដ្ឋិតិ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយដែល កន្លងនូវរូបសញ្ញា ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុង ចិត្ត នូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយបរិកម្មថា អាកាសមិនមាន ទីបំផុតដូច្នេះ ហើយចូលដល់អាកាសានញ្ចាយតនជ្ឈាន នេះជា វិញ្ញា-ណដ្ឋិតិ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយដែលកន្លងនូវ អាកាសានញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយបរិកម្មថា វិញ្ញាណ មិនមានទីបំផុតដូច្នេះ ហើយចូលដល់វិញ្ញាណញ្ចាយតនជ្ឈាន នេះជា វិញ្ញាណដ្ឋិតិ ទី ៦ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយដែល កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយបរិកម្មថា វត្ថុតិចតួចមិនមានដូច្នេះ ហើយចូលដល់អាកិញ្ចញ្ញាយតនជ្ឈាន នេះជា វិញ្ញាណដ្ឋិតិ ទី ៧ ។ ធម៌ទាំង ៧ នេះ គួរកំណត់ដឹង ។

[៣០៧] កតមេ សត្ត ធម្មា បហាតព្វា ។ សត្ត អនុសយា[១] កាមរាគានុសយោ បដិឃានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ។ ឥមេ សត្ត ធម្មា បហាតព្វា ។

[៣០៨] កតមេ សត្ត ធម្មា ហានភាគិយា ។ សត្ត អស្សទ្ធម្មា ឥធាវុសោ ភិក្ខុ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ ហោតិ ។ ឥមេ សត្ត ធម្មា ហានភាគិយា ។

[៣០៩] កតមេ សត្ត ធម្មា វិសេសភាគិយា ។ សត្ត សទ្ធម្មា ឥធាវុសោ ភិក្ខុ សទ្ធោ ហោតិ ហិរិកោ ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ ឧបដ្ឋិតស្សតិ ហោតិ បញ្ញវា ហោតិ ។ ឥមេ សត្ត ធម្មា វិសេសភាគិយា ។

---

១ ឱ. សត្តានុសយា ។

[៣០៧] ធម៌ ៧ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ អនុស័យ[១] (កិលេសជាគ្រឿងដេកត្រាំក្នុងសន្តាន) ៧ គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ មានានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ។ ធម៌ទាំង ៧ នេះ គួរលះបង់ ។

[៣០៨] ធម៌ ៧ ជាចំណែកខាងសេចក្តីវិនាស តើដូចម្តេចខ្លះ ។ អសទ្ធម្ម (ធម៌របស់អសប្បុរស) ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្មានសទ្ធា ១ ជាអ្នកមិនខ្មាសបាប ១ ជាអ្នកមិនខ្លាចបាប ១ ជាអ្នកចេះដឹងតិច ១ ជាអ្នកខ្ជិលច្រអូស ១ ជាអ្នកភ្លេចស្មារតី ១ ជាអ្នកឥតប្រាជ្ញា ១ ។ ធម៌ទាំង ៧ នេះ ជាចំណែកខាងសេចក្តីវិនាស ។

[៣០៩] ធម៌ ៧ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ សទ្ធម្ម (ធម៌របស់សប្បុរស) ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ ជាអ្នកមានសេចក្តីខ្មាសបាប ១ ជាអ្នកមានសេចក្តីខ្លាចបាប ១ ជាអ្នកចេះដឹងច្រើន ១ ជាអ្នកប្រារព្ធព្យាយាម ១ ជាអ្នកមានស្មារតីតម្កល់ខ្ជាប់ ១ ជាអ្នកមានប្រាជ្ញា ១ ។ ធម៌ទាំង ៧ នេះ ជាចំណែកវិសេស ។

---

១ ចូលមើល នយលក្ខណៈក្នុងសង្គីតិសូត្រខាងដើមផងចុះ ។

ទសុត្តរសុត្តេ ធម្មប្បភេទសត្តកំ

[៣១០] កតមេ សត្ត ធម្មា ទុប្បដិវិជ្ឈា ។ សត្ត សប្បុរិសធម្មា ឥធាវុសោ ភិក្ខុ ធម្មញ្ញូ ហោតិ អត្ថញ្ញូ អត្តញ្ញូ មត្តញ្ញូ កាលញ្ញូ បរិសញ្ញូ បុគ្គលបរោបរញ្ញូ ។ ឥមេ សត្ត ធម្មា ទុប្បដិវិជ្ឈា ។

[៣១១] កតមេ សត្ត ធម្មា ឧប្បាទេតព្វា ។ សត្ត សញ្ញា អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទី-នវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ ឥមេ សត្ត ធម្មា ឧប្បាទេតព្វា ។

[៣១២] កតមេ សត្ត ធម្មា អភិញ្ញេយ្យា ។ សត្ត និទ្ទសវត្ថូនិ ឥធាវុសោ ភិក្ខុ សិក្ខាសមាទានេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច សិក្ខាសមាទានេ អវិគតប្បេមោ

ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំពីរ ៗ

[៣១០] ធម៌ ៧ ដឹងបានដោយកម្រ តើដូចម្តេចខ្លះ ។ សប្បុរិសធម៌ (ធម៌របស់សប្បុរស) ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកដឹងធម៌ ១ ជាអ្នកដឹងអត្ថ ១ ជាអ្នកដឹងខ្លួន ១ ជាអ្នកដឹងប្រមាណ ១ ជាអ្នកដឹងកាល ១ ជាអ្នកដឹងបរិស័ទ ១ ជាអ្នកដឹងបុគ្គលដទៃដែលគួរសេពគប់ ១ ។ ធម៌ទាំង ៧ នេះ ដឹងបានដោយកម្រ ។

[៣១១] ធម៌ ៧ គួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សញ្ញា ៧ ប្រការ គឺ អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។ ធម៌ទាំង ៧ នេះ គួរឲ្យកើតឡើង ។

[៣១២] ធម៌ ៧ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ និទ្ទស-[១]វត្ថុ ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការសមាទាននូវសិក្ខា សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់សេចក្តីពេញចិត្ត ក្នុងការសមាទាននូវសិក្ខា ១ ជា

---

១ ហេតុនៃភិក្ខុមិនមានអាយុ ១០ ឆ្នាំ ។ តែពាក្យនេះ លោកសំដៅយកព្រះខីណាស្រព ព្រោះលោក សូម្បីបរិនិព្វានពីអាយុ ១០ ឆ្នាំ (ជាដើម) ក៏លោកលែងមានអាយុ ១០ ឆ្នាំតទៅខាងមុខ កុំថាតែ ១០ ឆ្នាំ សូម្បីតែថយចុះមក ៩ ឆ្នាំ រហូតដល់ ១ ថ្ងៃ ឬ ១ យាម ក៏មិនមាន ព្រោះលោកមិនមានចាប់បដិសន្ធិថ្មីទៀត ។ អដ្ឋកថា ។

ធម្មនិសន្តិយា តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ធម្មនិ-
សន្តិយា អវិគតប្បេមោ ឥច្ឆាវិនយេ តិព្វច្ឆន្ទោ ហោតិ
អាយតិញ្ច ឥច្ឆាវិនយេ អវិគតប្បេមោ បដិសល្លានេ
តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច បដិសល្លានេ អវិគត-
ប្បេមោ វីរិយារម្ភេ តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច វីរិ-
យារម្ភេ អវិគតប្បេមោ សតិនេបក្កេ តិព្វច្ឆន្ទោ ហោតិ
អាយតិញ្ច សតិនេបក្កេ អវិគតប្បេមោ ទិដ្ឋិប្បដិវេធេ
តិព្វច្ឆន្ទោ ហោតិ អាយតិញ្ច ទិដ្ឋិប្បដិវេធេ អវិគត-
ប្បេមោ ។ ឥមេ សត្ត ធម្មា អភិញ្ញេយ្យា ។

អ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការពិចារណានូវធម៌ សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការកម្ចាត់បង់នូវតណ្ហា គឺតណ្ហា សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការកម្ចាត់បង់នូវតណ្ហា គឺតណ្ហា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការពួនសម្ងំ សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការប្រារព្ធព្យាយាម សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការតាំងស្មារតីនិងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការតាំងស្មារតីនិងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការចាក់ធ្លុះដោយទិដ្ឋិ គឺឃើញច្បាស់នូវមគ្គ សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ធម៌ទាំង ៧ នេះ គួរដឹងច្បាស់ ។

## ទសុត្តរសុត្តេ ធម្មប្បភេទសត្តកំ

[៣១៣] កតមេ សត្ត ធម្មា សច្ឆិកាតព្វា ។ សត្ត ខីណាសវពលានិ ឥធាវុសោ ខីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ យំចាវុសោ[១] ខីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទំ[២] ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ អាវុសោ ខីណាសវស្ស ភិក្ខុនោ អង្គារកាសូបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ យំចាវុសោ ខីណាសវស្ស ភិក្ខុនោ អង្គារកាសូបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទំ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ អាវុសោ

---
១ ឱ. យម្បាវុសោ ។ ២ ឱ. ឥទម្បិ ។ ម. ឥទំបិ ។

[៣១៣] ធម៌ ៧ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ កម្លាំងរបស់ព្រះខីណាស្រព ៧ ម្នាលអាវុសោទាំងឡាយ សង្ខារទាំងពួង ដែលភិក្ខុជាព្រះខីណាស្រព ក្នុងសាសនានេះ បានឃើញថា មិនទៀង តាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃហើយ ម្នាលអាវុសោទាំងឡាយ ក៏សង្ខារទាំងពួង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញថា មិនទៀង តាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃ នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុ ជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំង នេះ ទើបប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំង-ឡាយ របស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាមទាំងឡាយមានឧបមាដូចរណ្តៅដ៏ពេញដោយរងើកភ្លើង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញតាមសេចក្តីពិត ដោយបញ្ញាដ៏ ប្រពៃហើយ ម្នាលអាវុសោទាំងឡាយ ក៏កាមទាំងឡាយមានឧបមា ដូចរណ្តៅដ៏ពេញដោយរងើកភ្លើង ដែលភិក្ខុជាព្រះខីណាស្រព បាន ឃើញតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃ នេះឯងចាត់ជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវ កម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈ ទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ

ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកពោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានិយេហិ ធម្មេហិ យំបាវុសោ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកពោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានិយេហិ ធម្មេហិ ឥទំបិ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ អាវុសោ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា យំបាវុសោ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា ឥទំបិ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ អាវុសោ ខីណាសវស្ស ភិក្ខុនោ បញ្ចិន្ទ្រិយានិ

មួយទៀត ចិត្តរបស់ភិក្ខុ ជាព្រះខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ម្នាលអាវុសោទាំងឡាយ ក៏ចិត្តរបស់ភិក្ខុជាព្រះខីណាស្រព ដែលឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រពអាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយ ថាអាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត សតិប្បដ្ឋានទាំង ៤ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ក៏សតិប្បដ្ឋានទាំង ៤ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អ នេះឯងចាត់ជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ឥន្ទ្រិយ ៥ ដែលភិក្ខុ

ភាវិតានិ ហោន្តិ សុភាវិតានិ យំចាវុសោ ខីណាសវស្ស ភិក្ខុនោ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ ឥទំបិ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ អាវុសោ ខីណាសវស្ស ភិក្ខុនោ សត្ត ពោជ្ឈង្គា ភាវិតា ហោន្តិ សុភាវិតា យំចាវុសោ ខីណាសវស្ស ភិក្ខុនោ សត្ត ពោជ្ឈង្គា ភាវិតា ហោន្តិ សុភាវិតា ឥទំបិ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ អាវុសោ ខីណាសវស្ស ភិក្ខុនោ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ យំចាវុសោ ខីណាសវស្ស ភិក្ខុនោ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ឥទំបិ

ជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ក៏ឥន្ទ្រិយ ៥ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អ នេះឯងចាត់ជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រពអា-ស្រ័យនូវកម្លាំងយ៉ាងនេះ ទើបប្ដេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ពោជ្ឈង្គទាំង ៧ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ពោជ្ឈង្គ ៧ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អ នេះឯងចាត់ជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្ដេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ក៏មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អ នេះឯងចាត់

វីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម វីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ វីណា មេ អាសវាតិ ។ ឥមេ សត្ត ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ សត្តតិ ធម្មា ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

បឋមភាណវារំ ។

[៣១៤] អដ្ឋ ធម្មា ពហុការា អដ្ឋ ធម្មា ភាវេតព្វា អដ្ឋ ធម្មា បរិញ្ញេយ្យា អដ្ឋ ធម្មា បហាតព្វា អដ្ឋ ធម្មា ហានភាគិយា អដ្ឋ ធម្មា វិសេសភាគិយា អដ្ឋ ធម្មា ទុប្បដិវិជ្ឈា អដ្ឋ ធម្មា ឧប្បាទេតព្វា អដ្ឋ ធម្មា អភិញ្ញេយ្យា អដ្ឋ ធម្មា សច្ឆិកាតព្វា ។

[៣១៥] កតមេ អដ្ឋ ធម្មា ពហុការា ។ អដ្ឋ ហេតូ អដ្ឋ បច្ចយា អាទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ ចារិបូរិយា សំវត្តន្តិ កតមេ អដ្ឋ ឥធាវុសោ ភិក្ខុ សត្ថារំ វា ឧបនិស្សាយ វិហរតិ

ជាកម្លាំង របស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញាច្បាស់ នូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ធម៌ទាំង ៧ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៧០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតបានត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

ចប់ បឋមភាណវារៈ ។

[៣១៤] ធម៌ ៨ មានឧបការៈច្រើន ធម៌ ៨ គួរចម្រើន ធម៌ ៨ គួរកំណត់ដឹង ធម៌ ៨ គួរលះបង់ ធម៌ ៨ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៨ ជាចំណែកវិសេស ធម៌ ៨ ត្រាស់ដឹងបានដោយក្រ ធម៌ ៨ គួរឲ្យកើតឡើង ធម៌ ៨ គួរដឹងច្បាស់ ធម៌ ៨ គួរធ្វើឲ្យជាក់ច្បាស់ ។

[៣១៥] ធម៌ ៨ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ ហេតុ ៨ ប្រការ បច្ច័យ ៨ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ហេតុ ៨ ប្រការ បច្ច័យ ៨ ប្រការនោះ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានចូលទៅអាស្រ័យនៅនឹងគ្រូ

៣០៤



អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ យត្ថស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ បេមញ្ច គារវោ ច អយំ បឋមោ ហេតុ បឋមោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ តំ ខោ បន សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ យត្ថស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ បេមញ្ច គារវោ ច តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខដ្ឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ អយំ ទុតិយោ ហេតុ ទុតិយោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។

ឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព បានតម្កល់ចំពោះនូវហិរិនិង ឱត្តប្បៈដ៏មានកម្លាំងផង នូវសេចក្តីស្រឡាញ់និងសេចក្តីគោរពផង ក្នុងគ្រូ ឬសព្រហ្មចារីបុគ្គល នេះជា ហេតុទី ១ បច្ច័យទី ១ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ លុះភិក្ខុនោះ ចូលទៅអាស្រ័យនៅនឹងគ្រូនោះ ឬសព្រហ្មចារីបុគ្គលណាមួយដែលគួរជាទីគោរពនោះ ហើយតម្កល់ចំពោះនូវហិរិនិងឱត្តប្បៈដ៏មានកម្លាំងផង នូវសេចក្តីស្រឡាញ់និងសេចក្តីគោរពផង ក្នុងគ្រូឬសព្រហ្មចារីបុគ្គល បានចូលទៅសាកសួរពិគ្រោះនឹងគ្រូឬសព្រហ្មចារីបុគ្គលទាំងនោះ តាមកាលដ៏គួរថា បពិត្រលោកដ៏ចម្រើន វត្ថុនេះដូចម្តេច វត្ថុនេះមានប្រយោជន៍ដូចម្តេច គ្រូឬសព្រហ្មចារីបុគ្គលដ៏មានអាយុទាំងនោះ បានបើកបង្ហាញសេចក្តីដែលកំបាំងផង បានធ្វើសេចក្តីដែលជ្រៅឲ្យរាក់ផង បានបន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយដែលគួរសង្ស័យដ៏ច្រើនផង ដល់ភិក្ខុនោះ នេះជាហេតុទី ២ បច្ច័យទី ២ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។

តំ ខោ បន ធម្មំ សុត្វា ទ្វយេន វូបកាសេន សម្បាទេតិ កាយវូបកាសេន ច ចិត្តវូបកាសេន ច អយំ តតិយោ ហេតុ តតិយោ បច្ចយោ អាទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ ចារិបូរិយា សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អយំ ចតុត្ថោ ហេតុ ចតុត្ថោ បច្ចយោ អាទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោ-ភាវាយ វេបុល្លាយ ភាវនាយ ចារិបូរិយា សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិក-ល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា

លុះភិក្ខុនោះ បានស្តាប់ធម៌នោះហើយ ក៏បានបរិបូណ៌ដោយសេចក្តីស្ងប់ស្ងាត់ពីរប្រការ គឺស្ងាត់កាយ ១ ស្ងាត់ចិត្ត ១ នេះជា ហេតុទី ៣ បច្ច័យទី ៣ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើម នៃមគ្គព្រហ្មចារ្យដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមក្នុបាតិមោក្ខសំវរសីលបរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ នេះជា ហេតុទី ៤ បច្ច័យទី ៤ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើម នៃមគ្គព្រហ្មចារ្យដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ចេះចាំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈដែលខ្លួន បានស្តាប់ហើយ ធម៌ទាំងឡាយណា ពីពោះបទដើម ពីពោះបទកណ្តាល ពីពោះបទចុង

៣០៧



សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធាតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា អយំ បញ្ចមោ ហេតុ បញ្ចមោ បច្ចយោ អាទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អយំ ឆដ្ឋោ ហេតុ ឆដ្ឋោ បច្ចយោ អាទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា

ប្រកាសនូវព្រហ្មចារ្យ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះឯង ក៏បានស្តាប់ច្រើន បានចាំទុក ចាំរត់មាត់ ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អដោយទិដ្ឋិ នេះជា ហេតុទី ៥ បច្ច័យទី ៥ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុអ្នកមានសេចក្តីព្យាយាមប្រារព្ធ ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសល ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ចុះនូវធុរៈក្នុងធម៌ទាំងឡាយជាកុសល នេះជាហេតុទី ៦ បច្ច័យទី ៦ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតីនិងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា ដ៏ខ្ពង់ខ្ពស់ នឹកឃើញនូវអំពើដែលខ្លួនធ្វើរួចយូរហើយផង នូវសំដីដែលខ្លួន និយាយរួចយូរហើយផង

អយំ សត្តមោ ហេតុ សត្តមោ បច្ចយោ អា-
ទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិ-
លាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភា-
វនាយ ចារិបូរិយា សំវត្តតិ ។ បុន ចបរំ អាវុសោ ភិក្ខុ
បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ
ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ
ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ
អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ
ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ
សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ
ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស
អត្ថង្គមោ អយំ អដ្ឋមោ ហេតុ អដ្ឋមោ បច្ចយោ អា-
ទិព្រហ្មចរិយកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលា-
ភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ
ចារិបូរិយា សំវត្តតិ ។ ឥមេ អដ្ឋ ធម្មា ពហុការា ។

នេះជា ហេតុទី ៧ បច្ច័យទី ៧ ប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកពិចារណាឃើញនូវទីកើតទីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ហេតុជាទីកើតរបស់រូបដូច្នេះ ការរលត់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ហេតុជាទីកើតរបស់វេ-ទនាដូច្នេះ ការរលត់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ហេតុជាទីកើតរបស់សញ្ញាដូច្នេះ ការរលត់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ហេតុជាទីកើតរបស់សង្ខារទាំងឡាយដូច្នេះ ការរលត់ទៅនៃសង្ខារទាំង-ឡាយដូច្នេះ វិញ្ញាណដូច្នេះ ហេតុជាទីកើតនៃវិញ្ញាណដូច្នេះ ការរលត់ទៅនៃវិញ្ញាណដូច្នេះ[១] នេះជា ហេតុទី ៨ បច្ច័យទី ៨ រមែងប្រ-ព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូ-លាយ ចម្រើន បរិបូណ៌ឡើង ។ ធម៌ទាំង ៨ នេះ មានឧបការៈច្រើន ។

---

១ តាំងពីរូបរហូតដល់វិញ្ញាណនេះចូរមើល ក្នុងសតិបដ្ឋានសូត្រមជ្ឈិមនិកាយផងចុះ នឹងមាននយលក្ខណៈ ជាសេចក្តីពិស្តារ ។

[៣១៦] កតមេ អដ្ឋ ធម្មា ភាវេតព្វា ។ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវា-យាមោ សម្មាសតិ សម្មាសមាធិ ។ ឥមេ អដ្ឋ ធម្មា ភាវេតព្វា ។

[៣១៧] កតមេ អដ្ឋ ធម្មា បរិញ្ញេយ្យា ។ អដ្ឋ លោកធម្មា លាភោ ច អលាភោ ច យសោ ច អយសោ ច និន្ទា ច បសំសា ច សុខញ្ច ទុក្ខញ្ច ។ ឥមេ អដ្ឋ ធម្មា បរិញ្ញេយ្យា ។

[៣១៨] កតមេ អដ្ឋ ធម្មា បហាតព្វា ។ អដ្ឋ មិច្ឆត្តា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ ។ ឥមេ អដ្ឋ ធម្មា បហាតព្វា ។

[៣១៩] កតមេ អដ្ឋ ធម្មា ហានភាគិយា ។ អដ្ឋ កុសីតវត្ថូនិ ឥធាវុសោ ភិក្ខុនា កម្មំ កា-តព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ

ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំបី ៗ

[៣១៦] ធម៌ ៨ ដែលគួរចម្រើន តើដូចម្ដេចខ្លះ ។ ផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ ៨ គឺ សេចក្ដីឃើញត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ និយាយត្រូវ ១ ធ្វើការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការតាំងចិត្តនឹងត្រូវ ១ ។ ធម៌ទាំង ៨ នេះ គួរចម្រើន ។

[៣១៧] ធម៌ ៨ ដែលគួរកំណត់ដឹង តើដូចម្ដេចខ្លះ ។ លោក-ធម៌ ៨ ប្រការ គឺ មានលាភ ១ ឥតលាភ ១ មានយស ១ ឥតយស ១ សេចក្ដីនិន្ទា ១ សេចក្ដីសរសើរ ១ សុខ ១ ទុក្ខ ១ ។ ធម៌ទាំង ៨ នេះ គួរកំណត់ដឹង ។

[៣១៨] ធម៌ ៨ ដែលគួរលះបង់ តើដូចម្ដេចខ្លះ ។ សភាពដែលខុស ៨ យ៉ាង គឺ សេចក្ដីឃើញខុស ១ សេចក្ដីត្រិះរិះខុស ១ ពោលពាក្យខុស ១ ធ្វើការងារខុស ១ ចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ ការរលឹកខុស ១ ការតាំងចិត្តនឹងខុស ១ ។ ធម៌ទាំង ៨ នេះគួរលះបង់ ។

[៣១៩] ធម៌ ៨ ជាចំណែកនៃសេចក្ដីវិនាស តើដូចម្ដេចខ្លះ ។ កុសី-តវត្ថុ (ហេតុនៃបុគ្គលខ្ជិល) ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវធ្វើការងារ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មា

៣១០



កាតព្វំ ភវិស្សតិ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ បឋមំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលន្តោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ ។ បេ ។ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ទុតិយំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ ខោ បន មេ គច្ឆន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ ។

អញនឹងត្រូវធ្វើការងារហ្នឹងឯង តែកាលបើអាត្មាអញធ្វើការងារទៅ កាយនឹងលំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនបានប្រារព្ធសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌[១] ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹង នូវគុណធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជា កុសីតវត្ថុទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ការងារដែលភិក្ខុធ្វើរួចហើយ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញធ្វើការងាររួចហើយ តែថាកាលដែលអាត្មាអញធ្វើការងារនុ៎ះឯង កាយក៏លំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនបានប្រារព្ធសេចក្តីព្យាយាម ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជា កុសីតវត្ថុ ទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវដើរទៅកាន់ផ្លូវ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញត្រូវដើរទៅកាន់ផ្លូវហ្នឹងឯង តែកាលបើអាត្មាអញដើរទៅកាន់ផ្លូវនុ៎ះ កាយនឹងលំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។

១ ក្នុងសង្គីតិសុត្តវណ្ណនាពន្យល់ពាក្យថា ធម៌នេះបានដល់ឈាន វិបស្សនា មគ្គ និងផល ។

សោ និបជ្ជតិ ន វិរិយំ អារភតិ ។ បេ ។ អសច្ឆិ-កាតស្ស សច្ឆិកិរិយាយ ឥទំ តតិយំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ មគ្គំ អគមាសឹ មគ្គំ ខោ បន មេ គច្ឆន្តស្ស កាយោ កិលន្តោ ហន្ទា-ហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វិរិយំ អារភតិ ។ បេ ។ អសច្ឆិកាតស្ស សច្ឆិកិរិយាយ ឥទំ ចតុត្ថំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ន លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិប្ចូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ នាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិប្ចូរឹ តស្ស មេ កាយោ កិលន្តោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វិរិយំ អារភតិ ។ បេ ។ អសច្ឆិកា-

ភិក្ខុនោះ ក៏ដេកទៅ មិនបានប្រុងប្រៀបសេចក្ដីព្យាយាម ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានដើរទៅកាន់ផ្លូវរួចហើយ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញបានដើរទៅកាន់ផ្លូវរួចហើយ តែកាលដែលអាត្មាអញដើរទៅកាន់ផ្លូវនុ៎ះឯង កាយក៏លំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនបានប្រុងប្រៀបសេចក្ដីព្យាយាម ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា កុសីតវត្ថុ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកាលដើរទៅបិណ្ឌបាតក្នុងស្រុកឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់-គ្រាន់បាន ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅបិណ្ឌ-បាតក្នុងស្រុកឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បានឡើយ កាយរបស់អាត្មាអញនោះនឿយហត់ ជាកាយមិនគួរនឹងប្រកបការងារបាន បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនផ្ដួចផ្ដើមសេចក្ដីព្យាយាម ។ បេ ។ ដើម្បីធ្វើឲ្យជាក់

តស្ស សច្ចិកិរិយាយ ឥទំ បញ្ចមំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ អលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស មេ កាយោ គរុកោ អកម្មញ្ញោ មាសាចិតំ មញ្ញេ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ ។ បេ ។ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ឆដ្ឋំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ បន មេ អយំ អប្បមត្តកោ អាពាធោ អត្ថិ កប្បោ និបជ្ជិតុំ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ។ បេ ។ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ សត្តមំ កុសីតវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា

ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា កុសីតវត្ថុ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅបិណ្ឌបាត ក្នុងស្រុក ឬនិគម ក៏បានភោជន សៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅ បិណ្ឌបាតក្នុងស្រុកឬនិគម បានភោជន សៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែត គ្រប់គ្រាន់ហើយ កាយរបស់អាត្មាអញនោះធ្ងន់ ជាកាយមិនគួរនឹងប្រកប ការងារបាន ទំនងដូចជាសណ្តែកពជមាសដែលត្រូវទឹកហើយ បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេកទៅ មិនបានផ្តួចផ្តើម សេចក្តីព្យាយាម ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួន មិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា កុសីតវត្ថុ ទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកកើតអាពាធបន្តិចបន្តួចសោះទេ ភិក្ខុនោះមាន គំនិតយ៉ាងនេះថា អាត្មាអញជាអ្នកទើបនឹងកើតអាពាធនេះ មានប្រមាណ តិចទេ តែជាអាពាធគួរនឹងសម្ងំដេក បើដូច្នោះ មានតែអាត្មាអញ ដេកសិន ។ ភិក្ខុនោះក៏ដេកទៅ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា កុសីវត្ថុ ទី ៧ ។ ម្នាល អាវុសោទាំងឡាយ មួយទៀត ភិក្ខុទើបតែនឹងបានជាសះស្បើយពីជំងឺថ្មី ៗ

តស្ស ឯវំ ហោតិ អហំ[១] គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា តស្ស មេ កាយោ ទុព្វលោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ ។ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិ-កតស្ស សច្ឆិកិរិយាយ ឥទំ អដ្ឋមំ កុសីតវត្ថុ ។ ឥមេ អដ្ឋ ធម្មា ហានភាគិយា ។

[៣៦០] កតមេ អដ្ឋ ធម្មា វិសេសភាគិយា ។ អដ្ឋ អារព្ភវត្ថូនិ ឥធាវុសោ ភិក្ខុនា កម្មំ កាតព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ កាតព្វំ ភ-វិស្សតិ កម្មំ ខោ បន មេ ករោន្តស្ស ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អា-រភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ

---

១ ម. អហំ ខោ ។

ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញបានជាសះស្បើយពីជំងឺថ្មី ៗ ហើយ ឯកាយរបស់អាត្មាអញ ក៏នៅទុព្វលភាព មិនគួរប្រកបការងារបាននៅឡើយ ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេកទៅ មិនបានប្រុងប្រៀបសេចក្តីព្យាយាម ដើម្បីបានដល់នូវគុណធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា កុសីតវត្ថុ ទី ៨ ។ ធម៌ទាំង ៨ នេះ ជាចំណែកខាងសេចក្តីវិនាស ។

[៣២០] ធម៌ ៨ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ អារព្ភវត្ថុ (ហេតុនៃការប្រារព្ធសេចក្តីព្យាយាម) ៨ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវធ្វើការងារ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវធ្វើការហ្នឹងឯង តែកាលបើអាត្មាអញ ធ្វើការងារទៅហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំង-ឡាយបានឡើយ បើដូច្នោះ មានតែអាត្មាអញនឹងតាំងផ្តើមសេចក្តីព្យា-យាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យ

អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិ-កតស្ស សច្ឆិកិរិយាយ ឥទំ បឋមំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បនាហំ ករោន្តោ នាសក្ខឹ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អន-ធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយា-យាតិ ។ បេ ។ ឥទំ ទុតិយំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ ខោ បន មេ គច្ឆន្តេន ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា

ជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏តាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ការងារ ភិក្ខុបានធ្វើរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបាន ធ្វើការងាររួចហើយ ឯអាត្មាអញកាលដែលធ្វើការងារនុ៎ះឯង មិនអាច ធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយបានឡើយ បើដូច្នោះ មានតែអាត្មាអញ តាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវ គុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ បេ ។ នេះជា អារព្ភវត្ថុទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវដើរទៅកាន់ផ្លូវ ភិក្ខុនោះមាន គំនិតយ៉ាងនេះថា ផ្លូវហ្នឹងឯង អាត្មាអញនឹងត្រូវដើរទៅ តែកាលបើ អាត្មាអញដើរទៅកាន់ផ្លូវ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយបានទេ បើដូច្នោះ មានតែអាត្មាអញតាំងផ្ដើម សេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញ មិនទាន់បានដល់

អនជិតតស្ស អជិតមាយ អសច្ឆិកាតស្ស សច្ឆិកិ-
រិយាយាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា
អនជិតតស្ស អជិតមាយ អសច្ឆិកាតស្ស សច្ឆិកិរិ-
យាយ ឥទំ តតិយំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ
ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស ឯវំ ហោតិ អហំ
ខោ មគ្គំ អគមាសឹ មគ្គំ ខោ បនាហំ គច្ឆន្តោ
ជាសក្ខឹ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ
អារភាមិ អប្បត្តស្ស បត្តិយា អនជិតតស្ស អជិតមាយ
អសច្ឆិកាតស្ស សច្ឆិកិរិយាយាតិ ។ សោ វីរិយំ អារភតិ
អប្បត្តស្ស បត្តិយា អនជិតតស្ស អជិតមាយ អសច្ឆិ-
កាតស្ស សច្ឆិកិរិយាយ ឥទំ ចតុត្ថំ អារព្ភវត្ថុ ។

ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញ មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុទៅកាន់ផ្លូវរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរទៅកាន់ផ្លូវរួចហើយ ឯអាត្មាអញ កាលដែលដើរទៅកាន់ផ្លូវនុ៎ះឯង មិនអាចធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំង-ឡាយបានឡើយ បើដូច្នោះ មានតែអាត្មាអញតាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏តាំងធ្វើសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ៤ ។

បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ន លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ បន គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ជាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស មេ កាយោ លហុកោ កម្មញ្ញោ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។ សោ វីរិយំ អា-រភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ បញ្ចមំ អារព្ភ-វត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណី-តស្ស វា ភោជនស្ស យាវទត្ថំ ចារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ អលត្ថំ លូខស្ស វា បណីតស្ស វា ភោជ-នស្ស យាវទត្ថំ ចារិបូរឹ តស្ស មេ កាយោ ពលវា

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជន សៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជន សៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់-គ្រាន់ កាយរបស់អាត្មាអញនោះស្រាល ជាកាយគួរប្រកបការងារបាន បើដូច្នោះ អាត្មាអញតាំងផ្ដើមសេចក្ដីព្យាយាម ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏តាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម បានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម បានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បានហើយ កាយរបស់អាត្មាអញនោះ មានកម្លាំងគួរនឹង

កម្មញ្ញោ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកាតស្ស សច្ឆិកិរិយាយាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកាតស្ស សច្ឆិកិរិយាយ ឥទំ ឆដ្ឋំ អារព្ភវត្ថុ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ មេ អប្បមត្តកោ អាពាធោ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អាពាធោ បវឌ្ឍេយ្យ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកាតស្ស សច្ឆិកិរិយាយាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា ។ បេ ។ អសច្ឆិកាតស្ស សច្ឆិកិរិយាយ ឥទំ សត្តមំ អារព្ភវត្ថុ ។

ប្រកបការងារបាន បើដូច្នោះ មានតែអាត្មាអញតាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញ មិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏តាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកទើបនឹងកើតអាពាធបន្តិចបន្តួចទេ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកើតអាពាធបន្តិចបន្តួចហើយ តែអាពាធរបស់អាត្មាអញ គង់តែនឹងចម្រើនឡើងដោយហេតុនេះមិនខាន បើដូច្នោះ មានតែអាត្មាអញតាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏តាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលខ្លួនមិនទាន់បានដល់ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ៧ ។

បុន ចបរំ អាវុសោ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា តស្ស ឯវំ ហោតិ អហំ ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អាពាធោ បច្ចុទាវត្តេយ្យ ហន្ទាហំ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិ-យាយាតិ ។ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ អដ្ឋមំ អារព្ភវត្ថុ ។ ឥមេ អដ្ឋ ធម្មា វិសេសភាគិយា ។

[៣២១] កតមេ អដ្ឋ ធម្មា ទុប្បដិវិជ្ឈា ។ អដ្ឋ អក្ខណា អសមយា ព្រហ្មចរិយវាសាយ ឥធា-វុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ទេសិយតិ ឧបសមិ-កោ បរិនិព្វានិកោ សម្ពោធគាមី សុគតប្បវេទិតោ

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុទើបតែនឹងបានជាសះស្បើយពីជំងឺថ្មី ៗ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានជាសះស្បើយពីជំងឺថ្មី ៗ ហើយ អាពាធអាត្មាអញសមជាវេត្រឡប់កម្រើកឡើងវិញ (លាប់) ដោយហេតុនោះមិនខាន បើដូច្នោះ មានតែអាត្មាអញតាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជា អារព្ភវត្ថុ ទី ៨ ។ ធម៌ទាំង ៨ នេះ ជាចំណែកវិសេស ។

[៣២១] ធម៌ ៨ ដែលយល់បានដោយក្រ តើដូចម្តេចខ្លះ ។ ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យមាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធត្រាស់ដឹងហើយក្នុងលោកនេះ ទាំងបានសំដែងធម៌ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ជាធម៌ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្តីត្រាស់ដឹង ជាធម៌ដែលព្រះសុគត ទ្រង់ប្រកាសហើយ

អយញ្ច បុគ្គលោ និរយំ ឧបបន្នោ ហោតិ អយំ បឋមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគតប្បវេទិតោ អយញ្ច បុគ្គលោ តិរច្ឆានយោនឹ ឧបបន្នោ ហោតិ អយំ ទុតិយោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគតប្បវេទិតោ អយញ្ច បុគ្គលោ បិត្តិវិសយំ ឧបបន្នោ ហោតិ អយំ តតិយោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ

តែបុគ្គលនេះឯងត្រឡប់ជាទៅកើតក្នុងនរកវិញ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ត្រាស់ហើយក្នុងលោក ទាំងបានសំដែងធម៌ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ជាធម៌ប្រព្រឹត្តទៅ ដើម្បីបានព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្តីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសហើយ តែបុគ្គលនេះឯងត្រឡប់ជាទៅកើតក្នុងកំណើតតិរច្ឆានវិញ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធត្រាស់ឡើងហើយ ក្នុងលោក ទាំងបានសំដែងធម៌ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ជាធម៌ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្តីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសហើយ តែបុគ្គលនេះឯង ត្រឡប់ជាទៅកើតក្នុងកំណើតប្រេតវិស័យវិញ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធត្រាស់ឡើងហើយ ក្នុងលោក

ធម្មោ ច ទេសិយតិ ឧបសមិកោ ។ បេ ។ អយញ្ច បុគ្គលោ អញ្ញតរំ ទីឃាយុកំ ទេវនិកាយំ ឧប-បន្នោ ហោតិ អយំ ចតុត្ថោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ទេសិយតិ ។ បេ ។ អយញ្ច បុគ្គលោ បច្ចន្តិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ មិលក្ខកេសុ អវិញ្ញាតារេសុ យត្ថ នត្ថិ គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ អយំ បញ្ចមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ មិច្ឆាទិដ្ឋិ វិបរីតទស្សនោ នត្ថិ ទិន្នំ

ទាំងបានសំដែងធម៌ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ។ បេ ។ តែបុគ្គលនេះឯងត្រូវឡប់ជាទៅកើត ក្នុងពួកទេវតាណាមួយ ដែលមានអាយុវែង នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងហើយក្នុងលោក ទាំងបានសំដែងធម៌ ។ បេ ។ តែបុគ្គលនេះឯងត្រូវឡប់ជាទៅកើត ក្នុងពួកមិលក្ខជនដែលជាអ្នកល្ងង់ខ្លៅ ក្នុងបច្ចន្តជនបទ ដែលជាប្រទេសឥតមានគតិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឡើយ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងហើយ ក្នុងលោក ។ បេ ។ ឯបុគ្គលនេះ ត្រូវឡប់មកកើតក្នុងមជ្ឈិមជនបទដែរ តែបុគ្គលនោះជាមិច្ឆាទិដ្ឋិ មានសេចក្ដីឃើញខុសថា ទានដែលបុគ្គលឲ្យហើយគ្មានផល

នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលវិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សមគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ អយំ ឆដ្ឋោ អក្ខណោ អសមយោ ព្រហ្មចរិយវា-សាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោ-កេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ ទុប្បញ្ញោ ជឡោ ឯលមូគោ នប្បដិពលោ សុភាសិតទុព្ភាសិតានំ អត្ថមញ្ញាតុំ អយំ សត្តមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ អាវុសោ តថាគតោ ច លោកេ ន ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ន ទេសិ-យតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី

ការបូជាធំគ្មានផល ការបូជាតូចគ្មានផល ផលវិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើល្អធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន សត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ ក្នុងលោក ដែលជាអ្នកដល់នូវសេចក្ដីស្ងប់រម្ងាប់ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញារបស់ខ្លួន ហើយទើបញ៉ាំងអ្នកដទៃឲ្យដឹងផង ក៏មិនមាន ដូច្នេះ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ឡើងហើយក្នុងលោក ។ បេ ។ ឯបុគ្គលនេះ បានត្រឡប់មកកើតក្នុងមជ្ឈិមជនបទដែរ តែបុគ្គលនោះ ជាអ្នកឥតប្រាជ្ញា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្ស-គ ជាមនុស្សមិនអាច ដើម្បីដឹងសេចក្ដីអធិប្បាយរបស់ពាក្យ ដែលគេនិយាយល្អ ឬនិយាយអាក្រក់បានឡើយ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ មិនបានត្រាស់ឡើងក្នុងលោក ទាំងមិនបានសំដែងធម៌ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ប្រព្រឹត្តទៅដើម្បីបាននូវព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្ដីត្រាស់ដឹង ជាធម៌ដែលព្រះសុគត

សុគតប្បវេទិតោ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនប-
ទេសុ បច្ចាជាតោ ហោតិ សោ ច បញ្ញវា អជឡោ
អនេលមូគោ បដិពលោ សុភាសិតទុព្ភាសិតានំ អត្ថ-
មញ្ញាតុំ អយំ អដ្ឋមោ អក្ខណោ អសមយោ ព្រហ្មច-
រិយវាសាយ ។ ឥមេ អដ្ឋ ធម្មា ទុប្បដិវិជ្ឈា ។

[៣២២] កាតមេ អដ្ឋ ធម្មា ឧប្បាទេតព្វា ។ អដ្ឋ
មហាបុរិសវិតក្កា អប្បិច្ឆស្សាយំ[១] ធម្មោ នាយំ ធម្មោ
មហិច្ឆស្ស សន្តុដ្ឋស្សាយំ ធម្មោ នាយំ ធម្មោ
អសន្តុដ្ឋស្ស បវិវិត្តស្សាយំ ធម្មោ នាយំ ធម្មោ

---

១ ឱ. អប្បិច្ឆស្ស អយំ ។

ទ្រង់ប្រកាសហើយ បុគ្គលនេះឯង បានត្រឡប់មកកើតក្នុងមជ្ឈិមជនបទ ហើយ ៗ ជាអ្នកមានប្រាជ្ញា មិនល្ងង់ មិនមែនជាមនុស្ស-គ ជាអ្នកអាចដើម្បីដឹងសេចក្តីអធិប្បាយ របស់ពាក្យគេនិយាយល្អ ឬអាក្រក់បាន នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៨ ។ ធម៌ទាំង ៨ នេះ យល់បានដោយក្រ ។

[៣២២] ធម៌ ៨ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សេចក្តីត្រិះរិះរបស់មហាបុរស ៨ យ៉ាង (ត្រិះរិះថា) នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីប្រាជ្ញាតិច នេះមិនមែនជាធម៌របស់បុគ្គល អ្នកមានសេចក្តីប្រាជ្ញាច្រើន ១ នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីសន្តោស (ក្នុងបច្ច័យ ៤) នេះមិនមែនជាធម៌របស់បុគ្គលគ្មានសេចក្តីសន្តោស ១ នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីស្ងប់ស្ងាត់[១] នេះមិនមែនជាធម៌របស់អ្នក

---

១ សេចក្តីស្ងប់រម្ងាប់មាន ៣ ប្រការ គឺ កាយវិវេក ស្ងាត់កាយ ១ ចិត្តវិវេក ស្ងាត់ចិត្ត ១ ឧបធិវិវេក ស្ងាត់កិលេស ១ ។ បុគ្គលគេចចេញចាកពួកក្រុម ហើយពួនសម្ងំនៅតែខ្លួនមួយ ដោយអំណាចអារព្ភវត្ថុ ៨ ប្រការ ហៅថា កាយវិវេក បុគ្គលធ្វើកសិណបរិកម្ម ដរាបដល់បានសម្រេចសមាបត្តិទាំង ៨ ហៅថា ចិត្តវិវេក បុគ្គលធ្វើឈានគឺសមាបត្តិទាំង ៨ នោះ ឲ្យជាទីតាំងហើយពិចារណានូវសង្ខារធម៌ទាំងឡាយ ដរាបដល់សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ហៅថា ឧបធិវិវេក ។ អដ្ឋកថា ។

សង្គណិកាកាមស្ស អារទ្ធវិរិយស្សាយំ ធម្មោ នាយំ ធម្មោ កុសីតស្ស ឧបដ្ឋិតស្សតិស្សាយំ ធម្មោ នាយំ ធម្មោ មុដ្ឋស្សតិស្ស សមាហិតស្សាយំ ធម្មោ នាយំ ធម្មោ អសមាហិតស្ស បញ្ញវតោ អយំ ធម្មោ នាយំ ធម្មោ ទុប្បញ្ញស្ស និប្បបញ្ចារាមស្សាយំ ធម្មោ និប្បបញ្ចរតិនោ នាយំ ធម្មោ បបញ្ចារាមស្ស បបញ្ចរតិនោតិ ។ ឥមេ អដ្ឋ ធម្មា ឧប្បាទេតព្វា ។

[៣២៣] កតមេ អដ្ឋ ធម្មា អភិញ្ញេយ្យា ។ អដ្ឋ អភិភាយតនានិ អជ្ឈត្តំរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជា-នាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បឋមំ អភិភា-យតនំ ។ អជ្ឈត្តំរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ

ត្រេកអរក្នុងពួកក្រុម ១ នេះជាធម៌របស់បុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម មិនមែនជាធម៌របស់បុគ្គលអ្នកខ្ជិលច្រអូស ១ នេះជាធម៌របស់បុគ្គលអ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់បុគ្គលអ្នកភ្លេចស្មារតី ១ នេះជាធម៌របស់បុគ្គលអ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់បុគ្គលអ្នកមានចិត្តមិនតាំងមាំ ១ នេះជាធម៌របស់បុគ្គលអ្នកមានបញ្ញា នេះមិនមែនជាធម៌របស់បុគ្គលអ្នកឥតបញ្ញា ១ នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីត្រេកអរ ក្នុងដំណើរមិនយឺតយូរ មានតម្រេក ក្នុងដំណើរមិនយឺតយូរ នេះជាធម៌របស់បុគ្គល អ្នកមានសេចក្តីត្រេកអរ ក្នុងដំណើរយឺតយូរ មានតម្រេកក្នុងដំណើរយឺតយូរ ១ ។ ធម៌ទាំង ៨ នេះ គួរឲ្យកើតឡើង ។

[៣២៣] ធម៌ ៨ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អភិភាយតនៈ[១] (ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអារម្មណ៍ផង) ៨ យ៉ាង គឺ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅមានប្រមាណតិច មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជា អភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណ

១ ឲ្យមើល នយលក្ខណៈ ក្នុងមហាបរិនិព្វានសូត្រ ទីឃនិកាយមហាវគ្គ ផងចុះ នឹងមានពិស្តារតាំងពី ទី ១ ដល់ ទី ៨ ។

អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ តតិយំ អភិ-កាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិ-ភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីល-និភាសានិ សេយ្យថាបិ នាម ឧម្មារបុប្ផំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ នីលំ នីលវណ្ណំ

ច្រើន មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់ នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជា អភិភាយតនៈ ទី ២ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជា អភិភាយតនៈ ទី ៣ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់ នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់ នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជា អភិភាយតនៈ ទី ៤ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់ នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ប្រៀបដូចជាផ្កាត្រកៀតខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថាសំពត់ខៀវ មានពណ៌ខៀវ

នីលនិទស្សនំ នីលនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បញ្ចមំ អភិ-ភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភា-សានិ សេយ្យថាបិ នាម កណ្ណិការបុប្ផំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ

ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈ ទី ៥ ។ បុគ្គលពួក ១ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង ប្រៀបដូចជាផ្កាកណ្ណិការលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់លឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ

ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិ-
ភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ
បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិ-
តកនិទស្សនានិ លោហិតកនិភាសានិ សេយ្យថាបិ
នាម ពន្ធុជីវកបុប្ផំ លោហិតកំ លោហិតកវណ្ណំ
លោហិតកនិទស្សនំ លោហិតកនិភាសំ សេយ្យថាបិ
វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ
លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ
លោហិតកនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ
ពហិទ្ធារូបានិ បស្សតិ លោហិតកានិ លោហិតក-
វណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ
តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី
ហោតិ ឥទំ សត្តមំ អភិភាយតនំ ។ អជ្ឈត្តំអរូបសញ្ញី
ឯកោ ពហិទ្ធារូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ
ឱទាតនិទស្សនានិ ឱទាតនិភាសានិ សេយ្យថាបិ
នាម ឱសធិតារកា ឱទាតា ឱទាតវណ្ណា ឱទាត-
និទស្សនា ឱទាតនិភាសា សេយ្យថាបិ វា បន តំ

ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជា អភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ប្រៀបដូចជាផ្កាច្បាក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថាសំពត់ក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជា អភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូប-ស មានពណ៌-ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌-ស មានពន្លឺ-ស ប្រៀបដូចជាផ្កាយព្រឹកដែល-ស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺ-ស ពុំនោះសោត រូបនោះប្រៀបដូច

វត្ថុំ ពាពណាសេយ្យកំ ឧភតោភាគវិមដ្ឋំ ឱជាតំ ឱជាតវណ្ណំ ឱជាតនិទស្សនំ ឱជាតនិភាសំ ឯវមេវ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ ឱជាតានិ ឱជាតវណ្ណានិ ឱជាតនិទស្សនានិ ឱជាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយតនំ ។ ឥមេ អដ្ឋ ធម្មា អភិញ្ញេយ្យា ។

[៣២៤] កតមេ អដ្ឋ ធម្មា សច្ឆិកាតព្វា ។ អដ្ឋ វិមោក្ខា រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំអរូបសញ្ញី ឯកោ ពហិទ្ធារូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ ។

ជាសំពត់ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់ស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺ-ស យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូប-ស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺ-ស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជា អភិភាយតនៈ ទី ៨ ។ ធម៌ទាំង ៨ នេះ គួរដឹងច្បាស់ ។

[៣២៨] ធម៌ ៨ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្ដេចខ្លះ ។ វិមោក្ខ ៨ ប្រការ[១] បុគ្គលបានរូបឈាន រមែងឃើញនូវរូបគឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជា វិមោក្ខទី ១ ។ បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវអរូបខាងក្នុង រមែងឃើញនូវរូបខាងក្រៅទាំងឡាយ គឺកសិណមាននីលកសិណជាដើម នេះជា វិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណដ៏បរិសុទ្ធ នេះជា វិមោក្ខទី ៣ ។

១ វិមោក្ខទាំង ៨ នេះ ចូរមើល នយលក្ខណៈ ក្នុងមហានិទានសូត្រ ទីឃនិកាយ មហាវគ្គផងចុះ នឹងមានពន្យល់ពិស្ដារក្នុងកន្លែងខ្លះ ៗ ។

សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ ឥមេ អដ្ឋ ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ អសីតិ ធម្មា ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

បុគ្គលដែលកន្លងនូវរូបសញ្ញា ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជា វិមោក្ខទី ៤ ។ បុគ្គលដែលកន្លងនូវអាកាសា-នញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវវិញ្ញាណញ្ចា-យតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជា វិមោក្ខទី ៥ ។ បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមានដូច្នេះ នេះជា វិមោក្ខ ទី ៦ ។ បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជា វិមោក្ខទី ៧ ។ បុគ្គលដែលកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវសញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) នេះជា វិមោក្ខទី ៨ ។ ធម៌ទាំង ៨ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៨០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតបានត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

ទសុត្តរសុត្តំ ធម្មប្បភេទនវកំ

[៣២៥] នវ ធម្មា ពហុការា នវ ធម្មា ភាវេតព្វា នវ ធម្មា បរិញ្ញេយ្យា នវ ធម្មា បហាតព្វា នវ ធម្មា ហានភាគិយា នវ ធម្មា វិសេសភាគិយា នវ ធម្មា ទុប្បដិវិជ្ឈា នវ ធម្មា ឧប្បាទេតព្វា នវ ធម្មា អភិញ្ញេយ្យា នវ ធម្មា សច្ឆិកាតព្វា ។

[៣២៦] កតមេ នវ ធម្មា ពហុការា ។ នវ យោនិសោមនសិការមូលិកា[១] ធម្មា យោនិសោមនសិការោតោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ សមាហិតចិត្តោ យថាភូតំ[២] ជានាតិ បស្សតិ យថាភូតំ ជានំ បស្សំ សយំ[៣] និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ ឥមេ នវ ធម្មា ពហុការា ។

---

១ ឱ. ម. នវ យោនិសោមនសិការមុលកា ។ ២ ឱ. សមាហិតេន ចិត្តេន យថាភូតំ ។ ៣ ឱ. ម. សយន្តិ ន ទិស្សតិ ។

ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំបួន ៗ

[៣២៥] ធម៌ ៩ មានឧបការៈច្រើន ធម៌ ៩ គួរចម្រើន ធម៌ ៩ គួរកំណត់ដឹង ធម៌ ៩ គួរលះបង់ ធម៌ ៩ ជាចំណែកនៃសេចក្ដីវិនាស ធម៌ ៩ ជាចំណែកវិសេស ធម៌ ៩ យល់បានដោយក្រ ធម៌ ៩ គួរឲ្យកើតឡើង ធម៌ ៩ គួរដឹងច្បាស់ ធម៌ ៩ គួរធ្វើឲ្យជាក់ច្បាស់ ៗ

[៣២៦] ធម៌ ៩ មានឧបការៈច្រើន តើដូចម្ដេចខ្លះ ៗ ធម៌ដែលមានយោនិសោមនសិការៈជាឫស ៩ យ៉ាង កាលភិក្ខុធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា សេចក្ដីត្រេកអរទន់ក៏កើតឡើង ១ កាលលោកត្រេកអរហើយសេចក្ដីឆ្អែតចិត្តកើតឡើង ១ កាលលោកមានសេចក្ដីឆ្អែតចិត្ត កើតឡើងហើយ កាយក៏ស្ងប់រម្ងាប់ ១ លុះលោកមានកាយស្ងប់រម្ងាប់ហើយក៏បានសោយសេចក្ដីសុខ ១ លុះលោកមានសេចក្ដីសុខហើយ ចិត្តក៏តាំងនៅមាំ ១ លុះលោកមានចិត្តតាំងនៅមាំហើយ ក៏ដឹងឃើញច្បាស់តាមសភាវៈពិត ១ កាលលោកបានដឹងបានឃើញច្បាស់ តាមសភាវៈពិតហើយ តែងនឿយណាយដោយខ្លួនឯង ១ លុះលោកនឿយណាយហើយ រមែងប្រាសចាកតម្រេក រមែងផុតស្រឡះចាកតម្រេក ១ ៗ ធម៌ទាំង ៩ នេះ មានឧបការៈច្រើន ៗ

[៣៦៧] កតមេ នវ ធម្មា ភាវេតព្វា ។ នវ ចារិសុទ្ធិបធានិយង្គានិ សីលវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ ចិត្តវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ ទិដ្ឋិវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ កង្ខាវិតរណវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ បដិបទាញាណទស្សនវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ ញាណទស្សនវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ បញ្ញាវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ វិមុត្តិវិសុទ្ធិ ចារិសុទ្ធិបធានិយង្គំ ។ ឥមេ នវ ធម្មា ភាវេតព្វា ។

[៣៦៨] កតមេ នវ ធម្មា បរិញ្ញេយ្យា ។ នវ សត្តាវាសា សន្តាវុសោ សត្តា នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមោ សត្តាវាសោ ។

[៣២៧] ធម៌ ៩ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ៩ យ៉ាង គឺ សីលវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ ចិត្តវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ ទិដ្ឋិវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ កង្ខាវិតរណវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ បដិបទាញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ ញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ បញ្ញាវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ វិមុត្តិវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធ ១ ។ ធម៌ទាំង ៩ នេះ គួរចម្រើន ។

[៣២៨] ធម៌ ៩ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ សត្តាវាសៈ (ប្រទេសជាទីនៅរបស់សត្វ) មាន ៩ ម្នាលអាវុសោទាំងឡាយ សត្វទាំង-ឡាយ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកមនុស្ស និងទេវតាពួកខ្លះ និងអសុរកាយពួកខ្លះ នេះជា សត្តាវាសៈ ទី ១ ។

សន្តាវុសោ សត្តា នានត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា អយំ ទុតិយោ សត្តាវាសោ ។ សន្តាវុសោ សត្តា ឯកត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយោ សត្តាវាសោ ។ សន្តាវុសោ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហា អយំ ចតុត្ថោ សត្តាវាសោ ។ សន្តាវុសោ សត្តា អសញ្ញិនោ អប្បដិសំវេទិនោ សេយ្យថាបិ ទេវា អសញ្ញិសត្តា អយំ បញ្ចមោ សត្តាវាសោ ។ សន្តាវុសោ សត្តា សព្វសោ រូប-សញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនូបគា អយំ ឆដ្ឋោ សត្តាវាសោ ។ សន្តាវុសោ សត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនូ-បគា អយំ សត្តមោ សត្តាវាសោ ។ សន្តាវុសោ

ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នាក៏មាន ដូចព្រហ្មកាយិកទេវតា ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជា សត្តាវាសៈ ទី ២ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយដូចគ្នា តែមានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជា សត្តាវាសៈ ទី ៣ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយដូចគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជា សត្តាវាសៈ ទី ៤ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយឥតសញ្ញា ឥតមានសោយអារម្មណ៍ ដូចពួកទេវតាជាអសញ្ញិសត្វ នេះជា សត្តាវាសៈ ទី ៥ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ លុះបានកន្លងនូវរូបសញ្ញា បានរម្ងាប់នូវបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយចូលដល់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ក៏មាន នេះជា សត្តាវាសៈ ទី ៦ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ កន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានចូលដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះក៏មាន នេះជា សត្តាវាសៈ ទី ៧ ។ ម្នាលអាវុសោទាំងឡាយ

សត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគា អយំ អដ្ឋមោ សត្តាវាសោ ។ សន្តាវុសោ សត្តា សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម សន្តមេតំ បណីតមេតន្តិ នេវសញ្ញានាសញ្ញាយតនូបគា អយំ នវមោ សត្តាវាសោ ។ ឥមេ នវ ធម្មា បរិញ្ញេយ្យា ។

[៣២៩] កតមេ នវ ធម្មា បហាតព្វា ។ នវ តណ្ហាមូលិកា ធម្មា តណ្ហំ បដិច្ច បរិយេសនា បរិយេសនំ បដិច្ច លាភោ លាភំ បដិច្ច វិនិច្ឆយោ វិនិច្ឆយំ បដិច្ច ឆន្ទរាគោ ឆន្ទរាគំ បដិច្ច អជ្ឈោសានំ[១] អជ្ឈោសានំ បដិច្ច បរិគ្គហោ បរិគ្គហំ បដិច្ច មច្ឆរិយំ

---

១ ម. អជ្ឈោសានោ ។

សត្វទាំងឡាយ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានចូលដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួច មិនមាន ដូច្នេះក៏មាន នេះជា សត្តាវាសៈ ទី ៨ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា របស់នេះល្អិត របស់នេះឧត្តម ដូច្នេះក៏មាន នេះជា សត្តាវាសៈ ទី ៩ ។ ធម៌ទាំង ៩ នេះ គួរកំណត់ដឹង ។

[៣២៩] ធម៌ ៩ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ ធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង គឺ ការអាស្រ័យតណ្ហា ទើបមានការស្វែងរក ១ អាស្រ័យការស្វែងរក ទើបកើតលាភ ១ អាស្រ័យលាភ ទើបកើតសេចក្តីត្រិះរិះ ១ អាស្រ័យសេចក្តីត្រិះរិះ ទើបកើតសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ១ អាស្រ័យសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ទើបកើតសេចក្តីជឿស៊ប់ ១ អាស្រ័យសេចក្តីជឿស៊ប់ ទើបកើតការហួងហែងទុក ១ អាស្រ័យការហួងហែងទុក ទើបកើតសេចក្តីកំណាញ់ ១

មច្ឆរិយំ បដិច្ច អារក្ខោ អារក្ខាធិករណំ បដិច្ច ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវំបេសុញ្ញ-មុសាវាទា អនេកេ បាបកា អកុសលា ធម្មា សំវត្តន្តិ[១] ។ ឥមេ នវ ធម្មា បហាតព្វា ។

[៣៣០] កតមេ នវ ធម្មា ហានភាគិយា ។ នវ អាឃាតវត្ថូនិ អនត្ថំ មេ អចរីតិ អាឃាតំ ពន្ធតិ ។ អនត្ថំ មេ ចរតីតិ អាឃាតំ ពន្ធតិ ។ អនត្ថំ មេ ច-រិស្សតីតិ អាឃាតំ ពន្ធតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ អចរីតិ អាឃាតំ ពន្ធតិ ។ បិយស្ស មេ មនា-បស្ស អនត្ថំ ចរតីតិ អាឃាតំ ពន្ធតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ ។

---

១ ឱ. សម្ភវន្តិ ។

អាស្រ័យសេចក្តីកំណាញ់ ទើបកើតការរក្សាទុក ១ អាស្រ័យនូវការរក្សាទុកជាហេតុហើយ ទើបអកុសលធម៌ទាំងឡាយដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែងជជែកគ្នាថា ឯង ៗ ទាំងនិយាយញុះញង់ និយាយកុហក ក៏ប្រព្រឹត្តទៅ ១ ធម៌ទាំង ៩ នេះ គួរលះបង់ ។

[៣៣០] ធម៌ ៩ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ អាឃាតវត្ថុ (ហេតុនៃការចងគំនុំ) ៩ យ៉ាង គឺបុគ្គលចងគំនុំ ដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញហើយ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ កំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ នឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ បានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញហើយ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ កំពុងតែប្រព្រឹត្តអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ នឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ១ ។

អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ អាឃាតំ ពន្ធតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរតីតិ អាឃាតំ ពន្ធតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរិស្សតីតិ អាឃាតំ ពន្ធតិ ។ ឥមេ នវ ធម្មា ហានភាគិយា ។

[៣៣១] កតមេ នវ ធម្មា វិសេសភាគិយា ។ នវ អាឃាតប្បដិវិនយា អនត្ថំ មេ អចរីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ អនត្ថំ មេ ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ អនត្ថំ មេ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេ-តិ ។ បិយស្ស មេ មនាបស្ស អនត្ថំ អចរីតិ

ចងគំនុំដោយគិតថា អ្នកនេះ បានប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញហើយ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ កំពុងតែប្រព្រឹត្តអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ នឹងប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អញ ១ ។ ធម៌ទាំង ៩ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[៣៣១] ធម៌ ៩ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ អាឃាតប្បដិវិន័យ (ហេតុសម្រាប់កម្ចាត់បង់គំនុំ) ៩ យ៉ាង គឺ បុគ្គលកម្ចាត់បង់គំនុំដោយគិតថា អ្នកនេះ បានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា អ្នកនេះ កំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា អ្នកនេះ នឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា អ្នកនេះ បានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទី

តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ ចរិស្សតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិនេតិ ។ អប្បិយស្ស មេ អមនា-បស្ស អត្ថំ ចរតីតិ តំ កុតេត្ថ លព្ភាតិ អាឃាតំ បដិវិ-នេតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរិស្សតីតិ តំ

គាប់ចិត្តរបស់អាត្មាអញហើយ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតប ទៅ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា អ្នកនេះ កំពុងតែប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទី ស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងមានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់ នូវគំនុំដោយគិតថា អ្នកនេះ នឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ (បើ) អាត្មា អញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់ បង់នូវគំនុំ ដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើជាប្រយោជន៍ ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ ព្រោះហេតុ នោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការ អ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា អ្នកនេះ កំពុងតែប្រព្រឹត្ត អំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ អាត្មាអញ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា អ្នក នេះ នឹងប្រព្រឹត្តអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិន

កុតេត្ថ លព្ភតិ អាឃាតំ បដិវិនេតិ ។ ឥមេ នវ ធម្មា វិសេសភាគិយា ។

[៣៣២] កតមេ នវ ធម្មា ឧប្បាទេតព្វា ។ នវ យោនិសោ មនសិការមូលកា ធម្មា ឧប្បាទេតព្វា ។

ជានត្តា ជាតុជានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សជានត្តំ ផស្សជានត្តំ បដិច្ច ឧប្បជ្ជតិ វេទនាជានត្តំ វេទនាជានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញាជានត្តំ សញ្ញាជានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បជានត្តំ សង្កប្បជានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទជានត្តំ ឆន្ទជានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហជានត្តំ បរិឡាហជានត្តំ បដិច្ច ឧប្បជ្ជតិ បរិយេសនាជានត្តំ បរិយេសនាជានត្តំ បដិច្ច ឧប្បជ្ជតិ លាភជានត្តំ[១] ។ ឥមេ នវ ធម្មា ទុប្បដិវិជ្ឈា ។

១ ឥតោ បរំ លាភនានត្តំ បដិច្ច ឧប្បជ្ជតិ អារក្ខនានត្តន្តិ ទិស្សន្តិ ។

ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ (បើ) អាត្មាអញ (ធ្វើតបទៅ) អ្នកនេះវិញ តើនឹងបានជាការធ្វើ ១ ។ ធម៌ទាំង ៩ នេះ ជាចំណែកវិសេស ។

[៣៣២] ធម៌ ៩ ដែលយល់បានដោយក្រ តើដូចម្ដេចខ្លះ ។ ធម៌ផ្សេង ៗ ៩ យ៉ាង គឺ ផស្សៈផ្សេង ៗ អាស្រ័យធាតុផ្សេង ៗ ហើយទើបកើតឡើង ១ វេទនាផ្សេង ៗ អាស្រ័យផស្សៈផ្សេង ៗ ហើយទើបកើតឡើង ១ សញ្ញាផ្សេង ៗ អាស្រ័យវេទនាផ្សេង ៗ ហើយទើបកើតឡើង ១ សេចក្ដីត្រិះរិះផ្សេង ៗ អាស្រ័យសញ្ញាផ្សេង ៗ ហើយទើបកើតឡើង ១ សេចក្ដីប្រាថ្នាផ្សេង ៗ អាស្រ័យសេចក្ដីត្រិះរិះផ្សេង ៗ ហើយទើបកើតឡើង ១ សេចក្ដីក្ដៅក្រហាយផ្សេង ៗ អាស្រ័យសេចក្ដីប្រាថ្នាផ្សេង ៗ ហើយទើបកើតឡើង ១ ការស្វែងរកផ្សេង ៗ អាស្រ័យសេចក្ដីក្ដៅក្រហាយផ្សេង ៗ ហើយទើបកើតឡើង ១ លាភផ្សេង ៗ អាស្រ័យការស្វែងរកផ្សេង ៗ ហើយទើបកើតឡើង ១[១] ។ ធម៌ទាំង ៩ នេះ យល់បានដោយក្រ ។

---

១ ក្នុងពួកធម៌នេះថាមាន ៩ ប្រការ តែរាប់មើលទៅឃើញតែ ៨ វិញ មិនដឹងជាបាត់ត្រង់ទីណា បានយកគម្ពីរជាច្រើនមកផ្ទៀងផ្ទាត់មើល ឃើញមានបាលីកែដូចគ្នាទាំងអស់ ។ តែបើតាមសេចក្ដីចូលចិត្តរបស់ក្រុមជំនុំថា គួរបន្ថែម កិរិយារក្សាផ្សេង ១ កើតឡើង ព្រោះអាស្រ័យលាភផ្សេង ១ មកទៀត ទើបគ្រប់ដូច នយលក្ខណៈខាងបាលី ។

៣៣៧

ទសុត្តរសុត្តេ ធម្មប្បភេទនវកំ

[៣៣៣] កតមេ នវ ធម្មា ឧប្បាទេតព្វា ។ នវ សញ្ញា អសុភសញ្ញា មរណសញ្ញា អាហារេ បដិកូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា ។ ឥមេ នវ ធម្មា ឧប្បាទេតព្វា ។

[៣៣៤] កតមេ នវ ធម្មា អភិញ្ញេយ្យា ។ នវ អនុបុព្វវិហារា ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច

ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំបួន ៗ

[៣៣៣] ធម៌ ៩ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សេចក្តីសំគាល់ ៩ យ៉ាង គឺ សេចក្តីសំគាល់ថាមិនល្អ ១ សេចក្តីសំគាល់ដោយមរណានុបស្សនាញាណ ១ សេចក្តីសំគាល់ក្នុងអាហារថា ជារបស់គួរខ្ពើម ១ សេចក្តីសំគាល់របស់បុគ្គលអ្នកមិនត្រេកអរក្នុងលោកទាំងពួង ១ សេចក្តីសំគាល់ថាមិនទៀង ១ សេចក្តីសំគាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសំគាល់ក្នុងរបស់ដែលជាទុក្ខ ថាមិនមែនរបស់ខ្លួន ១ សេចក្តីសំគាល់នូវរបស់ដែលត្រូវលះបង់ ១ សេចក្តីសំគាល់ថាគួរនឿយណាយ ១ ។ ធម៌ទាំង ៩ នេះ គួរឲ្យកើតឡើង ។

[៣៣៤] ធម៌ ៩ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អនុបុព្វវិហារៈ (ធម៌ជាគ្រឿងសម្រេចសម្រាន្តនៅតាមលំដាប់) ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ក៏បានចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ និងបីតិសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ១ លុះរម្ងាប់វិតក្កៈ និងវិចារៈទាំងឡាយហើយ ក៏បានចូលទុតិយជ្ឈានជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុង ដ៏ញ៉ាំងចិត្តជាសមាធិឲ្យចម្រើនឡើង គ្មានវិតក្កៈ វិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិ ១ លុះលះបង់បីតិចេញហើយ ជាបុគ្គលព្រងើយកន្តើយ ប្រកបដោយសតិនិងសម្បជញ្ញៈ សោយសុខ

កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧប-សម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេ វ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧប-សម្បជ្ជ វិហរតិ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិ-ការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចាយតនំ សម-តិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វ-សោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញា-វេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ ឥមេ នវ ធម្មា អភិញ្ញេយ្យា ។

ដោយកាយផង ក៏បានចូលដល់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយតែងសំដែងថា បុគ្គលអ្នកបានតតិយជ្ឈាន រមែងជាអ្នកមានចិត្តព្រងើយមានស្មារតី នៅជាសុខដូច្នេះ ១ លុះលះបង់នូវសុខផង លះបង់នូវទុក្ខផង រំលត់នូវសោមនស្សនិងទោមនស្សអំពីមុខផង ក៏បានចូលដល់ ចតុត្ថជ្ឈាន ឥតសុខឥតទុក្ខ មានតែសតិដ៏ស្អាតដោយឧបេក្ខា ១ លុះកន្លងបង់នូវរូបសញ្ញា រំលត់នូវបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយក៏បានចូលដល់ អាកាសានញ្ចាយតនជ្ឈានដោយបរិកម្មថា អាកាសមិនមានទីបំផុត ១ លុះកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់ វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ១ លុះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ១ លុះកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ លុះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់សញ្ញាវេទយិតនិរោធ ១ ។ ធម៌ទាំង ៩ នេះ គួរដឹងច្បាស់ ។

៣៣៩

## ទសុត្តរសុត្តេ ធម្មប្បភេទនវកំ

[៣៣៨] កតមេ នវ ធម្មា សច្ឆិកាតព្វា ។ នវ អនុបុព្វនិរោធា បឋមំ ឈានំ សមាបន្នស្ស កាម-សញ្ញា និរុទ្ធា ហោតិ ទុតិយំ ឈានំ សមាបន្នស្ស វិតក្កវិចារា និរុទ្ធា ហោន្តិ តតិយំ ឈានំ សមាបន្នស្ស បីតិ និរុទ្ធា ហោតិ ចតុត្ថំ ឈានំ សមាបន្នស្ស អស្សា-សប្បស្សាសា និរុទ្ធា ហោន្តិ អាកាសានញ្ចាយតនំ ស-មាបន្នស្ស រូបសញ្ញា និរុទ្ធា ហោតិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា និរុទ្ធា ហោ-តិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយត-នសញ្ញា និរុទ្ធា ហោតិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា និរុទ្ធា ហោតិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច និរុទ្ធា ហោន្តិ ។ ឥមេ នវ ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ នវុតិ ធម្មា ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធា ។

ទសុត្តរសូត្រ ប្រភេទនៃធម៌ប្រាំបួន ៗ

[៣៣៥] ធម៌ ៩ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ អនុ-បុព្វនិរោធ (ធម៌ជាគ្រឿងរំលត់តាមលំដាប់) ៩ យ៉ាង គឺ បុគ្គលចូលកាន់បឋមជ្ឈាន រលត់កាមសញ្ញា ១ ចូលកាន់ទុតិយជ្ឈាន រលត់វិតក្កៈវិចារៈ ១ ចូលកាន់តតិយជ្ឈាន រលត់បីតិ ១ ចូលកាន់ចតុត្ថជ្ឈាន រលត់អស្សា-សប្បស្សាសៈ ១ ចូលកាន់អាកាសានញ្ចាយតនជ្ឈាន រលត់រូបសញ្ញា ១ ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន រលត់អាកាសានញ្ចាយតនសញ្ញា ១ ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន រលត់វិញ្ញាណញ្ចាយតនសញ្ញា ១ ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន រលត់អាកិញ្ចញ្ញាយតនសញ្ញា ១ ចូលកាន់សញ្ញាវេទយិតនិរោធ រលត់សញ្ញានិងវេទនា ១ ។ ធម៌ទាំង ៩ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៩០ នេះ ជាធម៌ពិត ជាធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតបានត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

[៣៣៦] ទស ធម្មា ពហុការា ទស ធម្មា ភា-វេតព្វា ទស ធម្មា បរិញ្ញេយ្យា ទស ធម្មា បហាតព្វា ទស ធម្មា ហានភាគិយា ទស ធម្មា វិសេសភាគិយា ទស ធម្មា ទុប្បដិវិជ្ឈា ទស ធម្មា ឧប្បាទេតព្វា ទស ធម្មា អភិញ្ញេយ្យា ទស ធម្មា សច្ឆិកាតព្វា ។

[៣៣៧] កតមេ ទស ធម្មា ពហុការា ។ ទស នាថករណា ធម្មា ឥធាវុសោ ភិក្ខុ សីលវា ហោតិ ចាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ យំចាវុសោ ភិក្ខុ សីលវា ហោតិ ចាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អយំ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា

[៣៣៦] ធម៌ ១០ មានឧបការៈច្រើន ធម៌ ១០ គួរចម្រើន ធម៌ ១០ គួរកំណត់ដឹង ធម៌ ១០ គួរលះបង់ ធម៌ ១០ ជាចំណែកនៃសេចក្តីវិនាស ធម៌ ១០ ជាចំណែកវិសេស ធម៌ ១០ យល់បានដោយក្រ ធម៌ ១០ គួរឲ្យកើតឡើង ធម៌ ១០ គួរដឹងច្បាស់ ធម៌ ១០ គួរធ្វើឲ្យជាក់ច្បាស់ ។

[៣៣៧] ធម៌ ១០ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ នាថ-ករណធម៌ (ធម៌ធ្វើឲ្យជាទីពឹង) ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិ-បូណ៌ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ នេះឯងជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ចេះចាំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយ មានលំអបទដើម

មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ ស-
ព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ
តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា
បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។
យំបាវុសោ ភិក្ខុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា
សុប្បដិវិទ្ធា អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ
អាវុសោ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណ-
សហាយោ កល្យាណសម្បវង្កោ ។ យំបាវុសោ ភិក្ខុ
កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យា-
ណសម្បវង្កោ អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ
អាវុសោ ភិក្ខុ សុវចោ ហោតិ សោវចស្សករណេហិ
ធម្មេហិ សមន្នាគតោ ខមោ ហោតិ បទក្ខិណគ្គាហី
អនុសាសនឹ ។ យំបាវុសោ ភិក្ខុ សុវចោ ហោតិ សោ-
វចស្សករណេហិ ធម្មេហិ សមន្នាគតោ ខមោ ហោតិ

មានលំអបទកណ្ដាល មានលំអបទចុង ប្រកាសនូវព្រហ្មចារ្យ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះឯង ក៏បានស្ដាប់ច្រើន បានចាំទុក ចាំរត់មាត់ ចាំជាប់ក្នុងចិត្ត ចាក់ធ្លុះល្អដោយទិដ្ឋិ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាពហុស្សូត ។ បេ ។ ចាក់ធ្លុះល្អដោយទិដ្ឋិ នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានមិត្តល្អ មានសំឡាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អ នេះឯង ជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយចំណែកខាងស្ដាំ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើ នូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអំណត់

បធក្ខិណគ្គាហី អនុសាសនី អយំបិ ធម្មោ ឆាថការ-
ណោ ។ បុន ចបរំ អាវុសោ ភិក្ខុ យានិ តានិ
សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ទក្ខោ
ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នា-
គតោ អលំ កាតុំ អលំ សំវិធាតុំ ។ យំបាវុសោ ភិក្ខុ
យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ
តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ
វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ
អយំបិ ធម្មោ ឆាថការណោ ។ បុន ចបរំ អាវុ-
សោ ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ
អភិធម្មេ អភិវិនយេ ឱឡារបាមោជ្ជោ ។ យំបាវុសោ

ទទួលយកនូវពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ នេះឯង ជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិច្ចការណាទីមួយ ធំឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងនោះឡើយ ប្រកបដោយការពិចារណាជាឧបាយក្នុងកិច្ចការទាំងនោះ ជាអ្នកអាចធ្វើបាន អាចចាត់ចែងបាន ។ ម្នាលអាវុសោទាំងឡាយ កិច្ចការណាទីមួយ ធំឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងនោះឡើយ ប្រកបដោយការពិចារណាជាឧបាយក្នុងកិច្ចការទាំងនោះ ជាបុគ្គលអាចធ្វើបាន អាចចាត់ចែងបាន នេះឯង ជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌[១] ជាអ្នកស្តាប់ដោយយកចិត្តទុកដាក់ ទាំងប្រាថ្នាប្រកាសប្រាប់ជនឯទៀត ដោយខ្លួនឯង ជាអ្នកច្រើនដោយសេចក្តីត្រេកអរដ៏ទន់ក្នុងអភិធម្ម[២] ក្នុងអភិវិន័យ[៣] ។ ម្នាលអាវុសោ

---

១ បានដល់ពុទ្ធវចនៈគឺបិដក ៣ ។ ២ បានដល់ព្រះអភិធម្មទាំង ៧ គម្ពីរមានធម្មសង្គណីជាដើម ។ ន័យ ១ ទៀតថា មគ្គនិងផលហៅថា អភិធម្ម ។ ៣ បានដល់ខន្ធកបរិវារៈ ។ ន័យ ១ ទៀតថា ការធ្វើឲ្យកិលេសស្ងប់រម្ងាប់ ហៅថា អភិវិន័យ ។ (សង្គីតិសុត្តវណ្ណនា) ។

ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទាហារោ អភិធម្មេ អភិវិនយេ ឧឡារបាមោជ្ជោ អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។ យំបាវុសោ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ យំបាវុសោ ភិក្ខុ អារទ្ធវីរិយោ វិហរតិ ។ បេ ។ អយំបិ ធម្មោ នាថករណោ ។ បុន ចបរំ អាវុសោ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា ។

ទាំងឡាយ ការដែលភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកស្តាប់ ដោយយកចិត្តទុកដាក់ ទាំងប្រាថ្នាប្រកាសប្រាប់ជនឯទៀត ដោយខ្លួនឯងជាអ្នកច្រើនដោយសេចក្តីត្រេកអរដ៏ទន់ក្នុងអភិធម្ម ក្នុងអភិវិន័យ នេះឯងជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារគឺថ្នាំជាបច្ច័យសម្រាប់អ្នកជំងឺ តាមមាន តាមបាន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យសម្រាប់អ្នកជំងឺ តាមមាន តាមបាន នេះឯងជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកតាំងផ្តើមសេចក្តីព្យាយាមដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីធ្វើកុសលធម៌ទាំងឡាយ ឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ការដែលភិក្ខុជាអ្នកផ្តើមសេចក្តីព្យាយាម ។ បេ ។ នេះឯង ជា នាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយ (ការតាំង) ស្មារតីនិងការៈជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ខ្ពង់ខ្ពស់ នឹងឃើញនូវអំពើដែលខ្លួនធ្វើរួចយូរហើយផង នូវសំដីដែលខ្លួននិយាយយូរហើយផង ។

យំចាវុសោ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា អយំបិ ធម្មោ នាថករណោ ។ បុនចបរំ អាវុសោ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ យំចាវុសោ ភិក្ខុ បញ្ញវា ហោតិ ។ បេ ។ សម្មាទុក្ខក្ខយគាមិនិយា អយំបិ ធម្មោ នាថករណោ ។ ឥមេ ទស ធម្មា ពហុការា ។

[៣៣៨] កតមេ ទស ធម្មា ភាវេតព្វា ។ ទស កសិណាយតនានិ បឋវីកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ ច តិរិយំ អទ្វយំ

ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយការតាំងស្មារតីនិងភាពជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ខ្ពង់ខ្ពស់ នឹកឃើញនូវអំពើដែលខ្លួនធ្វើរួចយូរហើយផង នូវសំដីដែលខ្លួននិយាយយូរហើយផង នេះឯងជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលអាចកំណត់នូវការកើតឡើង និងការវិនាសទៅ (នៃខន្ធបញ្ចកៈ) ជាគ្រឿងទំលាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតិដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកមានប្រាជ្ញា ។ បេ ។ ជាធម្មជាតិដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ នេះឯងជា នាថករណធម៌ ១ ។ ធម៌ទាំង ១០ នេះ មានឧបការៈច្រើន ។

[៣៣៨] ធម៌ ១០ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ កសិណាយតនៈ (ខេត្តឬទីតាំងរបស់ពួកធម៌ដែលមានកសិណជាអារម្មណ៍) មាន ១០ យ៉ាង គឺបុគ្គលពួកមួយ ស្គាល់ច្បាស់នូវបឋវីកសិណ ខាងលើ[១] ខាងក្រោម[២] និងទទឹង[៣] ជាកសិណតែបែបមួយ ឥតមានលាយឡំ (នឹងកសិណឯទៀត)

១ កសិណដែលត្រូវចម្រើនងើយមើលទៅខាងលើអាកាស ។ ២ កសិណដែលត្រូវចម្រើនដាក់មុខមករកផ្ទៃផែនដី ។ ៣ កសិណដែលត្រូវចម្រើនជុំវិញខេត្តមណ្ឌល (សង្ខិត្តិសុត្តវណ្ណនា) ។

អប្បមាណំ ។ អាបោកសិណមេកោ សញ្ជានាតិ ។ តេជោកសិណមេកោ សញ្ជានាតិ ។ វាយោកសិណមេកោ សញ្ជានាតិ ។ នីលកសិណមេកោ សញ្ជានាតិ ។ បីតកសិណមេកោ សញ្ជានាតិ ។ លោហិតកសិណមេកោ សញ្ជានាតិ ។ ឱទាតកសិណមេកោ សញ្ជានាតិ ។ អាកាសកសិណមេកោ សញ្ជានាតិ ។ វិញ្ញាណកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ ច តិរិយំ អទ្វយំ អប្បមាណំ ។ ឥមេ ទស ធម្មា ភាវេតព្វា ។

[៣៣៩] កតមេ ទស ធម្មា បរិញ្ញេយ្យា ។ ទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ ។ ឥមេ ទស ធម្មា បរិញ្ញេយ្យា ។

មានការផ្សាយនឹងប្រមាណមិនបាន ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវអាបោកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវតេជោ-កសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវវាយោកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវនីលកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវបីតកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវលោ-ហិតកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវឱទាតកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវអាកាសកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់ នូវវិញ្ញាណកសិណ ខាងលើ ខាងក្រោម និងទទឹង ជាកសិណតែបែបមួយ ឥតមានលាយឡំ (នឹងកសិណឯទៀត) ហើយ មានការផ្សាយនឹងប្រមាណមិនបាន ១ ។ ធម៌ទាំង ១០ នេះ គួរបម្រើន ។

[៣៣៩] ធម៌ ១០ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ អាយតនៈ (ហេតុជាទីកើតនៃចិត្ត) ១០ គឺ ភ្នែក ជាកន្លែងកើតចិត្ត ១ រូប ជាកន្លែងកើតចិត្ត ១ ត្រចៀក ជាកន្លែងកើតចិត្ត ១ សម្លេង ជាកន្លែងកើតចិត្ត ១ ច្រមុះ ជាកន្លែងកើតចិត្ត ១ ក្លិន ជាកន្លែងកើតចិត្ត ១ អណ្តាត ជាកន្លែងកើតចិត្ត ១ រស ជាកន្លែងកើតចិត្ត ១ កាយ ជាកន្លែងកើតចិត្ត ១ ផោដ្ឋព្វៈ ជាកន្លែងកើតចិត្ត ១ ។ ធម៌ទាំង ១០ នេះ គួរកំណត់ដឹង ។

[៣៤០] កតមេ ទស ធម្មា បហាតព្វា ។ ទស មិច្ឆត្តា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា មិច្ឆាកម្មន្តោ មិច្ឆាអាជីវោ មិច្ឆាវាយាមោ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាញាណំ មិច្ឆាវិមុត្តិ ។ ឥមេ ទស ធម្មា បហាតព្វា ។

[៣៤១] កតមេ ទស ធម្មា ហានភាគិយា ។ ទស អកុសលកម្មបថា បាណាតិបាតោ អទិន្នា-ទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ អភិជ្ឈា ព្យា-បាទោ មិច្ឆាទិដ្ឋិ ។ ឥមេ ទស ធម្មា ហាន-ភាគិយា ។

[៣៤២] កតមេ ទស ធម្មា វិសេសភាគិយា ។ ទស កុសលកម្មបថា បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី

[៣៤០] ធម៌ ១០ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ សភាពដែលខុស ១០ យ៉ាង គឺ ការយល់ខុស ១ ការត្រិះរិះខុស ១ ពោលពាក្យខុស ១ ការងារខុស ១ ចិញ្ចឹមជីវិតខុស ១ សេចក្តីព្យាយាមខុស ១ ការរលឹកខុស ១ ការតាំងចិត្តខុស ១ ការដឹងខុស ១ ការរួចខុស ១ ។ ធម៌ទាំងដប់នេះ គួរលះបង់ ។

[៣៤១] ធម៌ ១០ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ គន្លងនៃអកុសលកម្ម ១០ យ៉ាង គឺ ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ១ ពោលពាក្យទ្រគោះ ១ ពោលពាក្យឥតប្រយោជន៍ ១ ចិត្តគិតសំឡឹងរំពៃ បង្អោនទ្រព្យអ្នកដទៃ មកជាទ្រព្យរបស់ខ្លួន ១ ចិត្តគុំគួន ១ ការយល់ខុស ១ ។ ធម៌ទាំង ១០ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[៣៤១] ធម៌ ១០ ដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ គន្លងនៃកុសលកម្ម ១០ គឺ ចេតនាជាហេតុវៀរចាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ វៀរចាកការពោលពាក្យកុហក ១ វៀរចាកការពោលពាក្យញុះញង់ ១

ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អនភិជ្ឈា អព្យាបាទោ សម្មាទិដ្ឋិ ។ ឥមេ ទស ធម្មា វិសេសភាគិយា ។

[៣៤៣] កតមេ ទស ធម្មា ទុប្បដិវិជ្ឈា ។ ទស អរិយវាសា ឥធាវុសោ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាបស្សេ-នោ បនុណ្ណប្បច្ចេកសច្ចោ សមវយសដ្ឋេសនោ អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ សុវិមុត្តប្បញ្ញោ ។ កថញ្ចាវុសោ ភិក្ខុ បញ្ចង្គវិប្ប-ហីនោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ កាមច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ ថីន-មិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ វិចិកិច្ឆា បហីនា ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ បញ្ចង្គវិប្បហីនោ ហោតិ ។ កថញ្ចា-វុសោ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ ។

វៀរចាកការពោលពាក្យទ្រគោះ ១ វៀរចាកការពោលពាក្យ ពោយរាយឥតប្រយោជន៍ ១ ចិត្តមិនសំឡឹងរំពៃ បង្អោនទ្រព្យអ្នកដទៃ មកជាទ្រព្យរបស់ខ្លួន ១ ចិត្តមិនគុំគួន ១ ការយល់ត្រូវ ១ ។ ធម៌ទាំង ១០ នេះជាចំណែកវិសេស ។

[៣៤៣] ធម៌ទាំង ១០ ដែលយល់បានដោយក្រ តើដូចម្តេចខ្លះ ។ ធម៌ជាគ្រឿងនៅអាស្រ័យរបស់អរិយៈ ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់អង្គប្រាំ ១ ប្រកបដោយឆឡង្គុបេក្ខា ១ ជាអ្នករក្សាធម៌តែមួយ ១ មានធម៌ជាបង្អែក ៤ យ៉ាង ១ ជាអ្នកកម្ចាត់បង់នូវសច្ចធម៌ដោយឡែក ១ ជាអ្នកលះបង់ដោយប្រពៃនូវការស្វែងរក ១ មានសេចក្តីត្រិះរិះមិនសៅហ្មង ១ មានកាយសង្ខារស្ងប់រម្ងាប់ ១ មានចិត្តរួចស្រឡះហើយដោយល្អ ១ មានប្រាជ្ញាដឹងថា ចិត្តរួចស្រឡះដោយល្អ ១ ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកលះបង់អង្គ ៥ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់កាមច្ឆន្ទៈ ១ លះបង់ព្យាបាទៈ ១ លះបង់ថីនមិទ្ធៈ ១ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ១ លះបង់វិចិកិច្ឆា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុលះបង់អង្គ ៥ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុប្រកបដោយឆឡង្គុបេក្ខា តើដូចម្តេច ។

ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ ។ ឯវំ ខោ អាវុសោ ភិក្ខុ ឆឡង្គ-សមន្នាគតោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ ឯកា-រក្ខោ ហោតិ ។ ឥធាវុសោ ភិក្ខុ សតារក្ខេន ចេតសា សមន្នាគតោ ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ ឯការក្ខោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ ចតុរាបស្សេនោ ហោតិ ។ ឥធាវុសោ ភិក្ខុ សង្ខា-យេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខា-យេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ ចតុរាបស្សេនោ ហោតិ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូប ដោយភ្នែកហើយ ជាអ្នកមិនមានសោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយ ប្រកបដោយសតិនិងសម្បជញ្ញៈ ។ បានឮសំឡេង ដោយត្រចៀក ។ បានធុំក្លិនដោយច្រមុះ ។ បានទទួលរសដោយអណ្តាត ។ បានពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ បានដឹងធម្មារម្មណ៍ដោយចិត្ត ហើយជាអ្នកមិនមានសោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយ ប្រកបដោយសតិនិងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុរក្សាធម៌តែមួយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត មានសតិជាគ្រឿងរក្សាទុក ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុរក្សាធម៌តែមួយដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានធម៌ជាបង្អែក ៤ យ៉ាង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយទើបសេព របស់ដែលគួរសេព ១ ពិចារណាហើយទើបអត់សង្កត់របស់ដែលគួរអត់សង្កត់ ១ ពិចារណាហើយទើបវៀររបស់ដែលគួរវៀរ ១ ពិចារណាហើយទើបបន្ទោបង់របស់ដែលគួរបន្ទោបង់ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានបង្អែក ៤ យ៉ាង ដោយអាការយ៉ាងនេះឯង ។

កថញ្ចាវុសោ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ ហោតិ ។ ឥធាវុសោ ភិក្ខុនា[១] យានិ តានិ បុថុសមណ-ព្រាហ្មណានំ បុថុប្បច្ចេកសច្ចានិ សព្វានិ តានិ នុណ្ណានិ ហោន្តិ បនុណ្ណានិ ចត្តានិ វន្តានិ មុត្តា-និ បហីនានិ បដិនិស្សដ្ឋានិ[២] ។ ឯវំ ខោ អាវុសោ ភិក្ខុ បនុណ្ណប្បច្ចេកសច្ចោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ សមវយស្សដ្ឋេសនោ ហោតិ ។ ឥធាវុសោ ភិក្ខុនា[៣] កាមេសនា បហីនា ហោតិ ភវេសនា បហីនា ហោតិ ព្រហ្មចរិយេសនា បដិ-និស្សដ្ឋា ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ សម-វយស្សដ្ឋេសនោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ អនាវិលសង្កប្បោ ហោតិ ។ ឥធាវុសោ ភិក្ខុនា[៤] កាមសង្កប្បោ បហីនោ ហោតិ ព្យាបាទសង្កប្បោ បហីនោ ហោតិ វិហឹសាសង្កប្បោ បហីនោ ហោតិ ។

---

១ ម. ភិក្ខុនោ ។ ២ ឱ. ម. បដិបស្សទ្ធានិ ។ ៣-៤ ម. ភិក្ខុនោ ។

ទសុត្តរសូត្រ ប្រភេទនៃធម៌ដប់ ៗ

ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកកម្ចាត់បង់នូវសច្ចធម៌ ដោយឡែក តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បាននាំចេញ បន្ទោបង់ លះចោល ខ្ជាក់ចោល ស្រាយចេញ លះបង់ ផ្ដាច់ផ្ដិលនូវសច្ចៈដ៏ផ្សេងគ្នាជាច្រើន របស់សមណៈនិងព្រាហ្មណ៍ដ៏ច្រើន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកកម្ចាត់បង់ នូវសច្ចធម៌ដោយឡែក ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកលះបង់ដោយប្រពៃ នូវការស្វែងរក តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់ការស្វែងរកកាម លះបង់ការស្វែងរកភព លះបង់ការស្វែងរកព្រហ្មចារ្យចេញហើយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកលះបង់ដោយប្រពៃ នូវការស្វែងរក ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានសេចក្ដីត្រិះរិះមិនបានសៅហ្មង តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់សេចក្ដីត្រិះរិះក្នុងកាម លះបង់សេចក្ដីត្រិះរិះក្នុងការព្យាបាទ លះបង់សេចក្ដីត្រិះរិះ ក្នុងការបៀតបៀន ។

ឯវំ ខោ អាវុសោ ភិក្ខុ អនាវិលសង្កប្បោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ បស្សទ្ធកាយសង្ខារោ ហោតិ ។ ឥធាវុសោ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេ វ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧប-សម្បជ្ជ វិហរតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ បស្សទ្ធ-កាយសង្ខារោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ សុវិមុត្តចិត្តោ ហោតិ ។ ឥធាវុសោ ភិក្ខុនោ រាគា ចិត្តំ វិមុត្តំ ហោតិ ទោសា ចិត្តំ វិមុត្តំ ហោតិ មោហា ចិត្តំ វិមុត្តំ ហោតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ សុវិ-មុត្តចិត្តោ ហោតិ ។ កថញ្ចាវុសោ ភិក្ខុ សុវិមុត្ត-ប្បញ្ញោ ហោតិ ។ ឥធាវុសោ ភិក្ខុ រាគោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភា-វង្កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះ មិនបានសៅហ្មងដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានកាយសង្ខារ ស្ងប់រម្ងាប់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះបានលះបង់សុខផង លះបង់ទុក្ខផង ព្រោះរំលត់នូវសោមនស្សនិងទោមនស្ស ក្នុងកាលមុនផង ហើយក៏បានចូលចតុត្ថជ្ឈាន ដែលគ្មានទុក្ខ គ្មានសុខ មានតែឧបេក្ខានិងសតិដ៏បរិសុទ្ធ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកាយសង្ខារ ស្ងប់រម្ងាប់ហើយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តរួចស្រឡះហើយចាករាគៈ មានចិត្តរួចស្រឡះហើយចាកទោសៈ មានចិត្តរួចស្រឡះហើយចាកមោហៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានប្រាជ្ញាដឹងថាចិត្តរួចស្រឡះហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះដឹងច្បាស់ថា រាគៈអាត្មាអញបានលះបង់ហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀត ដូចដើមត្នោត (កំបុត-ក) ហើយធ្វើមិនឲ្យមានទៀត មិនឲ្យកើតតទៅទៀតជាធម្មតា ។

ទោសោ មេ បហីនោ ។ បេ ។ មោហោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ បជានាតិ ។ ឯវំ ខោ អាវុសោ ភិក្ខុ សុវិមុត្តបញ្ញោ ហោតិ ។ ឥមេ ទស ធម្មា ទុប្បដិវិជ្ឈា ។

[៣៦៦] កតមេ ទស ធម្មា ឧប្បាទេតព្វា ។ ទស សញ្ញា អសុភសញ្ញា មរណសញ្ញា អាហារេ បដិកូលសញ្ញា សព្វលោកេ អនភិរតសញ្ញា អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ ឥមេ ទស ធម្មា ឧប្បាទេតព្វា ។

ដឹងច្បាស់ថា ទោសៈអាត្មាអញបានលះបង់ហើយ ។ បេ ។ មោហៈ អាត្មាអញបានលះបង់ហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែង កើតទៀត ដូចជាដើមត្នោត (កំបុតក) ហើយធ្វើមិនឲ្យមានទៀត មិន ឲ្យកើតតទៅទៀតជាធម្មតា ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមាន ប្រាជ្ញាដឹងថា ចិត្តរួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះ ឯង ។ ធម៌ទាំង ១០ នេះ យល់បានដោយក្រ ។

[៣៤៤] ធម៌ ១០ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សេចក្តីសំគាល់ ១០ យ៉ាង គឺសេចក្តីសំគាល់ថា មិនល្អ ១ សេចក្តី សំគាល់ចំពោះមរណៈ ១ សេចក្តីសំគាល់ក្នុងអាហារថា ជារបស់គួរ ខ្ពើម ១ សេចក្តីសំគាល់របស់បុគ្គលជាអ្នកមិនត្រេកអរ ក្នុងលោកទាំង ពួង ១ សេចក្តីសំគាល់ថា មិនទៀង ១ សេចក្តីសំគាល់ក្នុងរបស់ ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសំគាល់ក្នុងរបស់ដែលជាទុក្ខថា មិន មែនរបស់ខ្លួន ១ សេចក្តីសំគាល់នូវរបស់ដែលត្រូវលះបង់ ១ សេចក្តីសំ-គាល់ថា គួរនឿយណាយ ១ សេចក្តីសំគាល់ថា រលត់ទៅនៃកងទុក្ខ ១ ។ ធម៌ទាំង ១០ នេះ គួរឲ្យកើតឡើង ។

[៣៤៩] កាតមេ ទស ធម្មា អភិញ្ញេយ្យា ។ ទស និជ្ជិណ្ណវត្ថូនិ[១] សម្មាទិដ្ឋិស្ស មិច្ឆាទិដ្ឋិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាទិដ្ឋិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស[២] និជ្ជិណ្ណា ហោន្តិ សម្មាទិដ្ឋិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសង្កប្បស្ស មិច្ឆាសង្កប្បោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆា-សង្កប្បប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មា-សង្កប្បប្បច្ចយា ច អនេកេ អកុសលា ធម្មា ភាវ-នាបារិបូរឹ គច្ឆន្តិ ។ សម្មាវាចស្ស មិច្ឆាវាចា និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាវាចាបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាវាចាបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាកម្មន្តស្ស មិច្ឆាកម្មន្តោ

---

១ ឱ. និជ្ជរវត្ថូនិ ។ ២ ម. តេចស្ស ។

[៣៤៥] ធម៌ ១០ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ ហេតុនៃសេចក្តីសាបសូន្យ ១០ គឺ បុគ្គលមានគំនិតយល់ត្រូវហើយ ការយល់ខុស ក៏សាបសូន្យអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះការយល់ខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវការចម្រើនបរិបូណ៌ឡើង ព្រោះគំនិតយល់ត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានសេចក្តីត្រិះរិះត្រូវហើយ សេចក្តីត្រិះរិះខុស ក៏សាបសូន្យអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះសេចក្តីត្រិះរិះខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវការចម្រើនបរិបូណ៌ឡើង ព្រោះសេចក្តីត្រិះរិះត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានវាចាត្រូវហើយ វាចាខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះវាចាខុសជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯអកុសលធម៌ច្រើន ក៏ដល់នូវការចម្រើនបរិបូណ៌ឡើង ព្រោះវាចាត្រូវជាបច្ច័យ ១ ។ បុគ្គលមានការងារត្រូវហើយ ការងារខុស

និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆាកម្មន្តប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាកម្មន្តប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាអាជីវស្ស មិច្ឆា-អាជីវោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆាអាជីវប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាអាជីវប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាវាយា-មស្ស មិច្ឆាវាយាមោ និជ្ជិណ្ណោ ហោតិ យេ ច មិច្ឆា-វាយាមប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាវាយា-មប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនា-បារិបូរឹ គច្ឆន្តិ ។ សម្មាសតិស្ស មិច្ឆាសតិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាសតិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាសតិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសមាធិស្ស មិច្ឆាសមាធិ

ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះការងារខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវការចម្រើនបរិបូណ៌ឡើង ព្រោះការងារត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានការចិញ្ចឹមជីវិតត្រូវហើយ ការចិញ្ចឹមជីវិតខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាងដែលកើតឡើង ព្រោះការចិញ្ចឹមជីវិតខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវសេចក្ដីចម្រើនបរិបូណ៌ឡើង ព្រោះការចិញ្ចឹមជីវិតត្រូវជាបច្ច័យ ១ ។ បុគ្គលដែលមានព្យាយាមត្រូវហើយ សេចក្ដីព្យាយាមខុស ក៏សាបសូន្យអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះសេចក្ដីព្យាយាមខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្ដីចម្រើនបរិបូណ៌ឡើង ព្រោះសេចក្ដីព្យាយាមត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានការរលឹកត្រូវហើយ ការរលឹកខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលកើតឡើង ព្រោះការរលឹកខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្ដីចម្រើនបរិបូណ៌ឡើង ព្រោះការរលឹកត្រូវ ជាបច្ច័យ ១ ។ បុគ្គលដែលមានការស្មឹងស្មាធិ៍ត្រូវហើយ ការស្មឹងស្មាធិ៍ខុស

និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាសមាធិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាសមាធិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាញាណស្ស មិច្ឆា-ញាណំ និជ្ជិណ្ណំ ហោតិ យេ ច មិច្ឆាញាណប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មាញាណប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាវិមុត្តស្ស មិច្ឆាវិមុត្តិ និជ្ជិណ្ណា ហោតិ យេ ច មិច្ឆាវិមុត្តិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេបស្ស និជ្ជិណ្ណា ហោន្តិ សម្មា-វិមុត្តិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនា-បារិបូរឹ គច្ឆន្តិ ។ ឥមេ ទស ធម្មា អភិញ្ញេយ្យា ។

ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលកើតឡើង ព្រោះការស្មឹងស្មាធ៏ខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើនបរិបូណ៌ឡើង ព្រោះការស្មឹងស្មាធ៏ត្រូវ ជាបច្ច័យ ១ ។ បុគ្គលដែលមានកិរិយាដឹងត្រូវហើយ កិរិយាដឹងខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលកើតឡើង ព្រោះកិរិយាដឹងខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើនបរិបូណ៌ឡើង ព្រោះកិរិយាដឹងត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានកិរិយារួចត្រឹមត្រូវហើយ កិរិយារួចខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមក ច្រើនប្រការ ដែលកើតឡើង ព្រោះកិរិយារួចខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើនបរិបូណ៌ឡើង ព្រោះកិរិយារួចត្រូវ ជាបច្ច័យ ១ ។ ធម៌ទាំង ១០ នេះ គួរដឹងច្បាស់ ។

[៣៤៦] កតមេ ទស ធម្មា សច្ឆិកាតព្វា ។ ទស អសេក្ខា ធម្មា អសេក្ខា សម្មាទិដ្ឋិ អសេក្ខោ សម្មាសង្កប្បោ អសេក្ខា សម្មាវាចា អសេក្ខោ សម្មាកម្មន្តោ អសេក្ខោ សម្មាអាជីវោ អសេក្ខោ សម្មាវាយាមោ អសេក្ខា សម្មាសតិ អសេក្ខោ សម្មាសមាធិ អសេក្ខំ សម្មាញាណំ អសេក្ខា សម្មាវិមុត្តិ ។ ឥមេ ទស ធម្មា សច្ឆិកាតព្វា ។ ឥតិ ឥមេ សតធម្មា[១] ភូតា តច្ឆា តថា អវិតថា អនញ្ញថា សម្មា តថាគតេន អភិសម្ពុទ្ធាតិ ។

ឥទមវោច អាយស្មា សារីបុត្តោ ។ អត្តមនា តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

ទសុត្តរសុត្តំ ឯកាទសមំ[២] និដ្ឋិតំ ។

បាដិកវគ្គោ និដ្ឋិតោ[៣] ។

---

១ ឱ. សតំ ធម្មា ។ ២ ឱ. ទសុត្តរសុត្តន្តំ ។ ម. ទសុត្តរសុត្តន្តំ ឯកាទសមំ សមត្តំ ។ ៣ ឱ. បាដិកវគ្គោ ។

ទសុត្តរសូត្រ ប្រភេទនៃធម៌ដប់ ១

[៣៤៦] ធម៌ ១០ គួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ ធម៌ជារបស់អសេក្ខៈ ១០ យ៉ាង គឺសម្មាទិដ្ឋិ ជារបស់អសេក្ខៈ ១ សម្មាសង្កប្បៈ ជារបស់អសេក្ខៈ ១ សម្មាវាចា ជារបស់អសេក្ខៈ ១ សម្មាកម្មន្តៈជារបស់អសេក្ខៈ ១ សម្មាអាជីវៈ ជារបស់អសេក្ខៈ ១ សម្មាវាយាមៈជារបស់អសេក្ខៈ ១ សម្មាសតិ ជារបស់អសេក្ខៈ ១ សម្មាសមាធិ ជារបស់អសេក្ខៈ ១ សម្មាញាណ ជារបស់អសេក្ខៈ ១ សម្មាវិមុត្តិ ជារបស់អសេក្ខៈ ១ ។ ធម៌ទាំង ១០ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ១០០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។ លុះព្រះសារីបុត្តមានអាយុបានសំដែងសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះសារីបុត្តមានអាយុ ។

ចប់ ទសុត្តរសូត្រ ទី ១១ ។

ចប់ បាដិកវគ្គ តែប៉ុណ្ណោះ ។

សុត្តន្តបិដកេ ទីឃនិកាយស្ស បាដិកវគ្គោ

# តស្សុទ្ទានំ

ចាដិកញ្ច ឧទុម្ពរំ
ចក្កវត្តិ ច អគ្គញ្ញំ
សម្បសាទញ្ច ចាសាទំ
លក្ខណោ សិង្គាលកំ
អាដានាដិយំ សង្គីតិ
ទសុត្តរេ ឯកាទសាតិ[១] ។

ចតុត្តឹសសុត្តបតិមណ្ឌិតោ ទីឃនិកាយោ និដ្ឋិតោ[២] ។

---

១ ឱ. បាដិកោ ទុម្ពរី ចេវ ចក្កវត្តិ អគ្គញ្ញកំ សម្បសាទញ្ច បាសាទំ មហាបុរិសលក្ខណំ សិង្គាលាដានាដិយកំ សង្គីតិញ្ច ទសុត្តរំ ឯកាទសហិ សុត្តេហិ បាដិកវគ្គោតិ វុច្ចតីតិ ឥតិសុទ្ធានំ ទិស្សតិ ។ ម. តត្រុទ្ទានំ

បាដិកោ ច ឱទុម្ពរំ ចក្កវត្តិ អគ្គញ្ញកំ សម្បសាទនបាសាទំ មហាបុរិសលក្ខណំ សិង្គាលាដានាដិយកំ សំគីតិ ច ទសុត្តរំ ឯកាទសហិ សុត្តេហិ បាដិកវគ្គោតិ វុច្ចតីតិ ឥតិសុទ្ធានំ ទិស្សតិ ។ ២ ឱ. ម. ចតុត្តឹសសុត្តបតិមណ្ឌិតោ ទីឃនិកាយោ និដ្ឋិតោតិ ន ទិស្សតិ ។

សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ

បញ្ជីឈ្មោះសូត្រនៃបាដិកវគ្គនោះ ដូច្នេះគឺ

បាដិកសូត្រ ១ ឧទុម្ពរិកសូត្រ ១ ចក្កវត្តិសូត្រ ១ អគ្គញ្ញ-
សូត្រ ១ សម្បសាទនីយសូត្រ ១ បាសាទិកសូត្រ ១
លក្ខណសូត្រ ១ សិង្គាលកសូត្រ ១ អាដានាដិយសូត្រ ១
សង្គីតិសូត្រ ១ និងទសុត្តរសូត្រ ១ រួមត្រូវជា ១១ សូត្រ ។

ចប់ គម្ពីរទីឃនិកាយ ប្រដាប់ដោយសូត្រ ៣៤ ។

៣៤៧

ទសុត្តរសុត្តេ ឧទ្ទានគាថា

ចតុត្តឹសេ ច សុត្តន្តា
តិវគ្គោ យស្ស សង្គហោ
ឯស ទីឃនិកាយោតិ
បឋមោ អនុលោមិកោ ។
កស្មា បនេស
ទីឃនិកាយោតិ វុច្ចតិ ។
ទីឃប្បមាណានំ សុត្តានំ
សមូហតោ និវាសតោ
សមូហនិវាសាហិ
ទីឃនិកាយោតិ វុច្ចតិ[១] ។

---

១ ឱ. ម. ចតុត្តឹសេ ច សុត្តន្តា តិវគ្គោ យស្ស សង្គហោ ឯស ទីឃនិកាយោតិ បឋមោ អនុលោមិកោ ។ កស្មា បនេស ទីឃនិកាយោតិ វុច្ចតិ ។ ទីឃប្បមាណានំ សុត្តានំ សមូហតោ និវាសតោ សមូហនិវាសាហិ ទីឃនិកាយោតិ វុច្ចតីតិ ន ទិស្សន្តិ ។

ទសុត្តរសូត្រ ឧទ្ទានគាថា

និកាយណា សង្គ្រោះដោយសូត្រ ៣៤ និងវគ្គ ៣ និកាយនុ៎ះ ឈ្មោះថា ទីឃនិកាយ ជានិកាយអនុលោមដំបូង ។ ចុះនិកាយនោះ ដែលលោកហៅថា ទីឃនិកាយ តើព្រោះហេតុអ្វី ។ បានជាលោកហៅថា ទីឃនិកាយ ព្រោះជាទីប្រជុំ ជាទីនៅអាស្រ័យ ជាទីប្រជុំរួបរួមនៃសូត្រទាំងឡាយដែលមានប្រមាណវែង ៗ ។

# សុត្តន្តបិដកេ ទីឃនិកាយស្ស

# បាដិកវគ្គោ

# ឆដ្ឋោ ភាគោ

## លក្ខណសុត្តំ សត្តមំ


| មាតិកា | | អង្កេ |
|---|---|---|
| *លក្ខណសុត្តេ* | *ទ្វត្តឹសមហាបុរិសលក្ខណកថា*......................................... | *៣* |
| | *តថាគតបុញ្ញាធិការកថា*......................................................... | *៧* |
| | *តថាគតបុញ្ញាធិការគាថា*...................................................... | *២១* |
| | *តថាគតបុញ្ញាធិការកថា*......................................................... | *២៥* |
| | *តថាគតបុញ្ញាធិការគាថា*...................................................... | *២៧* |
| | *តថាគតបុញ្ញាធិការកថា*......................................................... | *៣៧* |
| | *តថាគតបុញ្ញាធិការគាថា*...................................................... | *៤១* |
| | *តថាគតបុញ្ញាធិការកថា*......................................................... | *៤៣* |
| | *តថាគតបុញ្ញាធិការគាថា*...................................................... | *៥៧* |
| | *តថាគតបុញ្ញាធិការកថា*......................................................... | *៥៩* |
| | *តថាគតបុញ្ញាធិការគាថា*...................................................... | *៦៥* |

# សុត្តន្តបិដក ទីឃនិកាយ

# បាដិកវគ្គ

# ឆដ្ឋភាគ

## *លក្ខណសូត្រ ទី ៧*

មាតិកា លេខទំព័រ

| | | |
|---|---|---|
| លក្ខណសូត្រ | ពោលអំពីមហាបុរិសលក្ខណៈ ៣២ ប្រការ...................................... | ៣ |
| | ពោលអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត .................................... | ៧ |
| | គាថាសំដែងអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត............................ | ២១ |
| | ពោលអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត .................................... | ២៥ |
| | គាថាសំដែងអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត............................ | ២៧ |
| | ពោលអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត .................................... | ៣៧ |
| | គាថាសំដែងអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត............................ | ៤១ |
| | ពោលអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត..................................... | ៤៣ |
| | គាថាសំដែងអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត............................ | ៥៧ |
| | ពោលអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត .................................... | ៥៩ |
| | គាថាសំដែងអំពីការកសាងបុញ្ញកម្មនៃព្រះតថាគត............................ | ៦៥ |

# មាតិកាបត្តានិ


| | មាតិកា | អង្កេ |
|---|---|---|
| | **សិង្គាលកសុត្តំ អដ្ឋមំ** | |
| *សិង្គាលកសុត្តេ* | *ចត្តារោ កម្មក្កិលេសា* | *៦៩* |
| | *ឆអបាយមុខកថា* | *៧១* |
| | *ចត្តារោ អមិត្តា* | *៧៩* |
| | *ចត្តារោ មិត្តា សុហទា* | *៨១* |
| | *និគមគាថា* | *៨៣* |
| | *៦ ទិសា ទក្ខិណា ទិសា* | *៨៥* |
| | *៦ ទិសា ឧត្តរា ទិសា* | *៨៧* |
| | *៦ ទិសា ឧបរិមា ទិសា* | *៨៩* |
| | *ហេដ្ឋិមា ទិសា ឧបរិមា ទិសា* | *៩១* |
| | *សិង្គាលកស្ស ថោមនា ច សរណគមនញ្ច* | *៩៣* |
| | **អាដានាដិយសុត្តំ នវមំ** | |
| *អាដានាដិយសុត្តេ* | *ចាតុម្មហារាជវត្ថុ* | *៩៥* |
| | *សត្តសម្មាសម្ពុទ្ធានំ នមក្ការគាថា* | *៩៧* |
| | *សុរិយាទិច្ចស្ស ឧគ្គមនំ* | *៩៩* |
| | *ទក្ខិណទិសាយ វិរុឡ្ហោ មហារាជា* | *១០១* |

# សន្លឹកចង្អុលប្រាប់មាតិកា

## សិង្គាលកសូត្រ ទី ៨


| | មាតិកា | លេខទំព័រ |
|---|---|---|
| សិង្គាលកសូត្រ | កម្មក្កិលេស ៤ យ៉ាង | ៦៩ |
| | ពោលអំពីអបាយមុខ ៦ យ៉ាង | ៧១ |
| | បុគ្គលមិនមែនជាមិត្តមាន ៤ ពួក | ៧៩ |
| | មិត្ត ៤ ពួកដែលមានសន្តានល្អ | ៨១ |
| | និគមគាថា | ៨៣ |
| | ទិសទាំង ៦ និយាយអំពីទិសខាងត្បូង | ៨៥ |
| | ទិសទាំង ៦ និយាយអំពីទិសខាងជើង | ៨៧ |
| | ទិសទាំង ៦ និយាយអំពីទិសខាងលើ | ៨៩ |
| | និយាយអំពីទិសខាងក្រោមនិងទិសខាងលើ | ៩១ |
| | សេចក្តីសរសើរនៃសិង្គាលកមាណនិងការដល់នូវសរណៈគមន៍ | ៩៣ |


## អាដានាដិយសូត្រ ទី ៩


| | | |
|---|---|---|
| អាដានាដិយសូត្រ | រឿងមហារាជទាំង ៤ | ៩៥ |
| | គាថានមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ៧ ព្រះអង្គ | ៩៧ |
| | ដំណើររះឡើងនៃព្រះអាទិត្យមានរស្មីដ៏ភ្លៀវភ្លា | ៩៩ |
| | វិរុឡ្ហមហារាជគង់ក្នុងទិសខាងត្បូង | ១០១ |

# មាតិកាបត្តានិ


| | មាតិកា | អង្កេ |
|---|---|---|
| អាដានាដិយសុត្តេ | សុរិយាទិច្ចស្ស ឧគ្គមនំ | ១០៣ |
| | ឧត្តរកុរុអាទិកថា | ១០៥ |
| | ហត្ថិយានាទិកថា | ១០៧ |
| | អាដានាដិយា រក្ខា | ១០៩ |
| | យក្ខាទយោ អមនុស្សា | ១១៥ |
| | ចាតុម្មហារាជាទិប្បវត្តិកថា | ១១៧ |


## សង្គីតិសុត្តំ ១០សមំ


| | | |
|---|---|---|
| សង្គីតិសុត្តេ | ភគវតោ សណ្ឋាគារូបសង្កមនំ | ១២៥ |
| | និគណ្ឋនាដបុត្តកាលកិរិយា | ១២៧ |
| | អទ្ធនិយព្រហ្មចរិយកថា | ១២៩ |
| | សង្គីតិយទុកំ | ១៣១ |
| | សង្គីតិយត្តិកំ | ១៣៥ |
| | សង្គីតិយចតុក្កំ | ១៤៧ |
| | សង្គីតិយបញ្ចកំ | ១៧៣ |
| | សង្គីតិយឆក្កំ | ១៩៣ |
| | សង្គីតិយសត្តកំ | ២០៩ |

# សង្ខេបតារាងមាតិកា


| | មាតិកា | លេខទំព័រ |
|---|---|---|
| អាដានាដិយសូត្រ | ដំណើររះឡើងនៃព្រះអាទិត្យមានរស្មីដ៏ភ្លៀវភ្លា................ | ១០៣ |
| | និយាយអំពីឧត្តរកុរុទ្វីបជាដើម........................................ | ១០៥ |
| | និយាយអំពីយានដំរីជាដើម........................................... | ១០៧ |
| | ការរក្សាជាប់ទាក់ទងដោយអាដានាដានគរ..................... | ១០៩ |
| | ពួកអមនុស្សមានយក្ខជាដើម......................................... | ១១៥ |
| | ពោលអំពីរឿងរ៉ាវនៃស្តេចធំទាំង ៤ ជាដើម ................... | ១១៧ |

*សង្គីតិសូត្រ ទី ១០*

| | | |
|---|---|---|
| សង្គីតិសូត្រ | ព្រះមានព្រះភាគស្តេចចូលទៅកាន់សណ្ឋាគារស្ថាន......... | ១២៥ |
| | ការធ្វើមរណកាលនៃនិគ្គណ្ឋនាដបុត្រ............................. | ១២៧ |
| | ពោលអំពីព្រហ្មចរិយធម៌ដែលតាំងនៅស្ថិតស្ថេរ.............. | ១២៩ |
| | ពួកធម៌ពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា.................. | ១៣១ |
| | ពួកធម៌បី ៗ ដែលរាប់ចូលក្នុងការសង្គាយនា.................... | ១៣៥ |
| | ពួកធម៌បួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា................ | ១៤៧ |
| | ពួកធម៌ប្រាំ ៗ ដែលរាប់ចូលក្នុងការសង្គាយនា................ | ១៧៣ |
| | ពួកធម៌ប្រាំមួយ ៗ ដែលរាប់ចូលក្នុងការសង្គាយនា........... | ១៩៣ |
| | ពួកធម៌ប្រាំពីរ ៗ ដែលរាប់ចូលក្នុងការសង្គាយនា............ | ២០៩ |

# មាតិកាបត្តានិ


| | មាតិកា | អង្កេ |
|---|---|---|
| *សង្គីតិសុត្តេ* | *សង្គីតិយអដ្ឋកំ* | ២១៥ |
| | *សង្គីតិយនវកំ* | ២៣៣ |
| | *សង្គីតិយទសកំ* | ២៤៣ |
| | *ភគវតោ សាធុការទានំ* | ២៥៣ |


## ទសុត្តរសុត្តំ ឯកាទសមំ


| | | |
|---|---|---|
| *ទសុត្តរសុត្តេ* | *ធម្មប្បភេទឯកកំ* | ២៥៥ |
| | *ធម្មប្បភេទទុកំ* | ២៥៧ |
| | *ធម្មប្បភេទត្តិកំ* | ២៥៩ |
| | *ធម្មប្បភេទចតុក្កំ* | ២៦៣ |
| | *ធម្មប្បភេទបញ្ចកំ* | ២៦៧ |
| | *ធម្មប្បភេទច្ឆក្កំ* | ២៧៩ |
| | *ធម្មប្បភេទសត្តកំ* | ២៩៥ |
| | *ធម្មប្បភេទអដ្ឋកំ* | ៣០៥ |
| | *ធម្មប្បភេទនវកំ* | ៣២៩ |
| | *ធម្មប្បភេទទសកំ* | ៣៤១ |
| | *ឧទ្ទានគាថា* | ៣៥៧ |

# សង្ខឹកចង្អុលប្រាប់មាតិកា


| | មាតិកា | លេខទំព័រ |
|---|---|---|
| សង្គីតិសូត្រ | ពួកធម៌ប្រាំបី ៗ ដែលរាប់ចូលក្នុងការសង្គាយនា.............. | ២១៥ |
| | ពួកធម៌ប្រាំបួន ៗ ដែលរាប់ចូលក្នុងការសង្គាយនា........... | ២៣៣ |
| | ពួកធម៌ដប់ ៗ ដែលរាប់ចូលក្នុងការសង្គាយនា................ | ២៤៣ |
| | ព្រះមានព្រះភាគទ្រង់ប្រទានសាធុការ............................ | ២៥៣ |
| | *ទសុត្តរសូត្រ ទី ១១* | |
| ទសុត្តរសូត្រ | ប្រភេទនៃធម៌មួយ ៗ...................................................... | ២៥៥ |
| | ប្រភេទនៃធម៌ពីរ ៗ ........................................................ | ២៥៧ |
| | ប្រភេទនៃធម៌បី ៗ .......................................................... | ២៥៩ |
| | ប្រភេទនៃធម៌បួន ៗ ...................................................... | ២៦៣ |
| | ប្រភេទនៃធម៌ប្រាំ ៗ ....................................................... | ២៦៧ |
| | ប្រភេទនៃធម៌ប្រាំមួយ ៗ ................................................. | ២៧៩ |
| | ប្រភេទនៃធម៌ប្រាំពីរ ៗ .................................................... | ២៩៥ |
| | ប្រភេទនៃធម៌ប្រាំបី ៗ ..................................................... | ៣០៥ |
| | ប្រភេទនៃធម៌ប្រាំបួន ៗ .................................................. | ៣២៩ |
| | ប្រភេទនៃធម៌ដប់ ៗ ........................................................ | ៣៤១ |
| | ឧទ្ទានគាថា..................................................................... | ៣៥៧ |

